អេស៊ីលីដា
ACLEDA BANK

# របាយការណ៍ប្រចាំឆ្នាំ
## ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

# អេស៊ីលីដា
# ម៉ូបាល




ស្កេន
ដើម្បីទាញយក

Download on the App Store

GET IT ON Google Play

EXPLORE IT ON AppGallery

# ទស្សនៈ

ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធនាគារពាណិជ្ជនាំមុខក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុល្អបំផុត ជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍ ។

# បេសកកម្ម

បេសកកម្មរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺផ្តល់ជូនសហគ្រិនខ្នាតតូចបំផុត ខ្នាតតូច ខ្នាតមធ្យម និងសាធារណជន នូវមធ្យោបាយក្នុងការគ្រប់គ្រង ចាត់ចែងធនធានហិរញ្ញវត្ថុឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីលើកស្ទួយជីវភាពរស់នៅឲ្យប្រសើរឡើង ដោយអនុវត្តឲ្យបាននូវនិរន្តរភាព និងបង្កើននូវអត្ថប្រយោជន៍ជូនដល់ភាគហ៊ុនិក កម្មករនិយោជិត ព្រមទាំងសហគមន៍ទាំងអស់ ។ យើងប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍សីលធម៌វិជ្ជាជីវៈ សង្គម ច្បាប់ និងបរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត ។

# គតិពេចន៍

ប្រជាធនាគារដែលលោកអ្នកជឿទុកចិត្ត ។

របាយការណ៍នេះរៀបចំ និងចេញផ្សាយដោយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ សម្រាប់ព័ត៌មានបន្ថែម និងចម្ងល់ផ្សេងៗ សូមទាក់ទងមក ៖

ការិយាល័យកណ្តាល ៖

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។
ប្រអប់សំបុត្រលេខ ៖ ១១៤៩
ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩
ទូរសារ ៖ ០២៣ ៤៣០ ៥៥៥
អ៊ីម៉ែល ៖ acledabank@acledabank.com.kh
គេហទំព័រ ៖ www.acledabank.com.kh
SWIFT Code: ACLBKHPP

ការិយាល័យទំនាក់ទំនងអតិថិជន
(បម្រើ ២៤ម៉ោង ក្នុងមួយថ្ងៃ និង៧ថ្ងៃ ក្នុងមួយសប្តាហ៍) ៖

ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣
អ៊ីម៉ែល ៖ inquiry@acledabank.com.kh

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | ២០២០ | ២០១៩ | ២០១៨ |
|---|---|---|---|
| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | | | |
| ទ្រព្យសកម្មសរុប | ២៦.៥០០.៧៩៣ | ២៥.១៦៣.៧៨៤ | ២២.៨៣៦.៥៩៩ |
| បំណុលសរុប | ២២.០៩៣.២៥៨ | ២១.២៣៣.៦០៣ | ១៩.៤០៩.៨៨៩ |
| មូលធនសរុប | ៤.៤០៧.៥៣៥ | ៣.៩៣០.១៨១ | ៣.៤២៦.៧១០ |
| លទ្ធផលហិរញ្ញវត្ថុ (គិតជាលានរៀល) | | | |
| ចំណូលសរុប | ២.៣៦១.៤៨៣ | ២.២២៩.១១៨ | ២.០៦៥.៦០១ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ៧៣៤.០០៥ | ៦២២.០៧៤ | ៦១០.១១៥ |
| ចំណេញ/(ខាត)សុទ្ធ ក្នុងការិយបរិច្ឆេទ | ៥៧៦.៨៦៥ | ៤៨៩.៧២៤ | ៤៨២.៦២៤ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ៥៦៩.៣៩៦ | ៤៩៧.១៩៦ | ៤៩០.០៧២ |
| អនុបាតហិរញ្ញវត្ថុ | | | |
| អនុបាតសាធនភាព | ២៥,១៥% | ២៦,៣១% | ២២,៦០% |
| អនុបាតបំណុលធៀបនឹងមូលធន | ៥០១,២៦% | ៥៤០,២៧% | ៥៦៦,៤៣% |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ១៤៩,៣១% | ១៦៧,២៧% | ១៥០,៦៤% |
| អនុបាតឥណទានមិនដំណើរការ (*) | ២,៤០% | ១,២៤% | ១,៨៧% |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ៩៧,៧៣% | ៨៨,៨២% | ៩៣,៩០% |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA) | ២,២០% | ២,០៧% | ២,២៣% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE) | ១៣,៦៦% | ១៣,៥២% | ១៥,១៨% |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ដង) | ២,១៩ | ១,៩៨ | ១,៩៨ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១.៣២០ | ១.២០៣ | ១.៣០៦ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | - | ៣១១ | ៤៣២ |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | - | - | - |

(*) ឥណទានមិនដំណើរការ = ឥណទាននៅដំណាក់កាលទី៣

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប និងស្ថិតិសង្ខេបប្រចាំឆ្នាំពីលទ្ធផលប្រតិបត្តិការ (Charts)

ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល)


















# សមាសភាពក្រុមប្រឹក្សាភិបាល

សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយភាគហ៊ុនិកសម្រាប់អាណត្តិ ៣ឆ្នាំ ដើម្បីធ្វើសកម្មភាពតំណាងឲ្យពួកគេផ្ទាល់ ។ តាមលក្ខន្តិកៈបានបញ្ជាក់ថា សមាសភាពក្រុមប្រឹក្សាភិបាលត្រូវមាន ១០រូប ដែល ៖

- ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើការកំណត់យុទ្ធសាស្ត្រ របស់ធនាគារ និងគ្រប់គ្រងរាល់ប្រតិបត្តិការអាជីវកម្ម ។ សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវធ្វើកិច្ចការ ដើម្បីជាប្រយោជន៍ខ្ពស់បំផុត សម្រាប់ធនាគារ ។
- អំណាចរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តរួមគ្នា ហើយគ្មានសមាជិក-សមាជិកាណាម្នាក់មានអំណាចក្នុងការផ្តល់ការណែនាំ ឬការបង្គាប់បញ្ជាតែឯកឯងលើថ្នាក់ដឹកនាំ ឬបុគ្គលិកណាម្នាក់របស់ធនាគារ ឬចុះហត្ថលេខាលើកិច្ចសន្យា ឬដឹកនាំគ្រប់គ្រងប្រតិបត្តិការរបស់ធនាគារបានឡើយ លើកលែងតែមានការផ្ទេរអំណាចជាក់លាក់ឲ្យអនុវត្ត តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។
- សមាជិក-សមាជិកាម្នាក់ៗ អាចពិនិត្យដោយគ្មានកំណត់ ចំពោះឯកសារ និងកំណត់ត្រាផ្សេងៗរបស់ធនាគារ គ្រប់ពេលម៉ោងធ្វើការ ។

ក្រុមប្រឹក្សាភិបាល ធ្វើការជ្រើសតាំងនូវសមាជិកម្នាក់ ឲ្យធ្វើជាប្រធានក្រុមប្រឹក្សាភិបាល តាមរយៈការបោះឆ្នោត ដោយយកតាមសំឡេងភាគច្រើនហើយបុគ្គលនោះជាអ្នកដឹកនាំ នូវរាល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ក៏ដូចជាមហាសន្និបាតប្រចាំឆ្នាំ ។

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើអភិបាលកិច្ចសាជីវកម្ម និងជំរុញអភិវឌ្ឍន៍ជោគជ័យរបស់ធនាគារ តាមរយៈការដឹកនាំរាល់ប្រតិបត្តិការការងារ និងអាជីវកម្ម ។ ក្រុមប្រឹក្សាភិបាលជាអ្នកតែងតាំង និងអាចដកតំណែងរបស់ប្រធាននាយកប្រតិបត្តិ ។ ក្រុមប្រឹក្សាភិបាលក៏ធានាផងដែរថាធនធានមនុស្ស ដែលចាំបាច់មានគ្រប់គ្រាន់ក្នុងការបង្កើតយុទ្ធសាស្ត្រ និងគោលដៅហិរញ្ញវត្ថុជាមួយថ្នាក់គ្រប់គ្រង ដើម្បីដាក់ឲ្យថ្នាក់គ្រប់គ្រងអនុវត្ត ព្រមទាំងត្រួតពិនិត្យលើការអនុវត្តរបស់ថ្នាក់គ្រប់គ្រងដោយផ្ទាល់ និងតាមរយៈគណៈកម្មាធិការក្រុមប្រឹក្សាភិបាល ។

ក្រុមប្រឹក្សាភិបាលបានបង្កើតគណៈកម្មាធិការ ចំនួន៣ ដូចជា គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការតែងតាំង និងលាភការ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ព្រមទាំងបង្កើតនូវ គណៈកម្មាធិការផ្សេងទៀត អាស្រ័យទៅតាមតម្រូវការចាំបាច់ ដើម្បីដំណើរការប្រតិបត្តិការអាជីវកម្មរបស់ធនាគារ ។ គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាលទាំងនេះ ត្រូវបង្កើតឡើងអាស្រ័យទៅនឹងក្រុមប្រឹក្សាភិបាល ហើយសមាជិក-សមាជិកាទាំងអស់នៅក្នុងគណៈកម្មាធិការ នឹងត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការទាំងនេះ មិនអនុវត្តអំណាចរបស់ក្រុមប្រឹក្សាភិបាលឡើយ លើកលែងតែមានការផ្ទេរសិទ្ធិអំណាចជាផ្លូវការ តែត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ចំពោះសកម្មភាពរួមរបស់ពួកគេ ។ គួរបញ្ជាក់ផងដែរថា សមាជិកភាពនៃគណៈកម្មាធិការមិនកំណត់ថា ត្រូវតែជាសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលនោះទេ ពោលគឺអាចជាអ្នកគ្រប់គ្រង ឬបុគ្គលណាផ្សេងទៀត ដែលសមស្របក្នុងតួនាទីរបស់គណៈកម្មាធិការនីមួយៗ ។ ប៉ុន្តែប្រធាននៃគណៈកម្មាធិការក្រុមប្រឹក្សាភិបាល គឺចាំបាច់ត្រូវតែជាសមាជិក-សមាជិការបស់ក្រុមប្រឹក្សាភិបាល ដែលអាចអញ្ជើញគណៈគ្រប់គ្រង និងភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីផ្តល់ព័ត៌មានប្រតិបត្តិការ និងពន្យល់នៅពេលចាំបាច់។ គណៈកម្មាធិការទាំងអស់ត្រូវមានប្រធានជាអភិបាលឯករាជ្យ ។



**លោក ឆាយ សឿន**
ប្រធានក្រុមប្រឹក្សាភិបាល



**បណ្ឌិត អ៊ិន ចាន់នី**
អភិបាល



**លោក វ័ត្ន យូម៉េង**
អភិបាល



**លោក Pieter Kooi**
អភិបាល



**លោក Ian S. Lydall**
អភិបាល



លោក វ៉ាន់ ស៊ូអៀង
អភិបាល



លោក Kenichiro Mori
អភិបាល



លោក Stéphane Mangiavacca
អភិបាល



លោកស្រី Mirjam Janssen
អភិបាល

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

## លោក ឆាយ សឿន

ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឲ្យធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ”) និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមធ្វើការបង្ហាញជូន អំពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២០ របស់ធនាគារ។



ឆ្នាំ២០២០ គឺជាឆ្នាំដែលមានការលំបាកសម្រាប់ស្ទើរគ្រប់វិស័យ ជាពិសេសទាក់ទងទៅនឹងវិស័យទេសចរណ៍។ ការរាតត្បាតជាសកល នៃជំងឺកូវីដ-១៩ បាន និងកំពុងជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងដល់អាជីវកម្មគ្រប់វិស័យទាំងអស់នៅជុំវិញពិភពលោក រួមទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ។ ស្របពេលជាមួយគ្នា រាជរដ្ឋាភិបាលកម្ពុជាបានដោះស្រាយស្ថានការណ៍ដ៏លំបាកនេះបានយ៉ាងល្អប្រសើរគួរជាទីមោទកភាព។ ជាលទ្ធផល ឧស្សាហកម្មធំៗ ត្រូវបានការពារយ៉ាងល្អពីផលប៉ះពាល់នៃជំងឺរាតត្បាតដ៏គួរឲ្យភ័យខ្លាចមួយនេះ។ រីឯកំណើនក្នុងវិស័យហិរញ្ញវត្ថុវិញ គឺនៅតែអាចរក្សាបាននូវអត្រាកំណើនប្រហាក់ប្រហែលនឹងឆ្នាំមុន ហើយស្ថានភាពបែបនេះត្រូវបានចាត់ទុកថា ជាការរក្សាបាននូវស្ថិរភាពដ៏ល្អនៅក្នុងអំឡុងពេលនៃវិបត្តិនេះ។ ទោះជាយ៉ាងណាក៏ដោយក៏មានសញ្ញាជាច្រើនបានបង្ហាញថាសកម្មភាពសេដ្ឋកិច្ចនឹងចាប់ផ្តើមរីកចម្រើនឡើងវិញនៅក្នុងឆ្នាំ២០២១ ដោយសារប្រសិទ្ធភាពនៃវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដែលនឹងត្រូវបានដាក់ឲ្យប្រើប្រាស់នៅទូទាំងពិភពលោក។

ដោយឡែក សម្រាប់ដំណើរការអាជីវកម្មរបស់ធនាគារនៅក្នុងឆ្នាំ២០២០ ក្រោមស្ថានភាពដ៏លំបាកនៃការរាតត្បាតជាសកល នៃជំងឺកូវីដ-១៩ និងដើម្បីឲ្យការផ្តល់សេវាកម្មហិរញ្ញវត្ថុប្រកបដោយគុណភាព ស្របតាមតម្រូវការរបស់សាធារណជន ធនាគារបានពង្រីកបណ្តាញស្វ័យប្រតិបត្តិការ អភិវឌ្ឍសេវាធនាគារឌីជីថល **អេស៊ីលីដា**ម៉ូបាល (**ACLEDA** mobile) ឲ្យកាន់តែមានភាពងាយស្រួល រហ័ស ទាន់ចិត្ត និងមានសុវត្ថិភាពខ្ពស់។ ស្របតាមការអនុវត្តនេះ ធនាគារសម្រេចបាននូវលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ប្រាក់បញ្ញើសរុបបានកើនឡើងចំនួន ២៨៣,៤០ លានដុល្លារអាមេរិក ហើយសមតុល្យឥណទានសរុបបានកើនឡើងចំនួន ៦២៧,១៨ លានដុល្លារអាមេរិក បើធៀបនឹងដំណាច់ឆ្នាំ២០១៩។

បើធៀបលទ្ធផលប្រចាំឆ្នាំ២០២០នេះ ទៅនឹងលទ្ធផលឆ្នាំ២០១៩ ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលបានប្រាក់ចំណេញសុទ្ធចំនួន ១៤១,៤៩ លានដុល្លារអាមេរិក ដោយកើនឡើង ១៧,០៧% ស្មើនឹង ២០,៦៣ លានដុល្លារអាមេរិក។ ជាលទ្ធផល អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យមចំនួន ២,២៣% ដោយកើនឡើងចំនួន ០,១៩% និង អនុបាតចំណេញធៀបនឹងមូលធនមធ្យមចំនួន ១៣,៧៩% ដោយកើនឡើងចំនួន ០,៤៩%។

គិតចាប់ពីថ្ងៃដែលធនាគារចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ រហូតមកដល់ដំណាច់ឆ្នាំ២០២០ វិនិយោគិនសាធារណៈរបស់ធនាគារបានកើនឡើងចំនួន ៤២,៦៣% (កើនឡើងពី ២.៤៩៦នាក់ ដល់ ៣.៥៦០នាក់)។ យោងតាមព្រឹត្តិបត្រព័ត៌មានប្រចាំខែរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ដែលបានចេញផ្សាយនៅខែធ្នូ ឆ្នាំ២០២០ មូលធនរូបនីយកម្មទីផ្សារសរុបមានកំណើនដល់ ២,៤៥ ពាន់លានដុល្លារអាមេរិក កើនឡើងជិត ២៥០% ធៀបនឹងឆ្នាំ ២០១៩។ ការចុះបញ្ជីរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាធនាគារដ៏ធំជាងគេក្នុងស្រុក បានបង្កើនសកម្មភាពជួញដូរលើទីផ្សារមូលបត្រកម្ពុជា ដោយជំរុញការជួញដូរប្រចាំថ្ងៃរហូតដល់ ១ លានដុល្លារអាមេរិកក្នុងរយៈពេលជាច្រើនថ្ងៃជាប់ៗគ្នា។

យើងខ្ញុំសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ ភាគហ៊ុនិក អតិថិជន និយោជិត និងជាពិសេសអាជ្ញាធរពាក់ព័ន្ធទាំងអស់ ដែលតែងតែផ្តល់ការគាំទ្រ និងការជ្រោមជ្រែងឲ្យធនាគារសម្រេចបាននូវលទ្ធផលតាមផែនការដ៏ត្រចះត្រចង់ ជាពិសេសក្នុងឆ្នាំ២០២០នេះ។



**លោក ឆាយ សឿន**

*ប្រធានក្រុមប្រឹក្សាភិបាល*

**ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១**

# សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ



**បណ្ឌិត អ៊ិន ចាន់នី**
ប្រធាននាយកប្រតិបត្តិ

ទោះបីជាស្ថិតក្នុងអន្តរកាលនៃផលប៉ះពាល់ជាសកលពីការរាតត្បាតជំងឺកូវីដ-១៩ ធនាគារបានខិតខំរីវឌ្ឍខ្លួន ដោយធ្វើការកែប្រែស្លាកសញ្ញាឡើងវិញជាមួយនឹងរូបរាងថ្មី ដើម្បីឆ្លុះបញ្ចាំងពីប្រវត្តិពិតរបស់ធនាគារ។ ឆ្នាំ២០២០ បានផ្តល់បទពិសោធន៍បន្ថែមយ៉ាងច្រើនដល់ធនាគារនូវមធ្យោបាយចម្បងចំនួនពីររួមមានៈ ទីមួយ ធនាគារបានពង្រឹងខ្លួនឯង តាមរយៈការជម្នះរាល់ហេតុការណ៍អវិជ្ជមានឲ្យក្លាយទៅជាគុណសម្បត្តិវិញ។ តាមបរិបទនេះយើងបានកត់សម្គាល់ឃើញថា អាជីវកម្មរបស់ធនាគារនៅតែបន្តរីកចម្រើន ព្រមទាំងអាចរក្សាបាននូវគុណភាពទ្រព្យសកម្មបានយ៉ាងល្អ។ ទីពីរ ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារពាណិជ្ជដំបូងបង្អស់ ដែលបានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ដូច្នេះធនាគារបានធ្វើកំណែទម្រង់ប្រតិបត្តិការ និងស្តង់ដាររបាយការណ៍ ដើម្បីឆ្លើយតបទៅនឹងតម្រូវការបទដ្ឋានរបស់ធនាគារជាតិ នៃ កម្ពុជា និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) និង ផ.ម.ក.។ មុនពេលចុះបញ្ជីក្នុង ផ.ម.ក. នៅក្នុងខែឧសភា ឆ្នាំ២០២០ ធនាគារមានភាគហ៊ុនិកជានីតិបុគ្គល ចំនួន៨។ បន្ទាប់ពីបានចុះបញ្ជីរួច ធនាគារមានភាគហ៊ុនិកថ្មីកើនឡើងជិត៤០០០នាក់ ដោយមានទាំងនីតិបុគ្គល និងរូបវន្តបុគ្គល ដែលបានបណ្តាក់ទុនជាមួយធនាគារប្រកបដោយទំនុកចិត្ត។

សូមថ្លែងអំណរគុណចំពោះបច្ចេកវិទ្យាឌីជីថល ដែលធនាគារបានធ្វើការអភិវឌ្ឍ និងការកែលម្អជាច្រើនឆ្នាំមកនេះ បានរួមចំណែកយ៉ាងសកម្មក្នុងការសម្រេចបាននូវសមិទ្ធផលដ៏ត្រចះត្រចង់នេះ ទាំងក្នុងដំណើរការអាជីវកម្ម និងទំនាក់ទំនងដ៏រឹងមាំជាមួយនិយ័តករ និងភាគហ៊ុនិកយ៉ាងច្រើនបែបនេះបានក្នុងពេលតែមួយ។

# សមិទ្ធិផលសម្រេចបានក្នុងឆ្នាំ២០២០

## ស្ថានភាពប្រកួតប្រជែង

ដំណោះស្រាយឌីជីថលយ៉ាងសកម្មបានក្លាយជាជម្រើសដ៏ល្អបំផុតសម្រាប់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការផ្តល់សេវាកម្មជូនអតិថិជនរបស់ខ្លួននៅក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលសាធារណជនជាច្រើនមានក្តីព្រួយបារម្ភយ៉ាងខ្លាំងអំពីសុខភាពរបស់ពួកគេ។ បច្ចេកវិទ្យាឌីជីថលត្រូវបានជឿថា គឺជាឧបករណ៍មួយ ក្នុងចំណោមឧបករណ៍ដ៏មានសក្តានុពលបំផុត ដើម្បីបំពេញបន្ថែម និងឆ្លើយតបតម្រូវការទីផ្សារបច្ចុប្បន្ន ចំពោះគ្រប់ស្ថាប័នហិរញ្ញវត្ថុ។ ធនាគារ តែងតែពង្រឹងគុណភាពបម្រើសេវាកម្មហិរញ្ញវត្ថុដល់អតិថិជនគ្រប់មជ្ឈដ្ឋាន ដើម្បីទទួលបានភាពរីកចម្រើនជាមួយគ្នា ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស តាមរយៈការទូទាត់ឆ្លងព្រំដែន ដោយ **ឃ្យូអរកូដ** (QR Code)។

## ចំណុចសំខាន់ៗនៃប្រតិបត្តិការក្នុងឆ្នាំ២០២០

- សមតុល្យឥណទានសរុបនៅចុងឆ្នាំ២០២០មានចំនួន ៤.៥០៦,៦៤ លានដុល្លារអាមេរិក ក្នុងនោះមានឥណទានចំនួន ៨៩៤,៦៥ លានដុល្លារអាមេរិក ស្មើនឹង ១៩,៨៥% បានផ្តល់ទៅឲ្យវិស័យកសិកម្ម។ បើធៀបទៅនឹងឆ្នាំ២០១៩ ការផ្តល់ឥណទានក្នុងវិស័យកសិកម្មមានចំនួន ៧៥៧,០៤ លានដុល្លារអាមេរិក។ គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២០ ចំនួនអតិថិជនឥណទានអាជីវកម្មខ្នាតតូចរបស់ធនាគារបានកើនដល់ ៤៨៩.៣៥២នាក់។
- ឥណទានមិនដំណើរការស្ថិតក្នុងអត្រាដែលអាចគ្រប់គ្រងបាន មានចំនួន ២,៤០% នៅក្នុងអំឡុងនៃវិបត្តិកូវីដ-១៩នេះ។
- ប្រាក់បញ្ញើ-សន្សំមានចំនួន ៤.៦១១,៣០ លានដុល្លារអាមេរិក ដែលមានគណនីសកម្មចំនួន ២.៨៩៤.៩០៧។
- ធនាគារទទួលបានប្រាក់ចំណេញសុទ្ធចំនួន ១៤១,៦៦ លានដុល្លារអាមេរិក។
- ធនាគារនៅតែបន្តកាត់បន្ថយចំណាយ និងត្រួតពិនិត្យហានិភ័យជាប្រចាំ ដើម្បីទទួលបានប្រាក់ចំណេញខ្ពស់បំផុត។
- សេវាធនាគារអេឡិចត្រូនិចតាមប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) បានបញ្ចូលជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធធនាគារអេឡិចត្រូនិកផ្សេងទៀតរបស់ធនាគារ ដើម្បីផ្តល់ជម្រើសជាច្រើនជូនអតិថិជន ក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ពួកគេ។

## សេវាលក់រាយ និងអាជីវកម្មខ្នាតតូច

ឥណទានខ្នាតតូចបានកើនឡើង ១០,១០% ឬស្មើនឹង ២០២,៨៣ លានដុល្លារអាមេរិក និងឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងផ្សេងៗ បានកើនឡើង ៣២,២០% ឬស្មើនឹង ៣៨,៥៥ លានដុល្លារអាមេរិក។ ចំណែក ឥណទានគេហដ្ឋានបានថយចុះ ១២,២៧% ឬស្មើនឹង ២២,៥០ លានដុល្លារអាមេរិក។ សមតុល្យឥណទានសរុបចំនួន ៤.៥០៦,៦៤ លានដុល្លារអាមេរិក នៅដំណាច់ឆ្នាំ២០២០។

ធនាគារ អេស៊ីលីដា ភីអិលស៊ី មានសមតុល្យប្រាក់បញ្ញើ-សន្សំសរុបចំនួន ៤.៦១១,៣០ លានដុល្លារអាមេរិក (កើនឡើង ៥,៥៧% ឬស្មើនឹង ២៤៣,៤០ លានដុល្លារអាមេរិក) និងមានគណនីសរុបជាង ២,៨៩ លានគណនី។ វិស័យលក់រាយគឺជាផ្នែកដែលធំជាងគេបំផុតនៃកំណើនប្រាក់បញ្ញើសរុប ដែលភាគច្រើនបានមកពីអតិថិជនដាក់ប្រាក់បញ្ញើដំបូង ដូចជាកម្មករនិយោជិត តាមរយៈ សេវាបើកប្រាក់បៀវត្ស និងអតិថិជននៅតាមជនបទ ដែលពួកគាត់បានប្រើប្រាស់គណនីវ៉ លឡេត របស់សេវា **អេស៊ីលីដាម៉ូបាល**។ ការពង្រីកផលិតផល និងសេវាកម្មហិរញ្ញវត្ថុ តាមរយៈ FinTech បានចូលរួមចំណែកធ្វើឲ្យមានកំណើនយ៉ាងខ្លាំងក្លា។

ធនាគារ អេស៊ីលីដា ភីអិលស៊ី កំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធឲ្យកាន់តែទូលំទូលាយ សម្រាប់ជាជម្រើសដ៏សម្បូរបែបជាមួយនឹងសាខាទាំង ២៦៣ទីតាំង (ឬការិយាល័យ) តាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗ ទៅជាមជ្ឈមណ្ឌលដែលអាចធ្វើស្វ័យប្រតិបត្តិការ ព្រមទាំងមានម៉ាស៊ីនអេធីអឹមចំនួន ៧៩០គ្រឿង និងម៉ាស៊ីនឆូតកាតចំនួន ៤.២៨៧គ្រឿង។ ចំណុចគួរជាទីមោទកភាព គឺធនាគារ អេស៊ីលីដា បានបោះពុម្ពប័ណ្ណឥណពន្ធចំនួន ១,៤០ លានប័ណ្ណជូនដល់អតិថិជន។ បន្ថែមលើនេះ **អេស៊ីលីដាម៉ូបាល** (ACLEDA mobile) បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំង ដែលមានអ្នកចុះឈ្មោះប្រើប្រាស់ច្រើនជាង ១,៧ លាននាក់ នៅដំណាច់ឆ្នាំ២០២០នេះ។

## ឥណទានខ្នាតមធ្យម និងសាជីវកម្ម

ក្នុងឆ្នាំ២០២០ ឥណទានប្រភេទនេះបានកើនឡើង ៣០,៨១% ដែលមានចំនួនស្មើនឹង ៣៥,០៦% នៃ សមតុល្យឥណទានសរុប។ សេវាកម្មគ្រប់គ្រងសាច់ប្រាក់បានកើនឡើងយ៉ាងខ្លាំង តាមរយៈការចាប់ដៃគូជាមួយនឹងវិស័យសាធារណៈ ជាពិសេសបេឡាជាតិសន្តិសុខសង្គម សេវាបើកប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការ សេវាប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ រួមទាំងក្រុមហ៊ុនឯកជនជាច្រើន ជាពិសេសរោងចក្រកាត់ដេរ។ ក្នុងនាមជាអ្នកគ្រប់គ្រងមូលនិធិបេឡាជាតិសន្តិសុខសង្គម ធនាគារ អេស៊ីលីដា ភីអិលស៊ី អាចទទួលបានប្រាក់បញ្ញើពីទូទាំងរាជធានី-ខេត្ត។ លើសពីនេះទៀត អតិថិជនថ្មីៗ ជាច្រើនបានបើកគណនី ដោយសារការបង្កើននូវមធ្យោបាយបម្រើតាមរយៈប្រព័ន្ធអេឡិចត្រូនិក ដូចជា ការបន្ថែមម៉ាស៊ីនអេធីអឹម និងការទូទាត់វិក្កយបត្ររបស់ស្ថាប័នផ្សេងៗ តាមរយៈសេវា **អេស៊ីលីដាម៉ូបាល** ព្រមទាំងសេវាអេស៊ីលីដា អ៊ីនធើណែត ផងដែរ។ កត្តាទាំងនេះ បានធ្វើឲ្យធនាគារមានលទ្ធភាពប្រមូលនូវប្រភពធនធានហិរញ្ញវត្ថុ ជារូបិយវត្ថុរៀល និងអាចធ្វើឲ្យធនាគារពង្រឹង និងពង្រីកការផ្តល់ឥណទានជាប្រាក់រៀលបានកាន់តែច្រើនផងដែរ។ តម្រូវការប្រើប្រាស់សេវាបើកប្រាក់បៀវត្សបានកើនឡើងខ្លាំងនៅក្នុងឆ្នាំ២០២០ ដោយមានស្ថាប័នរដ្ឋាភិបាល និងមន្ត្រីរាជការ ព្រមទាំងក្រុមហ៊ុនធំៗ ក្នុងស្រុក និងក្រៅប្រទេស រួមទាំងស្ថាប័ននានា បានចូលរួមប្រើប្រាស់ ដែលជាឱកាសដ៏ល្អសម្រាប់ការលក់ផលិតផលផ្សេងៗទៀត។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន នៅតែបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូយុទ្ធសាស្ត្ររយៈពេលវែង ដោយរួមបញ្ចូលគ្នានូវបទពិសោធន៍រាប់រយឆ្នាំក្នុងសេវាធនាគារ និងហិរញ្ញវត្ថុរបស់ដៃគូទាំងនោះ ដែលអាចជួយដល់អតិថិជនក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ពួកគាត់ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ទន្ទឹមនឹងនោះ កិច្ចសហការនេះជួយជំរុញឲ្យធនាគារ អេស៊ីលីដា ទទួលបានប្រាក់ចំណូល ដើម្បីបង្កើនប្រភពមូលនិធិយូរអង្វែង សម្រាប់គាំទ្រទិសដៅយុទ្ធសាស្ត្ររបស់ខ្លួន។ ភាពជាដៃគូទាំងនេះ បានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់ប្រភពមូលនិធិរយៈពេលវែងដល់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងជាប្រភពនៃប្រាក់ចំណូលក្រៅតារាងតុល្យការ។ ហើយម្យ៉ាងវិញទៀត ការចែករំលែកនូវជំនាញ និងបទពិសោធន៍ពីសំណាក់ដៃគូទាំងនោះ បានដើរតួយ៉ាងសំខាន់ និងរួមចំណែកដល់ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់ធនាគារ។

## រតនាភិបាល និងអន្តរជាតិ

ចំណូលពីសេវាប្តូរប្រាក់បន្តកើនឡើង និងចូលរួមបង្កើនចំណូលមិនមែនការប្រាក់របស់ធនាគារ។ ដោយយោងលើគោលការណ៍គ្រប់គ្រងហានិភ័យ ធនាគារ អេស៊ីលីដា ភីអិលស៊ី បម្រើសេវាប្តូរប្រាក់សម្រាប់តែគាំទ្រដល់អាជីវកម្មរបស់អតិថិជនប៉ុណ្ណោះ។ សេវានេះផ្តល់ប្រភពចំណូលដែលមានហានិភ័យទាប និងមានស្ថិរភាព ហើយមានកំណើនជាលំដាប់ និងរក្សាទំនាក់ទំនងយូរអង្វែងជាមួយអតិថិជន។

តាមរយៈការគ្រប់គ្រងស្ថានភាពរូបិយប័ណ្ណចំហបានល្អប្រសើរ បានធ្វើឲ្យតារាងតុល្យការរបស់ធនាគារកាន់តែរឹងមាំថែមទៀត ដែលញាំងឲ្យមានកំណើនប្រកបដោយគុណភាព និងបានធ្វើឲ្យអនុបាតឥណទានធៀបនឹងប្រាក់បញ្ញើមានភាពល្អប្រសើរ និងជួយទ្រទ្រង់ដល់ការរីកចម្រើននៅលើទីផ្សារ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី បានចូលរួមចំណែកផ្សព្វផ្សាយការប្រើប្រាស់ប្រាក់រៀល តាមរយៈការផ្តល់ឥណទានជាប្រាក់រៀលដល់អតិថិជន ដែលមានចំនួនច្រើនជាង ១៤% នៃទំហំឥណទានសរុប ដែលលើសពីបញ្ញត្តិតម្រូវត្រឹមតែ ១០% ប៉ុណ្ណោះ។ ធនាគារក៏បានចូលរួមយ៉ាងសកម្មនៅក្នុងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ដើម្បីទុកជាប្រភពទុនបន្ថែមជាប្រភេទរូបិយវត្ថុក្នុងស្រុក។

បន្ថែមពីនេះទៀត ធនាគារ អេស៊ីលីដា ភីអិលស៊ី បានរក្សាទំនាក់ទំនងល្អជាមួយនឹងដៃគូយុទ្ធសាស្ត្រទូទាំងសកលលោក ជាពិសេស នៅអឺរ៉ុប សហរដ្ឋអាមេរិក និងអាស៊ី ដើម្បីគាំទ្រដល់ធនាគារ ក្នុងការផ្តល់ប្រភពមូលនិធិរយៈពេលវែង។

ធនាគារនៅតែបន្តពង្រឹងទំនាក់ទំនងជាមួយស្ថាប័នហិរញ្ញវត្ថុជាច្រើន និងបានបង្កើនធនាគារដៃគូក្រៅប្រទេសថ្មីៗ ជាច្រើនបន្ថែមទៀត ដើម្បីពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួន។ នាដំណាច់ឆ្នាំ២០២០ ធនាគារមានធនាគារដៃគូចំនួន ២៧៤ នៅក្នុងចំណោម ៤៤ប្រទេស។ លើសពីនេះទៀត ធនាគារមានចំណែកទីផ្សារលើសលុប ក្នុងការគ្រប់គ្រងគណនីរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក ព្រមទាំងផ្តល់សេវាផ្ទេរប្រាក់ដល់ស្ថាប័នទាំងនោះនៅទូទាំងប្រទេស។

ធនាគារក៏បានរៀបចំ និងអនុវត្តបានទាំងស្រុង តាមគោលការណ៍គ្រប់គ្រងហានិភ័យផ្ទៃក្នុង តម្រូវការបទប្បញ្ញត្តិ និងកិច្ចព្រមព្រៀងជាមួយនឹងម្ចាស់បំណុលនានា។

## យុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០២១

១. បន្តអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ FinTech តាមរយៈកម្មវិធី **អេស៊ីលីដា**ម៉ូបាល ដើម្បីផ្តល់បណ្តាញសេវាកម្មហិរញ្ញវត្ថុក្នុងតំបន់ និងបង្កើនកម្មវិធីស្វ័យសេវាកម្មសម្រាប់អតិថិជន។

២. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតំបន់ស្វ័យសេវាកម្មធនាគារ ដើម្បីបម្រើសាធារណជន និងអតិថិជន ២៤ម៉ោងក្នុង១ថ្ងៃ និង៧ថ្ងៃក្នុង១សប្តាហ៍។

៣. អភិវឌ្ឍអត្តសញ្ញាណថ្មី និងពង្រឹងបន្ថែមនូវកេរ្តិ៍ឈ្មោះរបស់ធនាគារ។

៤. លើកកម្ពស់សមត្ថភាពប្រកួតប្រជែងដល់ក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងក្នុងស្រុក និងក្រៅប្រទេស។

៥. ធ្វើទំនើបកម្មប្រព័ន្ធឌីជីថល សម្រាប់គាំទ្រនូវដំណើរការ និងឯកសាររដ្ឋបាលផ្សេងៗ។

៦. បង្កើនប្រព័ន្ធ និងសុវត្ថិភាពបច្ចេកវិទ្យាព័ត៌មាន សម្រាប់មុខងារឌីជីថលឲ្យកាន់តែរឹងមាំ។

៧. ចាប់ដៃគូជាមួយស្ថាប័ននានាដែលមានកេរ្តិ៍ឈ្មោះល្អ សម្រាប់កំណើនអាជីវកម្ម។

៨. ដើរតួនាទីជាអ្នកថែរក្សា និងធ្វើពិពិធកម្មមូលនិធិ ដែលទទួលបានពីផ្សារមូលបត្រកម្ពុជា និងវិនិយោគិនទូទាំងពិភពលោក និង

៩. ធ្វើឲ្យសេវា **អេស៊ីលីដា**ម៉ូបាល ក្លាយជាសេវាដែលអាចទូទាត់កាន់តែទូលំទូលាយក្នុងទីផ្សារទាំងអស់។

## បញ្ហាចម្បងក្នុងឆ្នាំ២០២១

ក្នុងនាមជាក្រុមហ៊ុនចុះបញ្ជីមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ត្រូវតែអនុលោមតាមបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃ កម្ពុជា និង ន.ម.ក. ហើយនេះក៏ជាទំនួលខុសត្រូវរបស់ធនាគារចំពោះសាធារណជន និងវិនិយោគិនផងដែរ។ ក្នុងប្រវត្តិជាច្រើនឆ្នាំរបស់ខ្លួន ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបង្កើតទំនុកចិត្តដល់សាធារណជនតាមរយៈអភិបាលកិច្ចសាជីវកម្មល្អ គណៈគ្រប់គ្រងដែលមានបទពិសោធន៍យូរឆ្នាំ ព្រមទាំងមានវប្បធម៌ការងារប្រកបដោយតម្លាភាព។

ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងផលិតផល FinTech បានធ្វើឲ្យទីផ្សារហិរញ្ញវត្ថុមានភាពសម្បូរបែប។ តាមរយៈនេះវាបានជួយលុបបំបាត់គម្លាតរបស់អតិថិជនក្នុងទីផ្សារហិរញ្ញវត្ថុ ព្រមទាំងញាំងឲ្យអតិថិជនមានជម្រើសក្នុងចំណោមធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ដោយលែងខ្វល់អំពីតំបន់រស់នៅរបស់ពួកគេទៀត។ សេវា FinTech ក៏ជួយជំរុញដល់ការប្រកួតប្រជែងខ្លាំងក្លា ទាំងគុណភាព និងតម្លៃនៃសេវាកម្ម។ "**អេស៊ីលីដា**ម៉ូបាល" គឺបំពាក់មកជាមួយនូវបច្ចេកវិទ្យាជំនាន់ចុងក្រោយបំផុត ដែលមានរូបភាពទាន់សម័យគួរឲ្យទាក់ទាញសម្រាប់គ្រប់វ័យ។ វាត្រូវបានបង្កើតឡើងជាមួយនឹងបទពិសោធន៍របស់អតិថិជន និងអ្នកប្រើប្រាស់ដ៏មានប្រជាប្រិយភាព។ វាមានសុវត្ថិភាពខ្ពស់ និងអាចទាញយកដោយខ្លួនឯងនៅកន្លែងណា ដែលមាន WiFi ឬអ៊ីនធើណែត ហើយវាក៏ជាដំណោះស្រាយមួយដែរ ដើម្បីជួយឱ្យ អេស៊ីលីដាឈានមុខក្នុងការប្រកួតប្រជែង។

ការពន្យារពេលនៃការរីករាលដាលវីរុសកូវីដ-១៩ និងភាពយឺតយ៉ាវនៃការបែងចែកវ៉ាក់សាំងកូវីដ-១៩ នៅតែបន្តភាពភ័យខ្លាចដល់សាធារណជន និងម្យ៉ាងវិញទៀតអាចនឹងនៅតែបន្តប៉ះពាល់ដល់ការរីកចម្រើនសេដ្ឋកិច្ចជាសកល រួមទាំងកម្ពុជាផងដែរ។

ការអនុលោមជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ តាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ជាការទាមទារឲ្យមានប្រព័ន្ធដ៏ជឿនលឿន បទប្បញ្ញត្តិ និងគោលការណ៍ណែនាំ នៅគ្រប់កាលៈទេសៈតម្រូវ។ ធនាគារបានអភិវឌ្ឍដោយជោគជ័យ ហើយយើងខ្ញុំរីករាយនឹងចែករំលែកវា សម្រាប់ភាគីពាក់ព័ន្ធ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការគាំទ្ររបស់អតិថិជន ក្រុមប្រឹក្សាភិបាល ថ្នាក់គ្រប់គ្រង និងបុគ្គលិក ជាពិសេសរាជរដ្ឋាភិបាល ធនាគារជាតិ នៃ កម្ពុជា និងនិយ័តករមូលបត្រកម្ពុជា ក្នុងឆ្នាំ២០២០ និងការចូលរួមប្រកបដោយសោមនស្ស និងឧត្តុង្គឧត្តមក្នុងឆ្នាំ២០២១។



**បណ្ឌិត អ៊ិន ចាន់នី**

*ប្រធាននាយកប្រតិបត្តិ*

ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១

# មាតិកា

## ទំព័រ


១ ទស្សនៈ បេសកកម្ម គតិពេចន៍

២ ព័ត៌មានហិរញ្ញវត្ថុសង្ខេប

៣ ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប និង ស្ថិតិសង្ខេបប្រចាំឆ្នាំពីលទ្ធផលប្រតិបត្តិការ (Charts)

៤ សមាសភាពក្រុមប្រឹក្សាភិបាល

៧ សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

៨ សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ

**១២ ផ្នែកទី១ ព័ត៌មានទូទៅពាក់ព័ន្ធនឹងធនាគារ អេស៊ីលីដា ភីអិលស៊ី**

១៣ ក. អត្តសញ្ញាណធនាគារ អេស៊ីលីដា ភីអិលស៊ី

១៣ ខ. លក្ខណៈធុរកិច្ច

១៣ គ. សម្ព័ន្ធភាពធនាគារ អេស៊ីលីដា ភីអិលស៊ី

១៤ ឃ. ព្រឹត្តិការណ៍សំខាន់ៗរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

១៥ ង. ស្ថានភាពទីផ្សារ

១៦ ច. ស្ថានភាពប្រកួតប្រជែង

១៦ ឆ. ផែនការអនាគត

១៦ ជ. កត្តាហានិភ័យ

**១៨ ផ្នែកទី២ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច**

១៩ ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

២០ ខ. រចនាសម្ព័ន្ធចំណូល

**២១ ផ្នែកទី៣ ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម**

២២ ក. អង្គការលេខ

២៣ ខ. ក្រុមប្រឹក្សាភិបាល

២៣ គ. គណៈកម្មាធិការប្រតិបត្តិ

**២៤ ផ្នែកទី៤ ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី**

២៥ ក. ព័ត៌មានអំពីមូលបត្រ

២៥ ខ. ថ្លៃ និងបរិមាណជួញដូរមូលបត្រ

២៦ គ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (ចាប់ពី ៣០% ឡើងទៅ)

២៦ ឃ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន (ចាប់ពី ៥% ដល់តិចជាង ៣០%)

២៦ ង. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ

**២៧ ផ្នែកទី៥ របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង**

**៣០ ផ្នែកទី៦ របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ**

**៣១ ផ្នែកទី៧ ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍**

៣២ ក. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ

៣៣ ខ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់

៣៣ គ. ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម

៣៣ ឃ. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ

៣៣ ង. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលិកដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រក្រុមហ៊ុនសម្ព័ន្ធឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយបុគ្គលចុះបញ្ជីលក់មូលបត្រ

៣៥ ច. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល

៣៥ ឆ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលបានកាន់មុខដំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ

៣៥ ជ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ

**៣៦ ផ្នែកទី៨ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង**

៣៧ ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

៣៨ ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

៣៩ គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

៣៩ ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

៣៩ ង. ផលប៉ះពាល់នៃអតិផរណា

៣៩ ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

**៤១ ហត្ថលេខាអភិបាល**

**៤២ ឧបសម្ព័ន្ធ៖ របាយការណ៍ស្តីពីអភិបាលកិច្ចសាជីវកម្មតាមទម្រង់កំណត់ដោយអគ្គនាយកនៃ ន.ម.ក.**

# ផ្នែកទី ១

## ព័ត៌មានទូទៅពាក់ព័ន្ធនឹង
## ធនាគារ អេស៊ីលីដា ភីអិលស៊ី

# ក. អត្តសញ្ញាណធនាគារ អេស៊ីលីដា ភីអិលស៊ី

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ឈ្មោះក្រុមហ៊ុនជាអក្សរឡាតាំង | **ACLEDA Bank Plc.** |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ |
| លេខទូរសារ | +៨៥៥ (០)២៣ ៤៣០ ៥៥៥ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាប័ណ្ណអាជីវកម្ម | ០៦ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| សេចក្តីសម្រេចអនុញ្ញាតិ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | លេខ០៥៣/២០គ.ម.ក./ស.ស.រ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ចេញដោយគណៈកម្មការមូលបត្រកម្ពុជា (បច្ចុប្បន្នជា និយ័តករមូលបត្រកម្ពុជា “ន.ម.ក.”) |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | **បណ្ឌិត អ៊ិន ចាន់នី** |

# ខ. លក្ខណៈធុរកិច្ច

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារពាណិជ្ជដែលមានសាខា និងបណ្តាញការិយាល័យធំជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារបានចុះបញ្ជីនៅក្នុង ផ.ម.ក. ចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ បច្ចុប្បន្ននេះធនាគារមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤ រួមមាន៖ ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត, ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី, វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា, និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ព្រមទាំងមានការិយាល័យតំណាងចំនួន១ នៅប្រទេសមីយ៉ាន់ម៉ាផងដែរ។

# គ. សម្ព័ន្ធភាពធនាគារ អេស៊ីលីដា ភីអិលស៊ី

| លរ | ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | ភាគរយនៃការកាន់កាប់ភាគហ៊ុន | អាជីវកម្មចម្បង | កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម | ទីតាំងអាជីវកម្ម |
|---|---|---|---|---|---|---|
| ១ | ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុន ៩៩.៩០% និង វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា កាន់កាប់ភាគហ៊ុន ០.១០% | ធ្វើប្រតិបត្តិការជាធនាគារពាណិជ្ជទូទាំងប្រទេសឡាវដោយផ្តល់សេវាកម្មធនាគារ និងហិរញ្ញវត្ថុ | ១៩ មិថុនា ២០០៨ | #398, Corner of Dongpalane and Dongpaina Road, Unit 20, PhonesavanhNeua Village, Sisattanak District, Vientiane Capital Lao PDR. |

| ល.រ | ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | ភាគរយនៃការកាន់កាប់ភាគហ៊ុន | អាជីវកម្មចម្បង | កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម | ទីតាំងអាជីវកម្ម |
|---|---|---|---|---|---|---|
| ២ | អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុន ១០០% | ធ្វើប្រតិបត្តិការផ្តល់សេវាលើអាជីវកម្មឈ្មួញជើងសារមូលបត្រ និងអាជីវកម្មបន្ទាប់បន្សំដទៃផ្សេងទៀត | ០១ មីនា ២០១០ | ជាន់ទីប្រាំ អគារអេស៊ីលីដាលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| ៣ | វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុន ១០០% | ធ្វើប្រតិបត្តិការផ្តល់សេវាកម្មអប់រំបណ្តុះបណ្តាល កម្រិតបរិញ្ញាបត្ររង កម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ | ០៨ មិថុនា ២០១១ | អគារលេខ ១៣៩៧ មហាវិថីមិត្តភាព ភ្នំពេញ-ហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| ៤ | ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុន ៩៩.៩៩% និងវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា កាន់កាប់ភាគហ៊ុន ០.០១% | ធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ផ្តល់ប្រាក់កម្ចី និងសេវាកម្មមីក្រូហិរញ្ញវត្ថុ | ០៦ កញ្ញា ២០១២ | # 186(B) Shwe Gone Taing Road, Yae Tar Shae Block, Bahan Township, Yangon Myanmar. |
| ៥ | ការិយាល័យតំណាង ធនាគារ អេស៊ីលីដា ភីអិលស៊ី | ការិយាល័យតំណាង | ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុន ១០០% | ផ្សព្វផ្សាយផលិតផល និងសេវាកម្ម ធនាគារ អេស៊ីលីដា ភីអិលស៊ី | ០៦ ឧសភា ២០១៦ | # 186(B) Shwe Gone Taing Road, Yae Tar Shae Block, Bahan Township, Yangon Myanmar. |

# ឃ. ព្រឹត្តិការណ៍សំខាន់ៗរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

- ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានបង្កើតឡើង តាមប្រព័ន្ធច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ ធនាគារ អេស៊ីលីដា បានចាប់បដិសន្ធិឡើងនៅក្នុងខែមករា ឆ្នាំ១៩៩៣ ក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលមានទិសដៅអភិវឌ្ឍន៍មុខរបរខ្នាតតូចបំផុត និងខ្នាតតូច តាមរយៈការផ្តល់ឥណទាន។
- នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០០ ធនាគារ អេស៊ីលីដា បានទទួលអាជ្ញាប័ណ្ណជាធនាគារឯកទេស ពីធនាគារជាតិ នៃ កម្ពុជា។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារ អេស៊ីលីដា បានទទួលអាជ្ញាប័ណ្ណជាធនាគារពាណិជ្ជ ពីធនាគារជាតិ នៃ កម្ពុជា ដែលធ្វើឲ្យធនាគារ អេស៊ីលីដា មានលទ្ធភាពបំពេញទៅតាមតម្រូវការរបស់អតិថិជននូវសេវាធនាគារបានទូទៅ និងទូលំទូលាយថែមទៀត ហើយក៏បានប្តូរឈ្មោះជាផ្លូវការមកជា "ធនាគារ អេស៊ីលីដា ភីអិលស៊ី"។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារដំបូងគេនៅក្នុងប្រទេសកម្ពុជា ដែលទទួលបានការផ្តល់ចំណាត់ថ្នាក់ដោយស្ថាប័នផ្តល់ចំណាត់ថ្នាក់ធនាគារអន្តរជាតិ គឺ Standard & Poor's និង GIIRS។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា បានទទួលការដំឡើងចំណាត់ថ្នាក់ Stand-Alone Credit Profile (SACP) ពីកម្រិត 'bb-' ទៅកម្រិត 'bb' ពីភ្នាក់ងារវាយតម្លៃអន្តរជាតិ Standard & Poor's (S&P) Global Ratings។ ទស្សនវិស័យស្ថិរភាពដែលបង្ហាញនៅក្នុងចំណាត់ថ្នាក់នេះ ឆ្លុះបញ្ចាំងពីភាពរឹងមាំនៃហិរញ្ញវត្ថុជាមួយនឹងទ្រនាប់ដើមទុនគ្រប់គ្រាន់ ដើម្បីស្ថិរភាពនៃដំណើរការអាជីវកម្ម។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលបានពានរង្វាន់ជាស្ថាប័នរីកចម្រើនលំដាប់ថ្នាក់ពិភពលោក របស់វេទិកាសេដ្ឋកិច្ចពិភពលោក ឆ្នាំ២០១៤ (World Economic Forum Global Growth Companies 2014) និងបានចូលជាសមាជិកនៃវេទិកាសេដ្ឋកិច្ចពិភពលោក (World Economic Forum)។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី បានទិញសេវាធានារ៉ាប់រងពីក្រុមហ៊ុន Jardine Lloyd Thompson Asia ជាក្រុមហ៊ុនធានារ៉ាប់រងធំជាងគេបង្អស់របស់ចក្រភពអង់គ្លេស និងពីក្រុមហ៊ុនធានារ៉ាប់រងហ្វតតេ ប្រចាំព្រះរាជាណាចក្រកម្ពុជា។
- មុនពេលចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជានៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានការរួមចំណែកភាគហ៊ុនចំនួន ៥១% ដោយភាគហ៊ុនិកកម្ពុជារួមជាមួយបុគ្គលិកធនាគារក្នុងនោះផងដែរ ហើយចំណែកដែលនៅសល់ ៤៩% ទៀតកាន់កាប់ដោយ ៖ Sumitomo Mitsui Banking Corporation (១៨,២៥%), COFIBRED (១២,២៥%), ORIX Corporation (១២,២៥%), និងមូលនិធិវិនិយោគបីគ្រប់គ្រងដោយ Triodos Investment Management គឺ Triodos Sustainable Finance Foundation, Triodos Fair Share Fund, និង Triodos Microfinance Fund (៦,២៥%)។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី មានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន ៤ គឺ (១) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត (២) អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី (៣) វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា និង (៤) អេស៊ីលីដា មីក្រូហិរញ្ញវត្ថុ មីយ៉ាន់ម៉ា។

- នៅចុងខែកក្កដា ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា បានពង្រីកបណ្តាញប្រតិបត្តិការរហូតដល់ ២៦៣សាខា គ្របដណ្តប់គ្រប់ខេត្ត-រាជធានី។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី បានចុះបញ្ជីមូលបត្រកម្មសិទ្ធិរបស់ខ្លួនជាផ្លូវការនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ វិនិយោគិន អាចធ្វើការជួញដូរភាគហ៊ុនរបស់ធនាគារ នៅលើទីផ្សារមូលបត្រកម្ពុជា ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង៨ព្រឹក ដល់ម៉ោង៣រសៀល លើកលែងតែថ្ងៃឈប់សម្រាកជាសាធារណៈ។ ការចុះបញ្ជីរបស់ធនាគារ អេស៊ីលីដា គឺជាការបើកទំព័រសករាជថ្មីនៃប្រវត្តិជោគជ័យជាង២៧ឆ្នាំរបស់ធនាគារ អេស៊ីលីដា និងក្លាយជាធនាគារពាណិជ្ជទីមួយដែលបានចុះបញ្ជីនៅលើ ផ.ម.ក.។
- ធនាគារបានទទួលនូវវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ “មាស” សុពលភាពរយៈពេល២ឆ្នាំ (២០២០ និង ២០២១) ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ការអនុវត្តការបង់ពន្ធអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។
- ធនាគារបានដាក់ឲ្យដំណើរការសេវាផ្ទេរប្រាក់ពីប្រទេសជប៉ុនមកប្រទេសកម្ពុជា ដោយបានសហការជាមួយ SBI Remit Co., Ltd.។ តាមរយៈភាពជាដៃគូនេះ ប្រជាជនរស់នៅប្រទេសជប៉ុន ជាពិសេសពលករកម្ពុជាដែលធ្វើការនៅប្រទេសជប៉ុន អាចទទួលបាននូវជម្រើសថ្មីបន្ថែមទៀតក្នុងការផ្ញើប្រាក់មកកាន់ប្រទេសកម្ពុជា តាមរយៈ SBI Remit Co., Ltd. និងធនាគារ អេស៊ីលីដា ភីអិលស៊ី។
- ធនាគារបានអភិវឌ្ឍមុខងារបន្ថែមថ្មីក្នុង **អេស៊ីលីដាម៉ូបាល** (**ACLEDA mobile**) ជំនាន់ថ្មីទី៤,០ ដែលផ្តល់បទពិសោធន៍ជូនអតិថិជនកាន់តែងាយស្រួល និងមានសុវត្ថិភាព ហើយជាពិសេសរឹតកាន់តែសាមញ្ញ និងទាក់ទាញសម្រាប់អតិថិជននាសម័យបច្ចុប្បន្ន។
- ធនាគារបានចូលរួមចំណែកក្នុងសកម្មភាពសង្គម និងមនុស្សធម៌ក្នុងការប្រយុទ្ធប្រឆាំង និងការការពារពីការរីករាលដាលនៃជំងឺកូវីដ-១៩ គាំទ្របុព្វហេតុសប្បុរសធម៌នៃមូលនិធិគន្ធបុប្ផាកម្ពុជា និងដើម្បីគាំទ្រដល់សកម្មភាព មនុស្សធម៌របស់កាកបាទក្រហមកម្ពុជា។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី បានចុះកិច្ចព្រមព្រៀងទទួលហិរញ្ញប្បទានរយៈពេលវែងចំនួន ១៣០ លានដុល្លារអាមេរិក ពីធនាគារ CHINA DEVELOPMENT BANK (CDB) ដែលជាស្ថាប័នអភិវឌ្ឍន៍ហិរញ្ញវត្ថុធំជាងគេក្នុងពិភពលោក។ ហិរញ្ញប្បទាននេះ គឺជាប្រភពទុនមួយនៃប្រភពទុនផ្សេងទៀត សម្រាប់គាំទ្រដល់ការរីកចម្រើនរយៈពេលវែងរបស់ធនាគារ និងការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យមនៅប្រទេសកម្ពុជា។
- ធនាគារបានបញ្ចុះអត្រាការប្រាក់ពី ០,៤% រហូតដល់ ១% ក្នុង១ឆ្នាំ បន្ថែមទៀត លើការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន។
- ធនាគារបានដាក់ឲ្យដំណើរការសេវាផ្ទេរប្រាក់ និងដាក់-ដកប្រាក់ ជាមួយគ្រឹះស្ថាន យេស អ៊ិននើវេសិន ម.ក។ កិច្ចសហប្រតិបត្តិការនេះនឹងអាចពង្រីកសេវាផ្ទេរប្រាក់ និងដាក់-ដកប្រាក់របស់ស្ថាប័នទាំងពីរឲ្យកាន់តែទូលំទូលាយថែមទៀត និងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពខ្ពស់។
- ធនាគារបានសហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ដាក់ឲ្យដំណើរការសេវាបង់កម្រៃសេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន តាមរយៈ **អេស៊ីលីដាម៉ូបាល**។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបរិច្ចាគថវិកាចំនួន ២៥ម៉ឺនដុល្លារអាមេរិក ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋដែលរងគ្រោះ ដោយសារទឹកជំនន់ដែលកំពុងកើតមាននៅក្នុងប្រទេស និងជាការព្រួយបារម្ភរបស់ប្រជាជនទូទាំងប្រទេសផងដែរ។
- នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញរបស់ខ្លួន ហើយនេះគឺជាលើកទី១ ដែលធនាគារបានរៀបចំមហាសន្និបាតដោយមានការចូលរួមពីភាគហ៊ុនិកសាធារណៈ។
- ធនាគារបានបរិច្ចាគថវិកាចំនួន ១.០០០.០០០.០០០ (មួយពាន់លានរៀល) ចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការទិញវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដើម្បីលើកកម្ពស់សុខុមាលភាពសាធារណៈ។
- ធនាគារបានប្រារព្ធពិធីដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នូវនិមិត្តសញ្ញាថ្មីរបស់ខ្លួន ដោយរក្សានូវនិមិត្តរូប អត្តសញ្ញាណ និងអត្ថន័យដែលធនាគារបានកសាងជាង២៨ឆ្នាំកន្លងមក។ ស្លាកសញ្ញាថ្មីរបស់ធនាគារ ជា "និមិត្តរូបបក្សីស្វត្ថិ" ឈរនៅចំកណ្តាលរង្វង់មូលពណ៌ខៀវទឹកប៊ិក ដែលបង្ហាញពីភាពរឹងមាំ និងវឌ្ឍនភាពប្រកបដោយចីរភាព។
- បន្ថែមពីការដាក់ឲ្យប្រើប្រាស់នូវស្លាកសញ្ញាថ្មី កម្មវិធីទូរស័ព្ទចល័តរបស់ធនាគារក៏បានកែប្រែរូបរាងថ្មី និងប្តូរឈ្មោះពីអេស៊ីលីដាយូនីធីទាន់ចិត្ត ទៅ **អេស៊ីលីដាម៉ូបាល**។ រូបរាងថ្មីរបស់ **អេស៊ីលីដាម៉ូបាល** ត្រូវបានរចនាឡើងដោយអ្នកជំនាញដែលមានបទពិសោធន៍ខាងបញ្ចូលបច្ចេកវិទ្យាចុងក្រោយទៅក្នុងកម្មវិធី (app) ហើយវាត្រូវបានបំពាក់ដោយប្រព័ន្ធសុវត្ថិភាពអាយអេសអូ (ISO) និងឧស្សាហកម្មប័ណ្ណទូទាត់ (PCI) លំដាប់ថ្នាក់ពិភពលោកដែលធានាបាននូវកម្រិតសុវត្ថិភាពខ្ពស់បំផុត។ ជាមួយនឹងរូបរាងថ្មីរបស់ **អេស៊ីលីដាម៉ូបាល** គឺដើម្បីជួយឲ្យសេវាទូរស័ព្ទចល័តរបស់ធនាគារអាចឆ្លើយតបទៅនឹងភាពរីកចម្រើននៃបច្ចេកវិទ្យារបស់ពិភពលោក និងវឌ្ឍនភាពរបស់ធនាគារក្នុងយុគសម័យឌីជីថល។

# ង. ស្ថានភាពទីផ្សារ

រហូតមកដល់បច្ចុប្បន្ន វិស័យធនាគារបានអភិវឌ្ឍយ៉ាងឆាប់រហ័ស និងបានរួមចំណែកយ៉ាងសកម្មក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ។ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានចំណែកទីផ្សារ ១៤,៩៨% និង ១៣,៨៩% រៀងគ្នាសម្រាប់ប្រាក់បញ្ញើ និងឥណទានគិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២០។ ទោះបីជាការរីករាលដាលនៃជំងឺឆ្លងជាសកលបានប៉ះពាល់ជាអវិជ្ជមានគ្រប់វិស័យនៅក្នុងប្រទេសក៏ដោយ បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា ភីអិលស៊ីនៅតែបន្តអនុវត្តប្រាក់បញ្ញើសរុប បានកើនឡើងចំនួន ២៤៣,៤០ លានដុល្លារអាមេរិក និងសមតុល្យឥណទានសរុបបានកើនឡើងចំនួន ៦២៧,១៨ លានដុល្លារអាមេរិក បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩ ។

រីឯស្ថានភាពថ្លៃសម្រាប់គ្រឹះស្ថានធនាគារ អត្រាការប្រាក់ឥណទានជាប្រាក់រៀល និងជាដុល្លារអាមេរិក បានកើនឡើងដល់ ១១,៥៥% និង ៩,៨៨% ខ្ពស់ជាងឆ្នាំ២០១៩ ដែលមានត្រឹមតែ ១០,៤៧% និង ៨,៧៧% ខណៈដែល វិស័យមីក្រូហិរញ្ញវត្ថុបានធ្លាក់ចុះរៀងគ្នាពី ១៧,៩២% និង ១៥,៩៥% នៅឆ្នាំ២០១៩ មកនៅត្រឹម ១៦,៥៦% និង ១៤,៨៦% នៅឆ្នាំ២០២០។ ចំពោះអត្រាប្រាក់បញ្ញើជាប្រាក់រៀលសម្រាប់គ្រឹះស្ថានធនាគារ បានថយចុះបន្តិចពី ៦,៣៥% មក ៥,៩៣% និងជាប្រាក់ដុល្លារអាមេរិកមានចំនួន ៤,៩៣% ប្រហាក់ប្រហែលនឹងឆ្នាំមុន ៤,៨៣% ខណៈដែល វិស័យមីក្រូហិរញ្ញវត្ថុបានធ្លាក់ចុះរៀងគ្នាពី ៧,៩៣% និង ៧,៧១% នៅឆ្នាំ២០១៩ មកនៅត្រឹម ៧,៣១% និង ៧,២៥% នៅឆ្នាំ២០២០។ [1]

## ច. ស្ថានភាពប្រកួតប្រជែង

ចំនួនធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុនៅកម្ពុជា បន្តរីកចម្រើនគួរឲ្យកត់សម្គាល់។ គិតត្រឹមខែធ្នូ ឆ្នាំ២០២០ ធនាគារពាណិជ្ជមានចំនួន ៥៣ (ធនាគារក្នុងស្រុកចំនួន២២, បុត្រសម្ព័ន្ធធនាគារបរទេសចំនួន១៧, និងសាខាធនាគារបរទេសចំនួន១៤), ធនាគារឯកទេសចំនួន ១៤ (ធនាគារក្នុងស្រុកចំនួន០៦ និងធនាគារបរទេសចំនួន០៨), គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៨១ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៦ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន៧៥), ក្រុមហ៊ុនភតិសន្យាចំនួន១៥, ការិយាល័យតំណាងធនាគារបរទេសចំនួន០៦, គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន២៤, និងគ្រឹះស្ថានឥណទានជនបទចំនួន២៤៦ ។

ស្របគ្នានេះដែរ សមតុល្យឥណទានអតិថិជនកើនឡើងរហូតដល់ ១៥១,៣ទ្រីលានរៀល (វិស័យធនាគារ ១២២,៤ទ្រីលានរៀល វិស័យមីក្រូហិរញ្ញវត្ថុ២៧,៦ទ្រីលានរៀល វិស័យភតិសន្យាហិរញ្ញវត្ថុ១,៣ទ្រីលានរៀល និងគ្រឹះស្ថានឥណទានជនបទ ២៨៥,៣ប៊ីលានរៀល) កើនឡើង ១៨,៨% (ក្នុងនោះវិស័យធនាគារកើនឡើង១៥,៣% វិស័យមីក្រូហិរញ្ញវត្ថុ១២,៥% និងវិស័យភតិសន្យាហិរញ្ញវត្ថុ១២,១%) ដោយមានគណនីឥណទានសរុប ៣,២លានគណនី (វិស័យធនាគារ១,២លានគណនី វិស័យមីក្រូហិរញ្ញវត្ថុ១,៩លានគណនី វិស័យភតិសន្យាហិរញ្ញវត្ថុ០,១លានគណនី និងគ្រឹះស្ថានឥណទានជនបទ ១៩៨.០១៥នាក់)។ រីឯសមតុល្យប្រាក់បញ្ញើក៏រីកលូតលាស់ផងដែរដោយបន្តកើនឡើងដល់ ១៣៦,៩ទ្រីលានរៀល (វិស័យធនាគារ ១២១,៧ទ្រីលានរៀល និងវិស័យមីក្រូហិរញ្ញវត្ថុ១៥,២ទ្រីលានរៀល) កើនឡើង១៥,៤% (ក្នុងនោះវិស័យធនាគារកើនឡើង ១៥,៥%) ដោយមានគណនីប្រាក់បញ្ញើចំនួន៨,៩ លានគណនី (វិស័យធនាគារ៦,៣លានគណនី និងវិស័យមីក្រូហិរញ្ញវត្ថុ២,៧លានគណនី)។ (ប្រភពទិន្នន័យ៖ ធនាគារជាតិ នៃ កម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា)

ស្ថានភាពអតិថិជន ទីផ្សារ ថ្លៃ និងការប្រកួតប្រជែងនៅក្នុងវិស័យធនាគារ មានការប្រែប្រួលគួរឲ្យកត់សម្គាល់ ក៏ប៉ុន្តែធនាគារ អេស៊ីលីដា នៅតែបន្តរក្សាបានឧត្តមភាពប្រកួតប្រជែង លើគ្រប់ផលិតផល-សេវាកម្ម បណ្តាញប្រតិបត្តិការ ប្រភពទុន និងធនធានបច្ចេកទេស ព្រមទាំងបន្តភាពរីកចម្រើនបានយ៉ាងល្អប្រសើរ។ គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២០ ឥណទានរបស់ធនាគារ អេស៊ីលីដា មានកំណើនរៀងគ្នា ៣,៤៣% និង ១៦,១៧% ទាំងចំនួនឥណទាន និងទំហំឥណទានសរុបធៀបនឹងឆ្នាំ២០១៩ ស្របគ្នានឹងប្រាក់បញ្ញើមានកំណើន ១០,៤៦% និង ៥,៥៧% ទាំងចំនួនគណនី និងសមតុល្យប្រាក់បញ្ញើសរុប។ ដោយឡែក ចំនួនប្រតិបត្តិការសរុបដែលអតិថិជនបានប្រើប្រាស់ជាមួយធនាគារ អេស៊ីលីដា បន្តកើនឡើងចំនួន ៤៥,៥៥% (ក្នុងនោះនៅតាមបញ្ជរធនាគារកើនឡើង ១៩,៨៥% និង តាមរយៈសេវាឌីជីថល កើនឡើងចំនួន ៥៩,៥១%) និងចំនួនប្រតិបត្តិការសរុបដែលអតិថិជនបានប្រើប្រាស់ជាមួយធនាគារ អេស៊ីលីដា និងបុត្រសម្ព័ន្ធ កើនឡើងចំនួន ៤៧,០៩% (ក្នុងនោះនៅតាមបញ្ជរកើនឡើង ២៣,២៣% និង តាមរយៈសេវាឌីជីថល កើនឡើងចំនួន ៦០,០៤%) បើប្រៀបធៀបនឹងឆ្នាំ២០១៩។

## ឆ. ផែនការអនាគត

ធនាគារ អេស៊ីលីដា មានផែនការបន្តធ្វើឲ្យប្រសើរឡើង និងកាន់តែងាយស្រួលសម្រាប់អតិថិជនក្នុងការប្រើប្រាស់សេវាកម្មឌីជីថលរបស់ខ្លួន ដោយបន្តធ្វើនវានុវត្តន៍ផលិតផល-សេវាកម្មថ្មីៗ និងបន្តធ្វើបច្ចុប្បន្នភាពទៅលើផលិតផល-សេវាកម្មឌីជីថលដែលមានស្រាប់។ បន្ថែមពីនេះ ធនាគារ អេស៊ីលីដា មានផែនការកាត់បន្ថយចំនួនសាខាបច្ចុប្បន្ន ដែលប្រើប្រាស់មនុស្សច្រើន តែជំនួសមកវិញដោយការបង្កើនចំនួនការិយាល័យសេវាកម្មធនាគារស្វ័យប្រតិបត្តិការ (Banking Self Service) ដែលបំពាក់ទៅដោយម៉ាស៊ីន និងអាចគាំទ្រប្រតិបត្តិការរបស់អតិថិជនបាន ២៤/៧ ទាំងនៅរាជធានីភ្នំពេញ និងនៅតាមបណ្តារខេត្តនានា។

## ជ. កត្តាហានិភ័យ

### ១. ការវិភាគ

ការរីករាលដាលនៃជំងឺកូវីដ-១៩ ធ្វើឲ្យប៉ះពាល់ដល់សង្គមសេដ្ឋកិច្ចសកល និងប្រទេសជាតិ ជាពិសេស  វិស័យសំខាន់ៗដូចជា ទេសចរណ៍ ការនាំចេញសម្លៀកបំពាក់ វាយនភណ្ឌ និងស្បែកជើង វិស័យសំណង់ និងអចលនទ្រព្យ និងការដឹកជញ្ជូន ។ ទន្ទឹមនេះដែរ ការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ជាកត្តាហានិភ័យសារវន្តចំពោះធនាគារ អេស៊ីលីដា ផងដែរដូចជា ៖

#### ១-១ ហានិភ័យឥណទាន

ហានិភ័យ និងបញ្ហាប្រឈមជាចម្បង ដោយសារការរីករាលដាលនៃវិបត្តិជំងឺកូវីដ-១៩ បណ្តាលឲ្យប៉ះពាល់ដល់សេដ្ឋកិច្ច ដែលបានធ្វើឲ្យអតិថិជនឥណទាន ឬដៃគូពាណិជ្ជកម្ម មិនអាចបំពេញកាតព្វកិច្ចហិរញ្ញវត្ថុក្នុងការទូទាត់សង ធ្វើឲ្យមានផលប៉ះពាល់ដល់លំហូរសាច់ប្រាក់ និងស្ថានភាពអនាគតរបស់ធនាគារ ។ ការរីករាលដាលនៃជំងឺកូវីដ-១៩ ធ្វើឲ្យអតិថិជនឥណទានបាត់បង់ ឬប៉ះពាល់ការងារអាជីវកម្ម ដែលបណ្តាលឲ្យប៉ះពាល់ដល់ការបំពេញកាតព្វកិច្ចសងឥណទានមកធនាគារ និងកំណើនអតិថិជនស្នើសុំរៀបចំហ្វាស៊ីលីធីឡើងវិញ ។

#### ១-២ ហានិភ័យសន្ទនីយភាព

បញ្ហាប្រឈមនៃការរីករាលដាលនៃជំងឺកូវីដ-១៩ អាចឈានទៅដល់ការភ្ញាក់ផ្អើល និងជ្រួលច្របល់ដល់សាធារណជន និងអតិថិជន និងបង្កឲ្យមានហានិភ័យសន្ទនីយភាព។

#### ១-៣ ហានិភ័យប្រតិបត្តិការ

ការរីករាលដាលនៃជំងឺកូវីដ-១៩ ធ្វើឲ្យប៉ះពាល់ ឬអាក់ខានដល់ប្រតិបត្តិការអាជីវកម្មមួយផ្នែក ឬទាំងស្រុង ករណីមានបុគ្គលិក ឬអតិថិជនឆ្លងជំងឺកូវីដ-១៩ ដែលមានការពាក់ព័ន្ធដល់បុគ្គលិក ឬការិយាល័យប្រតិបត្តិការ របស់ធនាគារ ឬការបិទទីកន្លែង តំបន់ ខណ្ឌ-ស្រុក ដែលស្ថិតនៅក្នុងតំបន់ប្រតិបត្តិការរបស់ធនាគារ ដោយសារតែការរីករាលដាលខ្លាំងនៃជំងឺកូវីដ-១៩ ។

# ២. ទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់

ទោះបីជាយ៉ាងណាថ្នាក់គ្រប់គ្រងជឿជាក់ថា កត្តាហានិភ័យទាំងនេះអាចគ្រប់គ្រង និងចាត់វិធានការកាត់បន្ថយ ព្រមទាំងប្រែក្លាយវាជា កាលានុវត្តភាពផងដែរ ៖

## ២-១ វិធានការគ្រប់គ្រងហានិភ័យឥណទាន

- អនុវត្តយ៉ាងខ្ជាប់ខ្ជួននូវសារាចរណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា ស្តីពីការរៀបចំឥណទានឡើងវិញក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ ដោយបានរៀបចំយុទ្ធសាស្ត្រ គោលនយោបាយ នីតិវិធី និងបង្កើតក្រុមការងារឯករាជ្យដែលមានតួនាទីសិក្សា វិភាគ វាយតម្លៃឯករាជ្យលើសំណើសុំរៀបចំឥណទានឡើងវិញរបស់អតិថិជនដែលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ មុននឹងដាក់ជូន គណៈកម្មាធិការឥណទានកម្រិតប្រតិបត្តិពិនិត្យ និងអនុម័ត។
- បន្តផ្តល់ឥណទាន សេវាទូទាត់ផ្សេងៗ ដល់វិស័យអាទិភាពជាពិសេសអាជីវកម្មសណ្ឋាគារ ផ្ទះសំណាក់ ទេសចរណ៍ សំណង់ វាយនភណ្ឌ កាត់ដេរ និងផលិតផលស្បែកជើង ព្រមទាំងបន្ធូរបន្ថយការប្រាក់ឥណទានខ្នាតតូច ដើម្បីធានានិរន្តរភាពអាជីវកម្ម ។
- រក្សាភាពទន់ភ្លន់ និងពិនិត្យតាមលទ្ធភាពជាក់ស្តែង ក្នុងការដោះស្រាយបំណុលដែលយឺតយ៉ាវបណ្តាលមកពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ ជាមួយនឹងការលើកទឹកចិត្តភ្នាក់ងារឥណទាន ធ្វើការទាក់ទង និងដោះស្រាយជាមួយអតិថិជនតាមរយៈទូរស័ព្ទ ។
- ជម្រុញការប្រើប្រាស់ ប្រព័ន្ធស្វ័យប្រតិបត្តិការ (Self Service) ដូចជា ម៉ាស៊ីនឆូតកាត (ACLEDA POS) ម៉ាស៊ីនដាក់-ដកប្រាក់ (ATM and CDM) អេស៊ីលីដា អ៊ីនធើណែត (ACLEDA Internet Banking) អេស៊ីលីដា អ៊ីខុមមើស (ACLEDA E-Commerce) **អេស៊ីលីដា ម៉ូបាល** (**ACLEDA Mobile**) ក្នុងការផ្ទេរប្រាក់ និងការទូទាត់ផ្សេងៗ ដើម្បីកាត់បន្ថយការធ្វើប្រតិបត្តិការនៅបញ្ជរ និងការឆ្លងតាមរយៈការប្រើក្រដាសប្រាក់។

## ២-២ វិធានការគ្រប់គ្រងហានិភ័យសន្ទនីយភាព

ស្របជាមួយវិធានការបន្ថែមដែលធនាគារជាតិ នៃ កម្ពុជាបានដាក់ចេញ ដើម្បីផ្តល់សន្ទនីយភាពបន្ថែមដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងការកាត់បន្ថយផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ធនាគារ អេស៊ីលីដា បានដាក់ចេញនូវវិធានការគ្រប់គ្រងហានិភ័យដើម្បីកាត់បន្ថយ ហានិភ័យសន្ទនីយភាព និងរក្សានិរន្តរភាពអាជីវកម្ម ដោយបានត្រៀមបម្រុងមូលនិធិស្ថិតនៅកម្រិតខ្ពស់ដែលអាចគាំទ្រដល់កំណើនអាជីវកម្ម និងឆ្លើយតបបានទាន់ពេលទៅនឹងហេតុការណ៍ហានិភ័យដែលមិនអាចរំពឹងទុកនានា ។

## ២-៣ វិធានការគ្រប់គ្រងហានិភ័យប្រតិបត្តិការ

អនុលោមតាមសេចក្តីណែនាំនានារបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងសុខាភិបាល ស្តីពីការការពារ និងទប់ស្កាត់ការឆ្លង និងរីករាលដាលនៃជំងឺកូវីដ-១៩ ធនាគារ អេស៊ីលីដាបានយកចិត្តទុកដាក់អនុវត្ត និងដាក់ចេញនូវវិធានការ និងសេចក្តីណែនាំបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដើម្បីធានានូវ និរន្តរភាពអាជីវកម្ម ដូចជាៈ

- ពង្រឹង និងយកចិត្តទុកដាក់លើការការពារបង្ការការឆ្លងនូវជំងឺកូវីដ-១៩ ជាយថាហេតុ ចំពោះបុគ្គលិក និង អតិថិជន ទៅតាមការណែនាំរបស់ក្រសួងសុខាភិបាល និង ធនាគារជាតិ នៃ កម្ពុជា។
- ពង្រឹងក្នុងការត្រួតពិនិត្យដោយយកចិត្តទុកដាក់ និងហ្មត់ចត់អំពីស្ថានភាព និងសកម្មភាពរបស់បុគ្គលិក ដែលអាចបង្កឲ្យមានការីករាលដាលនូវជំងឺកូវីដ-១៩ ព្រមទាំងទទួលនូវរបាយការណ៍តាមគ្រប់មធ្យោបាយ អំពីករណីនៃការរីករាលដាល ពីបុគ្គលិកដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ ឬប្រយោល ។ បានត្រៀម និងបានអនុញ្ញាតិឲ្យបុគ្គលិកពាក់ព័ន្ធបំពេញការងារពីផ្ទះ និងអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល និងធនាគារជាតិ នៃ កម្ពុជា។
- រៀបចំផែនការយថាភាពសម្រាប់ធានានិរន្តរភាពប្រតិបត្តិការ ក្នុងករណីការិយាល័យសាខាខេត្ត-ក្រុងណាមួយត្រូវបានបិទប្រតិបត្តិការ ដោយសារ ការរីករាលដាលនៃជំងឺកូវីដ-១៩ ធនាគារ អេស៊ីលីដានៅតែអាចបន្ត ប្រតិបត្តិការបានដោយមិនមានភាពរាំងស្ទះឡើយ ។ ធនាគារ អេស៊ីលីដាបាននិងកំពុងធ្វើប្រតិបត្តិការដោយផ្អែកលើមូលដ្ឋានគ្រឹះរឹងមាំបី គឺបណ្តាញសាខាទូលំទូលាយ និងគ្រប់សាខាបានភ្ជាប់បណ្តាញ Online Real-time ប្រព័ន្ធស្វ័យប្រតិបត្តិការ (Self Service) ដូចជា ម៉ាស៊ីនឆូតកាត (ACLEDA POS) ម៉ាស៊ីនដាក់-ដកប្រាក់ (ACLEDA ATM and CDM) អេស៊ីលីដា អ៊ីនធើណែត (ACLEDA Internet Banking) អេស៊ីលីដា អ៊ីខុមមើស (ACLEDA E-Commerce) និង Digital Service ដូចជា **អេស៊ីលីដា ម៉ូបាល** ដែលអតិថិជនអាចធ្វើប្រតិបត្តិការពីផ្ទះ និងពីគ្រប់ទីកន្លែង គ្រប់ពេលវេលា។
- រៀបចំផែនការយថាភាព សម្រាប់ធានានិរន្តរភាពប្រតិបត្តិការ ក្នុងករណីការិយាល័យកណ្តាលត្រូវបានបិទប្រតិបត្តិការដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ធនាគារ អេស៊ីលីដា នឹងបន្តប្រតិបត្តិការ នៅទីតាំងការិយាល័យនៅជិតដែលបានបម្រុងទុក ។ ក្នុងករណីថ្នាក់ដឹកនាំជាន់ខ្ពស់ណាម្នាក់ ឬទាំងអស់ត្រូវធ្វើចត្តាឡីស័ក យើងអាចធ្វើការពីផ្ទះបានដោយមិនមានការរាំងស្ទះឡើយ។ ក្នុងករណីថ្នាក់គ្រប់គ្រងជាន់ខ្ពស់មានជំងឺ ឬតម្រូវឲ្យធ្វើចត្តាឡីស័ក ថ្នាក់គ្រប់គ្រងបន្ទាប់ដែលទទួលសិទ្ធិ ត្រូវបន្តការងារជំនួស ទៅតាមផែនការបន្តវេន ។

# ផ្នែកទី ២

## ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

# ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

គិតនៅត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទទួលបានលទ្ធផលល្អទាំងការលក់ និងចំណូល ។ លទ្ធផលសំខាន់ៗសម្រេចបានគិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២០ មានដូចខាងក្រោម៖

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | |
|---|---|---|
| | ២០២០ | ២០១៩ |
| **សេវាឥណទាន** | | |
| ចំនួនឥណទានសកម្ម | ៥៥៥.៣២៣ | ៥៣៦.៨៩១ |
| សមតុល្យឥណទានសរុប (លានរៀល) | ១៨.២២៩.៣៧២ | ១៥.៨០៨.៨១៤ |
| **សេវាបញ្ញើ-សន្សំ** | | |
| ចំនួនគណនីសរុប | ២.៨៩៤.៩០៧ | ២.៦២០.៧៧៨ |
| ចំនួនទឹកប្រាក់សរុប (លានរៀល) | ១៨.៦៥២.៦៩០ | ១៧.៧៩៩.១៨៤ |
| **សេវាធនាគារអេឡិចត្រូនិក** | | |
| **ប័ណ្ណអេធីអឹម អេស៊ីលីដា** | | |
| ចំនួនប័ណ្ណបោះផ្សាយសរុប | ១.៣៩៦.៧៧៨ | ១.២៧៧.៧២៥ |
| ចំនួនប្រតិបត្តិការសរុប | ១៩.៧៦៨.២២៣ | ២០.៤០៣.២០០ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៣.៧៧៥.៩១៨ | ១២.៥៤៨.០៦៦ |
| **សេវាធនាគារចល័ត** | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ១.៧៨២.៨១៤ | ១.២៧៦.៥២៨ |
| ចំនួនប្រតិបត្តិការសរុប | ៤៨.៧៤៩.៥៩៩ | ២៨.២៦៤.៩៧២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៥៩.២១១.២៧៩ | ៣៧.៣០៣.១៣៧ |
| **សេវាអេស៊ីលីដាអ៊ីនធើណែត** | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ១១.៦៧៩ | ១១.៣៣១ |
| ចំនួនប្រតិបត្តិការសរុប | ៨៨៦.៩៩០ | ៥១០.២៩៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១១.២៨៥.៩៤៨ | ៥.២៣៥.៦១៦ |
| **សេវាអេស៊ីលីដាអ៊ីខុមមើស** | | |
| ចំនួនដៃគូអាជីវកម្មសរុប | ៥១ | ៤៨ |
| ចំនួនប្រតិបត្តិការសរុប | ៤៤៧.៩២៩ | ៤៦៧.៦៦៨ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣៦០.០០០ | ២១៣.៦៦២ |
| **ម៉ាស៊ីនអេធីអឹម អេស៊ីលីដា** | | |
| ចំនួនម៉ាស៊ីនសរុប | ៧៩០ | ៦៨៣ |
| ចំនួនប្រតិបត្តិការសរុប | ២៦.៥៧៤.៦៧៨ | ២៤.១៨១.២៣១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២០.១៩៨.៧២៤ | ១៥.៩២៩.១៩៧ |
| **ម៉ាស៊ីនឆូតកាត អេស៊ីលីដា** | | |
| ចំនួនម៉ាស៊ីនឆូតកាតសរុប | ៤.២៨៧ | ៤.២៨៩ |
| ចំនួនប្រតិបត្តិការសរុប | ២.៤៥៧.៦២៦ | ២.៤១២.៩៣៨ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៦៥៧.៥០៦ | ៨៤៩.៣៩២ |
| **កូដ QR នៅតាមហាងទំនិញនានា** | | |
| ចំនួនពាណិជ្ជករបំពាក់កូដ QR | ៦៣.៧១៤ | ៣០.៩៨៩ |
| ចំនួនប្រតិបត្តិការសរុប | ១.៨៤២.៩១៣ | ៧៣៥.៣១២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៨៦.៦៩១ | ៩០.៨៨៦ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | |
|---|---|---|
| | ២០២០ | ២០១៩ |
| **បណ្ដាញប្រតិបត្តិការ និង បុគ្គលិក** | | |
| **ធនាគារ អេស៊ីលីដា ភីអិលស៊ី** | | |
| ចំនួនការិយាល័យសរុប | ២៦៣ | ២៦២ |
| ចំនួនបុគ្គលិកសរុប | ១២.០១៣ | ១១.៩៩៧ |
| **ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ក្នុង និង ក្រៅប្រទេស)** | | |
| ចំនួនការិយាល័យសរុប | ៥៦ | ៥៣ |
| ចំនួនបុគ្គលិកសរុប | ១.៦៩១ | ១.៦៥៨ |

ខាងក្រោម ជាចំនួនប្រតិបត្តិការសរុប ដែលអតិថិជនបានប្រើប្រាស់ផលិតផល-សេវាកម្មនៅតាមបញ្ជរ និងឌីជីថល របស់ធនាគារ អេស៊ីលីដា និងបុត្រសម្ព័ន្ធ៖

| ប្រភេទប្រតិបត្តិការ | លទ្ធផលសម្រេចបាន | |
|---|---|---|
| | ២០២០ | ២០១៩ |
| **នៅតាមបញ្ជរធនាគារ** | | |
| ចំនួនប្រតិបត្តិការ | ៣៣.៩១១.៣៥៨ | ២៧.៥១៧.៩៤៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២៤៨.០១៥.៧៧៩ | ២៤៧.៧៨១.៣៤៨ |
| **សេវាកម្មឌីជីថល (ធ្វើប្រតិបត្តិការដោយផ្ទាល់)** | | |
| ចំនួនប្រតិបត្តិការ | ៨១.២០៤.៤១២ | ៥០.៧៨១.៥៤២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៨៧.៨១៨.៨២៣ | ៥២.៨៥៣.៦៧០ |

# ខ. រចនាសម្ព័ន្ធចំណូល

| ប្រភពចំណូល (លានរៀល) | ២០២០ | | ២០១៩ | | ២០១៨ | |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ២.១០០.០៤០ | ៨៨,៩៣% | ១.៩៥៩.៣១៨ | ៨៧,៩០% | ១.៨៣៤.៦១២ | ៨៨,៨២% |
| ចំណូលកម្រៃ និងជើងសា | ១៨៦.៦២៥ | ៧,៩០% | ១៩៧.៤៧៣ | ៨,៨៦% | ១៧៣.២៩០ | ៨,៣៩% |
| ចំណូលផ្សេងៗ | ៧៤.៨១៨ | ៣,១៧% | ៧២.៣២៧ | ៣,២៤% | ៥៧.៦៩៩ | ២,៧៩% |
| ចំណូលសរុប | ២.៣៦១.៤៨៣ | ១០០% | ២.២២៩.១១៨ | ១០០% | ២.០៦៥.៦០១ | ១០០% |

# ផ្នែកទី ៣

## ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

# ក. អង្គការលេខ



ភាគទុនិក
ក្រុមប្រឹក្សាភិបាល
គណៈកម្មាធិការសវនកម្ម
គណៈកម្មាធិការតែងតាំង និងលាភការ
គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា
ប្រធាននាយកប្រតិបត្តិ
គណៈកម្មាធិការប្រតិបត្តិ
អេស៊ីលីដា ការិយាល័យតំណាង
ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា ម៉ីយ៉ាន់ម៉ា លីមីធីត
ធនាគារ អេស៊ីលីដា ឡាវ លីមីធីត
អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី
វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា
គណៈកម្មាធិការឥណទានកម្រិតប្រតិបត្តិ
គណៈកម្មាធិការធនធានមនុស្ស ទទួលខុសត្រូវបញ្ហាអេដស៍ និងការប្រយុទ្ធប្រឆាំងគ្រឿងញៀន
គណៈកម្មាធិការលទ្ធកម្ម
គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម
គណៈកម្មាធិការគ្រប់គ្រងវិនិយោគ
គណៈកម្មាធិការដឹកនាំ និងគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មាន
គណៈកម្មាធិការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រ
គណៈកម្មាធិការគ្រប់គ្រងហានិភ័យកម្រិតប្រតិបត្តិ
គណៈកម្មាធិការគ្រប់គ្រងហានិភ័យប្រតិបត្តិការ
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ
នាយកប្រតិបត្តិប្រតិបត្តិការ
នាយកប្រតិបត្តិគ្រប់គ្រងសេវាឥណទាន
នាយិកាប្រតិបត្តិទីផ្សារ
នាយកប្រតិបត្តិអភិវឌ្ឍន៍ផលិតផល
នាយកប្រតិបត្តិសេវាហិរញ្ញវត្ថុ
នាយិកាការិយាល័យហិរញ្ញប្បទានពាណិជ្ជកម្ម
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ
នាយិកាប្រតិបត្តិហិរញ្ញវត្ថុ
នាយកប្រតិបត្តិរៀបចំ និងត្រួតពិនិត្យផែនការថវិកា
នាយកប្រតិបត្តិវិនិយោគសាធារណៈ
នាយិកាការិយាល័យគណនេយ្យគ្រប់គ្រង
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល
នាយិកាប្រតិបត្តិប្រតិបត្តិការហិរញ្ញវត្ថុ
នាយកការិយាល័យរតនាភិបាល
នាយកការិយាល័យជាន់ខ្ពស់ប្រាក់កម្ចីនិងអាគ្រាប្រូប័យប័ណ្ណ
នាយកការិយាល័យរតនពាណិជ្ជកម្ម
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរដ្ឋបាលកិច្ច
នាយកប្រតិបត្តិធនធានមនុស្ស
នាយកប្រតិបត្តិរដ្ឋបាល
នាយិកាការិយាល័យគ្រប់គ្រងប្រព័ន្ធ SWIFT
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន
នាយកប្រតិបត្តិនីតិកម្ម
នាយកប្រតិបត្តិលេខាធិការក្រុមហ៊ុន និងបង្ហាញព័ត៌មាន
នាយកការិយាល័យប្រឹក្សាប្រុងមត្តិ
នាយកការិយាល័យគ្រប់គ្រងវិវាទ
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា
នាយកប្រតិបត្តិគ្រប់គ្រងសេវាកម្មផ្នែកទន់
នាយកប្រតិបត្តិសន្តិសុខព័ត៌មានវិទ្យា
នាយកប្រតិបត្តិប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ
នាយកប្រតិបត្តិរៀបចំយុទ្ធសាស្ត្រ និងអភិបាលព័ត៌មានវិទ្យា
នាយកប្រតិបត្តិគ្រប់គ្រងសេវាកម្មឌីជីថល
នាយិកាការិយាល័យសេវាកម្មព័ត៌មានវិទ្យា
អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ
នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ
នាយកប្រតិបត្តិឥណទាន
នាយកប្រតិបត្តិភិភាគទិន្នន័យឥណទាន និងស្រាវជ្រាវ
នាយកការិយាល័យត្រួតពិនិត្យឥណទាន
គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង
នាយកប្រតិបត្តិអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង
នាយកការិយាល័យរបាយការណ៍សវនកម្ម
នាយកការិយាល័យសវនកម្មសន្តិសុខព័ត៌មានវិទ្យា
នាយកការិយាល័យសវនកម្មឥណទាន
នាយកការិយាល័យសវនកម្មហិរញ្ញវត្ថុ
នាយិកាការិយាល័យ សវនកម្មប្រាក់បញ្ញើ និង Digital Banking
នាយកប្រតិបត្តិអនុលោមបញ្ញត្តិ
២៦៣ សាខា គ្របដណ្តប់ទូទាំងប្រទេស

# ខ. ក្រុមប្រឹក្សាភិបាល

## សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិ |
|---|---|---|---|---|
| ១ | **លោក ឆាយ សឿន** | ប្រធានក្រុមប្រឹក្សាភិបាល | ១៨ សីហា ២០១៤ | ១៨ សីហា ២០២៣ |
| ២ | **បណ្ឌិត អ៊ិន ចាន់នី** | អភិបាលប្រតិបត្តិ | ១៨ សីហា ២០១៤ | ១៨ សីហា ២០២៣ |
| ៣ | **លោក រ័ត្ន យូម៉េង** | អភិបាលប្រតិបត្តិ | ១៨ សីហា ២០១៤ | ១៨ សីហា ២០២៣ |
| ៤ | **លោក Pieter Kooi** | អភិបាលឯករាជ្យ | ១២ មករា ២០០៤ | ១២ មករា ២០២២ |
| ៥ | **លោក វ៉ាន់ ស៊ូអៀង** | អភិបាលឯករាជ្យ | ០២ កញ្ញា ២០២០ | ០២ កញ្ញា ២០២៣ |
| ៦ | **លោក Ian Samuel Lydall** | អភិបាលឯករាជ្យ | ២១ សីហា ២០១៥ | ២១ សីហា ២០២១ |
| ៧ | **លោក Kenichiro Mori** | អភិបាលមិនប្រតិបត្តិ | ២៤ តុលា ២០១៩ | ០៦ ធ្នូ ២០២២ |
| ៨ | **លោក Stéphane MANGIAVACCA** | អភិបាលមិនប្រតិបត្តិ | ២១ មេសា ២០២០ | ២១ សីហា ២០២១ |
| ៩ | **លោកស្រី Mirjam Janssen** | អភិបាលមិនប្រតិបត្តិ | ២០ មករា ២០២០ | ១២ មករា ២០២២ |

ឈ្មោះលេខាធិការ ធនាគារ អេស៊ីលីដា ភីអិលស៊ី៖ **លោកស្រី ប៊ុត ប៊ុនសីហា, លោក យិន វីរៈ, លោក សេន សុខឡា, លោកស្រី ទេព សរចិន្តា**

# គ. គណៈកម្មាធិការប្រតិបត្តិ

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | **បណ្ឌិត អ៊ិន ចាន់នី** | ប្រុស | ប្រធាននាយកប្រតិបត្តិ |
| ២ | **បណ្ឌិត សូ ផនណារី** | ស្រី | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ |
| ៣ | **លោកស្រី ម៉ារ អមរា** | ស្រី | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ |
| ៤ | **លោក រ័ត្ន យូម៉េង** | ប្រុស | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល |
| ៥ | **លោក លី ថៃ** | ប្រុស | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច |
| ៦ | **លោកស្រី ប៊ុត ប៊ុនសីហា** | ស្រី | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន |
| ៧ | **លោក ម៉ាច ធែរី** | ប្រុស | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា |
| ៨ | **បណ្ឌិត ឡឹង សុភាព** | ប្រុស | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ |

សម្គាល់៖ ព័ត៌មានលម្អិតពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្មមានភ្ជាប់ជាឧបសម្ព័ន្ធ។

# ផ្នែកទី ៤

## ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

# ក. ព័ត៌មានអំពីមូលបត្រ

## ១. ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ)

| | |
|---|---|
| ឈ្មោះមូលបត្រកម្មសិទ្ធិ | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| និមិត្តសញ្ញាមូលបត្រកម្មសិទ្ធិ | ធអក (ABC) |
| ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ | ភាគហ៊ុនធម្មតាមានសិទ្ធិបោះឆ្នោត |
| តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៤.០០០ រៀល |
| ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (IPO Price) | ១៦.២០០ រៀល |
| បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ | ៤៣៣.១៦៣.០១៩ ភាគហ៊ុន |
| មូលធនូបនីយកម្មទីផ្សារ (គិតជាលានរៀល) | ៧.៤០៧.០៨៨ |
| ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត | ផ្សារមូលបត្រកម្ពុជា កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ៖ ២៥ ឧសភា ២០២០ |

## ២. ព័ត៌មានអំពីមូលបត្របំណុល (ករណីចុះបញ្ជីលក់មូលបត្របំណុល)៖ មិនមាន

# ខ. ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| | មូលបត្រកម្មសិទ្ធិ | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | ២៣.៦០០ | ២២.៩៥០ | ១៨.៣៦០ | ១៧.៩០០ | ១៧.៦០០ | ១៧.៤៦០ | ១៧.៣០០ | ១៧.៣០០ |
| | មធ្យម | ១៩.៦២៦ | ១៨.៩៨៥ | ១៧.៥២២ | ១៧.៣១០ | ១៧.៣១៨ | ១៧.២៥៧ | ១៧.១៨៥ | ១៧.០៩៩ |
| | អប្បបរមា | ១៦.១៨០ | ១៧.៦០០ | ១៦.៥០០ | ១៧.០២០ | ១៧.២០០ | ១៧.១០០ | ១៦.៩០០ | ១៦.៩០០ |
| បរិមាណជួញដូរ | អតិបរមា | ៧៩៣.១៥៩ | ៣០៥.៥២៩ | ១៣៣.៥៥២ | ៣០.៨៧៣ | ១៤.៥៨៥ | ១៤.២១១ | ១៥.៣៥៤ | ១៧.០៨៩ |
| | មធ្យម | ២៦៦.២៤៧ | ៧៩.៣៨២ | ២៥.៧០៦ | ១៣.៩២១ | ៧.០៤៦ | ៧.១៩៨ | ៦.៤២៣ | ៥.៦៥៩ |
| | អប្បបរមា | ១៥.៨៨៨ | ១២.៨៥៣ | ២.៦៤៨ | ៣.៦៨៦ | ២.៥៤៣ | ១.៧៣២ | ១.៧៨០ | ១.៥៩២ |

## គ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ (ចាប់ពី ៣០% ឡើងទៅ)៖ មិនមាន

## ឃ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន (ចាប់ពី ៥% ដល់តិចជាង ៣០%)

| ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ | ខ្មែរ | ១១១.៤៩២.៧១៩ | ២៥,៧៣៩២% |
| ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី | ខ្មែរ | ១០៧.២០៤.៥៤៧ | ២៤,៧៤៩២% |
| Sumitomo Mitsui Banking Corporation | ជប៉ុន | ៧៨.២៥៩.៣១០ | ១៨,០៦៦៩% |
| COFIBRED | បារាំង | ៥២.៥៣០.២២៣ | ១២,១២៧១% |
| ORIX Corporation | ជប៉ុន | ៥២.៥៣០.២២៣ | ១២,១២៧១% |
| សរុប | | ៤០២.០១៧.០២២ | ៩២,៨០៩៦% |

## ង. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ

| ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ២០២០ | ២០១៩ | ២០១៨ |
|---|---|---|---|
| ចំណេញសុទ្ធ (លានរៀល) | ៥៧៦.៨៦៥ | ៤៨៩.៧២៤ | ៤៨២.៦២៤ |
| ភាគលាភជាសាច់ប្រាក់សរុប (លានរៀល) | - | ១៣៣.៣៩៥ | ៣៤.០៦០ |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប (លានរៀល) | - | - | ១៣៦.៧៦១ |
| ភាគលាភផ្សេងទៀត | - | - | - |
| អនុបាតនៃការបែងចែកភាគលាភ (%) | - | ២៦,៨៣% | ៣៤,៨៦% |
| ទិន្នផលភាគលាភ (%) | - | - | - |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | - | ៣១១ | ៤៣២ |

# ផ្នែកទី ៥

## របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

# I. សេចក្តីផ្តើម

ប្រសិទ្ធភាពនៃអភិបាលកិច្ចការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង ត្រូវបានធានាដោយគោលបំណងច្បាស់លាស់ប្រកបដោយឯករាជ្យភាព តាមរយៈការធ្វើសវនកម្មផ្ទៃក្នុង ផ្តល់នូវការពិគ្រោះយោបល់ ដ៏មានគុណតម្លៃ ក្នុងការកែលម្អប្រតិបត្តិការធនាគារ ។
ដើម្បីធានាបាននូវឯករាជ្យភាពក្នុងការអនុវត្តការងារសវនកម្ម ក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី ព្រមទាំងក្រុមហ៊ុនបុត្រសម្ព័ន្ធ គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង ត្រូវបានចាត់តាំង និងធ្វើទំនាក់ទំនង ព្រមទាំងរាយការណ៍ដោយផ្ទាល់ជូនគណៈកម្មាធិការសវនកម្ម ។

# II. វិសាលភាពនៃមុខងារសវនកម្មផ្ទៃក្នុង

វិសាលភាពនៃសកម្មភាពសវនកម្មផ្ទៃក្នុង រួមមានការងារស្នូលចំនួនបី ប្រភេទដែលប្រកបដោយវិធីសាស្ត្រអនុវត្តលក្ខណៈជាប្រព័ន្ធ និងមាននិយមន័យច្បាស់លាស់ក្នុងការត្រួតពិនិត្យ និងការវាយតម្លៃប្រព័ន្ធត្រួតពិនិត្យគ្រប់គ្រងផ្ទៃក្នុង ទស្សនវិស័យនៃការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិការធនាគារ មានដូចជាៈ

- **ត្រួតពិនិត្យការអនុវត្តគោលការណ៍:** គឺការធ្វើសវនកម្មលើការអនុវត្តគោលការណ៍ គោលការណ៍ប្រតិបត្តិ នីតិវិធី និងសេចក្តីណែនាំផ្សេងៗ តាមរយៈការធ្វើតេស្តប៉ាន់គំរូសវនកម្មដើម្បីផ្តល់នូវការធានាដ៏មានប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រតិបត្តិតាមបទប្បញ្ញត្តិ ឲ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ដែលជាមូលដ្ឋានគ្រឹះទប់ស្កាត់កាត់បន្ថយហានិភ័យ ។

- **សវនកម្មប្រព័ន្ធព័ត៌មាន:** គឺជាការធ្វើសវនកម្មលើទិន្នន័យ និងសុវត្ថិភាពប្រព័ន្ធព័ត៌មានវិទ្យា រួមមានការប្រើប្រាស់ការរក្សាការសម្ងាត់ និងភាពទូលំទូលាយនៃទិន្នន័យ ដើម្បីផ្តល់ការធានានូវភាពជឿទុកចិត្ត និងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ។

- **សវនកម្មអង្កេតប្រតិបត្តិការ:** គឺជាការត្រួតពិនិត្យលម្អិតឲ្យបានហ្មត់ចត់លើប៉ាន់គំរូសវនកម្ម ដែលមានសញ្ញាណនៃការក្លែងបន្លំទាំងខាងក្នុង និងខាងក្រៅ ដើម្បីផ្តល់ការធានានូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងរឹងមាំការពារការក្លែងបន្លំ ទំនាស់ផលប្រយោជន៍ និងការការពារធនធានទ្រព្យសកម្មរបស់ធនាគារ ។

# III. សេចក្តីសង្ខេបនៃការអនុវត្តកិច្ចការសវនកម្មផ្ទៃក្នុង ឆ្នាំ២០២០

ការប្រតិបត្តិសវនកម្មផ្ទៃក្នុង ត្រូវបានកំណត់ដោយផែនការសកម្មភាពដាក់ជូនគណៈកម្មាធិការសវនកម្ម ដើម្បីអនុម័តការអនុវត្តផែនការសវនកម្ម ទំនាក់ទំនងពិភាក្សាលទ្ធផលសវនកម្ម ការផ្តល់របាយការណ៍សវនកម្ម និងការតាមដានវិធានការកែតម្រូវរបស់ថ្នាក់គ្រប់គ្រង ។

ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០២០ បានរៀបចំឡើងដោយផ្អែកលើវិធីសាស្ត្រវាយតម្លៃហានិភ័យដ៏ទូលំទូលាយជាមូលដ្ឋានស្របតាមយុទ្ធសាស្ត្ររបស់ធនាគារបង្កើតបានជាគោលដៅនិងវិសាលភាពសវនកម្មច្បាស់លាស់ នៃគម្រោងកិច្ចសវនកម្មនីមួយៗ។ គណៈកម្មាធិការសវនកម្មបានអនុម័តផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ គួបផ្សំដោយថវិកាសមស្របដើម្បីគាំទ្រដល់សកម្មភាពសវនកម្ម រួមទាំងធនធានមនុស្ស និងការអភិវឌ្ឍចំណេះដឹងជំនាញ ។

ផែនការសកម្មភាពសវនកម្មផ្ទៃក្នុងឆ្នាំ២០២០ ត្រូវបានអនុម័តដោយគណៈកម្មាធិការសវនកម្ម រួមមានគម្រោងកិច្ចសវនកម្ម ត្រួតពិនិត្យការអនុវត្តគោលការណ៍ ចំនួន ៤២ សវនកម្មប្រព័ន្ធព័ត៌មានវិទ្យា ចំនួន ១៥ និង សវនកម្មអង្កេតប្រតិបត្តិការចំនួន ៣៤ ដែលត្រូវប្រតិបត្តិគ្រប់សវនដ្ឋានទាំងអស់ក្នុងធនាគារ រួមមាន ការិយាល័យកណ្តាល និង សាខា ដោយអនុវត្តតាមប្រធានបទសវនកម្ម ដូចជាសវនកម្មគ្រប់គ្រងហានិភ័យ សវនកម្មធនធានមនុស្ស សវនកម្មគ្រប់គ្រងការិយាល័យ សវនកម្មឥណទាន សវនកម្មសន្តិសុខព័ត៌មានវិទ្យា សវនកម្មហិរញ្ញវត្ថុ សវនកម្មធនាគារឌីជីថល និងបញ្ជរបេឡា និងសវនកម្មប្រឆាំងការសម្អាតប្រាក់ ។

បញ្ហាសំខាន់ៗត្រូវបានកំណត់ច្បាស់លាស់ក្នុងរបាយការណ៍សវនកម្មផ្ទៃក្នុង ដើម្បីផ្តល់យោបល់ជូនថ្នាក់គ្រប់គ្រងរៀបចំកែលម្អឲ្យបានសមស្រប និងទាន់ពេលវេលា ដូចជាការអភិវឌ្ឍគោលការណ៍ គោលការណ៍ប្រតិបត្តិ និងនីតិវិធី ព្រមទាំងការពង្រឹង និងការហ្វឹកហ្វឺនដល់ថ្នាក់គ្រប់គ្រង និងបុគ្គលិកដែលពាក់ពន្ធ័ ។

របាយការណ៍សវនកម្មផ្ទៃក្នុងសរុបប្រចាំខែត្រូវបានរាយការណ៍ជូនគណៈកម្មាធិការសវនកម្ម និងចម្លងជូនទៅថ្នាក់ដឹកនាំជាន់ខ្ពស់ ដែលខ្លឹមសារនៃរបាយការណ៍រួមមានផែនការសកម្មភាពក្នុងការពង្រឹងដោយថ្នាក់គ្រប់គ្រង ដើម្បីធ្វើការតាមដានការកែតម្រូវការរកឃើញ ។

# IV. សេចក្តីសន្និដ្ឋាន

ផែនការកិច្ចការសវនកម្មផ្ទៃក្នុងឆ្នាំ ២០២០ បានសម្រេចជោគជ័យ ដោយអនុវត្តយ៉ាងតឹងរឹងនូវមូលដ្ឋានហានិភ័យគ្រប់ប្រធានបទ និងសវនដ្ឋាន ដើម្បីផ្តល់នូវយោបល់ស្តីពីការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើការគ្រប់គ្រងហានិភ័យ ដំណើរការត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធី និងការគ្រប់គ្រងទៅតាមបទប្បញ្ញត្តិ ។ លើសពីនេះទៅទៀតមិនមានការរកឃើញទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុឡើយ ។

ជាការឆ្លើយតបនឹងអនុសាសន៍សវនកម្មថ្នាក់គ្រប់គ្រងបានយល់ស្របរៀបចំផែនការសកម្មភាពកែលម្អដើម្បីបង្កើនប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យប្រតិបត្តិការធនាគារពីមួយថ្ងៃទៅមួយថ្ងៃ ។

ផ្អែកលើសមិទ្ធិផលនៃការអនុវត្តកិច្ចការសវនកម្មផ្ទៃក្នុងឆ្នាំ២០២០ យើងសន្និដ្ឋានថាក្របខ័ណ្ឌអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងលើការត្រួតពិនិត្យបានរៀបចំជាប្រព័ន្ធប្រកបដោយប្រសិទ្ធភាពស្របតាមគោលការណ៍ផ្ទៃក្នុង នីតិវិធី និងបទប្បញ្ញត្តិនានា ។

បានអាន និងឯកភាព
ភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១



Mr. Ian S. Lydall
ប្រធានគណៈកម្មាធិការសវនកម្ម

ភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១



គីម សុធាវី
គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង

# ផ្នែកទី ៦

## របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ

របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ

# ផ្នែកទី ៧

## ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍

បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ត្រូវបង្ហាញពីព័ត៌មានប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធនៅក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយបញ្ជាក់ពីឈ្មោះ ទំនាក់ទំនងរវាងបុគ្គលចុះបញ្ជីលក់មូលបត្រ និងភាគីជាប់ពាក់ព័ន្ធ ទំហំនៃប្រតិបត្តិការ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងនោះ ដូចខាងក្រោម៖

## ក. ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយ ឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ

ធនាគារ អេស៊ីលីដា ភីអិលស៊ី (ABC) មានភាគហ៊ុនិកចំនួន ៥ ដែលកាន់កាប់ភាគហ៊ុនយ៉ាងតិច ៥% ឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ ក្នុងនោះរួមមាន៖ (១) អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ (២) ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី (៣) Sumitomo Mitsui Banking Corporation (៤) COFIBRED និង (៥) ORIX Corporation។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា មានប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារដូចខាងក្រោម៖

| បរិយាយ | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សមតុល្យជាមួយសម្ព័ន្ធញាតិ** | **៤១២.១៦២** | **១.៦៦៧.១៩៥** | **៤៨៧.៣៥៦** | **១.៩៨៥.៩៧៦** |
| Sumitomo Mitsui Banking Corporation | ៤១២.១៦២ | ១.៦៦៧.១៩៥ | ៤៨៧.៣៥៦ | ១.៩៨៥.៩៧៦ |
| **ចំណូលការប្រាក់** | **១៦.៩៨៩** | **៦៩.២៦៤** | **-** | **-** |
| Sumitomo Mitsui Banking Corporation | ១៦.៩៨៩ | ៦៩.២៦៤ | - | - |
| **គណនីត្រូវទូទាត់** | **៥០០** | **២.០២៣** | **១.៤៧៤** | **៦.០០៧** |
| ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី | ៥០០ | ២.០២៣ | ១.៤៧៤ | ៦.០០៧ |
| **ប្រាក់បញ្ញើ** | **១៣.១១៧.៥៩៦** | **៥៣.០៦០.៦៧៦** | **៤.៥០៦.២៣០** | **១៨.៣៦២.៨៨៨** |
| អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ | **១២.៧៩៤.៦១០** | **៥១.៧៥៤.១៩៧** | **៤.១២២.៦៧៦** | **១៦.៧៩៩.៨០៥** |
| គណនីចរន្ត | ១២.៧៩៤.៦១០ | ៥១.៧៥៤.១៩៧ | ៤.១២២.៦៧៦ | ១៦.៧៩៩.៨០៥ |
| ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី | **២៥០.២១២** | **១.០១២.១០៨** | **៣២៦.១៥២** | **១.៣២៩.០៧០** |
| គណនីបញ្ញើសំចៃ | ៩៩.៧១២ | ៤០៣.៣៣៥ | ២៤.៦៧៨ | ១០០.៥៦៣ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១៥០.៥០០ | ៦០៨.៧៧៣ | ៣០១.៤៧៤ | ១.២២៨.៥០៧ |
| Sumitomo Mitsui Banking Corporation | **៧២.៧៧៤** | **២៩៤.៣៧១** | **៥៧.៤០២** | **២៣៣.៩១៣** |
| គណនីចរន្ត | ៧២.៧៧៤ | ២៩៤.៣៧១ | ៥៧.៤០២ | ២៣៣.៩១៣ |
| **ចំណូលកម្រៃនិងជើងសា** | **២៨.០៦៣** | **១១៤.៤១៣** | **២៨.០៦៣** | **១១៤.៣៥៧** |
| អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ | ២៦.៤០០ | ១០៧.៦៣៣ | ២៦.៤០០ | ១០៧.៥៨០ |
| ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី | ១.៦៦៣ | ៦.៧៨០ | ១.៦៦៣ | ៦.៧៧៧ |
| **ចំណាយការប្រាក់** | **២០១.៦៧០** | **៨២២.២០៨** | **១៥.៥០១** | **៦៣.១៦៧** |
| អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ | ១៨៤.៤៩៨ | ៧៥២.១៩៨ | - | - |
| ក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី | ១៧.១៧២ | ៧០.០១០ | ១៥.៥០១ | ៦៣.១៦៧ |

## ខ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា មានប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់ដូចខាងក្រោម៖

| បរិយាយ | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទាននិងបុរេប្រទាន | ១១.៥៣៧.២២០ | ៤៦.៦៦៨.០៥៥ | ៥.០៩៥.០២២ | ២០.៧៦២.២១៥ |
| ចំណូលការប្រាក់ | ១.០៧៤.០៣១ | ៤.៣៧៨.៨២៤ | ១៣២.៤៧៩ | ៥៣៩.៨៥២ |
| ប្រាក់បញ្ញើ | ៣.០៩៤.២២១ | ១២.៥១៦.១២៤ | ២.១៥៧.១៣៧ | ៨.៧៩០.៣៣៣ |
| ចំណាយការប្រាក់ | ១៣៥.៧០៤ | ៥៥៣.២៦៥ | ១៣៣.៣០៤ | ៥៤៣.២១៤ |
| ការប្រាក់ត្រូវបង់ | ២២.៥៨៨ | ៩១.៣៦៩ | ១៦.៨២៨ | ៦៨.៥៧៤ |
| ចំណាយកម្រៃនិងជើងសា | ៦.៥១៨.២៤១ | ២៦.៥៧៤.៨៦៨ | ៦.៤១០.០៨៤ | ២៦.១២១.០៩២ |

## គ. ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា ពុំមានប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម។

## ឃ. ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា មានប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅដូចខាងក្រោម៖

| បរិយាយ | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទាននិងបុរេប្រទាន | ១.៤៥៨.៩៤៩ | ៥.៩០១.៤៤៩ | ១៧១.៨៩៥ | ៧០០.៤៧២ |
| ប្រាក់បញ្ញើ | ១.៤១៩.៦៣១ | ៥.៧៤២.៤០៧ | - | - |
| ការប្រាក់ត្រូវបង់ | ៥.៧៨៧ | ២៣.៤០៨ | - | - |

## ង. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលិកដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រក្រុមហ៊ុនសម្ព័ន្ធឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលចុះបញ្ជីលក់មូលបត្រដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលបានធ្វើឡើងដោយបុគ្គលចុះបញ្ជីលក់មូលបត្រ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា មានប្រតិបត្តិការសំខាន់ៗជាមួយក្រុមហ៊ុនបុត្រសម្ព័ន្ធដូចខាងក្រោម៖

| បរិយាយ | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ឥណទាននិងបុរេប្រទាន** | **៦.៤៨០.៥៩០** | **២៦.០៥២.១៨៧** | **៤.៩៧៥.២០១** | **២០.២៧៣.៩៤៤** |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | ៦.៤៨០.៥៩០ | ២៦.០៥២.១៨៧ | ៤.៩៧៥.២០១ | ២០.២៧៣.៩៤៤ |
| **សមតុល្យជាមួយសម្ព័ន្ធញាតិ** | **៥០២.៦៧៨** | **២.០៣៣.៣៣៣** | - | - |
| ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត | ៥០២.៦៧៨ | ២.០៣៣.៣៣៣ | - | - |
| **ចំណូលការប្រាក់** | **៣៩៩.៥២៤** | **១.៦២៨.៤៥៩** | **២៥៣.១៤៥** | **១.០៣១.៥៦៦** |
| ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត | ៦.៧២០ | ២៧.៣៩៧ | ២៣.៩៧៨ | ៩៧.៧១០ |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | ៣៩២.៨០៤ | ១.៦០១.៤៦២ | ២២៩.១៦៧ | ៩៣៣.៨៥៦ |
| **គណនីត្រូវទទួល** | **១៦៩.៥៤៤** | **៦៨៥.៨០៦** | **១៦៣.២០៦** | **៦៦៥.០៦៤** |
| ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត | ២.៦៧៨ | ១០.៨៣៣ | ៦១៧ | ២.៥១៤ |
| ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា | ១៦៦.៨៦៦ | ៦៧៤.៩៧៣ | ១៦២.១៩៣ | ៦៦០.៩៣៦ |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | - | - | ៣៩៦ | ១.៦១៤ |
| **គណនីត្រូវទូទាត់** | **២.១៩៧** | **៨.៨៨៦** | **៣៨.៥៦៥** | **១៥៧.១៥៣** |
| ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី | ២.១៩៧ | ៨.៨៨៦ | ១៦.៥៩៥ | ៦៧.៦២៥ |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | - | - | ២១.៩៧០ | ៨៩.៥២៨ |
| **ប្រាក់បញ្ញើ** | **៣.៥១៧.៣២១** | **១៤.២២៧.៥៦៣** | **៨.៨១៨.២២១** | **៣៥.៩៣៤.២៥១** |
| ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត | **១.៥៩៧.៩២១** | **៦.៤៦៣.៥៩០** | **៥.៣០៣.៦៥១** | **២១.៦១២.៣៧៨** |
| គណនីចរន្ត | ១.៥៩៧.៩២១ | ៦.៤៦៣.៥៩០ | ៥.៣០៣.៦៥១ | ២១.៦១២.៣៧៨ |
| ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី | **១.៨៨០.០៩៧** | **៧.៦០៤.៩៩២** | **១.៨១៩.៥០៣** | **៧.៤១៤.៤៧៥** |
| គណនីបញ្ញើសំចៃ | ១៨០.១៣៥ | ៧២៨.៦៤៦ | ១៤២.៩០៨ | ៥៨២.៣៥០ |
| បញ្ញើមានកាលកំណត់ | ១.៦៩៩.៩៦២ | ៦.៨៧៦.៣៤៦ | ១.៦៧៦.៥៩៥ | ៦.៨៣២.១២៥ |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | **៣៩.៣០៣** | **១៥៨.៩៨១** | **១.៦៨០.៤៥៥** | **៦.៨៤៧.៨៥៤** |
| គណនីចរន្ត | ៣៩.៣០៣ | ១៥៨.៩៨១ | ៤៧៣.៦០៥ | ១.៩២៩.៩៤០ |
| បញ្ញើមានកាលកំណត់ | - | - | ១.២០៦.៨៥០ | ៤.៩១៧.៩១៤ |
| ក្រុមហ៊ុន អេស៊ីលីដា ប្រូភើធី អិលធីឌី | - | - | ១៤.៦១២ | ៥៩.៥៤៤ |
| គណនីបញ្ញើសំចៃ | - | - | ១៤.៦១២ | ៥៩.៥៤៤ |
| **ចំណូលកម្រៃនិងជើងសា** | **១២.២៨៨** | **៥០.០៩៩** | **៧.៥៧០** | **៣០.៨៤៨** |
| ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត | **១៤** | **៥៧** | **១៤** | **៥៧** |
| កម្រៃសេវាធនាគារ | ១៤ | ៥៧ | ១៤ | ៥៧ |
| ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី | **៥០១** | **២.០៤៣** | **៤៧០** | **១.៩១៥** |
| កម្រៃសេវាធនាគារ | ៥០១ | ២.០៤៣ | ៤៧០ | ១.៩១៥ |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | **១១.៧៧៣** | **៤៧.៩៩៩** | **៧.០៧៦** | **២៨.៨៣៥** |
| កម្រៃសេវាធនាគារ | ១១.៧៧៣ | ៤៧.៩៩៩ | ៧.០៧៦ | ២៨.៨៣៥ |
| ក្រុមហ៊ុន អេស៊ីលីដា ប្រូភើធី អិលធីឌី | - | - | ១០ | ៤១ |
| កម្រៃសេវាធនាគារ | - | - | ១០ | ៤១ |
| **ចំណាយការប្រាក់** | **៩៥.៣៩៣** | **៣៨៨.៩១៧** | **១០៤.៥៦៤** | **៤២៦.០៩៨** |
| ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី | ៩១.១១៤ | ៣៧១.៤៧២ | ៨៦.៥២៥ | ៣៥២.៥៨៩ |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | ៤.២៧៩ | ១៧.៤៤៥ | ១៨.០៣៩ | ៧៣.៥០៩ |
| **ចំណាយកម្រៃនិងជើងសា** | **២.២០០.៧៩៦** | **៨.៩៧២.៦៤៥** | **១.៤១១.០០៧** | **៥.៧៤៩.៨៥៤** |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | ២.២០០.៧៩៦ | ៨.៩៧២.៦៤៥ | ១.៤១១.០០៧ | ៥.៧៤៩.៨៥៤ |
| **កិច្ចសន្យាផ្សេងៗ** | **៣៧០.៤៤៨** | **១.៥១០.៣១៦** | **៤៤៨.៣៤៣** | **១.៨២៦.៩៩៨** |
| វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា | ៣៧០.៤៤៨ | ១.៥១០.៣១៦ | ៤៤៨.៣៤៣ | ១.៨២៦.៩៩៨ |

### ច. ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា ពុំមានប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាល។

### ឆ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលបានកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា ពុំមានប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពីបុគ្គលចុះបញ្ជីលក់មូលបត្រ។

### ជ. ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពីបុគ្គលចុះបញ្ជីលក់មូលបត្រទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា មានអភិបាល ២ (ពីរ) រូបដែលជាអភិបាលប្រតិបត្តិទទួលបានផលប្រយោជន៍ជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុពីធនាគារ អេស៊ីលីដា និងអភិបាលដទៃទៀតជាអភិបាលមិនប្រតិបត្តិ និងអភិបាលឯករាជ្យ ដែលទទួលបានផលប្រយោជន៍ពីធនាគារ អេស៊ីលីដា មានដូចខាងក្រោម៖

| បរិយាយ | ២០២០ | | ២០១៩ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទាននិងបុរេប្រទាន | ៧៤៩.៨២៤ | ៣.០៣៣.០៣៨ | ៧១០.៥១៦ | ២.៨៩៥.៣៥៣ |
| ប្រាក់បញ្ញើ | ២.៥៨២.៨៥១ | ១០.៤៤៧.៦៣២ | ២.១២២.៤៦១ | ៨.៦៤៩.០២៩ |
| ការប្រាក់ត្រូវបង់ | ១៨.៧៨៧ | ៧៥.៩៩៣ | ១៦.៦៦៤ | ៦៧.៩០៦ |
| ចំណាយកម្រៃនិងជើងសា | ៥២៧.៧០៤ | ២.១៥១.៤៤៩ | ៥៧៧.២៨៤ | ២.៣៥២.៨៣២ |

# ផ្នែកទី ៨

## ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះផ្តោតសំខាន់លើលទ្ធផលប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដែលត្រូវបានធ្វើសវនកម្មរួចរាល់ ដោយសវនករឯករាជ្យ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា(ស.រ.ហ.អ.ក)។ មានតែសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារប៉ុណ្ណោះត្រូវបានយកមកធ្វើការពិភាក្សា និងការវិភាគ។

# ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

## ១. ការវិភាគចំណូល

ធនាគារ អេស៊ីលីដា ភីអិលស៊ី មានប្រភពចំណូលធំៗចំនួនបីគឺ ចំណូលការប្រាក់ ចំណូលកម្រៃនិងជើងសា និងចំណូលផ្សេងៗ។

- ចំណូលការប្រាក់៖ រួមមានចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគហិរញ្ញវត្ថុ។
- ចំណូលកម្រៃនិងជើងសា៖ រួមមានកម្រៃជើងសា កម្រៃជើងសាបានពីភ្នាក់ងារធានារ៉ាប់រង កម្រៃពីម៉ាស៊ីនអេធីអឹម កម្រៃពីការសងឥណទានមុនកាលកំណត់ កម្រៃពីសេវាប្រាក់បញ្ញើ កម្រៃពីសេវាធានា និងកម្រៃពីការបណ្តុះបណ្តាល។
- ចំណូលផ្សេងៗ៖ រួមមានចំណេញពីការប្តូររូបិយប័ណ្ណ ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ ភាគលាភលើការវិនិយោគហិរញ្ញវត្ថុ និងចំណូលផ្សេងៗ។

## ២. ការវិភាគចំណូលតាមផ្នែក

| ប្រភពចំណូល (គិតជាលានរៀល) | ២០២០ | | ២០១៩ | | ២០១៨ | |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ២.១០០.០៤០ | ៨៨,៩៣% | ១.៩៥៩.៣១៨ | ៨៧,៩០% | ១.៨៣៤.៦១២ | ៨៨,៨២% |
| ចំណូលកម្រៃនិងជើងសា | ១៨៦.៦២៥ | ៧,៩០% | ១៩៧.៤៧៣ | ៨,៨៦% | ១៧៣.២៩០ | ៨,៣៩% |
| ចំណូលផ្សេងៗ | ៧៤.៨១៨ | ៣,១៧% | ៧២.៣២៧ | ៣,២៤% | ៥៧.៦៩៩ | ២,៧៩% |
| **ចំណូលសរុប** | ២.៣៦១.៤៨៣ | ១០០% | ២.២២៩.១១៨ | ១០០% | ២.០៦៥.៦០១ | ១០០% |

ចំណូលសរុបចំនួន ២,៣៦ទ្រីលានរៀល ក្នុងឆ្នាំ២០២០ ភាគច្រើនបានមកពីចំណូលការប្រាក់ដែលមានចំណែក ៨៨,៩៣% នៃចំណូលសរុប និង ចំណូលសរុបកើនឡើង ១៣២,៣៧ប៊ីលានរៀល ឬ ៥,៩៤% បើប្រៀបធៀបទៅនឹងចំណូលសរុបក្នុងឆ្នាំ២០១៩។

## ៣. ការវិភាគគម្លាតចំណេញដុល

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី បានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីគម្លាតចំណេញដុលទេ។ ចំណូលការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់សរុប ដែលនឹងត្រូវយកមកបង្ហាញនៅក្នុងការវិភាគចំណេញ/(ខាត) មុនបង់ពន្ធដូចខាងក្រោម។

## ៤. ការវិភាគចំណេញ/(ខាត)មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ២០២០ | ២០១៩ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ២.១០០.០៤០ | ១.៩៥៩.៣១៨ | ១៤០.៧២២ | ៧,១៨% |
| ចំណាយការប្រាក់ | (៦១៤.៧១៩) | (៦៣៥.៦៤៨) | ២០.៩២៩ | -៣,២៩% |
| **ចំណូលការប្រាក់សុទ្ធ** | **១.៤៨៥.៣២១** | **១.៣២៣.៦៧០** | **១៦១.៦៥១** | **១២,២១%** |
| ចំណូលកម្រៃនិងជើងសា | ១៨៦.៦២៥ | ១៩៧.៤៧៣ | (១០.៨៤៨) | -៥,៤៩% |
| ចំណាយកម្រៃនិងជើងសា | (៧.១០៣) | (៤.០៣៩) | (៣.០៦៤) | ៧៥,៨៦% |
| **ចំណូលកម្រៃនិងជើងសាសុទ្ធ** | **១៧៩.៥២៣** | **១៩៣.៤៣៣** | **(១៣.៩១០)** | **-៧,១៩%** |
| សំវិធានធនសម្រាប់ការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាននិងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងគណនីត្រូវទទួលផ្សេងៗ | (៨៤.៧៧៧) | (៩៤.៨៦២) | ១០.០៨៥ | -១០,៦៣% |
| សំវិធានធនសម្រាប់ការខាតបង់ឱនភាពនៃតម្លៃកិច្ចសន្យាក្រៅតារាងតុល្យការ | ២២១ | ៣៥៧ | (១៣៦) | ៣៨,១០% |
| **ឱនភាពនៃតម្លៃខាតបង់សុទ្ធ** | **(៨៤.៥៥៦)** | **(៩៤.៥០៦)** | **៩.៩៥០** | **-១០,៥៣%** |
| **ចំណូលសុទ្ធបន្ទាប់ពីសំវិធានធនសម្រាប់ឱនភាពនៃតម្លៃសុទ្ធ** | **១.៥៨០.២៨៧** | **១.៤២២.៥៩៨** | **១៥៧.៦៨៩** | **១១,០៨%** |
| ចំណូលផ្សេងៗ | ៧៤.៨១៨ | ៧២.៣២៧ | ២.៤៩១ | ៣,៤៤% |
| ចំណាយទូទៅនិងរដ្ឋបាល | (៩២១.១០១) | (៨៧២.៨៥១) | (៤៨.២៥០) | ៥,៥៣% |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **៧៣៤.០០៥** | **៦២២.០៧៤** | **១១១.៩៣១** | **១៧,៩៩%** |

នៅឆ្នាំ២០២០ ប្រាក់ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញបានកើនឡើង ១១១,៩៣ប៊ីលានរៀល ឬ ១៧,៩៩% បើប្រៀបធៀបនឹងឆ្នាំ២០១៩។ ចំណូលការប្រាក់បានកើនឡើង ៧,១៨% ខណៈពេលដែលចំណាយការប្រាក់បានថយចុះ ៣,២៩% ដែលនាំឲ្យមានការកើនឡើងនូវចំណូលការប្រាក់សុទ្ធ ១២,២១%។

## ៥. ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ២០២០ | ២០១៩ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | ៧៣៤.០០៥ | ៦២២.០៧៤ | ១១១.៩៣១ | ១៧,៩៩% |
| ចំណាយពន្ធលើប្រាក់ចំណេញ | (១៥៧.១៣៩) | (១៣២.៣៥០) | (២៤.៧៨៩) | ១៨,៧៣% |
| **ប្រាក់ចំណេញក្នុងឆ្នាំ** | ៥៧៦.៨៦៥ | ៤៨៩.៧២៤ | ៨៧.១៤១ | ១៧,៧៩% |

ប្រាក់ចំណេញសម្រាប់ឆ្នាំ២០២០នេះ ខ្ពស់ជាងឆ្នាំ២០១៩ ចំនួន ៨៧,១៤ប៊ីលានរៀល ឬ ១៧,៧៩%។ ការកើនឡើងនេះ ភាគច្រើនបណ្តាលមកពីការកើនឡើងនូវចំណូលការប្រាក់សុទ្ធចំនួន ១២,២១% ស្មើនឹង ១៦១,៦៥ប៊ីលានរៀល ធៀបនឹងឆ្នាំ២០១៩។

## ៦. ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតសរុប (លានរៀល) | ២០២០ | ២០១៩ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ** | ៥៧៦.៨៦៥ | ៤៨៩.៧២៤ | ៨៧.១៤១ | ១៧,៧៩% |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | |
| **ធាតុដែលនឹងមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញទៅចំណេញឬខាត៖** | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | ៦៩១ | ១៤១ | ៥៥០ | ៣៩០,០៧% |
| **ធាតុដែលត្រូវឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅការិយបរិច្ឆេទបន្ទាប់ទៅចំណេញ ឬខាត៖** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | (៨.១៦០) | ៧.៣៣០ | (១៥.៤៩០) | -២១១,៣២% |
| **លទ្ធផលលម្អិតផ្សេងៗក្នុងឆ្នាំសរុប** | ៥៦៩.៣៩៦ | ៤៩៧.១៩៦ | ៧២.២០០ | ១៤,៥២% |

## ៧. ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ មានឥទ្ធិពលគួរឲ្យកត់សម្គាល់លើស្ទើរតែគ្រប់វិស័យទាំងអស់ រួមទាំងធនាគារ និងហិរញ្ញវត្ថុផងដែរ។ ឧស្សាហកម្មទេសចរណ៍រួមទាំងសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងរបស់របរទាក់ទងនឹងម្ហូបអាហារបានរងផលប៉ះពាល់យ៉ាងខ្លាំង។ ទោះបីជាគ្រប់សហគ្រាសទទួលរងនូវផលប៉ះពាល់ក៏ដោយ ប៉ុន្តែធនាគារ អេស៊ីលីដា បានបង្កើតឲ្យមានភាពវិជ្ជមានដោយបង្កើតឲ្យមានកម្មវិធីសំណើសុំឥណទានដែលមានភាពសាមញ្ញ និងងាយស្រួលប្រើប្រាស់ដោយមធ្យោបាយឌីជីថលតាមរយៈកម្មវិធី "អេស៊ីលីដាម៉ូបាល" ហើយវាក៏អាចប្រើជាមួយគណនីប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) ផងដែរ រួមជាមួយអត្រាការប្រាក់ដែលមានភាពបត់បែន។

# ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

## ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ធនាគារ អេស៊ីលីដា ទទួលបានជោគជ័យនៅលើទីផ្សារដែលនាំមកនូវផលចំណេញអាស្រ័យដោយកត្តាពីរគឺ៖

- កំណើនសំពៀតឥណទាន ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារលើផលិតផលឥណទានរបស់ធនាគារ ជាពិសេសវិស័យ SME។
- កំណើនប្រាក់បញ្ញើ-សន្សំ របស់ធនាគារ រួមជាមួយផលិតផល និងសេវាកម្មផ្សេងទៀត។

កត្តាទាំងពីរនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធឌីជីថលរបស់ធនាគារ ដែលផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងទាន់សម័យ។

ការបង្កើនភាពងាយស្រួលដល់អតិថិជន និងពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ីនធើណែត គឺជាចំណុចដែលធនាគារ អេស៊ីលីដា ផ្តោតការយកចិត្តទុកដាក់បំផុត។ ដើម្បីសម្រេចនូវវឌ្ឍនភាពគោលដៅដ៏រឹងមាំទាំងនេះ ធនាគារនឹងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើបចុងក្រោយ ពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងពង្រីក និងកែលម្អដំណើរការអាជីវកម្ម។ ជាយុទ្ធសាស្រ្ត ធនាគារកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដែលអាចឲ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាចភ្ជាប់ប្រព័ន្ធនេះដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជនដ៏ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដៃគូអាជីវកម្មរបស់យើងផងដែរ។ យើងខ្ញុំទទួលស្គាល់ថាអតិថិជន និងដៃគូអាជីវកម្មទាំងអស់គឺជាបណ្តាញតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ពង្រីកសេវាកម្មរបស់ធនាគារ និងរីកចម្រើនជាមួយគ្នា។

អេស៊ីលីដាម៉ូបាល បានកែលម្អយ៉ាងទូលំទូលាយ និងផ្លាស់ប្តូររូបរាងថ្មី កាន់តែទំនើប ងាយស្រួល និងមានសុវត្ថិភាពខ្ពស់ ជាមួយនឹងមុខងារពិសេសៗជាច្រើន។ ឥឡូវនេះអតិថិជនទាំងអស់អាចប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) តាមរយៈ អេស៊ីលីដាម៉ូបាល បានភ្លាមៗ ថែមទាំងទទួលបានការប្រាក់ខ្ពស់ទៀតផង។ លោកអ្នកក៏អាចដាក់ប្រាក់បញ្ញើមានកាលកំណត់ ដោយខ្លួនឯងបានយ៉ាងងាយស្រួល ជាមួយម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ផងដែរ។

ធនាគារក៏បាន និងកំពុងបន្តវិនិយោគក្នុងការពង្រីកទីតាំងស្វ័យសេវាធនាគារ ដោយធ្វើការដំឡើងបន្ថែមនូវម៉ាស៊ីនអេធីអឹម ម៉ាស៊ីនដក-ដាក់ប្រាក់ ម៉ាស៊ីនឆូតកាត និងការពង្រីកបណ្តាញទូទាត់តាម QR របស់ខ្លួន។

ដើម្បីគាំទ្រដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (ក្នុងអំឡុងពេលនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩) ឲ្យមានសន្ទនីយភាពបន្ថែមទៀតដើម្បីឆ្លើយតបទៅនឹងតម្រូវការទុនរបស់ខ្លួន ធនាគារជាតិ នៃ កម្ពុជាបានបន្ធូរបន្ថយអនុបាតមួយចំនួនដូចជា៖ សាធនភាព ទ្រនាប់ដើមទុន ប្រាក់បម្រុងកាតព្វកិច្ច។ល។ ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកាត់បន្ថយពន្ធកាត់ទុកលើការប្រាក់កម្ចី ក៏ដូចជាបង្កើតសន្ទនីយភាពបន្ថែមទៀតនៅលើទីផ្សារដែលមានថ្លៃដើមទាប។ កត្តាទាំងនេះបានផ្តល់ឱកាសសម្រាប់ការប្រកួតប្រជែងថ្លៃដែលអាចប៉ះពាល់ដល់ចំណូលរបស់ធនាគារក្នុងរយៈពេលខ្លី ប៉ុន្តែវានឹងជួយឲ្យមានភាពរឹងមាំសម្រាប់រយៈពេលវែង។

## ២. ការវិភាគការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រតិបត្តិការក្នុងវិស័យសេវាកម្ម ដែលការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនអាចអនុវត្តបានចំពោះធនាគារឡើយ។

## ៣. ការវិភាគលើពន្ធ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃប្រទេសនីមួយៗ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធមានកាតព្វកិច្ចបង់ពន្ធតាមការកំណត់របស់អាជ្ញាធរពន្ធដារនីមួយៗ។

ការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារមិនត្រឹមតែជាកាតព្វកិច្ច និងការទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ “មាស” ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ ២០២០ ដល់ ២០២១ ប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមចំណែកក្នុងសង្គម និងកំណើនសេដ្ឋកិច្ចផងដែរ។

## ៤. ការវិភាគធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

ធនាគារមិនមានធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលខុសពីធម្មតាជាសារវន្តនោះទេ។ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌសេដ្ឋកិច្ចដែលបានរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ អាចជះឥទ្ធិពលដល់សមត្ថភាពសងត្រលប់មកវិញរបស់អតិថិជន ដែលគុណភាពឥណទានរបស់ធនាគារអាចរងផលប៉ះពាល់បន្តិចបន្តួច។

# គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបញ្ចុះអត្រាការប្រាក់ពី ០,៤% រហូតដល់ ១% ក្នុង ១ឆ្នាំ បន្ថែមទៀតលើការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ និងដោយកាន់តែមានភាពងាយស្រួល អតិថិជនទាំងអស់អាចដាក់សំណើសុំឥណទានតាមរយៈ **អេស៊ីលីដាម៉ូបាល**។ ជាលទ្ធផល សមតុល្យឥណទានដុលសរុបនៅដំណាច់ឆ្នាំ២០២០ មានការកើនឡើងចំនួន ២,៤២ ទ្រីលានរៀល ស្មើនឹង ១៥,៣១% ធៀបនឹងដំណាច់ឆ្នាំ២០១៩។

# ឃ. ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានរក្សានូវស្ថិរភាព ដោយមានការប្រែប្រួលក្នុងចន្លោះពី៤.០៥០ រៀល ទៅ ៤.១១០ រៀលក្នុងមួយដុល្លារអាមេរិក ក្នុងអំឡុងពេលរងផលប៉ះពាល់នៃជំងឺ កូវីដ-១៩ ក្នុងឆ្នាំ ២០២០។ នៅចុងឆ្នាំ ២០២០ តម្លៃប្រាក់រៀលរក្សាបាននូវស្ថិរភាពក្នុងរង្វង់ ៤.០៦៥ រៀលក្នុងមួយដុល្លារអាមេរិក និងរំពឹងថាវាអាចបន្តរក្សានូវស្ថិរភាពនេះនៅក្នុងឆ្នាំ ២០២១។ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានអនុវត្តយ៉ាងម៉ឺងម៉ាត់តាមបទប្បញ្ញត្តិ និងគោលនយោបាយផ្ទៃក្នុងធនាគារ ទាក់ទងទៅនឹងស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ។ ហេតុដូចនេះ ផលប៉ះពាល់មកលើអាជីវកម្មធនាគារដែលបណ្តាលមកពីការឡើងចុះនៃអត្រាប្តូរប្រាក់ គឺមានតិចតួចប៉ុណ្ណោះ។ ផលប៉ះពាល់នេះ ត្រូវបានវាស់វែង តាមដាន និងគ្រប់គ្រងជាប្រចាំថ្ងៃ ដើម្បីចាត់វិធានការដោះស្រាយឲ្យបានទាន់ពេលវេលា ក្នុងករណីចាំបាច់។

អត្រាការប្រាក់ជាមធ្យមនៃប្រាក់បញ្ញើ-សន្សំរបស់ធនាគារក្នុងឆ្នាំ២០២០ បានរក្សាតម្លៃថេរ បើធៀបនឹងឆ្នាំមុន (៤,០៣% នៅចុងឆ្នាំ២០១៩ និង ៤,០៦% នៅចុងឆ្នាំ២០២០)។ អត្រាការប្រាក់ជាមធ្យមនៃឥណទានរបស់ធនាគារក្នុងឆ្នាំ២០២០ បានថយចុះបន្តិច (០,៥%) បើធៀបនឹងឆ្នាំមុន (ពី ១១,៩៣% នៅចុងឆ្នាំ២០១៩ មកត្រឹម ១១,៤៣% នៅចុងឆ្នាំ២០២០)។ បម្រែបម្រួលនេះ ស្ថិតនៅក្នុងរង្វង់នៃការរំពឹងទុកជាមុននៃអាជីវកម្មរបស់ធនាគារ ដោយសារការប្រកួតប្រជែងនៅក្នុងទីផ្សារក្នុងស្រុកនាពេលបច្ចុប្បន្ន។ ជាសង្ខេបផលប៉ះពាល់ពីបម្រែបម្រួលអត្រាការប្រាក់នេះ គឺមានកម្រិតតិចតួច និងស្ថិតនៅក្នុងរង្វង់អាចគ្រប់គ្រងបាន ដោយហេតុថាធនាគារធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួនផ្អែកលើអត្រាការប្រាក់ថេរ (ទាំងប្រាក់បញ្ញើ និងឥណទាន) ដែលមិនមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងចលនាអត្រាការប្រាក់នៅក្នុងទីផ្សារហិរញ្ញវត្ថុអន្តរជាតិ។ ក្រៅពីនេះ ហានិភ័យអត្រាការប្រាក់ត្រូវបានវាស់វែង តាមដាន និងចាត់ចែងជាប្រចាំខែ ដើម្បីចាត់វិធានការដោះស្រាយបានទាន់ពេលវេលា និងជៀសវាងបាននូវផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធផលអាជីវកម្មរបស់ធនាគារ។

ធនាគារមិនបានធ្វើប្រតិបត្តិការជួញដូរនានាដែលមានទម្រង់ជា Commodity នោះទេ។

# ង. ផលប៉ះពាល់នៃអតិផរណា

អត្រាអតិផរណាសម្រាប់ឆ្នាំ ២០២០ គឺមានកម្រិតទាប (ជាមធ្យម ២,៩%) ទោះបីស្ថិតក្នុងអំឡុងពេលនៃមេរោគរាតត្បាត កូវីដ-១៩ ក៏ដោយ។ អតិផរណាសម្រាប់ឆ្នាំ ២០២១ ត្រូវបានព្យាករណ៍ថានឹងស្ថិតក្នុងកម្រិតស្ថិរភាពដដែល។ ដូចនេះ ផលប៉ះពាល់ពីអតិផរណាមកលើអាជីវកម្មរបស់ធនាគារ គឺមានតិចតួចបំផុត។

# ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

## គោលនយោបាយសេដ្ឋកិច្ច៖

កំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២០ ត្រូវបានប៉ាន់ស្មានថាអាចធ្លាក់ចុះជាងការរំពឹងទុកកាលពីដើមឆ្នាំ ដែលថាអត្រាកំណើនអាចមានកម្រិត -៣,១%។ ការធ្លាក់ចុះជាងការរំពឹងទុកនេះ ជាចម្បងដោយសារវិស័យទេសចរណ៍មិនមានភាពប្រសើរឡើង ដោយបន្តធ្លាក់ចុះខ្លាំងនៅក្នុងឆមាសទី២ ស្របពេលដែលការនាំចេញក្នុងវិស័យកាត់ដេរ ដែលរួមចំណែករហូតដល់ ៧០%នៃការនាំចេញសរុប បន្តមាននិន្នាការធ្លាក់ចុះ។ អត្រាអតិផរណាសម្រាប់ឆ្នាំ២០២០ មានកម្រិតជាមធ្យម ២,៩% ខ្ពស់ជាងឆ្នាំមុនបន្តិច (១,៩%) និងអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបន្តមានស្ថិរភាព ដោយមានកម្រិតជាមធ្យមក្នុងរង្វង់ ៤.០៩០ រៀលក្នុង ១ដុល្លារអាមេរិក ខ្ពស់ជាងឆ្នាំមុន (៤.០៦១ រៀល)។

ក្នុងបរិការណ៍ដែលថ្នាំបង្ការមានប្រសិទ្ធភាពអាចទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងឆមាសដំបូងនៃឆ្នាំ២០២១ ធនាគារជាតិ នៃ កម្ពុជា បានព្យាករថា សេដ្ឋកិច្ចកម្ពុជាអាចនឹងងើបឡើងវិញក្នុងរង្វង់ ៣,៥% ហើយអត្រាអតិផរណារំពឹងថាមានកម្រិតគ្រប់គ្រងបានក្រោម ៣% ជាមួយនឹងស្ថិរភាពអត្រាប្តូរប្រាក់ និងការរក្សាបានកម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិ។ ចំណែកឯស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាបានព្យាករថា អត្រាកំណើនសេដ្ឋកិច្ចកម្ពុជាអាចសម្រេចបានពី ៤% ទៅ ៦,៨% អាស្រ័យលើប្រសិទ្ធភាពនៃថ្នាំបង្ការ ល្បឿននៃការងើបឡើងវិញនៃកំណើនក្នុងប្រទេសជាដៃគូសេដ្ឋកិច្ច និងការពង្រឹងមូលដ្ឋានសេដ្ឋកិច្ចក្នុងស្រុក។

ស្ថិតក្នុងបរិការណ៍នេះ ការបន្តពង្រឹងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកថែមទៀតនឹងជួយទ្រទ្រង់ និងកាត់បន្ថយការប៉ះពាល់លើកំណើនសេដ្ឋកិច្ចកម្ពុជា ដោយសារការធ្លាក់ចុះវិស័យខាងក្រៅ។ ដូច្នេះ ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ការជំរុញនវានុវត្តន៍ និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗលើគ្រប់វិស័យ មានសារសំខាន់ណាស់ ក្នុងការពង្រឹងមូលដ្ឋានកំណើនសកម្មភាពក្នុងស្រុក។ ជាមួយគ្នានេះ វិស័យកសិកម្មនឹងបន្តជាវិស័យដ៏សំខាន់ និងមានសក្តានុពលខ្ពស់ ដែលអាចជួយស្រូបឥទ្ធិពលផ្នែកខ្លះនៃវិបត្តិ ដូចជាភាពអត់ការងារធ្វើ ឬជួយគាំទ្រជីវភាពប្រជាជនក្រីក្រ។ ម្យ៉ាងទៀត ការពន្លឿនការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច និងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្ម នឹងជួយឲ្យសេដ្ឋកិច្ចកម្ពុជាងើបឡើងកាន់តែឆាប់រហ័សពីវិបត្តិនាបច្ចុប្បន្ននេះ។ លើសពីនេះ ការចាប់ផ្តើមទទួលបានចំណូលពីការផលិតប្រេងនៅកម្ពុជា នឹងផ្តល់ជាប្រភពថវិកាមួយទៀត សម្រាប់ការអភិវឌ្ឍវិស័យអាទិភាពនានានៅពេលខាងមុខ។ (១)(២)

## គោលនយោបាយសារពើពន្ធ៖

តាមរយៈអគ្គនាយកដ្ឋានពន្ធដារឲ្យដឹងថា សរុបរយៈពេល ១២ខែ ឆ្នាំ២០២០ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ) មានចំនួន ១១.៧០០,៥២ ប៊ីលានរៀល (ប្រមាណជា ២.៨៨៩,០២ លានដុល្លារអាមេរិក) ស្មើនឹង ១០១,៣៦% នៃផែនការប្រចាំឆ្នាំ ធៀបនឹងចំណូលពន្ធ-អាករប្រមូលបានក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩ ឃើញថាកើនឡើងចំនួន ៤២៣,២០ ប៊ីលានរៀល (ប្រមាណជា ១០៤,៤៩ លានដុល្លារអាមេរិក) ស្មើនឹង ៣,៧៣% ទោះក្នុងស្ថានភាពសេដ្ឋកិច្ចសកល ក៏ដូចជាសេដ្ឋកិច្ចកម្ពុជា មិនទាន់មានភាពប្រាកដប្រជា ជាពិសេសមានការទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីការរីករាលដាលនៃជំងឺកូវីដ-១៩។ ចំពោះលទ្ធផលក្នុងខែធ្នូ ឆ្នាំ២០២០ បានបង្ហាញថាចំណូលពន្ធ-អាករគ្រប់ប្រភេទដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន មានចំនួន ៩៧២,២៧ ប៊ីលានរៀល ស្មើប្រមាណជា ២៤០,០៧ លានដុល្លារអាមេរិក ស្មើនឹង ៨,៤២% នៃផែនការប្រចាំឆ្នាំ បើធៀបនឹងចំណូលពន្ធអាករប្រចាំខែធ្នូ ឆ្នាំ២០១៩ ឃើញថាកើនឡើងចំនួន ១៩២,១១ ប៊ីលានរៀល ស្មើប្រមាណជា ៤៧,៤៣ លានដុល្លារអាមេរិក ឬស្មើនឹង ២៤,៦២%។

សម្រាប់ឆ្នាំ២០២១ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានគាំទ្រលើវិធានការដែលបានដាក់ចេញរបស់អគ្គនាយកដ្ឋានពន្ធដារ និងបានផ្តល់អនុសាសន៍សំខាន់ៗ ជាទិសដៅអនុវត្តបន្តដូចជា៖ (១) ត្រូវយកចិត្តទុកដាក់ពិនិត្យ និងសិក្សាលើលទ្ធភាពនៃការប្រមូលចំណូលដែលមានសក្តានុពលផ្សេងទៀត ដោយគិតគូរទាំងទិដ្ឋភាពចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីធានាបាននូវអនុលោមភាពសារពើពន្ធ និងការប្រមូលចំណូលឲ្យបានគ្រប់ជ្រុងជ្រោយ ក្នុងនោះប្រភពចំណូលពីវិស័យ E-Commerce វិស័យប្រេងកាតដែលជាសក្តានុពលថ្មី វិស័យធនធានរ៉ែ ព្រមទាំងវិស័យដែលមានសក្តានុពលមួយចំនួនទៀត។ (២) រៀបចំកែសម្រួលបទប្បញ្ញត្តិក្នុងការកំណត់និយមន័យសហគ្រាសធុនតូច និងមធ្យម និងជំរុញសម្រួលលើកកម្ពស់សហគ្រាសធុនតូច និងមធ្យមមកក្នុងប្រព័ន្ធ ក្នុងគោលដៅជំរុញកំណើន និងបង្កើតជាកាលានុវត្តភាពសេដ្ឋកិច្ច។ (៣) ពង្រឹងការចុះបញ្ជីពន្ធដារ និងជំរុញការបំពេញកាតព្វកិច្ចសារពើពន្ធសម្រាប់សហគ្រាសក្នុងវិស័យកាស៊ីណូ ដើម្បីធានាឲ្យបាននូវតម្លាភាពសារពើពន្ធ និងការគ្រប់គ្រងប្រមូលចំណូលពន្ធឲ្យបានជាអតិបរមា។ (៤) បន្តអនុវត្តកំណែទម្រង់ស្ថាប័ន ទំនើបកម្មរដ្ឋបាលសារពើពន្ធ-ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយធានាយ៉ាងណាបង្កភាពងាយស្រួល (User Friendly) សម្រាប់អ្នកជាប់ពន្ធនិងមន្ត្រី ព្រមទាំងពង្រឹងអនុលោមភាពសារពើពន្ធ ដើម្បីជំរុញប្រសិទ្ធភាព និងភាពប្រទាក់ក្រឡាក្នុងការបំពេញបេសកកម្មគ្រប់គ្រងប្រមូលចំណូលពន្ធ។ (៥) បន្តអនុវត្តប្រកបដោយការយកចិត្តទុកដាក់នូវយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល។ (៦) បន្តពង្រឹងការអនុវត្តឲ្យមានប្រសិទ្ធភាពនូវការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (IT Platform) ស្របតាមខ្លឹមសារអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០។ (៧) ពង្រឹង និងយកចិត្តទុកដាក់លើការធ្វើសវនកម្ម ស្របតាមខ្លឹមសារប្រកាសលេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ស្តីពីសវនកម្មពន្ធដារ ដែលជាជញ្ជីងវាស់នូវអនុលោមភាពរបស់សហគ្រាស និងចៀសវាងការបង្កការលំបាកដល់អ្នកជាប់ពន្ធ។ (៨) បន្តលើកកម្ពស់ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ ពង្រឹងការផ្សព្វផ្សាយ និងការអនុវត្តបទប្បញ្ញត្តិថ្មីៗពាក់ព័ន្ធនឹងពន្ធដារជូនដល់មន្ត្រីអនុវត្តផ្ទាល់ អ្នកជាប់ពន្ធ និងសាធារណជន ដើម្បីពន្យល់និងដោះស្រាយការលំបាក និងចម្ងល់របស់ប្រជាពលរដ្ឋ។ (៩) បន្តកិច្ចសហការ និងពិគ្រោះយោបល់ជាមួយវិស័យពាក់ព័ន្ធ ដើម្បីទទួលយកធាតុចូលក្នុងការសិក្សា ការរៀបចំ និងការកែលម្អបទប្បញ្ញត្តិពាក់ព័ន្ធចាំបាច់នានា។ (3)(4)(5)

## គោលនយោបាយរូបិយវត្ថុ៖

គិតមកត្រឹមត្រីមាសទី៤ ឆ្នាំ២០២០ រូបិយវត្ថុទូទៅ M2 បានកើនឡើង ១៤,៧% ទាបជាងកំណើនឆ្នាំមុន (១៨,២%) ដែលបណ្តាលមកពីកំណើនទាបជាងមុននៃរូបិយវត្ថុក្នុងចរាចរណ៍ និងប្រាក់បញ្ញើសរុបរបស់និវាសជនទាំងប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ដោយសារតែការផ្អាកធ្វើអន្តរាគមន៍ទិញប្រាក់ដុល្លារអាមេរិកចាប់ពីខែឧសភា ឆ្នាំ២០២០ មកគួបផ្សំនឹងការឆ្លើយតបនឹងតម្រូវការខ្ពស់លើប្រាក់រៀលក្នុងឆ្នាំ២០១៩។ ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ធនាគារជាតិ នៃ កម្ពុជាបានបង្កើនកម្រិតសន្ទនីយភាពក្នុងប្រព័ន្ធធនាគារ និងបានពង្រឹងជំនឿទុកចិត្តមកលើវិស័យធនាគារ និងប្រាក់រៀល ដោយបានលក់ប្រាក់ដុល្លារអាមេរិក ៨០,២ លានដុល្លារអាមេរិក (៤លើក) ទៅគ្រឹះស្ថានហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ និងបានលក់ប្រាក់រៀល ឆ្លើយតបនឹងតម្រូវការចំនួន ៦៩,៥ ប៊ីលានរៀល (១៧ លានដុល្លារអាមេរិក)។ ទន្ទឹមនឹងនោះ ធនាគារជាតិ បានលក់ប្រាក់ដុល្លារអាមេរិកសុទ្ធចំនួន ១៤៧,១ លានដុល្លារអាមេរិក ទៅស្ថាប័នរដ្ឋ។ ធនាគារជាតិ នៃ កម្ពុជាបានទម្លាក់អត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀល និងជាដុល្លារអាមេរិកមកត្រឹម ៧% ចាប់ពីខែមេសា ឆ្នាំ២០២០ ពីកម្រិត ៨% ចំពោះប្រាក់បញ្ញើជាប្រាក់រៀល និង១២,៥% ចំពោះរូបិយប័ណ្ណបរទេស។ ការចេញផ្សាយ NCD ចារឹកជាដុល្លារអាមេរិកមានចំនួន ៣០,៨ ប៊ីលានដុល្លារអាមេរិកដែលបានកើនឡើង ៤៥,៣% ធៀបនឹងឆ្នាំមុន ដោយសារគ្រឹះស្ថានធនាគារមានសន្ទនីយភាពខ្ពស់។ ចំណែកឯការចេញផ្សាយ NCD ចារឹកជារៀលមាន ១០,៩ ទ្រីលានរៀល ដោយបានកើនឡើង ៤% ប៉ុណ្ណោះ។ រីឯអត្រាការប្រាក់ NCD ក៏ត្រូវបានកាត់បន្ថយក្នុងកម្រិតសមស្រប។ ចំណែកឯប្រតិបត្តិការ LPCO ត្រូវបានធ្វើឡើងចំនួន ២៣ លើក ដែលបានផ្តល់សន្ទនីយភាពជាប្រាក់រៀលសរុប ៥,៩ ទ្រីលានរៀល ដោយបានកើនឡើង ២៤,៥% ធៀបនឹងឆ្នាំមុន ជាមួយនឹងអត្រាការប្រាក់ដេញថ្លៃឈ្នះជាមធ្យម ៣,០៣% សម្រាប់ឥណប្រតិទាន៣ខែ ៣,៤៤% សម្រាប់ឥណប្រតិទាន៦ខែ ៣,៧៧% សម្រាប់ឥណប្រតិទាន ១ឆ្នាំ។ ទំហំ LPCO ដែលមិនទាន់ដល់ឥណប្រតិទានមាន ៣,៩ ទ្រីលានរៀល គិតត្រឹមចុងខែធ្នូ ឆ្នាំ២០២០។ គួររំលេចថា អត្រាការប្រាក់ដេញថ្លៃអប្បបរមា LPCO ត្រូវបានកាត់បន្ថយ ០,៥% សម្រាប់គ្រប់ឥណប្រតិទានទាំងអស់។ គោលនយោបាយនេះដកស្រង់ចេញពីរបាយការណ៍ប្រចាំឆ្នាំ២០២០ របស់ធនាគារជាតិ នៃ កម្ពុជា។

សម្រាប់ឆ្នាំ២០២១ ធនាគារជាតិ នៃ កម្ពុជា បានកំណត់អនុវត្តគោលនយោបាយរូបិយវត្ថុចំនួន៤ រួមមាន៖ (១) ការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឲ្យស្ថិតក្នុងកម្រិតសមស្រប (២) រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែកស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជន (៣) លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមយន្តការទីផ្សារ និង (៤) ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារតាមរយៈការបង្កើនឧបករណ៍គោលនយោបាយរូបិយវត្ថុចាំបាច់ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ។ (១)

**ឯកសារយោង:**


(១) https://www.nbc.org.kh/download_files/publication/annual_rep_kh/Ann_Report_2020_KHR.pdf

(២) https://www.nbc.org.kh/download_files/other_reports/khmer/Macroeconomic_2020_and_outlook_2021.pdf

(៣) https://dap-business.com/finance/2021/01/13/4567/

(៤) https://www.kampucheathmey.com/business-economic/45563/

(៥) https://cambojanews.com/tax-collections-rise-in-2020-despite-covid-19-pandemic/

# ហត្ថលេខាអភិបាល

ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១
បានអាន និងឯកភាព

លោក **ឆាយ សឿន**, ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១
បានអាន និងឯកភាព

បណ្ឌិត **អ៊ិន ចាន់នី**, អភិបាល

ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១
បានអាន និងឯកភាព

លោក **រ័ត្ន យូម៉េង**, អភិបាល

ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១
បានអាន និងឯកភាព

លោក **Pieter Kooi**, អភិបាល

ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១
បានអាន និងឯកភាព
លោក **Ian Samuel Lydall**,
អភិបាល, ផ្ទេរសិទ្ធិជូនៈ

លោក **ឆាយ សឿន**, ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១
បានអាន និងឯកភាព
លោក **Stéphane MANGIAVACCA**,
អភិបាល, ផ្ទេរសិទ្ធិជូនៈ

លោក **ឆាយ សឿន**, ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១
បានអាន និងឯកភាព
លោក **Kenichiro Mori**,
អភិបាល, ផ្ទេរសិទ្ធិជូនៈ

បណ្ឌិត **អ៊ិន ចាន់នី**, អភិបាល

ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១
បានអាន និងឯកភាព
លោកស្រី **Mirjam Janssen**,
អភិបាល, ផ្ទេរសិទ្ធិជូនៈ

លោក **ឆាយ សឿន**, ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១
បានអាន និងឯកភាព

លោក **វ៉ាន់ ស៊ូអៀង**, អភិបាល

# ឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ២០២០ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

# ផ្នែកទី១

## ភាគហ៊ុនិក

# ក. រចនាសម្ព័ន្ធភាគហ៊ុន (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០)

## ១. ព័ត៌មានភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៣.៣៤១ | ៤.០២៦.១៥៦ | ០,៩២៩៥% |
| | | និតិបុគ្គល | ១ | ២៤៧ | ០,០០០១% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ២១៨ | ៣១៨.៤៦២ | ០,០៧៣៥% |
| | | និតិបុគ្គល | ៣ | ២៦.៨០១.១៣២ | ៦,១៨៧៣% |
| ចាប់ពី ៥% ដល់ តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | និតិបុគ្គល | ២ | ២១៨.៦៩៧.២៦៦ | ៥០,៤៨៨៤% |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | និតិបុគ្គល | ៣ | ១៨៣.៣១៩.៧៥៦ | ៤២,៣២១២% |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | និតិបុគ្គល | - | - | - |
| | មិនមែនសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | - | - | - |
| | | និតិបុគ្គល | - | - | - |
| សរុប | | | ៣.៥៦៨ | ៤៣៣.១៦៣.០១៩ | ១០០,០០០០% |

## ២. ភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | - | - | - |
| បុគ្គលិកជាន់ខ្ពស់ (ចំណាំ-១) | ៨ | ៦៩.០៤៨ | ៣,២៩២៩% |
| និយោជិត | ១.៨៥៥ | ២.០២៧.៨៣៤ | ៩៦,៧០៧១% |
| សរុប | ១.៨៦៣ | ២.០៩៦.៨៨២ | ១០០,០០០០% |

ចំណាំ-១: មានភាគហ៊ុនិកចំនួនម្នាក់ ដែលកាន់មុខតំណែងពីរ (អភិបាល និង បុគ្គលិកជាន់ខ្ពស់) នៅក្នុងធនាគារ។

# ខ. សិទ្ធិរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាគហ៊ុនិក

## ១. សិទ្ធិរបស់ភាគហ៊ុនិក

ភាគហ៊ុនិករបស់ធនាគារ ត្រូវទទួលបាននូវ៖

- សិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក
- សិទ្ធិបោះឆ្នោតដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង ក្នុងមហាសន្និបាតភាគហ៊ុនិក
- សិទ្ធិទទួលបានភាគលាភ ឬផលប្រយោជន៍ដែលបានប្រកាសដោយធនាគារ
- សិទ្ធិទទួលបានទ្រព្យសម្បត្តិ ដែលនៅសល់របស់ធនាគារបន្ទាប់ពីការរំលាយ និងជម្រះបញ្ជី និង
- សិទ្ធិទទួលបានព័ត៌មានគ្រប់ប្រភេទ រួមទាំងព័ត៌មានអំពីអាជីវកម្មរបស់ធនាគារ ព្រមទាំងសៀវភៅ និងកំណត់ត្រាគណនេយ្យរបស់ធនាគារ ព្រមទាំងអាចពិនិត្យបញ្ជីឈ្មោះភាគហ៊ុនិក បាននៅទីស្នាក់ការកណ្តាល របស់ធនាគារនៅក្នុងម៉ោងធ្វើការ ឬនៅពេលមហាសន្និបាតភាគហ៊ុនិក។

## ២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក

សិទ្ធិរបស់ភាគហ៊ុនិក គឺត្រូវបានការពារដោយលក្ខន្តិកៈ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។ អនុលោមតាមមាត្រា១៤ (១៤.១ ចំណុចទី១) នៃលក្ខន្តិកៈ របស់ធនាគារ បានចែងថា “ភាគហ៊ុន” នីមួយៗរបស់ធនាគារផ្តល់ដល់អ្នកកាន់កាប់នូវសិទ្ធិបោះឆ្នោត ១ (មួយ) សំឡេងក្នុងមហាសន្និបាតភាគហ៊ុនិក”។

## ៣. ការការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនតិច

ភាគហ៊ុននីមួយៗ មានសិទ្ធិបោះឆ្នោត១ (មួយ) សំឡេង។ សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច ត្រូវបានការពារដោយលក្ខន្តិកៈ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។

# គ. មហាសន្និបាតភាគហ៊ុនិក

## ១. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

ធនាគារបានអនុម័តនូវគោលការណ៍ស្តីពីការបោះឆ្នោតមហាសន្និបាតភាគហ៊ុនិក ដែលផ្តល់នូវវិធាន និងការណែនាំច្បាស់លាស់ដល់ភាគហ៊ុនិក អំពីដំណើរការបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក។

### កូរ៉ុម

កូរ៉ុម នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក គឺជាចំនួនភាគហ៊ុនិកដែលចូលរួមដោយផ្ទាល់ និងតាមរយៈការប្រគល់សិទ្ធិ (អ្នកតំណាងដោយអាណត្តិ) ដែលកាន់កាប់ភាគហ៊ុនចំនួនយ៉ាងតិច៥១% នៃចំនួនភាគហ៊ុនសរុបរបស់ធនាគារ។

### ការជូនដំណឹង អំពីកិច្ចប្រជុំ

លិខិតជូនដំណឹង អំពីកិច្ចប្រជុំ នឹងត្រូវផ្ញើជូនភាគហ៊ុនិកតាមមធ្យោបាយផ្សេងៗដូចជា៖ Hard copy និង/ឬ តាមរយៈប្រព័ន្ធអេឡិចត្រូនិក ក្នុងកំឡុងពេលចាប់ពី២០ទៅ៥០ថ្ងៃមុនកាលបរិច្ឆេទប្រជុំ។ លិខិតជូនដំណឹង អំពីកិច្ចប្រជុំ មានបញ្ជាក់ច្បាស់ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលនឹងត្រូវប្រារព្ធកិច្ចប្រជុំ។

### កំឡុងពេលប្រជុំ និងដំណើរការបោះឆ្នោត

ប្រធានក្រុមប្រឹក្សាភិបាលនឹងចាប់ផ្តើមកិច្ចប្រជុំដោយផ្តល់នូវមតិស្វាគមន៍ និងកំណត់បង្ហាញនូវកូរ៉ុមដែលបានចូលរួម និងប្រកាស អំពីរបៀបវារៈនៃកិច្ចប្រជុំ។ ប្រធានក្រុមប្រឹក្សាភិបាលបញ្ជាក់ អំពីនីតិវិធីនៃការបោះឆ្នោតជូនដល់ភាគហ៊ុនិកដែលបានចូលរួម មុននឹងប្រកាសចាប់ផ្តើមដំណើរការបោះឆ្នោតលើសេចក្តីសម្រេចណាមួយ។

ធនាគារនឹងចាត់តាំងជាមុននូវបុគ្គលិក សម្រាប់ជួយសម្របសម្រួលដល់ដំណើរការនៃការបោះឆ្នោត។ លទ្ធផលនៃការបោះឆ្នោត នឹងត្រូវប្រកាសក្រោយពេលដែលការរាប់សន្លឹកឆ្នោត ត្រូវបានបញ្ចប់។

### ក្រោយកិច្ចប្រជុំ

ធនាគារត្រូវធ្វើការបង្ហាញព័ត៌មាន និងរាយការណ៍ស្របតាមប្រកាសលេខៈ ០០៧/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្មដែលចេញដោយគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) និងស្របតាមគោលការណ៍ស្តីពីការបង្ហាញព័ត៌មានរបស់ធនាគារ។

## ២. ព័ត៌មានមហាសន្និបាតភាគហ៊ុនិក

| លរ | កាលបរិច្ឆេទ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|
| ០១ | ២៨ មករា ២០២០ កិច្ចប្រជុំភាគហ៊ុនិកតាមរយៈអ៊ីម៉ែល | ១០០% | សម្រេចអនុម័តដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំចំនួន ៥% (ប្រាំភាគរយ) នៃ ប្រាក់បៀវត្សសុទ្ធសាធរបស់លោក ឆាយ សឿន ប្រធានក្រុមប្រឹក្សាភិបាល ដែលមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០។ | ភាគហ៊ុនិកបានសម្រេចអនុម័តដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំចំនួន ៥% (ប្រាំភាគរយ) នៃ ប្រាក់បៀវត្សសុទ្ធសាធរបស់លោក ឆាយ សឿន ប្រធានក្រុមប្រឹក្សាភិបាល ដែលមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០។ |
| ០២ | ១២ កុម្ភៈ ២០២០ កិច្ចប្រជុំភាគហ៊ុនិកតាមរយៈអ៊ីម៉ែល | ១០០% | សម្រេចអនុម័តកំណត់តម្លៃភាគហ៊ុនថ្មីរបស់ធនាគារ សម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ (IPO)។ | ភាគហ៊ុនិកបានសម្រេចអនុម័តកំណត់តម្លៃភាគហ៊ុនថ្មីរបស់ ធនាគារ សម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ (IPO) ពី ៣,៧៥ដុល្លារអាមេរិក (P/B ២០១៩E =១,៧៤x, P/E ២០១៩E=១៣,០២x) ស្មើនឹង ១៥.000រៀល ទៅ ៤,៣៥ដុល្លារអាមេរិក (P/B ២០១៩E=២,០២x, P/E ២០១៩E=១៥,១១x) ស្មើនឹង ១៧.៤០០ រៀល ក្នុងមួយភាគហ៊ុន។ |
| ០៣ | ២០ កុម្ភៈ ២០២០ កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ (EGM) | ១០០% | បញ្ហាដែលត្រូវសម្រេច៖ | ភាគហ៊ុនិកបានសម្រេចដូចខាងក្រោម៖ |
| | | | • សម្រេចអនុម័តរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០១៩ ដែលបានធ្វើសវនកម្ម រួចដោយសវនករឯករាជ្យ KPMG។ | ១-ភាគហ៊ុនិកបានសម្រេចអនុម័តរបាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ សម្រាប់គោលបំណងពិសេស ដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ KPMG។ |
| | | | • សម្រេចអនុម័តការបែងចែកភាគលាភ និងផ្ទេរសមតុល្យដែលនៅសល់ នៃប្រាក់ចំណេញសុទ្ធបន្ទាប់ពីបង់ពន្ធទៅជាទុនបម្រុងទូទៅ។ | ២-ភាគហ៊ុនិកបានសម្រេចអនុម័តបែងចែកភាគលាភ ជាសាច់ប្រាក់ ២៥% ស្មើនឹង ៣២.៧១៨.៨២៥,១៥ដុល្លារអាមេរិក នៃប្រាក់ចំណេញបន្ទាប់ពីបង់ពន្ធសម្រាប់ ឆ្នាំ២០១៩ ចំនួន ១៣០.៨៥៥.១៦៣ ដុល្លារអាមេរិក ក្នុងតម្លៃ ០,០៧៦៣ ដុល្លារអាមេរិក ក្នុងមួយភាគហ៊ុន និងបង្វែរសមតុល្យនៃប្រាក់ចំណេញ បន្ទាប់ពីបង់ពន្ធដែលនៅសល់ទៅជាទុនបម្រុងទូទៅ។ |
| | | | • សម្រេចអនុម័ត និងទទួលស្គាល់ការតែងតាំងក្រុមប្រឹក្សាភិបាលថ្មី។ | ៣-ភាគហ៊ុនិកបានសម្រេចអនុម័ត និងទទួលស្គាល់ការតែងតាំងលោក Stéphane Mangiavacca ពីស្ថាប័ន COFIBRED S.A ជា សមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី និងដកសិទ្ធិនៃតួនាទី និងការទទួលខុសត្រូវរបស់លោក Marc Robert ពីមុខងារជាសមាជិកក្រុមប្រឹក្សាភិបាលនៅក្នុង ធនាគារ អេស៊ីលីដា ភីអិលស៊ី។ |
| | | | • សម្រេចអនុម័តនិងទទួលស្គាល់ការតែងតាំងតំណាងភាគហ៊ុនិក។ | ៤-ភាគហ៊ុនិកបានសម្រេចអនុម័ត និងទទួលស្គាល់លោកស្រី Quitterie DE LA ROCHEFOREDIERE ពី ស្ថាប័ន COFIBRED S.A. ជាតំណាងភាគហ៊ុនិកថ្មី នៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី និងដកសិទ្ធិនៃតួនាទី និងការទទួលខុសត្រូវរបស់លោក Marc Robert ពីមុខងារជាតំណាងភាគហ៊ុនិកនៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី។ |
| | | | • សម្រេចអនុម័ត ចំពោះការកែប្រែកិច្ចព្រមព្រៀងភាគហ៊ុនិក និងលក្ខន្តិកៈ។ | ៥-ភាគហ៊ុនិកបានសម្រេចអនុម័តលើកិច្ចព្រមព្រៀងភាគហ៊ុនិក និងលក្ខន្តិកៈរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។ |

| លរ | កាលបរិច្ឆេទ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|
| | | | • ពិភាក្សា និងសម្រេចអនុម័តគោលការណ៍ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល។ | ៦-ភាគហ៊ុនិកបានសម្រេចអនុម័តគោលការណ៍ ស្តីពីការតែងតាំង និងលាភការ ក្រុមប្រឹក្សាភិបាល។ |
| | | | • សម្រេចអនុម័តឲ្យភាគហ៊ុន ដែលមានស្រាប់ចូលរួមក្នុងការលក់ភាគហ៊ុនរបស់ខ្លួនក្នុង IPO។ | ៧-សម្រេចអនុម័តទៅលើភាគហ៊ុនិកដែលមានស្រាប់ ដែលអនុញ្ញាតឲ្យចូលរួម និងលក់ភាគហ៊ុននៅក្នុង IPO រហូតដល់ ៣% (១៣.១២៧.០៨៦ ភាគហ៊ុន) នៃភាគហ៊ុនថ្មី ដែលត្រូវដាក់លក់ (៤៣៧.៥៦៩.៥៤៥ ភាគហ៊ុន)។ |
| | | | បញ្ហាផ្សេងៗសម្រាប់សម្រេច | |
| | | | • ពិភាក្សាពីសញ្ញាតិរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។<br>• IPO/Listing scenario | |
| ០៤ | ០៧ មេសា ២០២០<br>មហាសន្និបាតភាគហ៊ុនិកសាមញ្ញ | ១០០% | បញ្ហាដែលត្រូវសម្រេច៖ | ភាគហ៊ុនិកបានសម្រេចដូចខាងក្រោម៖ |
| | | | • សម្រេចអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុរួមបញ្ចូលគ្នា និងដាច់ដោយឡែករបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដោយផ្អែកតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា (CIFRS) ដែលបានធ្វើសវនកម្ម ដោយក្រុមហ៊ុនសវនកម្ម KPMG។ | ១-ភាគហ៊ុនិកបានសម្រេចអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុរួមបញ្ចូលគ្នា និងដាច់ដោយឡែករបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដោយផ្អែកតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា (CIFRS) ដែលបានធ្វើសវនកម្ម ដោយក្រុមហ៊ុនសវនកម្ម KPMG។ |
| | | | • សម្រេចអនុម័តការតែងតាំងក្រុមប្រឹក្សាភិបាលថ្មីរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីជំនួសអភិបាលដែលចូលនិវត្តន៍។ | ២-ភាគហ៊ុនិកបានសម្រេចអនុម័ត និងតែងតាំង លោក វ៉ាន់ ស៊ូអៀង ជាអភិបាលឯករាជ្យរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។ |
| | | | • ធ្វើការតែងតាំងអាណត្តិអភិបាលថ្មីរយៈពេល ៣ឆ្នាំខាងមុខ។ | ៣-ភាគហ៊ុនិកបានសម្រេចតែងតាំងអាណត្តិថ្មី របស់បណ្ឌិត អ៊ិន ចាន់នី លោក ឆាយ សឿន និងលោក រ័ត្ន យូម៉េង ជាសមាជិកក្រុមប្រឹក្សាភិបាលដែលមានរយៈពេល៣ឆ្នាំ បន្ទាប់ទៀត។ |
| | | | • អនុម័តលើការកែប្រែលក្ខន្តិកៈធនាគារ | ៤-ភាគហ៊ុនិកបានសម្រេចអនុម័តលើការកែប្រែឧបសម្ព័ន្ធ ១ នៃលក្ខន្តិកៈធនាគារ "តារាងសមាសភាពក្រុមប្រឹក្សាភិបាល ធនាគារ អេស៊ីលីដា ភីអិលស៊ី" ដោយលោក លោក វ៉ាន់ ស៊ូអៀង ត្រូវបានតែងតាំងជាអភិបាលឯករាជ្យជំនួសលោក Cornelius Obert ដែលចូលនិវត្តន៍នៅអាយុ៧០ ឆ្នាំ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០ ហើយចំនួនសមាជិកក្រុមប្រឹក្សាភិបាលត្រូវបានរក្សានៅដដែល។ |
| | | | • អនុម័តរបាយការណ៍ប្រចាំឆ្នាំ២០១៩។ | ៥-ភាគហ៊ុនិកបានសម្រេចអនុម័តរបាយការណ៍ប្រចាំឆ្នាំ២០១៩។ |
| | | | • អនុម័តគោលការណ៍ស្តីពីការតែងតាំង និងលាភការរបស់ ធនាគារ។ | ៦-ភាគហ៊ុនិកបានសម្រេចអនុម័តគោលការណ៍ស្តីពីការតែងតាំង និងលាភការរបស់ធនាគារ។ |

| លរ | កាលបរិច្ឆេទ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|
| | | | បញ្ហាដែលត្រូវរាយការណ៍/ បទបង្ហាញ | |
| | | | • របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាលសម្រាប់ ឆ្នាំ២០១៩ និងស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា។ | |
| | | | • របាយការណ៍របស់ប្រធាននាយកប្រតិបត្តិសម្រាប់ឆ្នាំ២០១៩ និងផែនការយុទ្ធសាស្រ្តសម្រាប់ ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។ | |
| | | | • រាយការណ៍ដំណើរការនៃការចូល IPO/ listing របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។ | |
| ០៥ | ២២ ឧសភា ២០២០ កិច្ចប្រជុំភាគហ៊ុនិកតាមរយៈអ៊ីម៉ែល | ១០០% | • សម្រេចអនុម័ត ឲ្យធនាគារបន្តបោះផ្សាយភាគហ៊ុន ក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា តាមផែនការនៅ សប្តាហ៍ក្រោយ (ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០)។ | • ភាគហ៊ុនិកបានសម្រេចឲ្យធនាគារបន្តបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ នៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា តាមផែនការនៅសប្តាហ៍ក្រោយ (ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០) ស្របតាមអនុសាសន៍របស់អាជ្ញាធរ។ |
| ០៦ | ២៣ ខែវិច្ឆិកា ឆ្នាំ២០២០ មហាសន្និបាតវិសាមញ្ញ (មានការចូលរួមដោយផ្ទាល់ពីភាគហ៊ុនិកសាធារណៈ និងតាមរយៈវីដីអូខលដោយភាគហ៊ុនិកដែលមានស្រាប់) | ១០០% | បញ្ហាដែលត្រូវសម្រេចៈ | ភាគហ៊ុនិកបានសម្រេចដូចខាងក្រោមៈ |
| | | | • អនុម័តលើការផ្លាស់ប្តូរស្លាកសញ្ញារបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី | ១-ភាគហ៊ុនិកបានសម្រេចអនុម័តលើការផ្លាស់ប្តូរស្លាកសញ្ញាថ្មីរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ជំនួសស្លាកសញ្ញាដែលមានស្រាប់ ដើម្បីកែលម្អនូវរូបរាងស្លាកសញ្ញានិមិត្តរូប និងអត្តសញ្ញាណរបស់ធនាគារ។ |
| | | | • ការអនុម័តលើការវិនិយោគរបស់អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ នៅក្នុង វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។ | ២-ភាគហ៊ុនិកបានសម្រេចអនុម័តលើការវិនិយោគទឹកប្រាក់ចំនួន ១០លានដុល្លារអាមេរិក ដើម្បីទទួលបានសិទ្ធិកាន់កាប់ភាគហ៊ុនរហូតដល់ ៦.០៤៧.០៤៦ ភាគហ៊ុន ស្មើនឹង ២៣,៣៩១៩% នៃភាគហ៊ុនសរុប របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។ |
| | | | • ការអនុម័ត ស្តីពីការដកការវិនិយោគរបស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា។ | ៣-ភាគហ៊ុនិកបានសម្រេចអនុម័តលើការដកការវិនិយោគរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅស្ថាប័ន មីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ានម៉ា។ |
| | | | • ការអនុម័តតែងតាំងលោក Albertus Bruggink មកពីស្ថាប័ន ORIX ជាអភិបាលថ្មីនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ជំនួសលោក Ryoji Nishimura។ | ៤-ភាគហ៊ុនិកបានសម្រេចអនុម័តលើការទទួលស្គាល់លោក Albertus Bruggink មកពីស្ថាប័ន ORIX Corporation ជាអភិបាលថ្មី នៅធនាគារ អេស៊ីលីដា ភីអិលស៊ី ជំនួសលោក Ryoji Nishimura។ |
| | | | • ការអនុម័ត និងការទទួលស្គាល់ការចូលនិវត្តន៍របស់អភិបាល ដែលតែងតាំងដោយធនាគារ Triodos នៅធនាគារ អេស៊ីលីដា ភីអិលស៊ី។ | ៥-ភាគហ៊ុនិកបានសម្រេចអនុម័តលើការទទួលស្គាល់ការចូលនិវត្តន៍របស់លោកស្រី Mirjam Janssen អភិបាលដែលបានតែងតាំងដោយធនាគារ Triodos នៅធនាគារ អេស៊ីលីដា ភីអិលស៊ី។ |

| លរ | កាលបរិច្ឆេទ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្តីសម្រេច |
|---|---|---|---|---|
| | | | • ការអនុម័ត តែងតាំងអភិបាលថ្មីនៅធនាគារ អេស៊ីលីដា ភីអិលស៊ី។ | ៦-ភាគហ៊ុនិកបានសម្រេចអនុម័តទទួលស្គាល់ លោក កាយ ឡូត ជាអភិបាលទីពីរ ដែលបានតែងតាំងដោយក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី នៅធនាគារ អេស៊ីលីដា ភីអិលស៊ី។ |
| | | | • ការអនុម័ត និងទទួលស្គាល់ការតែងតាំង លោក Hideomi Shigematsu មកពីស្ថាប័ន SMBC ជាតំណាងភាគហ៊ុនិកថ្មីនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ជំនួសលោក Yuichi Nishimura។ | ៧-ភាគហ៊ុនិកបានសម្រេចអនុម័តទទួលស្គាល់ លោក Hideomi Shigematsu មកពីស្ថាប័ន SMBC ជាតំណាងភាគហ៊ុនិកថ្មីនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ជំនួសលោក Yuichi Nishimura។ |
| | | | • ការអនុម័ត ការកែប្រែលក្ខន្តិកៈរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។ | ៨-ភាគហ៊ុនិកបានសម្រេចអនុម័តលើការកែប្រែលក្ខន្តិកៈត្រង់មាត្រា ៥.២ មាត្រា ៦.១ មាត្រា ៨ ឧបសម្ព័ន្ធ ១ និងឧបសម្ព័ន្ធ ២ និងបន្ថែមមាត្រា ៧.៩ និងឧបសម្ព័ន្ធ ៣ "បញ្ជីឈ្មោះភាគហ៊ុនិកសាធារណៈរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី" នៃអនុស្សរណៈ និងលក្ខន្តិកៈ ធនាគារ អេស៊ីលីដា ភីអិលស៊ី។ |
| | | | • ការអនុម័តតែងតាំងសវនករឯករាជ្យប្រចាំធនាគារ សម្រាប់ឆ្នាំ២០២១។ | ៩-ភាគហ៊ុនិកបានសម្រេចអនុម័តជ្រើសរើសក្រុមហ៊ុន Grant Thornton Cambodia ជាសវនករឯករាជ្យប្រចាំធនាគារ សម្រាប់ឆ្នាំ២០២១ ហើយចំណាយសម្រាប់ក្រុមការងារសវនកម្មមានចំនួន ២៥២,៣០០ ដុល្លារអាមេរិក (មិនបូកបញ្ចូលចំណាយផ្សេងៗ និង អាករលើតម្លៃបន្ថែម)។ |

# ឃ. ការបែងចែកភាគលាភ

## ១. គោលនយោបាយបែងចែកភាគលាភ

ធនាគារបានដាក់ចេញនូវគោលការណ៍ ស្តីពីការបែងចែកភាគលាភ ដើម្បីកំណត់នូវគោលការណ៍ និងការណែនាំ អំពីការបែងចែកភាគលាភជូនភាគហ៊ុនិកប្រកបដោយភាពត្រឹមត្រូវនិងមានប្រសិទ្ធភាព។ ធនាគារចាត់ថ្នាក់ភាគលាភជាប្រភេទដូចខាងក្រោម៖

- ភាគលាភជាសាច់ប្រាក់
- ភាគលាភជាភាគហ៊ុន និង
- ភាគលាភជាទម្រង់ផ្សេងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិក ស្របតាម ច្បាប់ បទប្បញ្ញត្តិ និងការអនុវត្តតាមស្តង់ដារអន្តរជាតិ។

## ២. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

| លរ | ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ២០២០ | ២០១៩ | ២០១៨ |
|---|---|---|---|---|
| ១ | កាលបរិច្ឆេទប្រកាសបែងចែកភាគលាភ | ២០ កុម្ភៈ ឆ្នាំ២០២០ | ២៥ មេសា ២០១៩ | ១០ ឧសភា ២០១៨ |
| ២ | កាលបរិច្ឆេទកំណត់ទុក | ៣១ ធ្នូ ២០១៩ | ៣១ ធ្នូ ២០១៨ | ៣១ ធ្នូ ២០១៧ |
| ៣ | កាលបរិច្ឆេទទូទាត់ភាគលាភ | ២០ កុម្ភៈ ២០២០ (សាច់ប្រាក់) | ២៥ មេសា ២០១៩ (សាច់ប្រាក់)<br>១៩ មិថុនា ២០១៩ (ភាគហ៊ុន) | ១០ ឧសភា ២០១៨ (សាច់ប្រាក់)<br>១៩ កក្កដា ២០១៨ (ភាគហ៊ុន) |

# ផ្នែកទី២

## ក្រុមប្រឹក្សាភិបាល

# ក. ក្រុមប្រឹក្សាភិបាល

## ១. សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទក្លាយជាអភិបាល | កាលបរិច្ឆេទបញ្ចប់អាណត្តិ |
|---|---|---|---|---|
| ១ | លោក ឆាយ សឿន | ប្រធានក្រុមប្រឹក្សាភិបាល | ១៨ សីហា ២០១៤ | ១៨ សីហា ២០២៣ |
| ២ | បណ្ឌិត អ៊ិន ចាន់នី | អភិបាលប្រតិបត្តិ | ១៨ សីហា ២០១៤ | ១៨ សីហា ២០២៣ |
| ៣ | លោក រ័ត្ន យូម៉េង | អភិបាលប្រតិបត្តិ | ១៨ សីហា ២០១៤ | ១៨ សីហា ២០២៣ |
| ៤ | លោក Pieter Kooi | អភិបាលឯករាជ្យ | ១២ មករា ២០០៤ | ១២ មករា ២០២២ |
| ៥ | លោក វ៉ាន់ ស៊ូអៀង | អភិបាលឯករាជ្យ | ០២ កញ្ញា ២០២០ | ០២ កញ្ញា ២០២៣ |
| ៦ | លោក Ian Samuel Lydall | អភិបាលឯករាជ្យ | ២១ សីហា ២០១៥ | ២១ សីហា ២០២១ |
| ៧ | លោក Kenichiro Mori | អភិបាលមិនប្រតិបត្តិ | ២៤ តុលា ២០១៩ | ០៦ ធ្នូ ២០២២ |
| ៨ | លោក Stéphane MANGIAVACCA | អភិបាលមិនប្រតិបត្តិ | ២១ មេសា ២០២០ | ២១ សីហា ២០២១ |
| ៩ | លោកស្រី Mirjam Janssen | អភិបាលមិនប្រតិបត្តិ | ២០ មករា ២០២០ | ១២ មករា ២០២២ |

## ២. ជីវប្រវត្តិសង្ខេបរបស់អភិបាលនីមួយៗ

### លោក ឆាយ សឿន, ប្រធានក្រុមប្រឹក្សាភិបាល

**គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការសវនកម្ម**

ជនជាតិខ្មែរ កើតនៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៥៤។ លោកបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលនៅខែសីហា ឆ្នាំ២០១៤។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតប្រតិបត្តិគ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ និងគណនេយ្យ ពីសាកលវិទ្យាល័យ Preston នៅសហរដ្ឋអាមេរិក។ លោកក៏បានបញ្ចប់វគ្គសិក្សាស្តីពីអភិបាលក្រុមហ៊ុន ពីវិទ្យាស្ថានអូស្ត្រាលី សម្រាប់អភិបាលក្រុមហ៊ុន (GAICD)។ លោកបានចូលបម្រើការជាមួយអេស៊ីលីដា ចាប់តាំងពីខែមករា ឆ្នាំ១៩៩៣ រហូតដល់ចូលនិវត្តន៍នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤។ តួនាទីចុងក្រោយមុនចូលនិវត្តន៍របស់លោកនៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី ជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ។ លោកធ្លាប់ធ្វើជាគណនេយ្យករ និងជាអនុប្រធានគណនេយ្យករនៃមន្ទីរពាណិជ្ជកម្មខេត្តកំពត ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩២។

បច្ចុប្បន្នលោកជាប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ភីអិលស៊ី សមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ឡាវ និងសមាជិកក្រុមប្រឹក្សាភិបាលនៃស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា។

### បណ្ឌិត អ៊ិន ចាន់នី, អភិបាល

ជនជាតិខ្មែរ កើតក្នុងខែមិថុនា ឆ្នាំ១៩៦០។ បណ្ឌិត អ៊ិន ចាន់នី ជាប្រធាននាយកប្រតិបត្តិ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំងពីធនាគារបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០។ លោកបណ្ឌិតបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែសីហា ឆ្នាំ២០១៤។ បណ្ឌិត អ៊ិន ចាន់នី ជាសហស្ថាបនិករបស់សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (អេស៊ីលីដា) តាំងពីខែមករា ឆ្នាំ១៩៩៣។ ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ លោកបណ្ឌិតជាអ្នកដឹកនាំគណៈកម្មាធិការប្រតិបត្តិទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្ររួម និងដំណើរការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ព្រមទាំងប្រតិបត្តិផែនការអាជីវកម្ម។ លោកបណ្ឌិតទទួលខុសត្រូវផ្ទាល់ចំពោះក្រុមប្រឹក្សាភិបាល។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកបណ្ឌិត រួមមាន ជាប្រធានក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ឡាវ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ព្រមទាំងជាតំណាងភាគហ៊ុនិករបស់ធនាគារ អេស៊ីលីដា ឡាវ អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា។ លោកបណ្ឌិតក៏ជាប្រធានក្រុមប្រឹក្សាភិបាលរបស់អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់។

បណ្ឌិត អ៊ិន ចាន់នី ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ Entrepreneurship Development Fund (EDF) ជាបរធនបាលកិច្ចបង្កើតដោយរាជរដ្ឋាភិបាលកម្ពុជា។ លោកបណ្ឌិតក៏ជាប្រធានសមាគមធនាគារនៅកម្ពុជា។ លោកបណ្ឌិតជាអ្នកតំណាងរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាសមាជិករបស់វេទិកាសេដ្ឋកិច្ចពិភពលោក។

នៅក្នុងឆ្នាំ១៩៩៨ លោកបានបញ្ចប់វគ្គគ្រប់គ្រងស្តីពីស្ថាប័នហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍សហគ្រាសឯកជន (FIPED) ពីសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក។ លោកបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្ម និងបានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD)។

## លោក វ័ត្ន យូម៉េង, អភិបាល

ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៦២។ លោក វ័ត្ន យូម៉េង បានបម្រើការឲ្យអេស៊ីលីដា ចាប់ពីខែមករា ឆ្នាំ១៩៩៩។ ចាប់ពីខែមករា ឆ្នាំ១៩៩៩ ដល់ខែសីហា ឆ្នាំ២០០៨ លោកបានកាន់តំណែងជាច្រើនដូចជា៖ ប្រធានគណនេយ្យករ និងអនុប្រធានហិរញ្ញវត្ថុ (ខែមករា ឆ្នាំ១៩៩៩ ដល់ខែឧសភា ឆ្នាំ២០០៧), នាយកប្រតិបត្តិនាយកដ្ឋានហិរញ្ញវត្ថុ (ខែមិថុនា ឆ្នាំ២០០៧ ដល់ខែសីហា ឆ្នាំ២០០៨) និងជានាយកប្រតិបត្តិរតនាភិបាល (ខែកញ្ញា ឆ្នាំ២០០៨ ដល់ខែឧសភា ឆ្នាំ២០១៥) និងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល (ខែមិថុនា ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន)។

លោកទទួលខុសត្រូវដឹកនាំក្រុមគ្រប់គ្រង និងត្រួតពិនិត្យរតនាភិបាល ដូចជា៖ នាយកដ្ឋានប្រតិបត្តិការហិរញ្ញវត្ថុ ការិយាល័យរតនាភិបាល ការិយាល័យប្រាក់តម្កល់ និងអត្រាប្តូររូបិយប័ណ្ណ និងការិយាល័យរតនពាណិជ្ជកម្ម។ លោកក៏ជាអ្នកគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ទាក់ទងនឹងការគ្រប់គ្រងមូលនិធិ។

បន្ថែមពីនេះទៀត លោកក៏កាន់មុខតំណែងជាប្រធាន និងសមាជិករបស់គណៈកម្មាធិការជាច្រើននៅក្នុងធនាគារ អេស៊ីលីដា ដូចជា៖ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម និងជាសមាជិកគណៈកម្មាធិការឥណទាន។

ចាប់ពីឆ្នាំ២០០១ រហូតដល់ខែកញ្ញា ឆ្នាំ២០១៤ លោកក៏ជាអ្នកតំណាងភាគហ៊ុនិករបស់ក្រុមហ៊ុន អេ អេស អេ ដែលជាភាគហ៊ុនិកក្នុងស្រុកមួយរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។ នៅខែសីហា ឆ្នាំ២០១៤ លោកបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ វេស្ទើន នៅទីក្រុងភ្នំពេញ ហើយលោកក៏បានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD)។

## លោក PIETER KOOI, អភិបាល

### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា (ប្រធាន) គណៈកម្មាធិការតែងតាំង និងលាភការ គណៈកម្មាធិការសវនកម្ម

ជនជាតិហុល្លង់ដ៍ កើតក្នុងឆ្នាំ១៩៥៨ បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែតុលា ឆ្នាំ២០០០។ លោកទទួលបានអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុសាជីវកម្ម និងសង្គមវិទ្យា នៅសាកលវិទ្យាល័យ Erasmus ក្នុងទីក្រុង Rotterdam ប្រទេសហុល្លង់ដ៍។ ចាប់ពីឆ្នាំ១៩៩៣ លោកបានធ្វើជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុឲ្យអេស៊ីលីដា រយៈពេលជាង ៧ឆ្នាំ ដើម្បីកម្លាយខ្លួនពីកម្មវិធីអភិវឌ្ឍន៍ទៅជាធនាគារពាណិជ្ជ។ ចាប់ពីឆ្នាំ១៩៩៩ លោក Pieter Kooi បានបម្រើការងារជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុរយៈពេលខ្លី ដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុ នៅក្នុង ១៥ប្រទេស ដែលភាគច្រើនស្ថិតក្នុងទ្វីបអាហ្វ្រិក និងអាស៊ី។ ចាប់ពីខែកញ្ញា ឆ្នាំ២០០២ ដល់ខែធ្នូ ឆ្នាំ២០០៥ លោកមានតួនាទីជានាយកផ្នែកមីក្រូហិរញ្ញវត្ថុរបស់ UNCDF ក្នុងទីក្រុងញូយ៉ក។ ចាប់ពីខែមីនា ឆ្នាំ២០០៦ រហូតដល់ខែឧសភា ឆ្នាំ២០១១ លោកបានធ្វើជាទីប្រឹក្សាក្រៅម៉ោងឲ្យធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងការបង្កើតធនាគារ អេស៊ីលីដា ឡាវ, អេស៊ីលីដា ត្រេននីង សេនធ័រ (បច្ចុប្បន្នជា វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា), និងអេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី។ បច្ចុប្បន្នលោក ជាសមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងស្ថាប័នជាច្រើននៅតំបន់អាស៊ី។ លោកបានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD)។

## លោក វ៉ាន់ ស៊ូអៀង, អភិបាល

### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖ គណៈកម្មាធិការតែងតាំង និងលាភការ (ប្រធាន)

ជនជាតិខ្មែរ កើតឆ្នាំ១៩៥៣។ លោក វ៉ាន់ ស៊ូអៀង បានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងខែកញ្ញា ឆ្នាំ២០២០។ លោកបានបញ្ចប់ការសិក្សាថ្នាក់គណិតវិទ្យា និងវិទ្យាសាស្ត្ររូបវិទ្យា ពីសាលា ACADEMIES DE CRETEIL ក្នុងតំបន់ Fontainebleau ទីក្រុងប៉ារីស នាឆ្នាំ១៩៧២។ លោកក៏បានបញ្ចប់ការសិក្សា "est diplómé de l'INSTITUT SUPERIEUR DE GESTION" ក្នុងទីក្រុងប៉ារីស ប្រទេសបារាំង នាឆ្នាំ១៩៧៦។

បច្ចុប្បន្នលោកមានតួនាទីនៅក្នុងស្ថាប័នជាច្រើនដូចជា៖ ប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA), ប្រធានក្រុមប្រឹក្សាភិបាលសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC), សមាជិក ASEAN Business Advisory Council (ABAC), សមាជិក ASEAN Federation of Textile Industries (AFTEX), ប្រធានកិត្តិយស Cambodia Federation of Equestrian (CFE), អនុប្រធានក្រុមប្រឹក្សាភិបាល National Training Board (NTB), សហប្រធាន Government-Private Sector Working Group, សមាជិក Labor Advisory Committee (LAC), អនុប្រធានក្រុមប្រឹក្សាភិបាល Labor Dispute Resolution Advisory Committee, សមាជិកក្រុមប្រឹក្សាភិបាល បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.), Member of Committee of the Review of Cambodia's Implementation of the UN Convention on Anti-Corruption Law, និង Member of the Inception Committee of the National Commercial Arbitration NAC។

លោកក៏មានតួនាទីជា អនុប្រធានក្រុមប្រឹក្សាភិបាល អេស៊ីអា អ៊ិនសូរិន (ខេមបូឌា), អនុប្រធានក្រុមប្រឹក្សាភិបាល Asia properties Cambodia Ltd, ប្រធានក្រុមប្រឹក្សាភិបាល PPS Garment Factory, ប្រធាន PPS Industrial Estate Holding Co., Ltd., ប្រធាន Cambodian Country Club (CCC), ប្រធាន ហ្គោលដេន សូរិយាម៉ល និងជាប្រធាន boutique Hotel named La Plantation Resort and SPA។

## លោក IAN SAMUEL LYDALL, អភិបាល

### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖ គណៈកម្មាធិការសវនកម្ម (ប្រធាន), គណៈកម្មាធិការតែងតាំង និងលាភការ, គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា

ជនជាតិអង់គ្លេស កើតក្នុងឆ្នាំ១៩៥៥។ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែសីហា ឆ្នាំ២០១៥។ លោកធ្លាប់ធ្វើជានាយកប្រតិបត្តិ និងជាប្រធានក្រុមហ៊ុន PwC នៅប្រទេសវៀតណាម។ លោកបានចូលនិវត្តន៍ពីក្រុមហ៊ុន PwC នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥។ លោកបានរួមចំណែកជាមួយធនាគារ អេស៊ីលីដា ដោយប្រើប្រាស់បទពិសោធន៍របស់លោកខាងផ្នែករបាយការណ៍ហិរញ្ញវត្ថុ អភិបាលកិច្ចសាជីវកម្ម ការគ្រប់គ្រងហានិភ័យ យុទ្ធសាស្ត្រ និងផ្នែកពាក់ព័ន្ធផ្សេងៗទៀត។ លោកមានបទពិសោធន៍យ៉ាងទូលំទូលាយ និងស៊ីជម្រៅទាក់ទងនឹងវិស័យហិរញ្ញវត្ថុ។

### លោក KENICHIRO MORI, អភិបាល

### គណៈកម្មាធិការក្រុមប្រឹក្សាភិបាល៖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា

ជនជាតិជប៉ុន កើតក្នុងឆ្នាំ១៩៧៣។ លោកបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែតុលា ឆ្នាំ២០១៩។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រពីសាកលវិទ្យាល័យតូក្យូ ថ្នាក់វិស្វករ នៅក្នុងខែមេសា ឆ្នាំ១៩៩៦។ លោកបានចាប់ផ្តើមការងារជាមួយធនាគារ Sumitomo (បច្ចុប្បន្ន Sumitomo Mitsui Banking Corporation (SMBC)) ជាភ្នាក់ងារទីផ្សារបម្រើការនៅសាខា Ikebukuro ក្នុងទីក្រុងតូក្យូ និងបន្តមកទៀតបានកាន់តំណែងជាច្រើនជាមួយធនាគារ Sumitomo ក្នុងគណៈកម្មាធិកាគ្រប់គ្រងសមតុល្យឥណទាន និងផែនការក្រុមហ៊ុន។ ក្នុងខែធ្នូ ឆ្នាំ២០១៩ លោក Mori ត្រូវបានតែងតាំងជាមន្ត្រីពិសេសទទួលបន្ទុករាយការណ៍ជូនប្រធានសមាគមធនាគារជប៉ុន ដែលគាត់ទទួលបានបទពិសោធន៍នៅក្នុងវិស័យធនាគារជប៉ុន តាមស្តង់ដារអន្តរជាតិ និងឧត្តមនុវត្តន៍។ នៅក្នុងខែមេសា ឆ្នាំ២០១៤ លោក Mori ត្រូវបានតែងតាំងជានាយកប្រតិបត្តិផែនការ និងគ្រប់គ្រងផ្នែកប្រតិបត្តិការធនាគារអន្តរជាតិ។ ក្នុងខែមេសា ឆ្នាំ២០១៦ លោកត្រូវបានតែងតាំងជាប្រធានក្រុមផែនការយុទ្ធសាស្ត្រ។ បច្ចុប្បន្ន លោកកាន់តំណែងជា អ្នកគ្រប់គ្រងទូទៅរួមនៃការិយាល័យផែនការ ក្នុងនាយកដ្ឋានប្រចាំអាស៊ីបាស៊ីហ្វិក របស់ SMBC។

### លោក STÉPHANE MANGIAVACCA, អភិបាល

ជនជាតិបារាំង។ លោក Stéphane MANGIAVACCA បានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែមីនាឆ្នាំ ២០២០។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រពីសាលា ECOLE NATIONALE SUPERIEURE DES MINES DE SAINT-ETIENNE ជំនាញវិស្វកម្ម និងបានសិក្សានៅ University of New Brunswick ក្នុងប្រទេសកាណាដា។ លោកបានចាប់ផ្តើមការងារក្នុងក្រសួងហិរញ្ញវត្ថុបារាំង ដែលទីកន្លែងបម្រើការងាររបស់លោកនៅក្នុងប្រទេសចិន។ បន្ទាប់មកលោកបានចូលរួមជាមួយសវនកម្មផ្ទៃក្នុងនៃក្រុម BPCE ដែលលោកបានក្លាយជានាយកជាន់ខ្ពស់នៃ Quantitative Audit។ ឥឡូវលោកបម្រើការឲ្យក្រុមហ៊ុន BRED Banque Populaire មានតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាលប្រតិបត្តិ និងជាប្រធានក្រុមអន្តរជាតិ ហើយគាត់ក៏ជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារបារាំងជាច្រើន ដែលគ្រប់គ្រងដោយក្រុម BRED។

### លោកស្រី MIRJAM JANSSEN, អភិបាល

ជនជាតិហុល្លង់ដ៍ កើតក្នុងខែធ្នូ ឆ្នាំ១៩៧០។ លោកស្រី Mirjam បានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលនៅខែមករា ឆ្នាំ២០២០។ លោកស្រីទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែក ការសិក្សាទំនាក់ទំនងអាជីវកម្ម ពីសាកលវិទ្យាល័យ Nijmegen ក្នុងប្រទេសហុល្លង់ដ៍។ បច្ចុប្បន្ន លោកស្រីធ្វើជាសមាជិកក្រុមប្រឹក្សាភិបាលនៅក្នុង ស្ថាប័នមីក្រូហិរញ្ញវត្ថុមីយ៉ាន់ម៉ា Early Dawn ព្រមទាំងធ្វើជានាយិកាគ្រប់គ្រងប្រចាំតំបន់អាស៊ី របស់ Triodos Investment Management។

## ៣. ករណីអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ឬសហកម្មសិទ្ធិកររបស់ក្រុមហ៊ុនផ្សេងទៀត

| ល រ | ឈ្មោះ | ក្រុមហ៊ុន | អភិបាល ជាភាគហ៊ុនិក ឬសហកម្មសិទ្ធិករ |
|---|---|---|---|
| ១ | លោក ឆាយ សឿន | គ្មាន | គ្មាន |
| ២ | បណ្ឌិត អ៊ិន ចាន់នី | អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់<br>Entrepreneurship Development Fund (EDF)<br>សមាគមធនាគារនៅកម្ពុជា | ប្រធានក្រុមប្រឹក្សាភិបាល<br>អភិបាល<br>ប្រធានក្រុមប្រឹក្សា |
| ៣ | លោក រ័ត្ន យូម៉េង | គ្មាន | គ្មាន |
| ៤ | លោក Pieter Kooi | Alter Modus MFI (Montenegro) | អភិបាលឯករាជ្យ |
| ៥ | លោក Ian Samuel Lydall | AIA Vietnam<br>AAA Corporation | អភិបាល<br>អភិបាល |
| ៦ | លោក Kenichiro Mori | គ្មាន | គ្មាន |
| ៧ | លោកស្រី Mirjam Janssen | Early Dawn Microfinance Co. Ltd (Myanmar)<br>Dawn Myanmar Microfinance Pte. Ltd. (Singapore) | អភិបាល<br>អភិបាល |

| ល រ | ឈ្មោះ | ក្រុមហ៊ុន | អភិបាល ជាភាគហ៊ុនិក ឬសហកម្មសិទ្ធិករ |
|---|---|---|---|
| ៨ | លោក Stéphane MANGIAVACCA | BRED IT | អភិបាល |
| | | BRD LAOS LTD | អភិបាល |
| | | BIC BRED SUISSE SA | អភិបាល |
| | | BRED VANUATU | អភិបាល |
| | | COFIBRED | អភិបាល |
| | | BRD CHONGQING | អភិបាល |
| | | BANQUE FRANCO LAO | ប្រធានក្រុមប្រឹក្សាភិបាល |
| | | BIC BRED | អគ្គនាយក (CEO) |
| | | BCI MER ROUGE | ប្រធានក្រុមប្រឹក្សាភិបាល |
| | | BRED BANK FIJI LIMITED | អភិបាល |
| | | BCEL | អភិបាល |
| | | FONCIERE DU VANUATU | អភិបាល |
| | | SOCREDO | អភិបាល |
| | | BCI NC | អភិបាល |
| | | SPIG | អភិបាល |
| | | Alumni Association of Mines Saint-Etienne | អភិបាល |
| | | SA HLM Residence L.A. Beaunier | ប្រធានក្រុមប្រឹក្សាភិបាល |
| ៩ | លោក វ៉ាន់ ស៊ូអៀង | GMAC | អភិបាល |
| | | CAMFEBA | អភិបាល |
| | | Plantation group of Co | អភិបាល |
| | | Pps Co | អភិបាល |
| | | Talent Land Co | អភិបាល |
| | | CCC Co. Ltd | អភិបាល |
| | | GSM Co Ltd | អភិបាល |
| | | Asia Insuance Co Ltd | អភិបាល |
| | | Landmark Co Ltd | អភិបាល |

## ៤. តួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងការអនុវត្ត

អភិបាលត្រូវបានតែងតាំងដោយភាគហ៊ុនិក សម្រាប់អាណត្តិបំពេញការងារដែលមានរយៈពេលពាឆ្នាំ។ សមាសភាពក្រុមប្រឹក្សាភិបាលត្រូវមានចំនួន ១០ រូប និងមានតួនាទីដូចខាងក្រោម៖

- ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការកំណត់យុទ្ធសាស្ត្ររបស់ធនាគារ និងអនុវត្ត ឬគ្រប់គ្រងប្រតិបត្តិការ និងកិច្ចការអាជីវកម្ម។ គ្រប់សមាជិកប្រឹក្សាភិបាលត្រូវអនុវត្តការងារ ដើម្បីបម្រើផលប្រយោជន៍ស្របច្បាប់របស់ធនាគារ។
- អំណាចរបស់ក្រុមប្រឹក្សាភិបាលត្រូវសម្រេចតាមមតិរួម ហើយគ្មានអភិបាលណាម្នាក់មានអំណាចក្នុងការដឹកនាំមន្ត្រី ឬបុគ្គលិកណាម្នាក់របស់ធនាគារ ដើម្បីចុះហត្ថលេខាលើកិច្ចសន្យា ឬដឹកនាំប្រតិបត្តិការរបស់ធនាគារបានឡើយ លើកលែងតែអភិបាលនោះត្រូវបានផ្តល់អំណាចឲ្យអនុវត្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។
- អភិបាលនីមួយៗមានសិទ្ធិក្នុងការទទួលបានរបាយការណ៍ ឬកំណត់ត្រារបស់ធនាគារក្នុងម៉ោងបំពេញការងារ។

ក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសអភិបាល ១ រូប ក្នុងចំណោមសមាសភាពក្រុមប្រឹក្សាភិបាលដោយមានសំឡេងឆ្នោតគាំទ្រមតិភាគច្រើនពីសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ ដើម្បីធ្វើជាប្រធាន ក្រុមប្រឹក្សាភិបាល ដែលត្រូវដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ព្រមទាំងមហាសន្និបាតភាគហ៊ុនិក។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការអនុវត្តអភិបាលកិច្ចល្អ និងជំរុញនូវភាពជោគជ័យរបស់ធនាគារ តាមរយៈការដឹកនាំ និងការគ្រប់គ្រងប្រតិបត្តិការ និងកិច្ចការអាជីវកម្ម។ ក្រុមប្រឹក្សាភិបាលអាចតែងតាំង និងដកហូតតំណែង ប្រធាននាយកប្រតិបត្តិ គណៈប្រធាននាយក-នាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង និងនាយក-នាយិកាប្រតិបត្តិអនុលោមបញ្ញត្តិ។ ក្រុមប្រឹក្សាភិបាលត្រូវធានាថាមាន ធនធានមនុស្សសមស្របដើម្បីបំពេញការងារ បង្កើតយុទ្ធសាស្ត្រគ្រប់គ្រង និងគោលដៅហិរញ្ញវត្ថុ ដើម្បីដាក់ឲ្យគណៈគ្រប់គ្រងអនុវត្ត និងតាមដានការអនុវត្ត ដោយផ្ទាល់ និងប្រយោលតាមរយៈគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាល មានគណៈកម្មាធិការចំនួនពាគឺ៖ គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការតែងតាំង និងលាភការ និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា។ ក្រុមប្រឹក្សាភិបាល អាចបង្កើតគណៈកម្មាធិការផ្សេងៗទៀត តាមការចាំបាច់ ឬតម្រូវការ ដើម្បីដឹកនាំអាជីវកម្ម និងប្រតិបត្តិការរបស់ធនាគារ។ គណៈកម្មាធិការក្រុមប្រឹក្សាភិបាលទាំងនេះ ត្រូវបង្កើតឡើងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ហើយអភិបាលទាំងអស់ នៃគណៈកម្មាធិការក្រុមប្រឹក្សាភិបាលទាំងនេះនឹងត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាល។ គណៈកម្មាធិការនីមួយៗនឹងពុំមានសិទ្ធិអំណាចណាមួយលើក្រុមប្រឹក្សាភិបាលឡើយ លើកលែងតែមានការផ្ទេរសិទ្ធិអំណាចទាំងនោះជាផ្លូវការដោយក្រុមប្រឹក្សាភិបាល ក៏ប៉ុន្តែអាចផ្តល់ជាអនុសាសន៍ជូនក្រុមប្រឹក្សាភិបាល សម្រាប់វិធានការរួមរបស់ខ្លួន។ ទន្ទឹមនឹងនោះ សមាជិកភាពក្នុងគណៈកម្មាធិការក្រុមប្រឹក្សាភិបាលត្រូវបានកម្រិតចំពោះអភិបាលផ្ទាល់។ ប្រធានក្រុមប្រឹក្សាភិបាលទាំងអស់អាចអញ្ជើញសមាជិក ថ្នាក់ដឹកនាំ និងភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីផ្តល់ព័ត៌មាន និងការពន្យល់ទាក់ទងនឹងប្រតិបត្តិការនៅពេលដែលមានការចាំបាច់។ គណៈកម្មាធិការក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវមានប្រធានជាអភិបាលឯករាជ្យ។

បញ្ជីឈ្មោះពេញលេញនៃគណៈកម្មាធិការក្រុមប្រឹក្សាភិបាលដែលមាន សមាជិក និងសកម្មភាពក្នុងអំឡុងឆ្នាំ២០២០ បង្ហាញក្នុងទំព័រទី៦០-៦៥ នៃរបាយការណ៍នេះ។

## ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១ | ០៣ កុម្ភៈ ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Marc Robert<br>លោក Ryoji Nishimura<br>លោកស្រី Mirjam Janssen |
| ២ | ០៤ កុម្ភៈ ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Marc Robert<br>លោក Ryoji Nishimura<br>លោកស្រី Mirjam Janssen |
| ៣ | ០៥ កុម្ភៈ ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Marc Robert<br>លោក Ryoji Nishimura<br>លោកស្រី Mirjam Janssen |
| ៤ | ១១ កុម្ភៈ ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Marc Robert<br>លោក Ryoji Nishimura<br>លោកស្រី Mirjam Janssen |
| ៥ | ១២ កុម្ភៈ ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Marc Robert<br>លោក Ryoji Nishimura<br>លោកស្រី Mirjam Janssen |

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ៦ | ១៨ កុម្ភៈ ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក រ័ត្ន យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Marc Robert<br>លោក Ryoji Nishimura<br>លោកស្រី Mirjam Janssen |
| ៧ | ៥ & ៦ មីនា ២០២០ | កិច្ចប្រជុំផ្ទាល់ | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក Pieter Kooi<br>លោក Cornelius Obert<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Ryoji Nishimura (ចូលរួមតាមរយៈ con-call)<br>លោកស្រី Mirjam Janssen (Absent with reason)<br>លោក រ័ត្ន យូម៉េង (ប្រគល់សិទ្ធិជូន បណ្ឌិត អ៊ិន ចាន់នី) |
| ៨ | ២៣ មីនា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក រ័ត្ន យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Ryoji Nishimura<br>លោកស្រី Mirjam Janssen |
| ៩ | ២៧ មីនា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក រ័ត្ន យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Ryoji Nishimura<br>លោកស្រី Mirjam Janssen |
| ១០ | ៣១ មីនា ២០២០ | កិច្ចប្រជុំផ្ទាល់ | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក រ័ត្ន យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert (ចូលរួមតាមរយៈ con-call)<br>លោក Ian S. Lydall (ចូលរួមតាមរយៈ con-call)<br>លោក Kenichiro Mori (ចូលរួមតាមរយៈ con-call)<br>លោក Ryoji Nishimura (ចូលរួមតាមរយៈ con-call)<br>លោកស្រី Mirjam Janssen (ចូលរួមតាមរយៈ con-call) |
| ១១ | ០២ មេសា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក រ័ត្ន យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Ryoji Nishimura<br>លោកស្រី Mirjam Janssen |

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១២ | ០៧ មេសា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Ryoji Nishimura<br>លោកស្រី Mirjam Janssen |
| ១៣ | ១៨ ឧសភា ២០២០ | កិច្ចប្រជុំផ្ទាល់ | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert (ចូលរួមតាមរយៈ con-call)<br>លោក Ian S. Lydall (ចូលរួមតាមរយៈ con-call)<br>លោក Kenichiro Mori (ចូលរួមតាមរយៈ con-call)<br>លោក Ryoji Nishimura (ចូលរួមតាមរយៈ con-call)<br>លោកស្រី Mirjam Janssen (ចូលរួមតាមរយៈ con-call)<br>លោក Stéphane Mangiavacca (ចូលរួមតាមរយៈ con-call) |
| ១៤ | ២៥ ឧសភា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Ryoji Nishimura<br>លោកស្រី Mirjam Janssen<br>លោក Stéphane Mangiavacca |
| ១៥ | ២៨ ឧសភា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Ryoji Nishimura<br>លោកស្រី Mirjam Janssen<br>លោក Stéphane Mangiavacca |
| ១៦ | ០៩ មិថុនា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Cornelius Obert (ចូលរួមតាមរយៈ con-call)<br>លោក Ian S. Lydall (ចូលរួមតាមរយៈ con-call)<br>លោក Kenichiro Mori (ចូលរួមតាមរយៈ con-call)<br>លោកស្រី Mirjam Janssen (ចូលរួមតាមរយៈ con-call)<br>លោក Stéphane Mangiavacca (ចូលរួមតាមរយៈ con-call) |
| ១៨ | ០៤ សីហា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Stéphane Mangiavacca<br>លោកស្រី Mirjam Janssen |

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១៩ | ១០ សីហា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Stéphane Mangiavacca<br>លោកស្រី Mirjam Janssen |
| ២០ | ១១ សីហា-២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Stéphane Mangiavacca<br>លោកស្រី Mirjam Janssen |
| ២១ | ១៣ សីហា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Stéphane Mangiavacca<br>លោកស្រី Mirjam Janssen |
| ២២ | ០៣ កញ្ញា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Ian S. Lydall<br>លោក Kenichiro Mori<br>លោក Stéphane Mangiavacca<br>លោកស្រី Mirjam Janssen |
| ២៣ | ២៩ កញ្ញា ២០២០ | កិច្ចប្រជុំផ្ទាល់ | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោក Ian S. Lydall (ចូលរួមតាមរយៈ con-call)<br>លោក Kenichiro Mori (ចូលរួមតាមរយៈ con-call)<br>លោក Stéphane Mangiavacca (ចូលរួមតាមរយៈ con-call)<br>លោកស្រី Mirjam Janssen (ចូលរួមតាមរយៈ con-call) |
| ២៤ | ២០ តុលា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Ian S. Lydall<br>លោក វ៉ាន់ ស៊ូអៀង<br>លោក Kenichiro Mori<br>លោក Stéphane Mangiavacca<br>លោកស្រី Mirjam Janssen |
| ២៥ | ២១ តុលា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក វ័ត្ត យូម៉េង<br>លោក Pieter Kooi<br>លោក Ian S. Lydall<br>លោក វ៉ាន់ ស៊ូអៀង<br>លោក Kenichiro Mori<br>លោក Stéphane Mangiavacca<br>លោកស្រី Mirjam Janssen |

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ២៦ | ០៥ វិច្ឆិកា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក រ័ត្ន យូម៉េង<br>លោក Pieter Kooi<br>លោក Ian S. Lydall<br>លោក វ៉ាន់ ស៊ូអៀង<br>លោក Kenichiro Mori<br>លោក Stéphane Mangiavacca<br>លោកស្រី Mirjam Janssen |
| ២៧ | ១០ វិច្ឆិកា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក រ័ត្ន យូម៉េង<br>លោក Pieter Kooi<br>លោក Ian S. Lydall<br>លោក វ៉ាន់ ស៊ូអៀង<br>លោក Kenichiro Mori<br>លោក Stéphane Mangiavacca<br>លោកស្រី Mirjam Janssen |
| ២៨ | ១១ វិច្ឆិកា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក រ័ត្ន យូម៉េង<br>លោក Pieter Kooi<br>លោក Ian S. Lydall<br>លោក វ៉ាន់ ស៊ូអៀង<br>លោក Kenichiro Mori<br>លោក Stéphane Mangiavacca<br>លោកស្រី Mirjam Janssen |
| ២៩ | ១៦ វិច្ឆិកា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក រ័ត្ន យូម៉េង<br>លោក Pieter Kooi<br>លោក Ian S. Lydall<br>លោក វ៉ាន់ ស៊ូអៀង<br>លោក Kenichiro Mori<br>លោក Stéphane Mangiavacca<br>លោកស្រី Mirjam Janssen |
| ៣០ | ១៨ វិច្ឆិកា ២០២០ | កិច្ចប្រជុំពិសេសតាមអ៊ីម៉ែល | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក រ័ត្ន យូម៉េង<br>លោក Pieter Kooi<br>លោក Ian S. Lydall<br>លោក វ៉ាន់ ស៊ូអៀង<br>លោក Kenichiro Mori<br>លោក Stéphane Mangiavacca<br>លោកស្រី Mirjam Janssen |
| ៣១ | ១៦ ធ្នូ ២០២០ | កិច្ចប្រជុំផ្ទាល់ | លោក ឆាយ សឿន<br>បណ្ឌិត អ៊ិន ចាន់នី<br>លោក រ័ត្ន យូម៉េង<br>លោក Pieter Kooi<br>លោក វ៉ាន់ ស៊ូអៀង<br>លោក Ian S. Lydall (ចូលរួមតាមរយៈ con-call)<br>លោក Kenichiro Mori (ចូលរួមតាមរយៈ con-call)<br>លោក Stéphane Mangiavacca (ចូលរួមតាមរយៈ con-call)<br>លោកស្រី Mirjam Janssen (ចូលរួមតាមរយៈ con-call) |

# ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

## ១. រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ១.១ គណៈកម្មាធិកាសវនកម្ម

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក Ian S. Lydall | ប្រធាន | ២៦ មិថុនា ២០១៩ | ២២ | ២២ |
| ២ | លោក Pieter Kooi | សមាជិក | ២៦ មិថុនា ២០១៩ | ២២ | ២២ |
| ៣ | លោក ឆាយ សឿន | សមាជិក | ២៦ មិថុនា ២០១៩ | ២២ | ២២ |

### តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម

តួនាទីរបស់គណៈកម្មាធិការនេះមានដូចជា៖

i. ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលចំពោះការអនុម័តការជ្រើសរើស ការជ្រើសរើសបន្ត និងការបញ្ឈប់ ព្រមទាំងលាភការផ្សេងៗ និងកិច្ចព្រមព្រៀងជាមួយសវនករខាងក្រៅ ដែលនឹងត្រូវបានអនុម័តដោយភាគហ៊ុនិករបស់ធនាគារ។

ii. ត្រួតពិនិត្យ និងតាមដានឯករាជ្យភាពរបស់សវនករខាងក្រៅ និងវត្ថុបំណង ព្រមទាំងប្រសិទ្ធភាពនៃដំណើរការសវនកម្ម ដោយពិចារណាលើតម្រូវការជំនាញ និងបទប្បញ្ញត្តិពាក់ព័ន្ធ និងវាយតម្លៃលើគុណភាពសេវាកម្មដែលបានផ្តល់ដោយសវនករខាងក្រៅ។

iii. ពិភាក្សា និងពិនិត្យលើបញ្ហានានាដែលលើកឡើងនៅក្នុងលិខិតគ្រប់គ្រងរបស់សវនករខាងក្រៅ និងការឆ្លើយតបរបស់គណៈគ្រប់គ្រង។

iv. អភិវឌ្ឍ និងអនុវត្តគោលការណ៍ ស្តីពីការផ្តល់សេវារបស់សវនករខាងក្រៅ ក្នុងការផ្គត់ផ្គង់សេវាកម្មមិនមែនសវនកម្ម ព្រមទាំងពិចារណាលើគោលការណ៍ណែនាំក្រមសីលធម៌ពាក់ព័ន្ធនឹងការផ្តល់សេវាមិនមែនសវនកម្មដោយសវនករខាងក្រៅ និងរាយការណ៍ទៅក្រុមប្រឹក្សាភិបាល ដោយកំណត់បញ្ហាណាមួយដែលគណៈកម្មាធិការពិចារណាឃើញថា សកម្មភាពនោះ ឬការធ្វើឲ្យប្រសើរឡើងណាមួយនោះចាំបាច់ រួចផ្តល់អនុសាសន៍ជាជំហ៊ានៗដើម្បីអនុវត្ត។

v. ត្រួតពិនិត្យ និងតាមដានដំណើរការគ្រប់គ្រងក្នុងការអភិវឌ្ឍ និងការផ្លាស់ប្តូរការប៉ាន់ប្រមាណគណនេយ្យ និងគោលការណ៍គណនេយ្យ ដើម្បីធានាថាការវិនិច្ឆ័យដែលបានកំណត់ ការកត់សម្គាល់ចំពោះការប៉ាន់ប្រមាណនូវចំនួនទឹកប្រាក់ និងប្រតិបត្តិការមិនប្រក្រតីឲ្យសមរម្យ និងសមហេតុផល។

vi. ធានាថាព័ត៌មានទាក់ទងនឹងហិរញ្ញវត្ថុ និងហានិភ័យ មានភាពច្បាស់លាស់ ហើយការវាយតម្លៃពាក់ព័ន្ធទៅនឹងវិធីសាស្រ្តវាយតម្លៃ និងគណនេយ្យ ដែលបានប្រើប្រាស់សម្រាប់ការបង្កើតជាលក្ខណៈបុគ្គល និងនៅកន្លែងណា ដែលអាចអនុវត្តបាននូវគណនេយ្យ និងហិរញ្ញវត្ថុរួមបញ្ចូលរួមគ្នា។ វាយតម្លៃពាក់ព័ន្ធទៅនឹងវិធីសាស្រ្តគណនេយ្យដែលត្រូវបានប្រើប្រាស់ ដើម្បីរៀបចំជាគណនីបុគ្គល និងគណនីរួម ប្រសិនបើមាន។

vii. ធានាថាព័ត៌មានដែលផ្តល់ឲ្យសាធារណជន និងធនាគារជាតិ នៃ កម្ពុជា មានភាពច្បាស់លាស់ ត្រឹមត្រូវ និងទុកចិត្តបាន។

viii. វាយតម្លៃគុណភាពនីតិវិធីត្រួតពិនិត្យផ្ទៃក្នុង ជាពិសេសចំណុចដែលប្រព័ន្ធវាស់វែង និងត្រួតពិនិត្យហានិភ័យ មានភាពស្របគ្នា និងផ្តល់អនុសាសន៍ សម្រាប់សកម្មភាពបន្តទៀត នូវចំណុចណាដែលសមស្រប។

ix. ត្រួតពិនិត្យនូវប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យហិរញ្ញវត្ថុផ្ទៃក្នុងរបស់ធនាគារ និងធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ។

x. ត្រួតពិនិត្យ និងតាមដានប្រសិទ្ធភាព នៃមុខងារសវនកម្មផ្ទៃក្នុង និងធានាថាដំណើរការនៃការធ្វើរបាយការណ៍ មានលក្ខណៈគ្រប់គ្រាន់ និងទាន់ពេលវេលា។

xi. អនុម័ត (និងធ្វើវិសោធនកម្មតាមការចាំបាច់ អំឡុងឆ្នាំដែលកំពុងអនុវត្ត) ផែនការសវនកម្មផ្ទៃក្នុង។

xii. ត្រួតពិនិត្យ និងផ្តល់អនុសាសន៍ដល់ គណៈកម្មាធិការតែងតាំង និងលាភការ ក្នុងការតែងតាំង និងការដកហូតគណៈប្រធាននាយក-នាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង ដែលត្រូវទទួលបានការអនុម័តចុងក្រោយពីក្រុមប្រឹក្សាភិបាល។

xiii. កំណត់លក្ខខណ្ឌវិនិច្ឆ័យ និងផ្តល់អនុសាសន៍ដល់គណៈកម្មាធិការតែងតាំង និងលាភការ លើការលើកទឹកចិត្តប្រចាំឆ្នាំដល់គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង បន្ទាប់មក គណៈកម្មាធិការតែងតាំង និងលាភការ សម្រេចហើយបញ្ជូនទៅក្រុមប្រឹក្សាភិបាលសម្រាប់ធ្វើការអនុម័តចុងក្រោយ។

xiv. ស្នើសុំនូវប្រាក់លើកទឹកចិត្តប្រចាំឆ្នាំ សម្រាប់គណៈប្រធាននាយិកាប្រតិបត្តិសវនករផ្ទៃក្នុង ព្រមទាំងផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលអនុម័ត។

xv. វាយតម្លៃ និងធ្វើចំណាត់ថ្នាក់លទ្ធផលការងារប្រចាំឆ្នាំ សម្រាប់គណៈប្រធាននាយក-នាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល សម្រាប់ការអនុម័តចុងក្រោយ។ បន្ទាប់មកជូនដំណឹងដល់ប្រធាននាយកប្រតិបត្តិ ដើម្បីធ្វើការទូទាត់ទឹកប្រាក់តាមចំណាត់ថ្នាក់លទ្ធផលការងារ និងរង្វាន់លើកទឹកចិត្ត។

xvi. តាមដានការអនុវត្តសកម្មភាពដែលកែតម្រូវប្រកបដោយប្រសិទ្ធភាព ជាពិសេសដោយធ្វើការតាមដានលើអនុសាសន៍ដែលមិនទាន់សម្រេច និងអនុសាសន៍ដែលចេញដោយសវនករផ្ទៃក្នុង និងការគាំទ្របន្ថែមលើការងាររបស់សវនកម្មផ្ទៃក្នុង។

xvii. ពិចារណាលើប្រធានបទផ្សេងៗទៀត តាមការស្នើសុំពីក្រុមប្រឹក្សាភិបាល។

### លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម

- បានត្រួតពិនិត្យ អនុម័ត និងស្នើក្រុមប្រឹក្សាភិបាលសម្រាប់ការអនុម័តចុងក្រោយលើរបាយការណ៍សវនកម្មហិរញ្ញវត្ថុឆ្នាំ២០១៩។
- បានត្រួតពិនិត្យ និងតាមដានដំណើរការការអនុវត្ត និងការអភិវឌ្ឍស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) របស់ថ្នាក់គ្រប់គ្រង។
- បានត្រួតពិនិត្យ និងអនុម័តរបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងឆ្នាំ២០១៩ ដើម្បីដាក់ជូនធនាគារជាតិ នៃ កម្ពុជា។
- បានត្រួតពិនិត្យរបាយការណ៍សវនកម្មផ្ទៃក្នុង និងការវិភាគនិន្នាការ ឬហេតុការណ៍នានាប្រចាំឆ្នាំ។
- បានត្រួតពិនិត្យ និងអនុម័តតួនាទីភារកិច្ចរបស់គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង។
- បានត្រួតពិនិត្យ និងអនុម័តលើផែនការប្រាក់រង្វាន់លើកទឹកចិត្តជូនគណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង និងលើកសំណើជូនក្រុមប្រឹក្សាភិបាលសម្រាប់ការអនុម័តចុងក្រោយ។
- បានត្រួតពិនិត្យ និងអនុម័តលើផែនការសវនកម្មផ្ទៃក្នុងសម្រាប់ឆ្នាំសារពើពន្ធ២០២១។
- បានត្រួតពិនិត្យ និងអនុម័តលើតួនាទីភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម និងផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលសម្រាប់ការអនុម័តចុងក្រោយ។
- បានពិភាក្សា និងជ្រើសរើសក្រុមហ៊ុនសវនកម្មដើម្បីជាសវនករខាងក្រៅរបស់ធនាគារប្រចាំឆ្នាំ២០២១។
- បានត្រួតពិនិត្យគោលការណ៍ផ្សេងៗ៖ គោលការណ៍សវនកម្ម គោលការណ៍ភាគលាភ គោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង និងគោលការណ៍បង្ហាញព័ត៌មានសាជីវកម្ម។
- បានត្រួតពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២០ សម្រាប់ខែមីនា មិថុនា និងកញ្ញា និងលើកសំណើជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយ។

## ១.២ គណៈកម្មាធិការតែងតាំង និងលាភការ

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក វ៉ាន់ ស៊ូអៀង | ប្រធាន | ២៩ កញ្ញា ២០២០ | ០២ | ០៥ |
| ២ | លោក Pieter Kooi | សមាជិក | ២៩ កញ្ញា ២០២០ | ០៥ | ០៥ |
| ៣ | លោក Ian S. Lydall | សមាជិក | ២៦ មិថុនា ២០១៩ | ០៥ | ០៥ |

### តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការតែងតាំង និងលាភការ

ក្នុងការបំពេញតួនាទីរបស់ខ្លួន គណៈកម្មាធិការតែងតាំង និងលាភការរក្សាទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធភាពជាមួយក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ដោយមិនធ្វើការជ្រៀតជ្រែកក្នុងការសម្រេចចិត្តទាក់ទងនឹងដំណើរការអាជីវកម្មណាមួយនោះទេ។

ការទទួលខុសត្រូវរបស់គណៈកម្មាធិការ គឺត្រូវធានាថាគោលការណ៍លាភការ ស្របគ្នាជាមួយនឹងកម្មវត្ថុ និងគុណតម្លៃរយៈពេលវែងរបស់ធនាគារ និងសមស្របទៅនឹងប្រាក់បំណាច់ សម្រាប់មុខងារប្រហាក់ប្រហែលនៅក្នុងក្រុមហ៊ុនផ្សេងទៀត និងកត្តាពាក់ព័ន្ធផ្សេងទៀតដែលទាក់ទងនឹងផលប្រយោជន៍របស់ម្ចាស់ភាគហ៊ុនិក និងតម្រូវការអាជីវកម្ម និងហិរញ្ញវត្ថុ របស់ធនាគារ។

តួនាទីរបស់គណៈកម្មាធិការនេះមានដូចតទៅ៖

#### ប្រាក់បំណាច់របស់ក្រុមប្រឹក្សាភិបាល

i. ផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលនូវគោលការណ៍ផ្លូវការនិងមានតម្លាភាពដើម្បីកំណត់ប្រាក់កម្រៃនិងការចំណាយជូនក្រុមប្រឹក្សាភិបាលដោយរួមបញ្ចូលទាំងសមាជិកភាពរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាល និងសកម្មភាពផ្សេងទៀត ទាក់ទងនឹងក្រុមប្រឹក្សាភិបាល ដែលបម្រើការឲ្យធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។ អនុសាសន៍ ត្រូវបានធ្វើឡើងដោយពិគ្រោះយោបល់ជាមួយប្រធានក្រុមប្រឹក្សាភិបាល និងស្នើសុំការយល់ព្រមពីក្រុមប្រឹក្សាភិបាលទាំងមូល។

ii. ពិនិត្យនូវសំណើដែលបានដាក់ជូនដោយប្រធាននាយកប្រតិបត្តិ សម្រាប់ជាការពិភាក្សាបន្ថែមរបស់ក្រុមប្រឹក្សាភិបាលដូចជា៖ តួនាទីក្នុងការផ្តល់យោបល់ ឬពិគ្រោះយោបល់ដោយរួមបញ្ចូលទាំង លក្ខខណ្ឌ និងការផ្តល់អនុសាសន៍សមស្របដល់ក្រុមប្រឹក្សាភិបាល ដើម្បីដាក់ស្នើទៅភាគហ៊ុនិក ធ្វើការអនុម័តចុងក្រោយ។

iii. ពិនិត្យលើគ្រប់ទិដ្ឋភាព នៃលាភការ ដោយរួមបញ្ចូលទាំង ប្រាក់កម្រៃ ប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ ការចំណាយ ថ្លៃសេវាប្រឹក្សាយោបល់ (ដែលអាចអនុវត្តបាន) និងអត្ថប្រយោជន៍ផ្សេងទៀត របស់ក្រុមប្រឹក្សាភិបាល។

iv. ផ្តល់អនុសាសន៍ អំពីលាភការរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ តាមរយៈ ក្រុមប្រឹក្សាភិបាល ដែលនឹងត្រូវធ្វើការសម្រេចនៅក្នុងមហាសន្និបាតប្រចាំឆ្នាំ។

#### ចំពោះលាភការរបស់គណៈគ្រប់គ្រងជាន់ខ្ពស់

i. ទទួលខុសត្រូវលើការពិនិត្យឡើងវិញ និងកំណត់ក្របខ័ណ្ឌលាភការ សម្រាប់គណៈប្រធាននាយក-នាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង (GCIAO) និងនាយក-នាយិកាប្រតិបត្តិអនុលោមបញ្ញត្តិ។

ii. ត្រូវទទួលខុសត្រូវលើការផ្តល់អនុសាសន៍ឲ្យក្រុមប្រឹក្សាភិបាល នូវក្របខ័ណ្ឌកញ្ចប់លាភការ និងលាភការជាក់លាក់ សម្រាប់ប្រធាននាយកប្រតិបត្តិ។ ការផ្តល់អនុសាសន៍ត្រូវដាក់ជូន ដើម្បីសុំការយល់ព្រមពីក្រុមប្រឹក្សាភិបាល។

iii. ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលនូវគោលដៅការងារ និងផែនការលើកទឹកចិត្ត ដោយរួមបញ្ចូលទាំងបុព្វលាភ និងផែនការផ្សេងៗទៀតដែលត្រូវបានរៀបចំឡើង ដើម្បីលើកទឹកចិត្តដល់ការចូលរួមចំណែកក្នុងការបង្កើតគុណតម្លៃរយៈពេលវែងដល់ក្រុមហ៊ុន សម្រាប់ប្រធាននាយកប្រតិបត្តិសម្រាប់ឆ្នាំបន្ទាប់។

iv. ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលនូវគោលដៅការងារ និងផែនការប្រាក់លើកទឹកចិត្ត ដោយរួមបញ្ចូលទាំងបុព្វលាភ និងផែនការផ្សេងៗទៀត ដែលត្រូវបានរៀបចំឡើង

ដើម្បីលើកទឹកចិត្តដល់ការចូលរួមចំណែកក្នុងការបង្កើតគុណតម្លៃរយៈពេលវែងដល់ក្រុមហ៊ុន ដល់គណៈប្រធាននាយក-នាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង និងនាយកប្រតិបត្តិអនុលោមបញ្ញត្តិសម្រាប់ឆ្នាំបន្ទាប់។

v. ពិគ្រោះយោបល់ជាមួយសមាជិកក្រុមប្រឹក្សាភិបាលផ្សេងទៀត ក្នុងការវាយតម្លៃលើការបំពេញការងារ និងសមិទ្ធផលរបស់ប្រធាននាយកប្រតិបត្តិ កាលពីឆ្នាំកន្លងមក និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលលើការផ្តល់ប្រាក់រង្វាន់ ការដំឡើងប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងទៀត។

vi. ពិនិត្យលើភាពពេញលេញ និងទម្រង់នៃប្រាក់បំណាច់ ដល់គណៈគ្រប់គ្រងប្រតិបត្តិសំខាន់ៗ ដើម្បីធានាថាប្រាក់បំណាច់នោះសមស្របជាក់ស្តែងទៅនឹងការទទួលខុសត្រូវ និងហានិភ័យពាក់ព័ន្ធទៅនឹងប្រសិទ្ធភាពរបស់សមាជិកនៃគណៈគ្រប់គ្រង។

vii. ពិនិត្យគ្រប់រាល់ទិដ្ឋភាពលាភការ ដោយរួមបញ្ចូលទាំង ប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ សោធននិវត្តន៍ បុព្វលាភ ជម្រើសផ្សេងៗ និងអត្ថប្រយោជន៍មិនមែនជាហិរញ្ញវត្ថុផ្សេងទៀត និង

viii. ពិនិត្យលើប្រាក់ឈ្នួល និងលក្ខខណ្ឌការងារ នៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនដែលមានទំហំប្រហាក់ប្រហែលគ្នា ដើម្បីធានាថាគណៈគ្រប់គ្រងប្រតិបត្តិសំខាន់ៗ គឺទទួលបានប្រាក់បំណាច់សមស្រប។

### សោធននិវត្តន៍ និងអត្ថប្រយោជន៍ដែលទទួលបានពីការចូលនិវត្តន៍

i. ពិនិត្យផែនការសោធននិវត្តន៍របស់និយោជិត និងអត្ថប្រយោជន៍ដែលទទួលបានពីការចូលនិវត្តន៍ ដែលត្រូវបានដាក់ជូនដោយគណៈគ្រប់គ្រង។

ii. ក្នុងករណីចាំបាច់ ត្រូវមានជំនាញការច្បាស់លាស់ ដើម្បីធានាថា យថាភាពហិរញ្ញវត្ថុរយៈពេលវែងរបស់ធនាគារ អាចព្យាករ និងវាស់វែងបាន ដោយសមហេតុផល។

iii. ផ្តល់អនុសាសន៍លើផែនការ និងការធ្វើវិសោធនកម្មនាពេលអនាគតជូន ក្រុមប្រឹក្សាភិបាល។

iv. ពិនិត្យ និងអនុម័តលើរបាយការណ៍សវនកម្ម ដែលរៀបចំដោយសវនករ ពាក់ព័ន្ធនឹងផែនការសោធននិវត្តន៍ និងអត្ថប្រយោជន៍ពីការចូលនិវត្តន៍ និង

v. ពិនិត្យថា ច្បាប់ និងបញ្ញត្តិ ដែលពាក់ព័ន្ធ ត្រូវបានគោរព។

### ការជ្រើសតាំង

i. យកចិត្តទុកដាក់លើតុល្យភាព និងប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាភិបាល និងតម្រូវការ នៃច្បាប់ និងបទប្បញ្ញត្តិ កំណត់អត្តសញ្ញាណ វាយតម្លៃ និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលនូវបេក្ខភាពអភិបាលដែលសាកសម ដោយពិចារណាទៅលើចរិតលក្ខណៈផ្ទាល់ខ្លួន សុចរិតភាព បទពិសោធន៍ និងចំណេះដឹងដែលពាក់ព័ន្ធ និងឯករាជ្យភាព។

ii. ដោយមានការតម្រូវពីក្រុមប្រឹក្សាភិបាល គណៈកម្មាធិការនេះត្រូវរៀបចំការសម្ភាសន៍បឋម និងចម្រាញ់យកបេក្ខជន។

iii. ផ្តល់អនុសាសន៍ឲ្យបេក្ខភាព សម្រាប់តួនាទីជាប្រធាន និងសមាជិក នៃគណៈកម្មាធិការក្រុមប្រឹក្សាភិបាល។

iv. កំណត់អត្តសញ្ញាណ វាយតម្លៃ និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលនូវបេក្ខភាពជាប្រធាននាយកប្រតិបត្តិ គណៈប្រធាននាយក-នាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង និងនាយក-នាយិកាប្រតិបត្តិអនុលោមបញ្ញត្តិ។

v. ផ្តល់អនុសាសន៍ អំពីគុណវុឌ្ឍិ និងនីតិវិធីក្នុងការជ្រើសរើស និងការជំនួសសមាជិកក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់។

vi. ផ្តល់អនុសាសន៍ជូនទៅក្រុមប្រឹក្សាភិបាលលើការតែងតាំងប្រធាននាយកប្រតិបត្តិ គណៈប្រធាននាយក-នាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង និងនាយក-នាយិកាប្រតិបត្តិអនុលោមបញ្ញត្តិ។

### តួនាទីផ្សេងៗទៀត

i. ពិនិត្យ និងណែនាំពីការវាយតម្លៃ អំពីប្រសិទ្ធភាព នៃក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការក្រុមប្រឹក្សាភិបាល យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។

ii. ពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើគោលការណ៍អភិបាលកិច្ចសាជីវកម្ម យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ដើម្បីស្នើសុំការអនុម័តពីក្រុមប្រឹក្សាភិបាល។

iii. បញ្ហាផ្សេងៗទៀតស្របនឹងលក្ខខណ្ឌយោង ដែលក្រុមប្រឹក្សាភិបាលអាចស្នើសុំប្រកបដោយហេតុផលត្រឹមត្រូវ។

## លទ្ធផលការងាររបស់គណៈកម្មាធិការតែងតាំង និងលាភការ

គណៈកម្មាធិការតែងតែង និងលាភការ បានប្រជុំចំនួន៥ដងក្នុងឆ្នាំ២០២០ នៅខែមីនា មិថុនា កញ្ញា តុលា និងធ្នូ ដោយបានពិភាក្សា ត្រួតពិនិត្យ និងអនុម័តលើចំណុចសំខាន់ៗដូចខាងក្រោម៖

- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តក្នុងការបង្កើនប្រាក់បៀវត្សជូនប្រធានក្រុមប្រឹក្សាភិបាល និងការបង្កើនប្រាក់បៀវត្សជូនប្រធាននាយកប្រតិបត្តិ។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តប្រាក់រង្វាន់លើកទឹកចិត្តប្រចាំឆ្នាំជូនថ្នាក់គ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តលក្ខខណ្ឌផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តឆ្នាំ២០២០ជូនថ្នាក់គ្រប់គ្រងជាន់ខ្ពស់។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តលើគោលការណ៍បោះឆ្នោត សម្រាប់មហាសន្និបាតភាគហ៊ុនិក។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តលើគោលការណ៍អភិបាលកិច្ចសាជីវកម្ម។
- បានសម្ភាសបេក្ខជនអភិបាលឯករាជ្យ និងផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័ត។
- បានស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តលើអភិបាលថ្មីមកពី ORIX។
- បានត្រួតពិនិត្យការធ្វើបច្ចុប្បន្នភាពលើផែនការស្នងតំណែង សម្រាប់តួនាទីជាន់ខ្ពស់ក្នុងធនាគារ អេស៊ីលីដា និងបុត្រសម្ព័ន្ធ។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តក្នុងការធ្វើវិសោធនកម្មលើលក្ខខណ្ឌយោងរបស់គណៈកម្មាធិការតែងតាំង និងលាភការ និងគោលការណ៍ស្តីពីការតែងតាំង និងលាភការ។

- បានត្រួតពិនិត្យផែនការសមាសភាពក្រុមប្រឹក្សាភិបាល សម្រាប់ឆ្នាំ២០២០។
- បានស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយលើអត្រាអតិផរណាប្រចាំឆ្នាំ២០១៩ សម្រាប់ចំណាយជូនកម្មករនិយោជិតរបស់ធនាគារចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១។
- បានពិភាក្សា និងរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីលទ្ធផលស្វ័យវាយតម្លៃប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាលសម្រាប់ឆ្នាំ២០១៩។
- បានត្រួតពិនិត្យ និងផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាល អំពីសំណើរបស់ប្រធាននាយកប្រតិបត្តិ។
- បានត្រួតពិនិត្យ និងស្នើផែនការសោធននិវត្តន៍ និងអត្ថប្រយោជន៍ចូលនិវត្តន៍របស់កម្មករនិយោជិត ជូនក្រុប្រឹក្សាភិបាល ដើម្បីអនុម័ត។
- បានត្រួតពិនិត្យកម្រិតចំណាយប្រចាំឆ្នាំជាក់ស្តែងលើកម្មករនិយោជិត និងបានត្រួតពិនិត្យសំណើរបស់ថ្នាក់គ្រប់គ្រង សម្រាប់ចំណាយលើកម្មករនិយោជិត នៅក្នុងផែនការដែលបានស្នើឡើង សម្រាប់ឆ្នាំបន្ទាប់។
- បានរៀបចំ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីពិចារណា និងអនុម័តគោលការណ៍ណែនាំ សម្រាប់បង្កើនកម្រៃសេវាជូនក្រុមប្រឹក្សាភិបាល។
- បានត្រួតពិនិត្យលក្ខខណ្ឌលទ្ធផលការងាររបស់ប្រធាននាយកប្រតិបត្តិ គណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង និងនាយកប្រតិបត្តិអនុលោមបញ្ញតិសម្រាប់ឆ្នាំ២០២១។
- បានត្រួតពិនិត្យប្រចាំឆ្នាំនូវគោលការណ៍។
- បានធ្វើស្វ័យវាយតម្លៃប្រចាំឆ្នាំរបស់គណៈកម្មាធិការតែងតាំង និងលាភការ។
- បានត្រួតពិនិត្យទម្រង់ស្វ័យវាយតម្លៃប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល។

## ១.៣ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា

| ល រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក Pieter Kooi | ប្រធាន | ២៩ កញ្ញា ២០២០ | ១២ | ១២ |
| ២ | លោក Kenichiro Mori | សមាជិក | ២៩ កញ្ញា ២០២០ | ១២ | ១២ |
| ៣ | លោក Ian S. Lydall | សមាជិក | ២៩ កញ្ញា ២០២០ | ១២ | ១២ |

### តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា

គណៈកម្មាធិការនេះ មានតួនាទីដូចខាងក្រោម៖

### ការគ្រប់គ្រងហានិភ័យ

i. ត្រួតពិនិត្យ និងលើកកម្ពស់ការគ្រប់គ្រងហានិភ័យ និងអភិបាលកិច្ចហានិភ័យរបស់ធនាគារ រួមទាំងសម្របសម្រួលការអភិវឌ្ឍនៃព័ត៌មានវិទ្យា ទាក់ទងនឹងជំនាញការគ្រប់គ្រងហានិភ័យសហគ្រាស។ ដើម្បីបំពេញនូវកិច្ចការនេះ គណៈកម្មាធិការត្រូវធ្វើការត្រួតពិនិត្យប្រចាំឆ្នាំនូវភាពពេញលេញ នៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ដែលកំណត់នូវគោលការណ៍កម្រិតខ្ពស់របស់ធនាគារ រួមមាន ការកំណត់អត្តសញ្ញាណហានិភ័យ ការវាយតម្លៃហានិភ័យ ការកាត់ន្ថយហានិភ័យ ការតាមដាន ការរាយការណ៍ ការបែងចែកសិទ្ធិអំណាច និងការទទួលខុសត្រូវការគ្រប់គ្រងហានិភ័យ នៅទូទាំងធនាគារ។

ii. តាមដានជាប្រចាំនូវការអនុវត្តគោលការណ៍គ្រប់គ្រងហានិភ័យ ដែលបានអនុម័ត ដោយក្រុមប្រឹក្សាភិបាល យ៉ាងហោចណាស់ពិនិត្យឡើងវិញ ក្នុងមួយឆ្នាំម្តង និងផ្តល់អនុសាសន៍លើការផ្លាស់ប្តូរណា ដែលគណៈកម្មាធិការពិចារណាឃើញថាចាំបាច់ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័តចុងក្រោយ។

iii. តាមដានថាគោលការណ៍ឥណទាន បានធ្វើបច្ចុប្បន្នភាពសាកសមទៅនឹងអាជីវកម្ម និងស្របជាមួយនឹងការអនុវត្តក្នុងការផ្តល់ប្រាក់កម្ចី និងពិនិត្យឡើងវិញនូវរាល់ការធ្វើវិសោធនកម្មលើគោលការណ៍ទាំងនោះ។

iv. ផ្តល់យោបល់ទៅលើសំណើរបស់គណៈគ្រប់គ្រង ពាក់ព័ន្ធទៅនឹង វិសអាប់តែថាយ (risk appetite) និង វិសថលើរែន (risk tolerance) និងកម្រិតកំណត់ផ្ទៃក្នុង។ សំណើចុងក្រោយត្រូវបានយល់ព្រម ដោយគណៈកម្មាធិការសម្រាប់ការអនុម័តចុងក្រោយដោយក្រុមប្រឹក្សាភិបាល និងផ្តល់អនុសាសន៍លើការផ្លាស់ប្តូរដែលសមស្រប រួមមានការត្រួតពិនិត្យនៃយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងដើមទុន និងសន្ទនីយភាព ក៏ដូចជា សម្រាប់ហានិភ័យពាក់ព័ន្ធទាំងអស់របស់ធនាគារ ដូចជា ហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យប្រតិបត្តិការ និងហានិភ័យកេរ្តិ៍ឈ្មោះ។

v. ត្រួតពិនិត្យ និងអនុម័តលើការវាយតម្លៃការគ្រប់គ្រងហានិភ័យ និងផែនការរបស់ខ្លួនក្នុងការគ្រប់គ្រង ឬការកាត់បន្ថយហានិភ័យ តាមរយៈការអនុវត្តការគ្រប់គ្រងហានិភ័យដែលសមស្រប និងធានាថាហានិភ័យត្រូវបានគ្រប់គ្រងនៅក្នុងកម្រិតថលើរែន (tolerance level) របស់ធនាគារ រួមជាមួយនឹងការផ្លាស់ប្តូរប្រព័ន្ធ បរិស្ថាន និងស្ថានភាពប្រតិបត្តិការ ដែលអាចមានផលប៉ះពាល់ដល់ធនាគារ។

vi. ត្រួតពិនិត្យប្រសិទ្ធភាព នៃការអនុវត្តការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងផ្ទៃក្នុង ដើម្បីសម្រេចបាននូវការសម្ងាត់នៃទិន្នន័យ សន្តិសុខប្រព័ន្ធ ភាពជឿទុកចិត្ត ភាពធន់ និងភាពអាចទទួលបានមកវិញក្នុងធនាគារ។

vii. ត្រួតពិនិត្យប្រសិទ្ធភាព និងលទ្ធផលនៃការអនុវត្តនៃក្របខ័ណ្ឌគ្រប់គ្រងការត្អូញត្អែររបស់អតិថិជន។

viii. ត្រួតពិនិត្យ និងផ្តល់យោបល់លើការធ្វើស្ត្រេសតេស្ត និងការធ្វើវិវើសស្ត្រេសតេស្ត ដែលត្រូវបានធ្វើឡើងដោយគណៈគ្រប់គ្រង។

ix. ត្រួតពិនិត្យរបាយការណ៍គ្រប់គ្រងហានិភ័យប្រចាំត្រីមាស ដែលបានដាក់ស្នើដោយគណៈគ្រប់គ្រង។

### អនុលោមភាពនៃច្បាប់

i. ត្រួតពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ដល់គណៈកម្មាធិការតែងតែង និងលាភការ ក្នុងការតែងតាំង និងការដកចេញនូវនាយក-នាយិកាប្រតិបត្តិអនុលោមបញ្ញត្តិ ដើម្បីបន្តស្នើជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយ។
ii. ក. កំណត់លក្ខណៈវិនិច្ឆ័យលើប្រាក់លើកទឹកចិត្តប្រចាំឆ្នាំ របស់នាយក-នាយិកាប្រតិបត្តិអនុលោមបញ្ញត្តិ និងផ្តល់អនុសាសន៍ដល់ BRENCO។ បន្ទាប់មក BRENCO ត្រួតពិនិត្យ និងស្នើជូនក្រុមប្រឹក្សាភិបាល សម្រាប់ការអនុម័តចុងក្រោយ។
ខ. ស្នើសុំប្រាក់លើកទឹកចិត្តប្រចាំឆ្នាំ របស់នាយក-នាយិកាប្រតិបត្តិអនុលោមបញ្ញត្តិ និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលសម្រាប់ការអនុម័តចុងក្រោយ។
iii. វាយតម្លៃ និងផ្តល់ចំណាត់ថ្នាក់លើការអនុវត្តការងារប្រចាំឆ្នាំរបស់នាយក-នាយិកាប្រតិបត្តិអនុលោមបញ្ញត្តិ និងផ្តល់អនុសាសន៍ទៅក្រុមប្រឹក្សាភិបាលសម្រាប់ការអនុម័តចុងក្រោយ។ បន្ទាប់មកជូនដំណឹងដល់ប្រធាននាយកប្រតិបត្តិ ដើម្បីធ្វើការទូទាត់ទឹកប្រាក់តាមចំណាត់ថ្នាក់ និងរង្វាន់លើកទឹកចិត្ត។
iv. ត្រួតពិនិត្យ និងតាមដានអនុលោមភាពនៃច្បាប់ ស្របតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលពាក់ព័ន្ធ និងបទប្បញ្ញត្តិផ្សេងៗទៀត ទាក់ទងនឹងការកាត់បន្ថយហានិភ័យផ្នែកច្បាប់។
v. ត្រួតពិនិត្យឡើងវិញ និងតាមដានប្រសិទ្ធភាព នៃការអនុវត្តការប្រឆាំងនឹងការសម្អាតប្រាក់ និងការប្រឆាំងនឹងហិរញ្ញប្បទានភេរវកម្ម រួមបញ្ចូលទាំងការត្រួតពិនិត្យគោលការណ៍ និងនីតិវិធីស្តីពី វិធានការប្រឆាំងការសម្អាតប្រាក់ ស្របជាមួយនឹងការផ្លាស់ប្តូរ និងការអភិវឌ្ឍនូវផលិតផល-សេវាកម្ម ប្រព័ន្ធបច្ចេកវិទ្យា និងគោលការណ៍ទំនាស់ផលប្រយោជន៍ ដើម្បីធានាឲ្យបានថាការអនុវត្តត្រូវបានអនុវត្តតាមបានយ៉ាងមានប្រសិទ្ធភាព។
vi. ត្រួតពិនិត្យ និងពិចារណាលើអនុលោមភាពស្របច្បាប់ និងគោលការណ៍កំណារពារនិវេទនជន និងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងផងដែរ។
vii. អនុម័ត (និងធ្វើវិសោធនកម្មតាមតម្រូវការចាំបាច់ ក្នុងអំឡុងឆ្នាំដែលកំពុងអនុវត្ត) នូវគម្រោងថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋានអនុលោមបញ្ញត្តិ។

### បច្ចេកវិទ្យាព័ត៌មាន

i. ត្រួតពិនិត្យ និងស្នើគោលការណ៍ និងនីតិវិធី ស្តីពីអភិបាលព័ត៌មានវិទ្យា ជូនក្រុមប្រឹក្សាភិបាល ដើម្បីការអនុម័តចុងក្រោយ។
ii. ធានាថាថ្នាក់គ្រប់គ្រងបានដាក់ដំណើរការនូវអភិបាលព័ត៌មានវិទ្យា ប្រកបដោយប្រសិទ្ធភាព។
iii. ធានាថាថ្នាក់គ្រប់គ្រងបានអនុវត្តដំណើរការ ដើម្បីធានាថាមុខងារព័ត៌មានវិទ្យាផ្តល់នូវតម្លៃដល់អាជីវកម្ម។
iv. ធានាថាការវិនិយោគលើបច្ចេកវិទ្យាព័ត៌មាន គឺត្រូវបង្ហាញអំពីហានិភ័យ និងអត្ថប្រយោជន៍ ហើយធានាថាមានថវិកាគ្រប់គ្រាន់។
v. បន្តអភិវឌ្ឍកម្មវិធី និងត្រួតពិនិត្យលើហានិភ័យព័ត៌មានវិទ្យាប្រកបដោយប្រសិទ្ធភាព។

## លទ្ធផលសម្រេចបានរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា

នៅខែកញ្ញា ឆ្នាំ ២០២០ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា នៃក្រុមប្រឹក្សាភិបាល ត្រូវបានរៀបចំឡើងវិញ ស្របតាមឧត្តមនុវត្តន៍ ជាលក្ខណៈអន្តរជាតិ និងដើម្បីប្រសិទ្ធភាពការងារ។ មុខងាររបស់គណៈកម្មាធិការ ត្រូវបានពង្រីក ដោយទទួលខុសត្រូវបន្ថែមលើហានិភ័យព័ត៌មានវិទ្យា ដែលពីមុនស្ថិតនៅក្រោមភារកិច្ចរបស់គណៈកម្មាធិការបច្ចេកវិទ្យាព័ត៌មាន នៃក្រុមប្រឹក្សាភិបាល ដែលត្រូវបានរំលាយ។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា នៃក្រុមប្រឹក្សាភិបាល បានជួបប្រជុំគ្នាចំនួន ១២ដង ក្នុងឆ្នាំ២០២០ ក្នុងនោះកិច្ចប្រជុំជួបគ្នាផ្ទាល់មានចំនួន ៤ដង និងតាមអ៊ីម៉ែលចំនួន ៨ដង។

- រាល់កិច្ចប្រជុំនីមួយៗ ហានិភ័យទាំងមូលត្រូវបានបង្ហាញដោយ អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធានគ្រប់គ្រងហានិភ័យ និងបានពិភាក្សាជាមួយសមាជិក និងអ្នកចូលរួម ដើម្បីធានាថា សូចនាករហានិភ័យសំខាន់ៗត្រូវបានអនុវត្តស្របទៅតាម រីសអាប់ភែថាយ រីសថលើរែន និងកម្រិតកំណត់ផ្ទៃក្នុង។
- បានវាយតម្លៃ និងបានពិភាក្សា អំពីហានិភ័យជាសារវន្ត នាពេលអនាគតរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។
- សម្រិតសម្រាំងដំណើរការវិភាគហានិភ័យឲ្យបានប្រសើរឡើងបន្ថែមទៀត និងការអនុវត្តសេណារីយ៉ូ ស្ត្រេសតេស្ត និងរីវើសស្ត្រេសតេស្ត ដែលបណ្តាលឲ្យមានការកើតឡើងនូវហានិភ័យដំណាលគ្នា រួមទាំងផលប៉ះពាល់នៃការឆ្លងរាលដាល។
- បានវាយតម្លៃការអភិវឌ្ឍសមតុល្យឥណទានទៅតាមលក្ខណៈវិនិច្ឆ័យផ្សេងៗ និងជាពិសេសទៅលើគុណភាពឥណទាន។ គណៈកម្មាធិការត្រូវធានាថាការធ្វើសំវិធានធនអនុលោមតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា។
- បានត្រួតពិនិត្យគម្រោងប្រឹក្សាយោបល់ អំពីការគ្រប់គ្រងហានិភ័យរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដោយធានាថាគម្រោងនឹងដំណើរការទាន់ពេល និងប្រកបដោយប្រសិទ្ធភាព។
- បានត្រួតពិនិត្យតាមដាន និងពិភាក្សា អំពីការរៀបចំហ្វាស៊ីលីធីឡើងវិញ បុនហិរញ្ញប្បទាន និងការលុបចោលហ្វាស៊ីលីធី។
- វិភាគពីផលប៉ះពាល់នៃសេណារីយ៉ូហានិភ័យ ដែលអាចកើតមាននៅលើតារាងតុល្យការ របាយការណ៍ចំណេញ-ខាត និងអនុបាតប្រុងប្រយ័ត្ន។
- ពិនិត្យនូវហានិភ័យដែលអាចមានផលប៉ះពាល់អវិជ្ជមាន ដល់ការប្រតិបត្តិស្តង់ដារអាជីវកម្មកម្រិតខ្ពស់ សម្រាប់សហគមន៍ និងបរិស្ថាន។
- បានពិនិត្យ និងវិភាគលើការអភិវឌ្ឍ នៃវិស័យធនាគារនៅក្នុងប្រទេសកម្ពុជា ដើម្បីវាយតម្លៃទៅលើហានិភ័យការប្រកួតប្រជែង។
- បានពិនិត្យឡើងវិញ និងពិភាក្សាលើការអភិវឌ្ឍទីផ្សារសេវាកម្មហិរញ្ញវត្ថុឌីជីថល ឥណទានអាជីវកម្មខ្នាតតូច មធ្យម និងឥណទានអចលនទ្រព្យ និងសំណង់ដែលមានកំណើនគួរឲ្យកត់សម្គាល់ ខណៈការប្រកួតប្រជែងមានការកើនឡើង។
- បានពិភាក្សា អំពីយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងព្រឹត្តិការណ៍ហានិភ័យដែលអាចកើតមាន ដើម្បីជាអត្ថប្រយោជន៍រយៈពេលវែងរបស់ធនាគារ អេស៊ីលីដា និងអតិថិជនរបស់ខ្លួន។
- បានពិនិត្យលទ្ធផលស្ត្រេសតេស្តសន្ទនីយភាព និងផែនការទុនយថាភាព សម្រាប់ឆ្នាំ២០២១ របស់ថ្នាក់គ្រប់គ្រងមុនពេល ធនាគាររាយការណ៍ ជូនធនាគារជាតិ នៃ កម្ពុជា។
- បានពិនិត្យ និងផ្តល់អនុសាសន៍លើសំណើកម្ចីមូលនិធិរបស់ធនាគារ សម្រាប់គាំទ្រដល់ប្រតិបត្តិការ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត។
- បានពិនិត្យរបាយការណ៍របស់នាយកដ្ឋានអនុលោមបញ្ញត្តិ និងបានទទួលរបាយការណ៍វិភាគ អំពីប្រតិបត្តិការសង្ស័យនានា។

- បានកំណត់លក្ខខណ្ឌលើកទឹកចិត្ត សម្រាប់នាយកដ្ឋានអនុលោមបញ្ញត្តិ ព្រមទាំងបានផ្តល់អនុសាសន៍ដល់គណៈកម្មាធិការតែងតាំង និងលាភការ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត។
- បានពិនិត្យ និងអនុម័តលើផែនការថវិការបស់នាយកដ្ឋានអនុលោមបញ្ញត្តិ សម្រាប់ឆ្នាំសារពើពន្ធ២០២០។
- បានពិនិត្យ និងអនុម័តលក្ខខណ្ឌយោងរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ព្រមទាំងបានផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ដើម្បីអនុម័ត។
- បានពិនិត្យ និងគាំទ្រគោលការណ៍ជាច្រើនដូចជា៖ គោលការណ៍គ្រប់គ្រងហានិភ័យ គោលការណ៍ឥណទាន ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព គោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង គោលការណ៍អនុលោមភាព គោលការណ៍កំណារពារនិវេទនជន គោលការណ៍ប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម គោលការណ៍ត្រួតពិនិត្យ-ស្គាល់អតិថិជន គោលការណ៍ប្រតិបត្តិការសម្ព័ន្ធញាតិ គោលការណ៍ទំនាស់ផលប្រយោជន៍ គោលការណ៍ការជួញដូរផ្ទៃក្នុង គោលការណ៍ IFRS9 Impairment គោលការណ៍ Credit Scoring គោលការណ៍សន្តិសុខព័ត៌មានវិទ្យា គោលការណ៍អភិបាលព័ត៌មានវិទ្យា។
- បានធ្វើការវាយតម្លៃខ្លួនឯងរៀលរាល់ឆ្នាំ ទៅលើលទ្ធផលសម្រេចទាក់ទងទៅនឹងគោលបំណង ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ដើម្បីធានាបាននូវការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព។

## ២. ការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការ

| ល.រ | គណៈកម្មាធិការ | ឈ្មោះ | មូលហេតុ |
|---|---|---|---|
| ១ | សវនកម្ម | លោក Cornelius Obert | លោក Cornelius Obert បានលាលែងពីតំណែងជាសមាជិក នៃគណៈកម្មាធិការសវនកម្ម។ |
| ២ | តែងតាំង និងលាភការ | លោក Ryoji Nishimura | លោក Ryoji Nishimura បានស្នើសុំលាឈប់ពីតំណែង អភិបាលរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដោយមូលហេតុលោកត្រូវបំពេញតួនាទីថ្មី។ |
| | | លោក Cornelius Obert | លោក Cornelius Obert បានលាលែងពីតំណែងជាសមាជិក នៃគណៈកម្មាធិការតែងតាំង និងលាភការ ដោយលោកដល់អាយុចូលនិវត្តន៍ ស្របតាមលក្ខន្តិកៈរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។ |
| | | លោក វ៉ាន់ ស៊ូអៀង | លោក វ៉ាន់ ស៊ូអៀង ជាសមាជិកអភិបាលឯករាជ្យថ្មី ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការតែងតាំង និងលាភការ។ |
| ៣ | គ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា | លោក Cornelius Obert | លោក Cornelius Obert បានលាលែងតំណែងជាប្រធាន គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ដោយលោកដល់អាយុចូលនិវត្តន៍ស្របតាមលក្ខន្តិកៈរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។ |
| | | លោក Pieter Kooi | លោក Pieter Kooi ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការ ជំនួសលោក Cornelius Obert។ |

# គ. លាភការ ឬប្រាក់បំណាច់

## ១. គោលការណ៍សង្ខេបស្តីពីលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

### អភិបាល

- ភាគហ៊ុនិករបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធកំណត់ អំពីលាភការ និងអត្ថប្រយោជន៍ សម្រាប់អភិបាលតាមស្ថានភាពជាក់ស្តែង តាមរយៈកិច្ចព្រមព្រៀងភាគហ៊ុនិក ដោយផ្អែកលើសំណើរបស់ក្រុមប្រឹក្សាភិបាល។
- ភាគហ៊ុនិករបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធតែងតាំងអភិបាលដូចមានចែងនៅក្នុងលក្ខន្តិកៈរបស់ធនាគារ។

### បុគ្គលិកជាន់ខ្ពស់

- ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ទទួលខុសត្រូវជ្រើសរើស និងតែងតាំងបុគ្គលដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ជា ប្រធាននាយក-នាយិកាប្រតិបត្តិ គណៈប្រធាននាយក-នាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង និងនាយក-នាយិកាប្រតិបត្តិអនុលោមបញ្ញត្តិ។
- ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ទទួលខុសត្រូវអនុម័តលាភការសម្រាប់ប្រធាននាយក-នាយិកាប្រតិបត្តិ គណៈប្រធាននាយក-នាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង និងនាយក-នាយិកាប្រតិបត្តិអនុលោមបញ្ញត្តិ។
- ក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ទទួលខុសត្រូវអនុម័តលើផែនការថវិកាប្រចាំឆ្នាំទាំងអស់ សម្រាប់ការផ្តល់លាភការជូនអភិបាល និងនិយោជិត។
- ក្រុមប្រឹក្សាភិបាលរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវវាយតម្លៃលទ្ធផលការងាររបស់ខ្លួនប្រចាំឆ្នាំ។

## ២. បុគ្គលទទួលលាភការ ឬប្រាក់បំណាច់

| លរ | បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់ | ចំនួនលាភការ ឬប្រាក់បំណាច់ | ផ្សេងៗ |
|---|---|---|---|
| ១ | អភិបាល | $ ៤២៩.៧០០,៣៧ | |
| ២ | អភិបាលប្រតិបត្តិ និង បុគ្គលិកជាន់ខ្ពស់ | $ ២.៤៣៤.៥៤៨,៥៤ | |
| ៤ | បុគ្គលិកដែលទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់បំផុត ៥រូប | $ ៩២.១២៣,៧៧ | |

# ឃ. ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល អភិបាលនីមួយៗ គណៈកម្មាធិការ និងនាយកប្រតិបត្តិ

| លរ | បរិយាយ | ដំណើរការនៃការវាយតម្លៃ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|
| ១ | ក្រុមប្រឹក្សាភិបាល | ក្រុមប្រឹក្សាភិបាលធ្វើស្វ័យវាយតម្លៃលើលទ្ធផលការងាររបស់ខ្លួន | • សិទ្ធិអំណាច តួនាទី និងការទទួលខុសត្រូវ ដែលបានកំណត់ក្នុងធម្មនុញ្ញក្រុមប្រឹក្សាភិបាល លក្ខន្តិកៈរបស់ធនាគារ និងច្បាប់ជាធរមាន<br>• ការចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល |
| ២ | អភិបាល | ក្រុមប្រឹក្សាភិបាលធ្វើស្វ័យវាយតម្លៃលើលទ្ធផលការងាររបស់ខ្លួន | • សិទ្ធិអំណាច តួនាទី និងការទទួលខុសត្រូវ ដែលបានកំណត់ក្នុងធម្មនុញ្ញក្រុមប្រឹក្សាភិបាល លក្ខន្តិកៈរបស់ធនាគារ និងច្បាប់ជាធរមាន<br>• ការចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល |
| ៣ | គណៈកម្មាធិការ | គណៈកម្មាធិការក្រុមប្រឹក្សាភិបាលធ្វើស្វ័យវាយតម្លៃលើលទ្ធផលការងាររបស់ខ្លួន | • សិទ្ធិអំណាច តួនាទី និងការទទួលខុសត្រូវ ដែលកំណត់នៅក្នុងតួនាទីភារកិច្ចរបស់ខ្លួន<br>• ការចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការ |
| ៤ | ប្រធាននាយកប្រតិបត្តិ | លទ្ធផលការងាររបស់ប្រធាននាយកប្រតិបត្តិ គឺ ត្រូវបានវាយតម្លៃដោយគណៈកម្មាធិការតែងតាំង និងលាភការ និងត្រូវផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយ | លក្ខខណ្ឌវាយតម្លៃលទ្ធផលការងារ(ទាំងបរិមាណ និងគុណភាព) ដែលកំណត់ដោយ គណៈកម្មាធិការតែងតាំង និងលាភការ និង ត្រូវផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយ |

# ង. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវបានទទួលនូវការបណ្តុះបណ្តាលវគ្គហ្វឹកហ្វឺន (វគ្គបំពាក់បំប៉ន, សិក្ខាសាលា, សន្និសីទ, ហ្វឹកហ្វឺន...) យោងតាមតម្រូវការជាក់ស្តែង ឬអនុសាសន៍ពីប្រធានក្រុមប្រឹក្សាភិបាល ដើម្បីអភិវឌ្ឍនូវចំណេះដឹង និងជំនាញដូចមានរបាយការណ៍ខាងក្រោមនេះ៖

| លរ | ឈ្មោះ | មុខតំណែង | វគ្គបណ្តុះបណ្តាល |
|---|---|---|---|
| ១ | លោក ឆាយ សឿន | ប្រធានក្រុមប្រឹក្សាភិបាល | • SECC Webinar ស្តីពីគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល<br>• ប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម |
| ២ | បណ្ឌិត អ៊ិន ចាន់នី | អភិបាល/<br>ប្រធាននាយកប្រតិបត្តិ | • SECC Webinar ស្តីពីគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល<br>• ប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម |
| ៣ | លោក រ័ត្ន យូម៉េង | អភិបាល/<br>អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល | SECC Webinar ស្តីពីគណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល |
| ៤ | លោកស្រី ម៉ារ អមរា | អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ | ប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម |
| ៥ | លោកស្រី ប៊ុត ប៊ុនសីហា | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន | ប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម |

# ផ្នែកទី៣

## ការអនុវត្តក្រមសីលធម៌
## សម្រាប់អនុវត្តធុរកិច្ច

## ក. ក្រមប្រតិបត្តិរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត៖

- ### ការអនុវត្តច្បាប់
  ធនាគារ អេស៊ីលីដា ភីអិលស៊ី ដំណើរការធុរកិច្ចរបស់ខ្លួនដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន និងស្របតាមគោលការណ៍សីលធម៌ក្នុងកម្រិតខ្ពស់បំផុត។ សម្ព័ន្ធធនាគារ អេស៊ីលីដា តម្រូវឲ្យគ្រប់អភិបាល និងនិយោជិតទាំងអស់អនុវត្តតាមស្របច្បាប់ និងបទប្បញ្ញត្តិជាធរមាន នៅគ្រប់ទីកន្លែងដែលខ្លួនប្រកបអាជីវកម្មឲ្យបានត្រឹមត្រូវ។ លើសពីនេះទៅទៀតគ្រប់កម្មករនិយោជិតទាំងអស់ ត្រូវតែយល់ដឹងអំពីគោលការណ៍របស់ធនាគារ ច្បាប់ វិធាន និងបទប្បញ្ញត្តិនានាដែលអនុវត្តចំពោះតួនាទីរបស់ខ្លួន។ ហេតុដូច្នេះហើយ ធនាគារបានដាក់ចេញនូវគោលការណ៍ ស្តីពីអនុលោមបញ្ញត្តិ ដើម្បីធានាថាធនាគារអនុវត្តត្រឹមត្រូវតាមច្បាប់ និងគោលការណ៍នានា បានគ្រប់ពេលវេលា។

- ### ការកសាងទំនុកចិត្ត និងភាពជឿជាក់
  ទំនុកចិត្ត និងភាពជឿជាក់ ដែលយើងទទួលបានពីភាគីពាក់ព័ន្ធ រួមមាន៖ និយោជិត អតិថិជន និងភាគហ៊ុនិក គឺជាផ្នែកនៃភាពជោគជ័យនៃអាជីវកម្មរបស់យើង។ យើងទទួលបានភាពជឿជាក់ដោយការប្រកាន់ខ្ជាប់ និងការប្តេជ្ញា ឈានដល់គោលដៅតាមរយៈការអនុវត្តការងារប្រកបដោយសេចក្តីថ្លៃថ្នូរ។

- ### គោលការណ៍ ស្តីពីក្រមប្រតិបត្តិ
  ធនាគារបានអនុម័តនូវគោលការណ៍ស្តីពីក្រមប្រតិបត្តិ ដោយកំណត់នូវស្តង់ដារក្រមសីលធម៌ សម្រាប់គ្រប់បុគ្គលិកទាំងអស់ ដោយមានគោលការណ៍សំខាន់ៗដូចខាងក្រោម៖

  ១. ស្មោះត្រង់ យុត្តិធម៌ និងសុច្ចរិតភាព៖ គ្រប់បុគ្គលិកទាំងអស់ត្រូវមានសេចក្តីស្មោះត្រង់ និងសុច្ចរិតភាពចំពោះរាល់សកម្មភាពរបស់ខ្លួន ហើយបុគ្គលិកទាំងអស់នឹងមិនត្រូវបានរើសអើងលើពូជសាសន៍ សាសនា ភេទ ស្ថានភាពគ្រួសារ ឬពិការភាពឡើយ។

  ២. ប្រតិបត្តិការផ្ទាល់ខ្លួន៖ មិនត្រូវប្រើប្រាស់ឈ្មោះធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីធ្វើកិច្ចការផ្ទាល់ខ្លួន ឬអាជីវកម្មផ្សេងៗឡើយ។

  ៣. ភាពសម្ងាត់នៃព័ត៌មាន៖ ធានារក្សាព័ត៌មានសម្ងាត់ពាក់ព័ន្ធនឹងអតិថិជន បុគ្គលិក និងប្រតិបត្តិការរបស់ធនាគារ និងគោរពឯកជនភាពរបស់បុគ្គលដទៃ។

  ៤. ការធានានូវសុក្រឹតភាពនៃរបាយការណ៍ និងការត្រួតពិនិត្យផ្ទៃក្នុង។

  ៥. អនុលោមភាពច្បាប់៖ បុគ្គលិកធនាគារត្រូវគោរព និងប្រតិបត្តិតាមច្បាប់ វិធាន និងបទប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ផ្ទៃក្នុងរបស់ធនាគារគ្រប់ពេលវេលា។

- ### ការជៀសវាងនូវទំនាស់ផលប្រយោជន៍ (គោលការណ៍ ស្តីពីទំនាស់ផលប្រយោជន៍)
  ធនាគារបានបង្កើតនូវគោលការណ៍ ស្តីពីទំនាស់ផលប្រយោជន៍ ដើម្បីឲ្យគ្រប់បុគ្គលិកទាំងអស់របស់ធនាគារមានភាពងាយស្រួលក្នុងការកំណត់ ការទប់ស្កាត់ និងការគ្រប់គ្រងទំនាស់ផលប្រយោជន៍ដែលអាចកើតឡើងក្នុងដំណើរការអាជីវកម្មរបស់ធនាគារ។

- ### គោលការណ៍ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម
  ធនាគារបានដាក់ចេញនូវគោលការណ៍ ស្តីពីការបង្ហាញព័ត៌មាន ដើម្បីធានាថាព័ត៌មានសាជីវកម្មរបស់ធនាគារ ត្រូវបានផ្សព្វផ្សាយទៅអាជ្ញាធរពាក់ព័ន្ធ វិនិយោគិន អតិថិជន ម្ចាស់កម្ចី និយោជិត និងសាធារណជនទូទៅ បានទាន់ពេលវេលា ត្រឹមត្រូវ គ្រប់គ្រាន់ ងាយយល់ និងមានលក្ខណៈសមស្រប។

- ### គោលការណ៍ ស្តីពីការជួញដូរផ្ទៃក្នុង
  គោលការណ៍ ស្តីពីការជួញដូរផ្ទៃក្នុង គឺបង្កើតឡើងដើម្បី

  - ការពារផលប្រយោជន៍របស់វិនិយោគិន និងការពារកេរ្តិ៍ឈ្មោះរបស់ធនាគារ
  - ជៀសវាងការប្រើប្រាស់មិនត្រឹមត្រូវនូវព័ត៌មានសំខាន់មិនផ្សព្វផ្សាយជាសាធារណៈ
  - អនុលោមតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិ។

  យោងតាមគោលការណ៍នេះ អ្នកផ្ទៃក្នុង (ក្រុមប្រឹក្សាភិបាល និងនិយោជិត) ដែលទទួលបាន ឬមានសិទ្ធិចូលយក/ប្រើប្រាស់ព័ត៌មានសំខាន់មិនផ្សព្វផ្សាយជាសាធារណៈរបស់ធនាគារ ត្រូវបានហាមមិនឲ្យទិញ-លក់ ឬធ្វើប្រតិបត្តិការណាមួយ ដោយផ្ទាល់ ឬដោយប្រយោល ដែលទាក់ទងនឹងមូលបត្រដែលកំពុងចុះបញ្ជីនៅលើទីផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ឬទីផ្សារមូលបត្រប្រតិស្រុតផ្សេងទៀត។ (មូលបត្រនៅទីនេះ គឺសំដៅទៅលើមូលបត្រដែលបោះផ្សាយដោយធនាគារ អេស៊ីលីដា ភីអិលស៊ី ឬក្រុមហ៊ុនបោះផ្សាយផ្សេងទៀត ប្រសិនបើអ្នកផ្ទៃក្នុងមានព័ត៌មានសំខាន់មិនផ្សព្វផ្សាយជាសាធារណៈទាំងនេះ តាមរយៈការងាររបស់ពួកគេជាមួយធនាគារ)។

- ### ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព
  ធនាគារបានបង្កើតក្របខ័ណ្ឌនេះឡើងក្នុងគោលដៅ ដើម្បី៖

  - ធានាថា ធនាគាររក្សាបានគ្រប់ពេលនូវមូលដ្ឋានមូលនិធិដែលមានលក្ខណៈពិពិធកម្ម និងមានស្ថេរភាព ដែលអាចឲ្យធនាគារបំពេញតម្រូវការប្រើប្រាស់សន្ទនីយភាពប្រចាំថ្ងៃ និងអាចបំពេញបាននូវតម្រូវការមូលនិធិទាំងបានរំពឹងទុក និងមិនបានរំពឹងទុក ក្នុងចំណាយដ៏សមរម្យ។
  - គ្រប់គ្រងមូលនិធិ និងសន្ទនីយភាព ក្នុងគោលដៅបង្កើតគុណតម្លៃ (អត្ថប្រយោជន៍) រយៈពេលវែងមួយដល់ភាគហ៊ុនិក។
  - ការពារបាននូវបញ្ហាសន្ទនីយភាពធ្ងន់ធ្ងរដែលអាចកើតមាននាពេលអនាគត និងកាត់បន្ថយផលវិបាកនានាមកលើធនាគារ ថែមទាំងការពាររាល់ភាគីដែលពាក់ព័ន្ធផងដែរ។

- ### គោលការណ៍ ស្តីពីកំណារពារនិវេទនជន
  ធនាគារបានបង្កើតគោលការណ៍នេះ ដើម្បី៖

  - ការពារនិវេទនជនម្នាក់ៗ ដែលបានរាយការណ៍ អំពីបញ្ហាផ្សេងៗដោយសច្ចភាព គ្មានបំណងអាក្រក់ ហើយមិនមានការរំពឹងទុកពីផលចំណេញផ្ទាល់ខ្លួន។
  - លើកទឹកចិត្តនិយោជិតគ្រប់លំដាប់ថ្នាក់ ឲ្យរាយការណ៍ទៅដល់ថ្នាក់គ្រប់គ្រងតាមកម្រិតដែលពាក់ព័ន្ធ នូវសកម្មភាព ឬបញ្ហាណាមួយ ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ របស់ធនាគារ និងសាធារណជនទូទៅ។

- ### គោលការណ៍ស្តីពីបរិស្ថាន សង្គម និងសហគមន៍

  ធនាគារបង្កើតគោលការណ៍នេះ ដើម្បី៖
  - ធានាថា ធនាគារអាចផ្តល់សេវាកម្មហិរញ្ញវត្ថុ ជាពិសេសដល់គម្រោង និងការផ្តួចផ្តើមប្រកបអាជីវកម្មដែលមាននិរន្តរភាព ដោយគោរពតាមគោលការណ៍ការពារធម្មជាតិ និងបរិស្ថាន។
  - ផ្តល់នូវក្របខ័ណ្ឌនៃគោលការណ៍ណែនាំ ដើម្បីឲ្យធនាគារអាចអនុវត្តអាជីវកម្មប្រកបដោយចីរភាព និងអាចគ្រប់គ្រងបាននូវផលប៉ះពាល់ដល់បរិស្ថាន សង្គម និងសហគមន៍។
  - អនុវត្តតាមច្បាប់បរិស្ថាន និងគោលការណ៍ណែនាំរបស់ប្រទេសកម្ពុជា។

- ### ការប្រឆាំងនឹងអំពើពុករលួយ

  ធនាគារហាមឃាត់មិនឲ្យផ្តល់ ឬទទួលសំណូក ឬប្រព្រឹត្តអំពើពុករលួយគ្រប់រូបភាព។ ទង្វើ និងសកម្មភាពហាមឃាត់ទាំងនេះ មានបញ្ជាក់នៅក្នុងអនុសញ្ញារួមនៃការងារ បទប្បញ្ញត្តិផ្ទៃក្នុង ក្រមប្រតិបត្តិអនុវត្តការងារ របាយកំហុស និងគោលការណ៍ប្រតិបត្តិ ស្តីពីអំណោយ កម្រៃជើងសា និងការបញ្ចុះបញ្ចូល។ គ្រប់និយោជិតត្រូវអនុវត្តអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។ សម្ព័ន្ធធនាគារប្តេជ្ញាអនុវត្តធុរកិច្ចដោយស្មោះត្រង់ សុចរិត និងអនុលោមតាមច្បាប់ជាធរមាន រួមទាំងច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយផងដែរ។ និយោជិតដែលអនុវត្តបំពាន ឬផ្ទុយនឹងច្បាប់ និងគោលការណ៍ពាក់ព័ន្ធ នឹងត្រូវទទួលរងនូវពិន័យតាមវិធានវិន័យ។

- ### គោលការណ៍ ស្តីពីការប្រឆាំងនឹងការសម្អាតប្រាក់ និងការប្រយុទ្ធប្រឆាំងនឹងហិរញ្ញប្បទានភេរវកម្ម

  នៅក្នុងការអនុវត្តសកម្មភាពអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ យើងអនុវត្តតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់នៅក្នុងគោលការណ៍ស្តីពីការប្រឆាំងនឹងការសម្អាតប្រាក់ និងការប្រយុទ្ធប្រឆាំងនឹងហិរញ្ញប្បទានភេរវកម្ម។ ថ្នាក់គ្រប់គ្រង និងកម្មករនិយោជិតធនាគារគ្រប់លំដាប់ថ្នាក់មានកាតព្វកិច្ចរាយការណ៍នូវរាល់ប្រតិបត្តិការសង្ស័យគ្រប់ប្រភេទ និងតម្រូវឲ្យរក្សាការសម្ងាត់ ចំពោះប្រតិបត្តិការសង្ស័យរបស់អតិថិជន និងធ្វើជារបាយការណ៍ឡើង។ នាយកប្រតិបត្តិអនុលោមបញ្ញត្តិត្រូវមានឯករាជ្យភាពក្នុងការបញ្ជូនព័ត៌មាន នៃប្រតិបត្តិការគួរឲ្យសង្ស័យទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្នុងរយៈពេល ២៤ ម៉ោង បន្ទាប់ពីទទួលបានរបាយការណ៍ហើយមានការសង្ស័យគួរឲ្យកត់សម្គាល់។ នាយកប្រតិបត្តិអនុលោមបញ្ញត្តិ ត្រូវកត់ត្រារាល់មតិយោបល់របស់ខ្លួនប្រសិនបើមិនមានហេតុផលសមរម្យ។

- ### គោលការណ៍ពាក់ព័ន្ធនឹងការងារ/វិធានផ្ទៃក្នុង

  យើងគោរពច្បាប់ដែលមានជាធរមាន រួមមានច្បាប់ និងបទប្បញ្ញត្តិក្នុងប្រទេសដែលពាក់ព័ន្ធនឹងការអនុវត្តធុរកិច្ចរបស់យើង។ ធនាគារមាននូវអនុសញ្ញារួមនៃការងារច្បាស់លាស់ ដែលរៀបចំឡើងស្របតាមជំពូកទី៥ នៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

  អនុសញ្ញារួមនៃការងារ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី កំណត់នូវលក្ខខណ្ឌការងារ ផលិតភាពនៃការងាររបស់កម្មករនិយោជិត និងគ្រប់គ្រងទំនាក់ទំនងរវាងនិយោជក និងនិយោជិត ក៏ដូចជានិយោជកជាមួយនឹងប្រតិភូបុគ្គលិកផងដែរ។

- ### ការដោះស្រាយជម្លោះ

  វិធីសាស្ត្រល្អបំផុត ដើម្បីដោះស្រាយជម្លោះនៅកន្លែងធ្វើការ គឺដើម្បីការពារកុំឲ្យមានជម្លោះកើតឡើងពីកន្លែងដំបូង។ អនុសញ្ញារួមនៃការងាររបស់ធនាគារក៏បានចែង អំពីនីតិវិធីបណ្តឹងតវ៉ា សម្រាប់បង្ហាញ និងដោះស្រាយវិវាទនៅកន្លែងធ្វើការ។ ការលើកឡើង និងការទទួលស្គាល់បញ្ហាដើម្បីជជែកដេញដោល ដើម្បីជម្រះមន្ទិលសង្ស័យ និងការយល់ច្រឡំ ដែលមិនសមហេតុផល ជាការងារអាទិភាពត្រូវចាត់វិធានការដោយ ធនាគារ អេស៊ីលីដា ភីអិលស៊ី និងប្រតិភូបុគ្គលិក។

- ### ការធ្វើអាជីវកម្មដោយស្មោះត្រង់

  ធនាគារបានប្តេជ្ញាប្រកបអាជីវកម្មដោយតម្លាភាព លក្ខណៈត្រឹមត្រូវ និងស្មោះត្រង់ ហើយថែមទាំងប្តេជ្ញាផ្តល់នូវលទ្ធភាពដោះស្រាយដោយយុត្តិធម៌ សម្រាប់អតិថិជន ដោយធានាថា រាល់ផលិតផល និងសេវាកម្ម ដែលធនាគារបម្រើជូនស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ហើយសមស្របតាមតម្រូវការរបស់អតិថិជនរបស់ធនាគារ។

## ខ. ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

ក្រុមប្រឹក្សាភិបាលបានអនុម័តគោលការណ៍ក្រមប្រតិបត្តិ (Code of Conduct Policy) និងបានអនុវត្តចាប់តាំងពីឆ្នាំ២០១៤។

## គ. យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

ដើម្បីឲ្យកម្មករនិយោជិតយល់ច្បាស់ពីក្រមក្នុងការដំណើរការអជីវកម្ម វិសាលភាពក្នុងការអនុវត្ត ធនាគារបានកំណត់នូវនីតិវិធីដូចខាងក្រោម៖

### សម្រាប់កម្មករនិយោជិតថ្មី

គ្រប់កម្មករនិយោជិតថ្មី ដែលត្រូវបានជ្រើសរើស និងតែងតាំងចូលបម្រើការងារក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវរៀបចំលិខិតក្រមប្រតិបត្តិការងារក្នុងតួនាទី នៅពេលចុះកិច្ចសន្យាការងារ ដោយត្រូវអានគ្រប់ចំណុចនូវខ្លឹមសារនៃក្រមប្រតិបត្តិ និងផ្តិតមេដៃស្តាំទុកជាសក្ខីភាព ដើម្បីបញ្ជាក់ថាយល់ច្បាស់ និងអះអាងរាល់ការបដិបត្តិ។

### សម្រាប់កម្មករនិយោជិតដែលកំពុងបម្រើការងារ

- គ្រប់កម្មករនិយោជិតដែលត្រូវបានតែងតាំង ឬដំឡើងលំដាប់ថ្នាក់ក្នុងមុខងារតួនាទីថ្មី ថ្នាក់គ្រប់គ្រងផ្ទាល់ចុងក្រោយ ត្រូវរៀបចំលិខិតក្រមប្រតិបត្តិការងារក្នុងតួនាទីថ្មី ជូនសាមីអានសាឡើងវិញ គ្រប់ចំណុចនៃខ្លឹមសារ និងផ្តិតស្នាមមេដៃស្តាំទុកជាសក្ខីភាព។
- គ្រប់កម្មករនិយោជិតដែលត្រូវចូលរួមធ្វើវិសោធនកម្ម នៅនាយកដ្ឋានធនធានមនុស្ស តម្រូវឲ្យសរសេរខ្លឹមសារនៃក្រមប្រតិបត្តិការងារក្នុងតួនាទីថ្មី។
- កម្មករនិយោជិតដែលត្រូវដល់កាលបរិច្ឆេទវាយតម្លៃលទ្ធផលការងារតាមកាលកំណត់ ឬមុនកាលកំណត់ត្រូវអនុវត្តដូចខាងក្រោម៖
- សាមីថ្នាក់គ្រប់គ្រងផ្ទាល់ត្រូវផ្តល់លិខិតនៃក្រមប្រតិបត្តិការងារក្នុងតួនាទី ជូនសាមីកម្មករនិយោជិត ដើម្បីអានដោយយកចិត្តទុកដាក់បំផុតតាមអត្ថន័យ និងមាតិកា ដែលមានបញ្ជាក់ក្នុងលិខិតភ្ជាប់ជាមួយទម្រង់វាយតម្លៃលទ្ធផលការងារ។
- បន្ទាប់ពីបានអាននូវអត្ថន័យ នៃក្រមប្រតិបត្តិការងារក្នុងតួនាទី សាមីកម្មករនិយោជិតត្រូវផ្តិតមេដៃស្តាំ ដើម្បីទុកជាសក្ខីភាព។

# ឃ. ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

## ១. គោលនយោបាយរបស់បុគ្គលិកចុះបញ្ជីលក់មូលបត្រ សម្រាប់គ្រប់គ្រងលើប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ១ | ក្រុមហ៊ុនហូលឌីង | មិនមាន |
| ២ | កិច្ចព្រមព្រៀងវិនិយោគចម្រុះ | មិនមាន |
| ៣ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | គោលការណ៍ប្រតិបត្តិស្តីពីសម្ព័ន្ធញាតិ |
| ៤ | ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងច្រើនលើសលុប | គោលការណ៍ប្រតិបត្តិស្តីពីសម្ព័ន្ធញាតិ |
| ៥ | អភិបាល និងសមាជិកគ្រួសារផ្ទាល់របស់អភិបាល | គោលការណ៍ប្រតិបត្តិស្តីពីសម្ព័ន្ធញាតិ |
| ៦ | បុគ្គលិក និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក | គោលការណ៍ប្រតិបត្តិស្តីពីសម្ព័ន្ធញាតិ |
| ៧ | ផ្សេងៗ | មិនមាន |

## ២. ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ឈ្មោះភាគីជាប់ពាក់ព័ន្ធ | ប្រភេទប្រតិបត្តិការ | ទំហំប្រតិបត្តិការ | | សង្ខេបអំពីប្រតិបត្តិការ |
|---|---|---|---|---|---|
| | | | គិតជាដុល្លារអាមេរិក | ពាន់រៀល | |
| ១ | ភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ | សមតុល្យជាមួយសម្ព័ន្ធញាតិ | ៤១២.១៦២ | ១.៦៦៧.១៩៥ | ប្រាក់បញ្ញើនៅភាគហ៊ុនិក |
| | | ប្រាក់បញ្ញើ | ១៣.១១៧.៥៩៦ | ៥៣.០៦០.៦៧៦ | ប្រាក់បញ្ញើពីភាគហ៊ុនិក |
| | | គណនីត្រូវទូទាត់ | ៥០០ | ២.០២៣ | គណនីត្រូវទទួលពីភាគហ៊ុនិក |
| | | ចំណូលការប្រាក់ | ១៦.៩៨៩ | ៦៩.២៦៤ | ចំណូលការប្រាក់ពីភាគហ៊ុនិក |
| | | ចំណូលកម្រៃនិងជើងសា | ២៨.០៦៣ | ១១៤.៤១៣ | ចំណូល និងកម្រៃជើងសាពីភាគហ៊ុនិក |
| | | ចំណាយការប្រាក់ | ២០១.៦៧០ | ៨២២.២០៨ | ការប្រាក់ចំណាយទៅភាគហ៊ុនិក |
| ២ | អភិបាល និងបុគ្គលិកជាន់ខ្ពស់ | ឥណទាននិងបុរេប្រទាន | ១១.៥៣៧.២២០ | ៤៦.៦៦៨.០៥៥ | ឥណទានផ្តល់ទៅអភិបាល និងបុគ្គលិកជាន់ខ្ពស់ |
| | | ប្រាក់បញ្ញើ | ៣.០៩៤.២២១ | ១២.៥១៦.១២៤ | ប្រាក់បញ្ញើពីអភិបាល និងបុគ្គលិកជាន់ខ្ពស់ |
| | | ចំណូលការប្រាក់ | ១.០៧៤.០៣១ | ៤.៣៧៨.៨២៤ | ចំណូលការប្រាក់ពីអភិបាល និងបុគ្គលិកជាន់ខ្ពស់ |
| | | ចំណាយការប្រាក់ | ១៣៥.៧០៤ | ៥៥៣.២៥៦ | ចំណាយការប្រាក់ទៅអភិបាល និងបុគ្គលិកជាន់ខ្ពស់ |
| | | ចំណាយកម្រៃនិងជើងសា | ៦.៥១៨.២៤១ | ២៦.៥៧៤.៨០៨ | ចំណាយកម្រៃនិងជើងសាទៅអភិបាល និងបុគ្គលិកជាន់ខ្ពស់ |
| | | ការប្រាក់ត្រូវបង់ | ២២.៥៨៨ | ៩១.៣៦៩ | ការប្រាក់ត្រូវបង់ទៅអភិបាល និងបុគ្គលិកជាន់ខ្ពស់ |
| ៣ | ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ | ឥណទាននិងបុរេប្រទាន | ១.៤៥៨.៩៤៩ | ៥.៩០១.៤៤៩ | ឥណទានផ្តល់ទៅសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក |
| | | ប្រាក់បញ្ញើ | ១.៤១៩.៦៣១ | ៥.៧៤២.៤០៧ | ប្រាក់បញ្ញើពីសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក |
| | | ការប្រាក់ត្រូវបង់ | ៥.៧៨៧ | ២៣.៤០៨ | ការប្រាក់ត្រូវបង់ទៅសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក |

| ល.រ | ឈ្មោះភាគីជាប់ពាក់ព័ន្ធ | ប្រភេទប្រតិបត្តិការ | ទំហំប្រតិបត្តិការ | | សង្ខេបអំពីប្រតិបត្តិការ |
|---|---|---|---|---|---|
| | | | គិតជាដុល្លារអាមេរិក | ពាន់រៀល | |
| ៤ | ប្រតិបត្តិការសំខាន់ៗជាមួយក្រុមហ៊ុនបុត្រសម្ព័ន្ធ | ឥណទាននិងបុរេប្រទាន | ៦.៤៤០.៥៩០ | ២៦.០៥២.១៨៧ | ឥណទានផ្តល់ទៅក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | សមតុល្យជាមួយសម្ព័ន្ធញាតិ | ៥០២.៦៧៨ | ២.០៣៣.៣៣៣ | ប្រាក់បញ្ញើនៅក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | ប្រាក់បញ្ញើ | ៣.៥១៧.៣២១ | ១៤.២២៧.៥៦៣ | ប្រាក់បញ្ញើពីក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | គណនីត្រូវទទួល | ១៦៩.៥៤៤ | ៦៨៥.៨០៦ | គណនីត្រូវទទួលពីក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | ចំណូលការប្រាក់ | ៣៩៩.៥២៤ | ១.៦២៨.៨៥៩ | ចំណូលការប្រាក់ពីក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | ចំណូលកម្រៃនិងជើងសា | ១២.២៨៤ | ៥០.០៩៩ | ចំណូលកម្រៃនិងជើងសាពីក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | ចំណាយការប្រាក់ | ៩៥.៣៩៣ | ៣៨៨.៩១៧ | ចំណាយការប្រាក់ទៅក្រុមហ៊ុនបុត្រ |
| | | ចំណាយកម្រៃនិងជើងសា | ២.២០០.៧៩៦ | ៨.៩៧២.៦៤៥ | ចំណាយកម្រៃនិងជើងសាទៅក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | គណនីត្រូវទូទាត់ | ២.១៨៧ | ៨.៨៤៦ | គណនីត្រូវទូទាត់ទៅក្រុមហ៊ុនបុត្រសម្ព័ន្ធ |
| | | កិច្ចសន្យាផ្សេងៗ | ៣៧០.៤៤៨ | ១.៥១០.៣១៦ | ECL លើការធានាហិរញ្ញវត្ថុលើកម្ចីរបស់វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា |

# ផ្នែកទី៤

# ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

## ក. សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ

ធនាគារ អេស៊ីលីដា ភីអិលស៊ី បាននិងកំពុងបន្តអនុវត្តវិធីសាស្ត្រក្នុងការលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ដើម្បីធានាបាននូវសុវត្ថិភាព និងប្រសិទ្ធភាព ចំពោះធនាគារ ។ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានវិធីសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យ តាមរយៈ ការកំណត់អត្តសញ្ញាណ ការវាយតម្លៃ ការកាត់បន្ថយ និងការត្រួតពិនិត្យតាមដានហានិភ័យ នៅទូទាំងវិស័យនៃអាជីវកម្មសំខាន់ៗទាំងអស់របស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី។ លើសពីនេះទៀត ធនាគារ អេស៊ីលីដា ភីអិលស៊ី មានការគាំទ្រដ៏រឹងមាំដោយរចនាសម្ព័ន្ធអភិបាលកិច្ចហានិភ័យ ដែលបានដាក់ឲ្យអនុវត្តស្របទៅតាម “ម៉ូដែលខ្សែបន្ទាត់ទាំងបី” ។ រចនាសម្ព័ន្ធអភិបាលកិច្ចហានិភ័យ បានចែងយ៉ាងច្បាស់លាស់អំពីការទទួលខុសត្រូវ ឯករាជ្យភាព ការរាយការណ៍ ទំនាក់ទំនង និងតម្លាភាព សម្រាប់ភាគីពាក់ព័ន្ធទាំងខាងក្នុង និងខាងក្រៅ ។ រីឯការទទួលខុសត្រូវក្នុងការគ្រប់គ្រងហានិភ័យ មាននៅគ្រប់កម្រិតនៃកម្មករនិយោជិត របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលនេះជាវិធីសាស្ត្រនៅក្នុងការគ្រប់គ្រងហានិភ័យដែលត្រូវបានបង្កើតឡើងតាមរយៈការត្រួតពិនិត្យជាផ្លូវការ ដោយមានការទទួលខុសត្រូវតាមតួនាទី និងការត្រួតពិនិត្យដោយឯករាជ្យ ។ ថ្នាក់គ្រប់គ្រងនីមួយៗ ទទួលខុសត្រូវលើការគ្រប់គ្រងហានិភ័យនៅក្នុងផ្នែករបស់ខ្លួន ព្រមទាំងតម្រូវឲ្យថ្នាក់គ្រប់គ្រងទាំងអស់ត្រូវតែយល់ដឹង និងគ្រប់គ្រងហានិភ័យជាសារវន្តដែលកើតមានឡើងនៅក្នុងអាជីវកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

## ខ. សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ធនាគារ អេស៊ីលីដា បានបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងយ៉ាងរឹងមាំតាមរយៈដាក់ចេញនូវគោលការណ៍ នីតិវិធី និងសេចក្ដីណែនាំផ្សេងៗ ដែលជាមូលដ្ឋានគ្រឹះការពារហានិភ័យ និងសម្រាប់អនុវត្តការប្រតិបត្តិប្រចាំថ្ងៃឲ្យមានប្រសិទ្ធភាព។ ធនាគារមានរចនាសម្ព័ន្ធនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងច្បាស់លាស់ ដូចជាក្រុមប្រឹក្សាភិបាលមានភារកិច្ចដាក់ចេញនូវគោលនយោបាយប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង អនុលោមតាមច្បាប់ ប្រកាស និងបទប្បញ្ញត្តិ។

ថ្នាក់ដឹកនាំជាន់ខ្ពស់មានតួនាទីប្រតិបត្តិតាមគោលនយោបាយ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាលតាមរយៈការដាក់ចេញនូវគោលការណ៍ប្រតិបត្តិ នីតិវិធី និងសេចក្ដីណែនាំ និងតាមដានត្រួតពិនិត្យការប្រតិបត្តិប្រចាំថ្ងៃ។ មន្ត្រីប្រតិបត្តិតាមមានភារកិច្ចគាំទ្រការគ្រប់គ្រងនិងការការពារហានិភ័យអនុលោមបញ្ញត្តិ និងត្រួតពិនិត្យប្រសិទ្ធភាពនៃការប្រតិបត្តិតាមរួមទាំងតាមដានយន្តការកែតម្រូវ។ ភាពរឹងមាំនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនិងការប្រតិបត្តិតាមគោលការណ៍នីតិវិធី និងសេចក្ដីណែនាំត្រូវបានធានាតាមរយៈការធ្វើសវនកម្មផ្ទៃក្នុងនិងភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុត្រូវបានធានាតាមរយៈការធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មឯករាជ្យ ។

## គ. ការធ្វើសវនកម្ម

### ១. សវនកម្មផ្ទៃក្នុង

#### ១.១ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង

សវនកម្មផ្ទៃក្នុងមានតួនាទីតាមដាន និងត្រួតពិនិត្យប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនិងការប្រតិបត្តិតាមគោលការណ៍ នីតិវិធី និងសេចក្ដីណែនាំការការពារហានិភ័យក្នុងប្រតិបត្តិការធនាគារប្រចាំថ្ងៃ។ សវនកម្មផ្ទៃក្នុងមានភារៈរៀបចំផែនការសវនកម្ម ប្រតិបត្តិសវនកម្ម និងរាយការណ៍ផ្ទាល់ជូនគណៈកម្មាធិការសវនកម្ម ។

គ្រប់បញ្ហារកឃើញតាមរយៈការធ្វើសវនកម្មត្រូវមានរបាយការណ៍ និងអនុសាសន៍ច្បាស់លាស់ផ្តល់ជូនគណៈកម្មាធិការសវនកម្ម និងថ្នាក់គ្រប់គ្រង។ រាល់ការកែលម្អតាមអនុសាសន៍មិនទាន់បានអនុវត្តពេញលេញ ត្រូវបន្តធ្វើសវនកម្មតាមដានយ៉ាងតិចពីរដងក្នុងមួយឆ្នាំ ព្រមទាំងរាយការណ៍ជូនគណៈកម្មាធិការសវនកម្ម ។

សវនកម្មផ្ទៃក្នុងដឹកនាំគ្រប់គ្រងការប្រតិបត្តិប្រចាំថ្ងៃដោយគណៈប្រធាននាយិកាសវនកម្មផ្ទៃក្នុង ដែលមានភារៈជាលេខាធិការ និងទំនាក់ទំនងផ្ទាល់ជាមួយគណៈកម្មាធិការសវនកម្ម ។

គណៈកម្មាធិការសវនកម្មមានតួនាទីតាមដាន វាយតម្លៃ ជ្រើសរើស ចាត់តាំង និងបញ្ឈប់គណៈប្រធាននាយិកាសវនកម្មផ្ទៃក្នុង ។

#### ១.២ ការតែងតាំង និងការដកហូត/ការលាលែងតំណែងរបស់ប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង

ក្នុងឆ្នាំ ២០២០ តំណែងគណៈប្រធាននាយក/នាយិកាសវនកម្មផ្ទៃក្នុងមិនមានការតែងតាំងថ្មី ឬការលាលែងឡើយ។

### ២. សវនកម្មខាងក្រៅ

គណៈកម្មាធិការសវនកម្មមានតួនាទីតាមដាន វាយតម្លៃ ជ្រើសរើស និងបញ្ចប់កិច្ចសន្យាសវនកម្មខាងក្រៅតាមរយៈការផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាលសម្រេច ។ សវនកម្មខាងក្រៅរបស់ធនាគារ អេស៊ីលីដា ប្រចាំឆ្នាំ២០២០ដោយក្រុមហ៊ុន KPMG Cambodia Ltd ។

| ល រ | ឈ្មោះក្រុមហ៊ុន | កាលបរិច្ឆេទជ្រើសតាំង | តម្លៃសេវាសវនកម្ម | តម្លៃសេវាមិនមែនសវនកម្ម |
|---|---|---|---|---|
| ១ | KPMG Cambodia Ltd | ៩ មេសា ២០២០ | ២៩៥.៩០០ ដុល្លារអាមេរិក | - |
| ២ | Deloitte (Cambodia) Co., Ltd | ២៧ មេសា ២០២០ | - | ២១៧.៨០០ ដុល្លារអាមេរិក |
| ៣ | Grant Thornton Cambodia | ៣ វិច្ឆិកា ២០២០ | ១៩០.០០០ ដុល្លារអាមេរិក | - |

- KPMG Cambodiaមានកិច្ចព្រមព្រៀងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសនីមួយៗក្នុងឆ្នាំ ២០២០ និងសវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២០ ។
- Deloitte កិច្ចព្រមព្រៀងផ្តល់ប្រឹក្សាលើការអនុវត្ត Basel Implementation and Asset Liability Management ។
- Grant Thornton មានកិច្ចព្រមព្រៀងសវនកម្មរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសនីមួយៗ និងប្រចាំឆ្នាំ ២០២១ ។

# ផ្នែកទី៥

## ភាគីពាក់ព័ន្ធ

## ក. ការបង្ហាញគោលការណ៍ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម៖

| ល រ | ខ្លឹមសារ | គោលការណ៍ | សកម្មភាព |
|---|---|---|---|
| ១ | សុខុមាលភាពរបស់អតិថិជន | ១. លិខិតលេខៈ នទផ ០១៩/១៧ សេចក្តីសម្រេចស្តីពី ការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវនីតិវិធី ស្តីពីការថែរក្សាអតិថិជន និងជំរុញលក់ Cross-Selling & Up-Selling ។ | **១. ការថែរក្សាអតិថិជន៖**<br>• មានប្រព័ន្ធក្នុងការគ្រប់គ្រងទិន្នន័យអតិថិជនប្រកបដោយសុវត្ថិភាព និងសុក្រឹតភាព ។<br>• មានការកំណត់ប្រភេទអតិថិជនច្បាស់លាស់ ដើម្បីយកចិត្តទុកដាក់ក្នុងការថែរក្សាអតិថិជន រួមមាន៖<br>▪ អតិថិជនសក្តានុពល (Top 20) ជាប្រភេទ Platinum ទទួលបម្រើជា អាទិភាពទីមួយ<br>▪ អតិថិជនសក្តានុពល (Top 21 to 100) ជាប្រភេទ Gold ទទួលបម្រើជា អាទិភាពទីពីរ<br>▪ អតិថិជនធម្មតា ជាប្រភេទ Classic ទទួលបម្រើជា លក្ខណៈធម្មតា ។<br>• ដើម្បីទទួលបានប្រសិទ្ធភាពលើការជម្រុញថែរក្សាអតិថិជនខាងលើ យើងបានកំណត់នូវវិធីសាស្រ្តថែរក្សាអតិថនដែលស្របទៅនឹងចំណង់ចំណូលចិត្តអតិថិជនរួមជាមួយនឹងមធ្យោបាយ មួយចំនួនរួមមាន៖ ការផ្តល់អត្រាពិសេស, ការជូនប័ណ្ណជូនពរដល់អតិថិជននាឱកាសបុណ្យជាតិ, ការជូនវត្ថុអនុស្សាវរីយ៍ជូនអតិថិជន, ការអញ្ជើញអតិថិជនពិសារភោជនាហារជាដើម ។ មានផែនការច្បាស់លាស់ក្នុងការចុះថែរក្សាអតិថិជនប្រកបដោយប្រសិទ្ធភាព រួមមានដូចជា៖<br>▪ ការចុះថែរក្សាផ្ទាល់ និងថែរក្សាដោយប្រយោល (តាមទូរស័ព្ទ ឬមធ្យោបាយអេឡិចត្រូនិចជាដើម) ។<br>▪ ការវិភាគប្រតិបត្តិការ និងតម្រូវការអតិថិជន<br>• មានការកំណត់ភ្នាក់ងារទទួលខុសត្រូវតាមដាន និងដឹកនាំលើការអនុវត្តផែនការក្នុងការចុះថែរក្សាអតិថិជននៅតាមបណ្តាលសាខាច្បាស់លាស់ និងប្រកបដោយចំណេះជំនាញ ។<br>• មានរបាយការណ៍ស្តីពីការថែរក្សាអតិថិជនជូនថ្នាក់គ្រប់គ្រងអំពីលទ្ធផលការងារប្រចាំថ្ងៃ ។<br>• មានមន្ត្រីជំនាញនៃនាយកដ្ឋានទីផ្សារ ធ្វើការតាមដាន និងជម្រុញលើការចុះថែរក្សាអតិថិជន ដើម្បីឲ្យសម្រេចទៅតាមផែនការដែលបានកំណត់ ។<br><br>**២. ការជម្រុញលក់ Cross-Selling & Up-Selling**<br>• មានការកំណត់ផែនការ Cross-Selling & Up-Selling ច្បាស់លាស់ ដើម្បីជាមូលដ្ឋាន សម្រាប់ការជម្រុញលក់ជាមួយអតិថិជនសក្តានុពល និងអតិថិជនធម្មតាប្រកដដោយប្រសិទ្ធភាពខ្ពស់ ។<br>• មានភ្នាក់ងារទទួលខុសត្រូវច្បាស់លាស់ លើការជម្រុញលក់លើគ្រប់ផលិតផល-សេវាកម្ម ជាមួយគ្រប់ប្រភេទអតិថិជនទាំងក្នុង និងក្រៅការិយាល័យ ដើម្បីសម្រេច ឲ្យបានទៅតាមផែនការអាជីវកម្ម ។<br>• មានប្រព័ន្ធដើម្បីរក្សាទុកនូវ លទ្ធផលស្តីពីការជម្រុញលក់ Cross-Selling ដើម្បីឲ្យភ្នាក់ងារទទួលខុសត្រូវងាយស្រួលក្នុងការតាមដានជាប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។<br>• មានមន្ត្រីជំនាញនៃនាយកដ្ឋានទីផ្សារ ធ្វើការតាមដាន និងដឹកនាំលើការជម្រុញលក់ ដល់ភ្នាក់ងារទទួលខុសត្រូវនៅតាមបណ្តាលសាខា ដើម្បីឲ្យសម្រេចទៅតាមផែនការយុទ្ធសាស្រ្តដែលបានកំណត់ ។ |
| | | ២.សេចក្តីសម្រេចលេខ ធអក ១៣១/១៩ ចុះថ្ងៃព្រហស្បតិ៍ ៤រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ស្តីពីគោលការណ៍ប្រតិបត្តិស្តីពីការបម្រើអតិថិជន របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ | • យកចិត្តទុកដាក់បម្រើអតិថិជន<br>• មធ្យោបាយ និងដំណោះស្រាយបញ្ហា ត្អូញត្អែររបស់អតិថិជន<br>• ខ្នាតគំរូនៃការបម្រើអតិថិជន<br>• កំណារពារសុវត្ថិភាព (រក្សាការសម្ងាត់លើព័ត៌មានគណនី និងប្រតិបត្តិការរបស់អតិថិជនខាងក្នុង/ក្រៅ ដោយមិនត្រូវបញ្ចេញឲ្យភាគីតតិយជនណាមួយបានដឹងឡើយ) ។ |

| លរ | ខ្លឹមសារ | គោលការណ៍ | សកម្មភាព |
|---|---|---|---|
| ២ | ការជ្រើសរើសអ្នកផ្គត់ផ្គង់ | • គោលការណ៍ប្រតិបត្តិស្តីពីលទ្ធកម្ម<br>• គោលការណ៍ណែនាំស្តីពីលទ្ធកម្ម | • ការរៀបចំផែនការអាជីវកម្ម (ផែនការអចលនទ្រព្យ)<br>• របាយការណ៍វិភាគតម្រូវការដោយការិយាល័យគ្រប់គ្រងគម្រោង<br>• ការប្រជុំពិភាក្សានិងអនុម័តដោយគណៈកម្មាធិការគ្រប់គ្រងវិនិយោគ<br>• ការអនុម័តលើសំណើសុំទិញ<br>• ដំណើរការលទ្ធកម្ម/ដេញថ្លៃ<br>▪ ការប្រកាសដេញថ្លៃ/យកសម្រង់តម្លៃ<br>▪ ការត្រួតពិនិត្យឯកសារផ្លូវច្បាប់របស់អ្នកផ្គត់ផ្គង់<br>▪ សិទ្ធិលក់ផលិតផល (អាជ្ញាប័ណ្ណ)<br>▪ ការចុះត្រួតពិនិត្យដល់ទីតាំងលក់របស់អ្នកផ្គង់ផ្គង់ (ប្រសិនបើមាន)<br>▪ ចំណុចសំខាន់ៗក្នុងការវាយតម្លៃជ្រើសរើសអ្នកផ្គត់ផ្គង់ (តម្លៃ, គុណភាពផលិតផល, ឯកសារផ្លូវច្បាប់, ឯកសារបញ្ជាក់ការបង់ពន្ធ, របាយការណ៍ហិរញ្ញវត្ថុ, ធនធានមនុស្ស, លក្ខណសម្បត្តិទីប្រឹក្សា, វិធីសាស្ត្រអនុវត្ត, កេរ្តិ៍ឈ្មោះក្រុមហ៊ុន, គណនីទូទាត់, បទពិសោធន៍ការងារក្នុងករណីចាំបាច់)<br>• ការប្រជុំពិភាក្សា និងអនុម័តដោយគណៈកម្មាធិការលទ្ធកម្ម<br>• ការរៀបចំកិច្ចព្រមព្រៀង/កិច្ចសន្យា<br>• ការប្រគល់-ទទួលផលិតផល/សេវាកម្ម និងការទូទាត់ |
| ៣ | ការគ្រប់គ្រង និងការការពារនិយោជិត | ១- បទបញ្ជាផ្ទៃក្នុង និងអនុសញ្ញារួមនៃការងារ<br>២- គោលការណ៍ប្រតិបត្តិស្តីពីសុខុមាលភាពកម្មករនិយោជិត<br>៣-កំណារពារនិវេទនជន. | ១- ថ្លៃបម្រើការងារ, ថិរវេលាធ្វើការ, ប្រាក់ម៉ោងបន្ថែម, ថ្ងៃឈប់សម្រាក, សុវត្ថិភាពការងារ, សិទ្ធិរបស់និយោជិតក្នុងការការពារខ្លួន, ការបៀតបៀន, តំណាងប្រតិភូបុគ្គលិក<br>២- កំណារពារសុខុមាលភាពកម្មករនិយោជិត, ផាសុកភាព, បរិយាកាសការងារ, កន្លែងធ្វើការប្រកបដោយសុវត្ថិភាពបរិយាកាសភ្លឺថ្លា, ការសង្គ្រោះបន្ទាន់, ការឧបត្ថម្ភព្យាបាលជំងឺ និងការឧបត្ថម្ភបេសកម្មការងារ<br>៣- កម្មករនិយោជិតអាចធ្វើការរាយការណ៍អំពីបញ្ហា ដែលអាចបណ្តាលឲ្យប៉ះពាល់អត្ថប្រយោជន៍របស់ធនាគារ ជូននាយកដ្ឋាន/ ការិយាល័យ តាមការយល់ដឹងរបស់ពួកគេ។ បញ្ហាទាំងនោះរួមមានៈ<br>▪ ការមិនអនុវត្តស្របតាមបទប្បញ្ញត្តិ និងក្របខ័ណ្ឌច្បាប់<br>▪ ការមិនប្រកាន់ខ្ជាប់នូវគោលការណ៍ និងនីតិវិធីផ្ទៃក្នុងរបស់ធនាគារអេស៊ីលីដា<br>▪ ការកេងប្រវ័ញ្ច, ការលួច, ការកែបំបាត់ ឬកំរែរើជើងសារផ្សេងៗ<br>▪ សំណូក, ការក្លែងបន្លំ ឬការគ្រប់គ្រងមិនតម្លាភាព, បក្សពួកនិយម<br>▪ ឥរិយាបថដែលអាចបណ្តាលឲ្យប៉ះពាល់ផ្លូវចិត្ត និងសុវត្ថិភាពរបស់កម្មករនិយោជិត<br>▪ ឥរិយាបថមិនត្រឹមត្រូវ ឬគ្មានក្រមសីលធម៌<br>▪ បំពានសិទ្ធិអំណាច, បង្ខំ ឬរូបភាពណាមួយនៃការបំពាន និងការបៀតបៀនដទៃទៀត<br>▪ បទឧក្រិដ្ឋ ឬសកម្មភាពខុសច្បាប់ដទៃទៀត ។ល។ |

| ល.រ | ខ្លឹមសារ | គោលការណ៍ | សកម្មភាព |
|---|---|---|---|
| ៤ | ការគាំពារបរិស្ថាន | លិខិតលេខធអក៣៨៦/18ស្តីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវគោលការណ៍បរិស្ថាន សង្គម និង សហគមន៍ | • ធនាគារអនុវត្តតាមច្បាប់ពាក់ព័ន្ធទៅនឹងបរិស្ថាន បទប្បញ្ញត្តិស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ព្រមទាំងលក្ខណ្ឌតម្រូវផ្សេងៗ ដែលត្រូវបានដាក់កម្រិតអនុវត្ត នៅក្នុងប្រទេសនីមួយៗ។<br>• ធនាគារធ្វើប្រតិបត្តិការប្រកបដោយនិរន្តរភាព ដោយកាត់បន្ថយផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម តាមរយៈការលើកកម្ពស់ការអនុវត្តដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌ និងសេចក្តីណែនាំ ។<br>• ធនាគារមិនផ្តល់ប្រាក់កម្ចី ឬ ផ្តល់សេវាហិរញ្ញវត្ថុដល់អតិថិជនដែលពាក់ព័ន្ធនឹងសកម្មភាពដែលបង្កគ្រោះថ្នាក់ដល់បរិស្ថាន ឬដែលមានចែងក្នុងបញ្ជីអាជីវកម្មដែលត្រូវហាមឃាត់ របស់ធនាគារ អេស៊ីលីដានិង/ឬគោលការណ៍ពាក់ព័ន្ធផ្សេងទៀតឡើយ។<br>• ធនាគារធ្វើការជាមួយភ្នាក់ងារមានសមត្ថកិច្ច និង ទីប្រឹក្សាតាមការចាំបាច់ក្នុងការអនុវត្តគោលការណ៍ បរិស្ថានប្រកបដោយប្រសិទ្ធភាព ក្នុងករណីដែលមិនមានចែងក្នុងបទប្បញ្ញត្តិ យើងនឹងកំណត់គោលការណ៍ណែនាំមួយដោយអនុលោមទៅតាមឧត្តមានុវត្តន៍ ដែលទទួលស្គាល់ជាអន្តរជាតិ ។<br>• ធនាគារផ្តល់អាទិភាពទៅលើការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងរាល់កាកសំណល់ និងសារធាតុពុល ពីសកម្មភាពប្រតិបត្តិការរបស់ខ្លួន ។<br>• ធនាគារផ្តល់អាទិភាព ចំពោះប្រភពថាមពលកកើតឡើងវិញ និងថាមពលប្រកបដោយប្រសិទ្ធភាពតាមរយៈសេវាហិរញ្ញវត្ថុ។<br>• ធនាគារបន្តណែនាំឲ្យមានការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព ក្នុងអគារការិយាល័យរបស់ខ្លួន និងចាត់ចែងតម្រូវការប្រើប្រាស់ថាមពលឲ្យសមស្រប នៅគ្រប់កន្លែងប្រតិបត្តិការ ។ |
| ៥ | ការទំនាក់ទំនងសហគមន៍ | លិខិតលេខ ធអក ៣៨៦/18 ស្តីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវគោលការណ៍បរិស្ថាន សង្គម និងសហគមន៍ | • អេស៊ីលីដាយល់ថាការឧបត្ថម្ភគាំទ្រចំពោះ សហគមន៍ដែលយើងរស់នៅមិនត្រឹមតែជាសុជីវធម៌ប៉ុណ្ណោះទេ ប៉ុន្តែវានាំឲ្យធុរកិច្ចរបស់ខ្លួន បានរីកចម្រើន ។ សុខភាពល្អ និងភាពរុងរឿងរបស់យើងគឺពឹងផ្អែកគ្នាទៅវិញ ទៅមក ។<br>• អេស៊ីលីដាជឿជាក់ថា ធនាគារអាចសម្រេចគោលដៅធុរកិច្ចទៅបាន ដោយត្រូវធានាថាសកម្មភាពរបស់ខ្លួនស្របជាមួយទៅនឹងសេចក្តីត្រូវការរបស់សហគមន៍ប្រកបដោយសចីរភាព ដូចជា៖<br>  ▪ ការផ្តល់ផលិតផល និងសេវាដែលត្រឹមត្រូវ តាមរយៈការជ្រើសរើស និងការអភិវឌ្ឍដោយប្រុងប្រយ័ត្នដើម្បីសេចក្តីត្រូវការជាពិសេសរបស់សហគមន៍កម្ពុជា ។<br>  ▪ បង្កើនការផ្តល់សេវា៖ ផ្តល់សេវាធនាគារដល់សហគមន៍ថ្មី នៅទីកន្លែងថ្មីៗ តាមរយៈការពង្រីកបណ្តាញប្រតិបត្តិការនៅតាមខេត្ត និងសេវាធនាគារឌីជីថល និងសេវាបញ្ញើ-សន្សំ ។<br>  ▪ ចូលរួមកម្មវិធីផ្តល់ការអប់រំដល់សាធារណជនទាក់ទងនឹងហិរញ្ញវត្ថុ ដូច្នេះពួកគេអាចគ្រប់គ្រងធនធានរបស់ពួកគេប្រកបដោយប្រសិទ្ធភាព បង្កើនជំនាញធ្វើធុរកិច្ច និងបង្កើនគុណភាពចំពោះវិស័យធនាគារ និងហិរញ្ញវត្ថុ ។<br>  ▪ ផ្តល់កម្មសិក្សា និងការហ្វឹកហ្វឺនដល់និស្សិត ដើម្បីលើកកម្ពស់បរិយាប័នហិរញ្ញវត្ថុ ដល់សាធារណជនយ៉ាងទូលំទូលាយ ។<br>  ▪ ស្វែងរកការកំណត់បទដ្ឋានអភិបាលកិច្ចល្អ ការអនុវត្តដ៏ល្អបំផុតនិងតម្លាភាពដើម្បីលើកកម្ពស់បរិស្ថានហិរញ្ញវត្ថុ។<br>  ▪ ធ្វើការជាមួយក្រុមសហគមន៍ អាជ្ញាធរ និងភាគីពាក់ព័ន្ធដើម្បីអភិវឌ្ឍផលិតផល និងសេវាថ្មី ដើម្បីបំពេញសេចក្តីត្រូវការរបស់ពួកគេ ។<br>  ▪ ចូលរួមកម្មវិធីសប្បុរសធម៌ ដែលមានគោលដៅ ធ្វើឲ្យមនុស្សចេះជួយខ្លួនឯង ឬ ជួយតាមរយៈការសិក្សា ។ |

| លរ | ខ្លឹមសារ | គោលការណ៍ | សកម្មភាព |
|---|---|---|---|
| ៦ | ការការពារសិទ្ធិរបស់ម្ចាស់បំណុល | • គោលការណ៍ ស្តីពីក្រមប្រតិបត្តិ<br>• គោលការណ៍ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម | • បុគ្គលិកទាំងអស់របស់ធនាគារត្រូវអនុវត្តនូវក្រមសីលធម៌ក្នុងកម្រិតខ្ពស់បំផុតដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ។<br>• ធនាគារធានាការបង្ហាញព័ត៌មានសាជីវកម្មជូនដល់ភាគីពាក់ព័ន្ធ រួមទាំងម្ចាស់បំណុលបានត្រឹមត្រូវ។ |
| ៧ | កម្មវិធីប្រឆាំងអំពើពុករលួយ | • អនុសញ្ញារួមនៃការងារ<br>• បទប្បញ្ញត្តិផ្ទៃក្នុង<br>• របាយលម្អិត ស្តីពីកំហុសរបស់កម្មករនិយោជិត | ជូនដំណឹង និងបណ្តុះបណ្តាលដល់និយោជិតទាំងអស់ ពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ។ |

## ខ. ពិពណ៌នាអំពីទំនួលខុសត្រូវសង្គម ឆ្នាំ២០២០ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

| លរ | អ្នកទទួលផលប្រយោជន៍ | ទំហំនៃការបរិច្ចាគ | គោលបំណងនៃការបរិច្ចាគ |
|---|---|---|---|
| ១ | រាជរដ្ឋាភិបាលកម្ពុជា | ១.០០០.០០០.០០០ រៀល | បរិច្ចាគថវិកាដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការទិញវ៉ាក់សាំងការពារជំងឺកូវីដ១៩ ។ |
| ២ | រាជរដ្ឋាភិបាលកម្ពុជា | ៨០០.០០០.០០០ រៀល | ឧបត្ថម្ភដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំង និងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។ |
| ៣ | មូលនិធិគន្ធបុប្ផាកម្ពុជា | ១.២០០.០០០.០០០ រៀល | ឧបត្ថម្ភដល់មូលនិធិគន្ធបុប្ផាកម្ពុជា ។ |
| ៤ | រាជរដ្ឋាភិបាលកម្ពុជា និងសមាគមធនាគារនៅកម្ពុជា | ២០០.០០០ ដុល្លារអាមេរិក | ឧបត្ថម្ភដល់រាជរដ្ឋាភិបាលកម្ពុជា និងសមាគមធនាគារនៅកម្ពុជា សម្រាប់ជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះដោយសារទឹកជំនន់ ។ |
| ៥ | កាកបាទក្រហមកម្ពុជា | ៨០០.០០០.០០០ រៀល | ឧបត្ថម្ភដល់កាកបាទក្រហមកម្ពុជា ក្នុងកម្មវិធី អបអរខួបទី១៥៧ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២០ ។ |

# ផ្នែកទី៦

## ការបង្ហាញព័ត៌មាន និងតម្លាភាព

## ក. ការបង្ហាញព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម៖

| ល.រ | ព័ត៌មាន | មាន /គ្មានបង្ហាញ |
|---|---|---|
| ១ | ចក្ខុវិស័យ/ បេសកម្ម/ គោលដៅអាជីវកម្ម | មាន |
| ២ | សូចនាករហិរញ្ញវត្ថុ | មាន |
| ៣ | សូចនាការមិនមែនហិរញ្ញវត្ថុ | មាន |
| ៤ | កត្តាហានិភ័យសំខាន់ៗ | មាន |
| ៥ | គោលការណ៍ភាគលាភ | មាន |
| ៦ | ជីវប្រវត្តិរបស់អភិបាល | មាន |
| ៧ | ការបណ្តុះបណ្តាលសម្រាប់អភិបាល | មាន |
| ៨ | ចំនួនកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ៩ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មាន |
| ១០ | លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ | មាន |

## ខ. ពិពណ៌នាអំពីយន្តការនៃការបង្ហាញព័ត៌មាន ដោយរៀបរាប់ពីមធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន

ធនាគារបានអនុម័តនូវគោលការណ៍ ស្តីពីការបង្ហាញព័ត៌មាន ដែលបង្ហាញពីវិធីសាស្ត្រក្នុងការកំណត់នូវព័ត៌មានសំខាន់ និងដើម្បីធានាថាព័ត៌មានសាជីវកម្មត្រូវបានបង្ហាញទៅអាជ្ញាធរពាក់ព័ន្ធ វិនិយោគិន អតិថិជន ម្ចាស់កម្ចី កម្មករនិយោជិត និងសាធារណជន បានទាន់ពេលវេលា ត្រឹមត្រូវ គ្រប់គ្រាន់ ងាយយល់ និងមានលក្ខណៈសមស្រប។

ដើម្បីអនុវត្តស្របតាមប្រកាសរបស់ គ.ម.ក. (បច្ចុប្បន្នជា និយ័តករមូលបត្រកម្ពុជា "ន.ម.ក.") លេខៈ ០០៧/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម ធនាគារបានតែងតាំង និងបានទទួលស្គាល់ដោយ គ.ម.ក. (បច្ចុប្បន្នជា និយ័តករមូលបត្រកម្ពុជា "ន.ម.ក.") នូវមន្ត្រីទំនាក់ទំនងសាធារណៈ មន្ត្រីទទួលបន្ទុកផ្តល់ព័ត៌មាន និងជំនួយការមន្ត្រីទទួលបន្ទុកផ្តល់ព័ត៌មាន នូវសមាសភាពដូចខាងក្រោម៖

### មន្ត្រីទំនាក់ទំនងសាធារណៈ

| ល.រ | ឈ្មោះ | តំណែង |
|---|---|---|
| ១ | អ្នកស្រី ម៉ារ អមរា | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ |

### មន្ត្រីទទួលបន្ទុកផ្តល់ព័ត៌មាន

| ល.រ | ឈ្មោះ | តំណែង |
|---|---|---|
| ១ | អ្នកស្រី ប៊ុត ប៊ុនសីហា | អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន |

### ជំនួយការមន្ត្រីទទួលបន្ទុកផ្តល់ព័ត៌មាន

| ល.រ | ឈ្មោះ | តំណែង |
|---|---|---|
| ១ | លោក សុង ផាន់នូ | ជំនួយការនាយកប្រតិបត្តិលេខាធិការក្រុមហ៊ុន និងបង្ហាញព័ត៌មាន |
| ២ | អ្នកស្រី លាង ច័ន្ទដារ៉ា | ជំនួយការនាយកប្រតិបត្តិលេខាធិការក្រុមហ៊ុន និងបង្ហាញព័ត៌មាន |
| ៣ | លោក លី សុទ្ធារិទ្ធិ | ប្រធានផ្នែកបង្ហាញព័ត៌មាន |

## គ. ទំនាក់ទំនងជាមួយវិនិយោគិន

### ១. ការបង្ហាញយន្តការ និងនីតិវិធីទំនាក់ទំនងជាមួយវិនិយោគិន

ធនាគារ អេស៊ីលីដា មានបណ្តាញទំនាក់ទំនងយ៉ាងទូលំទូលាយ ដើម្បីធ្វើទំនាក់ទំនងជាមួយនឹងអតិថិជនរបស់ខ្លួន ក៏ដូចជាវិនិយោគិន រួមមាន គេហទំព័រ អ៊ីម៉ែល ទូរស័ព្ទ ការជួបដោយផ្ទាល់ និងការអញ្ជើញភាគហ៊ុនិក ដើម្បីចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក។

### ២. ពិពណ៌នាដោយសង្ខេបអំពីទំនាក់ទំនងវិនិយោគិនក្នុងឆ្នាំ២០២០

ធនាគារ អេស៊ីលីដា គឺជាធនាគារពាណិជ្ជទីមួយ ដែលបានចុះបញ្ជីលក់ភាគហ៊ុនរបស់ខ្លួនក្នុងផ្សារមូលបត្រកម្ពុជា នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ដែលបានទាក់ទាញចំណាប់អារម្មណ៍យ៉ាងខ្លាំងពីសាធារណជន និងវិនិយោគិនទាំងក្នុងស្រុក និងបរទេស។ ចាប់ពីពេលចុះបញ្ជីលក់ភាគហ៊ុនក្នុងផ្សារមូលបត្រកម្ពុជា រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារ អេស៊ីលីដា បានទទួល និងឆ្លើយសំណួរជាច្រើន ពីសាធារណជន និងវិនិយោគិន ព្រមទាំងបានអញ្ជើញភាគហ៊ុនិក ដើម្បីចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ ដែលបានរៀបចំឡើងនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី
# និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ហិរញ្ញវត្ថុរួម
និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០
និង
របាយការណ៍របស់សវនករឯករាជ្យ

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

**របាយការណ៍ហិរញ្ញវត្ថុរួម និង របាយការណ៍ហិរញ្ញវត្ថុដោយឡែក**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០**

# មាតិកា


| | ទំព័រ |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ - ៨ |
| របាយការណ៍របស់សវនករឯករាជ្យ | ៩ - ១៤ |
| របាយការណ៍ហិរញ្ញវត្ថុ៖ | |
| របាយការណ៍ហិរញ្ញវត្ថុរួម៖ | |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម | ១៥ |
| របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម | ១៦ - ១៧ |
| របាយការណ៍បម្រែបម្រួលមូលធនរួម | ១៨ - ១៩ |
| របាយការណ៍លំហូរសាច់ប្រាក់រួម | ២០ - ២១ |
| របាយការណ៍ហិរញ្ញវត្ថុដោយឡែក៖ | |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដោយឡែក | ២២ |
| របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗដោយឡែក | ២៣ |
| របាយការណ៍បម្រែបម្រួលមូលធនដោយឡែក | ២៤ - ២៥ |
| របាយការណ៍លំហូរសាច់ប្រាក់ដោយឡែក | ២៦ - ២៧ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ២៨ - ២១១ |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរួម របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ហៅកាត់ថា ("ធនាគារ") និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (ដែលតទៅនេះ ទាំងធនាគារ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវហៅកាត់ថា "សម្ព័ន្ធធនាគារ") និង របាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ (ដែលតទៅនេះ ហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ")។

## អំពីធនាគារ

មុនថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយធ្វើប្រតិបត្តិការជាធនាគារឯកទេស ដែលមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ និងមានសាខាចំនួន១៥ក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណដល់ធនាគារ ជាធនាគារពាណិជ្ជឯកជន សម្រាប់រយៈពេលបីឆ្នាំ គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ អាជ្ញាប័ណ្ណរបស់ធនាគារ ត្រូវបានប្តូរសាជាថ្មីម្តងទៀត ទៅជាអាជ្ញាប័ណ្ណអចិន្ត្រៃយ៍។ ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ធនាគារ អាចបង្កើតការិយាល័យបន្ថែមទាំងក្នុង និងក្រៅប្រទេស ព្រមទាំងអាចផ្លាស់ប្តូរទីតាំងការិយាល័យ ដែលបានចុះបញ្ជីរួចហើយ ដោយចុះបញ្ជីការផ្លាស់ប្តូរទាំងនោះ នៅក្រសួងពាណិជ្ជកម្ម និងត្រូវមានការអនុម័តយល់ព្រមពីធនាគារជាតិ នៃ កម្ពុជា។

## សកម្មភាពអាជីវកម្មចម្បង

ធនាគារធ្វើប្រតិបត្តិការក្រោមបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃ កម្ពុជា ដោយផ្តោតជាពិសេសលើការផ្តល់ឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗទៀត សម្រាប់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាសហគ្រាសធុនតូច និង មធ្យម ព្រមទាំងសកម្មភាពអាជីវកម្មដទៃទៀត ដែលក្រុមប្រឹក្សាភិបាលជឿជាក់ថាគាំទ្រដល់គោលបំណងនេះ។

## ព្រឹត្តិការណ៍សំខាន់ៗ

*ការបោះផ្សាយមូលបត្រកម្មសិទ្ធិ ជាសាធារណៈដំបូង ("IPO")*

នៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០២០ ធនាគារទទួលបានការអនុម័ត ជាគោលការណ៍សម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិ ជាសាធារណៈដំបូង ("IPO") ពីក្រុមប្រឹក្សាភិបាលរបស់គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.)។ ធនាគារ និង ក្រុមហ៊ុនធានាទិញមូលបត្រ យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី ("YSC") បានបើកដំណើរការប៊ុកបៀលឌីង (Book Building) ពីថ្ងៃទី០៣ ដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២០។ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ លទ្ធផលនៃប៊ុកបៀលឌីងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដោយមានការចូលរួមពីអ្នកវិនិយោគិនចំនួន ២.១៨០នាក់ ក្នុងនោះមានវិនិយោគិនក្នុងស្រុកចំនួន ៩៥,៥៥% និងវិនិយោគិនបរទេសចំនួន ៤,៤៥%។



ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## ព្រឹត្តិការណ៍សំខាន់ៗ (ត)

*ការបោះផ្សាយមូលបត្រកម្មសិទ្ធិ ជាសាធារណៈដំបូង ("IPO") (ត)*

តម្លៃភាគហ៊ុនចុងក្រោយដែលបានកំណត់ ដោយអនុលោមតាមនីតិវិធីស្តីពីការធ្វើប៊ុកបៀលនឹង និងការធ្វើបរិវិសកម្ម ដែលបានអនុម័តដោយគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) គឺ ១៦.២០០ រៀល (៣,៩៧ ដុល្លារអាមេរិក)។

ដំណើរការបរិវិសកម្ម ចាប់ផ្តើមពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២០ ដល់ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ហើយលទ្ធផលនៃការធ្វើបរិវិសកម្មត្រូវបានផ្សព្វផ្សាយ ជាសាធារណៈនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ដែលក្នុងនោះមានភាគហ៊ុនចំនួន ៤.៣៨៤.៨៦៥ ភាគហ៊ុន ត្រូវបានធ្វើបរិវិសកម្ម។

ភាគហ៊ុនរបស់ធនាគារ ត្រូវបានចុះបញ្ជី នៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជានៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់សម្ព័ន្ធធនាគារ និង ធនាគារ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម និង របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗដោយឡែកនៅលើទំព័រទី១៦ - ១៧ និងទំព័រទី២៣ ។

## ដើមទុន និង បុព្វលាភភាគហ៊ុន

ដើមទុន និងបុព្វលាភភាគហ៊ុនត្រូវបានចាត់ថ្នាក់ជាមូលធន។ ចំណាយប្រតិបត្តិការទាក់ទងដោយផ្ទាល់លើការបោះផ្សាយដើមទុនថ្មី ត្រូវបានបង្ហាញក្នុងមូលធនបន្ទាប់ពីបានកាត់ពន្ធពីសាច់ប្រាក់ទទួលបានពីការលក់ភាគហ៊ុន។ ព័ត៌មានលម្អិតនៃភាគហ៊ុនត្រូវបានបង្ហាញដូចខាងក្រោមៈ

| | ចំនួនទឹកប្រាក់ | |
|---|---|---|
| | ជាដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៥) |
| នាថ្ងៃទី ១ ខែមករា ឆ្នាំ២០២០ | ៤២៨.៨១៨.១៥៤ | ១.៧៤៧.៤៣៣.៩៧៨ |
| *សាច់ប្រាក់បានមកពីការបោះផ្សាយភាគហ៊ុនថ្មី* | *១៧.០៨២.១០៥* | *៦៩.៦៤៣.៧៤២* |
| *ថ្លៃដើមប្រតិបត្តិការ* | *(១.០៣១.០២៥)* | *(៤.២០៣.៤៨៨)* |
| សាច់ប្រាក់ទទួលបាន - សុទ្ធ | ១៦.០៥១.០៨០ | ៦៥.៤៤០.២៥២ |
| ជាបុព្វលាភភាគហ៊ុន | (១១.៧០៦.២១៥) | (៤៧.៧២៦.២៣៩) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១៣.០០៣.៥៨១) |
| នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០ | ៤៣៣.១៦៣.០១៩ | ១.៧៥២.១៩៤.៤១២ |

នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ធនាគារបានចុះបញ្ជីភាគហ៊ុនរបស់ខ្លួននៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក)។ ចំនួនភាគហ៊ុនថ្មីដែលបានបោះផ្សាយ មានចំនួន ៤.៣៨៤.៨៦៥ ភាគហ៊ុន ដែលមានតម្លៃចារឹក ៤.០០០ (០,៩៨ ដុល្លារអាមេរិក) ក្នុងមួយភាគហ៊ុន នឹងតម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង ១៦.២០០ (៣,៩៧ ដុល្លារអាមេរិក) រៀលក្នុងមួយភាគហ៊ុន។ ភាគហ៊ុនដែលបោះផ្សាយទាំងអស់ត្រូវបានទូទាត់រួចរាល់។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តរវាងទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទានអាក្រក់ និងឥណទានសង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការជម្រះបុរេប្រទាន និងឥណទានអាក្រក់ចេញពីបញ្ជី ឬការធ្វើសំវិធានធនបុរេប្រទាន និងឥណទានសង្ស័យ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់បុរេប្រទាន និងឥណទានអាក្រក់ទាំងអស់ដែលបានដឹង ត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនពេញលេញសម្រាប់បុរេប្រទាន និងឥណទានអាក្រក់ និងសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីស្ថានភាពណាមួយដែលនាំឲ្យចំនួនឥណទាន និងបុរេប្រទានអាក្រក់ដែលបានជម្រះចេញពីបញ្ជី ឬសំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងសង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

## ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាល បានចាត់វិធានការ ដែលមានមូលដ្ឋានសមស្របដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មទាំងឡាយដែលទំនងជាមិនអាចបម្រើនៅក្នុងប្រតិបត្តិការអាជីវកម្មទៅតាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រើប្រាស់និងទទួលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការវាយតម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ថាមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## វិធីសាស្ត្រវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ហើយអាចបណ្តាលឲ្យប៉ះពាល់ដល់វិធីសាស្ត្រកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ មានភាពមិនត្រឹមត្រូវ ឬមិនសមស្របជាសារវន្តនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗទៀត

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះពុំមាន៖

(ក) បន្ទុកណាមួយលើទ្រព្យសកម្មរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលបានកើតឡើងចាប់តាំងពីចុងការិយបរិច្ឆេទមក ដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ និង

## ធនាគារ អេស៊ីលីដា ភីអិលស៊ី

### បំណុលយថាភាព និងបំណុលផ្សេងៗទៀត (ត)

(ខ) បំណុលយថាភាពណាមួយដែលកើតមាន ឬអាចនឹងកើតមានឡើងចំពោះសម្ព័ន្ធធនាគារ និងធនាគារ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារឡើយ ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀតរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែបន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទដែលនឹងមាន ឬអាចនឹងមានប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់សងនោះទេ។

### ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលមិនបានកែតម្រូវ ឬក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលនឹងបណ្តាលឲ្យចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

### ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយលើកលែងការផ្ទុះឡើងនូវ ណូវែលវីរុសកូរ៉ូណា ("កូវីដ-១៩")។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងជំណាច់ឆ្នាំនេះ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

*វីរុសកូរ៉ូណា និងផលប៉ះពាល់លើការខាតបង់ឥណទានរំពឹងទុក*

ការខាតបង់ឥណទានរំពឹងទុក ត្រូវបានប៉ាន់ប្រមាណដោយផ្អែកទៅលើលក្ខខណ្ឌសេដ្ឋកិច្ច ដែលបានព្យាករណ៍មួយចំនួននៅក្នុងការិយបរិច្ឆេទរាយការណ៍។ ការផ្ទុះឡើងនៃ ណូវែលវីរុសកូរ៉ូណា ("កូវីដ-១៩") បានរាលដាលលើប្រទេសចិនដីគោក កម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត ធ្វើឲ្យមានការរាំងស្ទះសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ផលប៉ះពាល់លើផលិតផលក្នុងស្រុកសរុប (ផ.ស.ស) និងសូចនករសំខាន់ផ្សេងៗ ត្រូវបានពិចារណាក្នុងការកំណត់ភាពធ្ងន់ធ្ងរ និងលទ្ធភាពនៃការធ្លាក់ចុះនៃសេដ្ឋកិច្ចដែលប្រើប្រាស់ក្នុងការព្យាករណ៍ការខាតបង់ឥណទានរំពឹងទុក ដែលក្នុងនោះការគណនានៃការខាតបង់ឥណទានរំពឹងទុក នៅស្ថានភាពបច្ចុប្បន្នអាចមានភាពមិនជាក់លាក់។ អ្នកគ្រប់គ្រងព្យាករណ៍ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើសម្ព័ន្ធធនាគារ និងធនាគារ ប៉ុន្តែការព្យាករណ៍អាចនឹងមានការផ្លាស់ប្តូរជាសារវន្ត ពេលមានព្រឹត្តិការណ៍ថ្មីកើតឡើង។ មើលកំណត់សម្គាល់លេខ ៣ (ខ) សម្រាប់លម្អិតបន្ថែម។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## ក្រុមប្រឹក្សាភិបាល និង គណៈកម្មាធិការប្រតិបត្តិ

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការក្នុងការិយបរិច្ឆេទរាយការណ៍ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន៖

| | |
|---|---|
| ▪ លោក ឆាយ សឿន | ប្រធានក្រុមប្រឹក្សាភិបាល (អភិបាលមិនប្រតិបត្តិ) |
| ▪ បណ្ឌិត អ៊ិន ចាន់នី | សមាជិក (អភិបាលប្រតិបត្តិ) |
| ▪ លោក វ័ត្ត យូម៉េង | សមាជិក (អភិបាលប្រតិបត្តិ) |
| ▪ លោក Kenichiro Mori | សមាជិក (អភិបាលមិនប្រតិបត្តិ) |
| ▪ អ្នកនាង Mirjam Janssen | សមាជិក (អភិបាលមិនប្រតិបត្តិ) |
| ▪ លោក Stéphane Mangiavacca | សមាជិក (អភិបាលមិនប្រតិបត្តិ) |
| ▪ បណ្ឌិត Pieter Kooi | សមាជិក (អភិបាលឯករាជ្យ) |
| ▪ លោក Ian Samuel Lydall | សមាជិក (អភិបាលឯករាជ្យ) |
| ▪ លោក Van Sou Ieng | សមាជិក (អភិបាលឯករាជ្យ)<br>(បានតែងតាំងនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២០) |

សមាជិកគណៈកម្មាធិការប្រតិបត្តិដែលបានបម្រើការក្នុងការិយបរិច្ឆេទរាយការណ៍ និងនាថ្ងៃចេញរបាយការណ៍នេះរួមមាន៖

| | |
|---|---|
| ▪ បណ្ឌិត អ៊ិន ចាន់នី | ប្រធាននាយកប្រតិបត្តិ |
| ▪ បណ្ឌិត សូ ផនណារី | អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ |
| ▪ លោកស្រី ម៉ារ អមរា | អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ |
| ▪ លោក វ័ត្ត យូម៉េង | អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល |
| ▪ លោក លី ថៃ | អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច |
| ▪ លោកស្រី ប៊ុត ប៊ុនសីហា | អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និង លេខាធិការក្រុមហ៊ុន |
| ▪ លោក ម៉ាច់ ធារី | អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា |
| ▪ បណ្ឌិត ឡឹង សុភាព | អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## ការទទួលខុសត្រូវរបស់ប្រធាននាយកប្រតិបត្តិ លើរបាយការណ៍ហិរញ្ញវត្ថុ

ប្រធាននាយកប្រតិបត្តិ ដោយមានការផ្តល់ប្រឹក្សាពីគណៈកម្មាធិការប្រតិបត្តិ ទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយមានការផ្តល់ប្រឹក្សាពីគណៈកម្មាធិការប្រតិបត្តិ ប្រធាននាយកប្រតិបត្តិ ចាំបាច់ត្រូវ៖

(i) អនុម័តគោលនយោបាយគណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តឲ្យមានសង្គតិភាព។

(ii) អនុវត្តតាមតម្រូវការលាតត្រដាងព័ត៌មាន ដែលអនុលោមទៅតាម ស.រ.ទ.ហ.អ.ក ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឲ្យមានភាពពិត និងត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបង្ហាញ ពន្យល់ និងកំណត់បរិមាណឲ្យបានសមស្រប នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(iii) រក្សាទុកកំណត់ត្រាគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

(iv) រៀបចំរបាយការណ៍ហិរញ្ញវត្ថុក្នុងការបន្តនិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមិនមានភាពសមស្រប ដែលសន្មតថាសម្ព័ន្ធធនាគារ និងធនាគារ នឹងបន្តនិរន្តរភាពនៃដំណើរការអាជីវកម្មនាពេលអនាគត និង

(v) ត្រួតពិនិត្យ និងដឹកនាំសម្ព័ន្ធធនាគារ និងធនាគារឲ្យមានប្រសិទ្ធភាព តាមការសម្រេចចិត្តជាសារវន្តទាំងអស់ ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងដំណើរការរបស់សម្ព័ន្ធធនាគារ និងធនាគារ ហើយត្រូវប្រាកដថា កិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## ការទទួលខុសត្រូវរបស់ប្រធាននាយកប្រតិបត្តិ លើរបាយការណ៍ហិរញ្ញវត្ថុ (ត)

ប្រធាននាយកប្រតិបត្តិ ធានាអះអាងថា សម្ព័ន្ធធនាគារ និងធនាគារ បានអនុវត្តតាមរាល់តម្រូវការដូចបាន រាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

**លោកស្រី ម៉ារ អមរា**
*អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ*

**បណ្ឌិត អ៊ិន ចាន់នី**
*ប្រធាននាយកប្រតិបត្តិ*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី៖ 25 FEB 2021

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងកំណត់សម្គាល់ទាំងឡាយដែលភ្ជាប់មកជាមួយដូចដែលបានបង្ហាញនៅទំព័រទី ១៥ ដល់ទី ២១១ ថាបានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាម ស.រ.ទ.ហ.អ.ក ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

*ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។*

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

**លោក ឆាយ សឿន**
*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី៖ 25 FEB 2021

KPMG Cambodia Ltd
4th Floor, Delano Center
No. 144, Street 169, Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia
+855 23 216 899 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យ
## ជូនចំពោះភាគហ៊ុនិក ធនាគារ អេស៊ីលីដា ភីអិលស៊ី

### *មតិសវនកម្ម*

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ហៅកាត់ថា ("ធនាគារ") និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ ដែលតទៅនេះទាំងធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវហៅកាត់ថា ("សម្ព័ន្ធធនាគារ") និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ធនាគារ ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និងដោយឡែក នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងលំហូរសាច់ប្រាក់រួម និងដោយឡែក សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី១៥ ដល់ទី២១១ (ហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ")។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។

### *មូលដ្ឋាននៃមតិសវនកម្ម*

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("ស.ស.អ.ក")។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី *ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីសម្ព័ន្ធធនាគារ និងធនាគារ ដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

KPMG Cambodia Ltd., a Cambodian single member private limited company and a member firm of the KPMG global organization of independent member firms affiliated with KPMG International Limited, a private English company limited by guarantee. All rights reserved.

KPMG

## *បញ្ហាសំខាន់ៗក្នុងការធ្វើសវនកម្ម*

បញ្ហាសំខាន់ៗ ក្នុងការធ្វើសវនកម្ម គឺជាបញ្ហាមួយដែលតាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំ កំណត់ថាជាបញ្ហាសំខាន់បំផុតក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរួម និងដោយឡែក សម្រាប់ការិយបរិច្ឆេទបច្ចុប្បន្ន។ បញ្ហាទាំងនេះត្រូវបានដោះស្រាយក្នុងបរិបទនៃការធ្វើសវនកម្មនិងជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុរួមនិងដោយឡែក ទាំងមូល ដោយមិនមានការបញ្ចេញមតិសវនកម្មដាច់ដោយឡែកសម្រាប់បញ្ហានេះទេ។

| **បញ្ហាសំខាន់ៗក្នុងការធ្វើសវនកម្ម** | **វិធីដែលបញ្ហានេះត្រូវបានដោះស្រាយក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ** |
|---|---|
| *ការខាតបង់ឥណទានរំពឹងទុក*<br><br>នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ សម្ព័ន្ធធនាគារ និងធនាគារ មានឥណទានដែលបានផ្តល់ជូនអតិថិជន ចំនួនស្មើនឹង ៦៨,២៥% និង៦៧,២៩% នៃទ្រព្យសកម្មសរុបរៀងគ្នា។<br><br>ស.រ.ហ.អ.ក ៩ "ឧបករណ៍ហិរញ្ញវត្ថុ" បានដាក់ចេញនូវម៉ូដែលក្នុងការកំណត់ សំវិធានធនលើការរំពឹងទុកលើការខាតបង់ឥណទាន លើទ្រព្យសកម្មដែលបានវាស់វែងតាមរំលស់ថ្លៃដើម។<br><br>សម្ព័ន្ធធនាគារ និងធនាគារ បានបង្កើតម៉ូដែលសម្រាប់កំណត់សំវិធានធនលើសម្ពាធឥណទានទាំងនេះ។ ការវិនិច្ឆ័យជាសារវន្ត ត្រូវបានយកមកប្រើក្នុងការបង្កើតម៉ូដែលទាំងនេះ និងកំណត់ធាតុចូលនិងការសន្មត់ផ្សេងៗដែលមានទំនាក់ទំនងគ្នា។<br><br>ចំពោះសម្ពាធឥណទានដែលមិនទាន់មានឱនភាពនៃតម្លៃ ការសន្មត និងការវិនិច្ឆ័យត្រូវបានតម្រូវឲ្យយកមកប្រើក្នុងចំណុចដូចខាងក្រោម៖<br><br>• បង្កើតប៉ារ៉ាម៉ែត្រម៉ូដែល នៃការរំពឹងទុកលើការខាតបង់ឥណទាន (ECL) ដែលរួមមាន ប្រូបាប៊ីលីតេនៃការខកខានសង (PD) ការបាត់បង់ដែលបណ្តាលមកពីការខកខានសង (LGD) និងទំហំនៃការខកខានសង (EAD)<br><br>• ការជ្រើសរើសយកលក្ខណៈវិនិច្ឆ័យ ដើម្បីកំណត់ថាតើសម្ពាធឥណទានបានកើតឡើងជាសារវន្ត នូវហានិភ័យឥណទាន ដែលនាំឲ្យមានការគណនាសំវិធានធន សម្រាប់ពេញមួយអាយុកាល (Life-time ECL) និង | យើងខ្ញុំបានធ្វើតេស្តលើការបង្កើត ការអនុវត្ត និងប្រសិទ្ធភាពប្រតិបត្តិការ នៃការគ្រប់គ្រងសំខាន់ៗទាក់ទងនឹងការកំណត់សំវិធានធនលើការរំពឹងទុក លើការខាតបង់ឥណទាន។<br><br>យើងខ្ញុំក៏មានការចូលរួមពី អ្នកឯកទេសព័ត៌មានវិទ្យា ("IT Specialist") ដើម្បីពិនិត្យលើរបាយការណ៍ឥណទានហួសកាលកំណត់សង ព្រមទាំងសិទ្ធិក្នុងការចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា និងការត្រួតពិនិត្យការគ្រប់គ្រងលើការផ្លាស់ប្តូរ។<br><br>ដើម្បីធ្វើឲ្យប្រាកដលើភាពត្រឹមត្រូវ នៃធាតុចូលសំខាន់ៗ របស់របាយការណ៍ឥណទានហួសកាលកំណត់សង យើងខ្ញុំក៏បានធ្វើការពិនិត្យឥណទានមួយចំនួន ធៀបទៅនឹងសក្ខីបត្រដើម។<br><br>យើងខ្ញុំបានវាយតម្លៃលើភាពសមស្រប នៃលក្ខណៈវិនិច្ឆ័យ ដែលបានយកមកប្រើប្រាស់ដើម្បីកំណត់លើការកើនឡើងជាសារវន្តនៃហានិភ័យឥណទាន។<br><br>យើងខ្ញុំ ក៏មានការចូលរួមពីសំណាក់អ្នកឯកទេសវាយតម្លៃ ការខាតបង់ឥណទាន ("ECL Specialist") លើចំណុចដូចខាងក្រោម៖<br><br>• ត្រួតពិនិត្យការធ្វើចំណាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ<br><br>• ត្រួតពិនិត្យការកាត់បំណែងចែកក្នុងការធ្វើម៉ូដែលលើការខាតបង់ឥណទានរបស់សម្ព័ន្ធធនាគារ និងធនាគារ |

KPMG

| បញ្ហាសំខាន់ៗក្នុងការធ្វើសវនកម្ម | វិធីដែលបញ្ហានេះត្រូវបានដោះស្រាយក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ |
|---|---|
| • ការកំណត់កត្តាម៉ាក្រូសេដ្ឋកិច្ចផ្សេងៗ ដែលពាក់ព័ន្ធ ដើម្បីយកទៅប្រើជាមួយម៉ូដែលនោះ។<br><br>ការវិនិច្ឆ័យ និងការប៉ាន់ស្មានរបស់អ្នកគ្រប់គ្រងចំពោះសម្ភាធឥណទាន ដែលមានឱនភាពនៃតម្លៃ ("credit impaired exposures") មានដូចជា: (i) ការកំណត់សម្ភាធឥណទានដែលមានឱនភាពនៃតម្លៃ (ii) ការប៉ាន់ស្មានទឹកប្រាក់ដែលអាចប្រមូលបានមកវិញ (iii) ការកំណត់តម្លៃទ្រព្យធានា និងពេលវេលានៃលំហូរសាច់ប្រាក់ដែលបានរំពឹងទុក ក្នុងករណីដែលអាចកំណត់បាន។<br><br>ដោយសារតែ លក្ខណៈជាសារវន្តនៃឥណទានដែលបានផ្តល់ជូនអតិថិជន និងភាពមិនប្រាកដប្រជានៃការប៉ាន់ស្មានដែលពាក់ព័ន្ធនឹងសំវិធានធនលើការរំពឹងទុកលើការខាតបង់ឥណទាន ឱនភាពនៃតម្លៃនៃឥណទានដែលបានផ្តល់ជូនអថិជនត្រូវបានចាត់ទុកជាបញ្ហាសំខាន់ក្នុងការធ្វើសវនកម្ម។ | • វាយតម្លៃលើអនុលោមភាពនៃវិធីសាស្ត្រ ដែលយកមកប្រើដើម្បី បង្កើតម៉ូដែលសម្រាប់កំណត់ការខាតបង់ឥណទានរំពឹងទុកទៅលើសម្ភាធឥណទានសំខាន់ៗមួយចំនួន ដោយធ្វើការប្រៀបធៀបជាមួយនឹងតម្រូវការរបស់ ស.រ.ហ.អ.ក ៩ និង<br>• ត្រួតពិនិត្យលើការគណនាលើការរំពឹងទុកលើការខាតបង់ឥណទាន សម្រាប់ឥណទានដែលបានជ្រើសរើស។<br><br>យើងខ្ញុំក៏បានវាយតម្លៃលើភាពសមស្របនៃការយកមកប្រើសេណារីយ៉ូសេដ្ឋកិច្ចតាមកំរិតថ្លឹងប្រូបាប៊ីលីតេក្នុងម៉ូដែល រួមទាំងការកែតម្រូវបន្ថែមរបស់អ្នកគ្រប់គ្រងសម្រាប់គណនីដែលមានឱនភាពនៃតម្លៃ (ដំណាក់កាលទី៣) និងគណនីដែលមិនទាន់មានឱនភាពនៃតម្លៃ (ដំណាក់កាលទី១ និងទី២)។<br><br>យើងខ្ញុំបានធ្វើការគណនាឡើងវិញដោយឯករាជ្យ នូវចំនួនសំវិធានធន លើការរំពឹងទុក លើការខាតបង់ឥណទាន លើគំរូឥណទានមួយចំនួន ដើម្បីផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវនៃការគណនា ដែលធ្វើឡើងដោយសម្ព័ន្ធធនាគារ និងធនាគារ។ |

## *ព័ត៌មានផ្សេងៗ*

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ ជាព័ត៌មាននៅក្នុងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី១ ដល់ទី៨។

មតិរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ។

ការទទួលខុសត្រូវរបស់យើងខ្ញុំ ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុឬការយល់ដឹងរបស់យើងខ្ញុំដែលទទួលបាននៅក្នុងការធ្វើសវនកម្មឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

KPMG

## *ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច*

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការសម្ព័ន្ធធនាគារ និងធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ។

## *ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ*

គោលដៅរបស់យើងខ្ញុំ គឺទទួលបាននូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលមតិរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈជាគុនិយម ក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របជាមូលដ្ឋានសម្រាប់មតិរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្ត ដែលកើតឡើងដោយសារតែការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការសមគំនិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនាការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់សម្ព័ន្ធធនាគារ និងធនាគារឡើយ។

KPMG

- ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។

- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃ ការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង និងដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់សារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារ ដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថាមានភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើង យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវធ្វើការកែប្រែមតិរបស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យសម្ព័ន្ធធនាគារ និងធនាគារបញ្ឈប់និរន្តរភាពនៃអាជីវកម្មបាន។

- វាយតម្លៃលើការបង្ហាញ ទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

- ទទួលបាននូវភស្តុតាងសវនកម្មដែលសមស្រប និងគ្រប់គ្រាន់ ពាក់ព័ន្ធនឹងព័ត៌មានហិរញ្ញវត្ថុរបស់បណ្តាបុត្រសម្ព័ន្ធ នៅក្នុងសម្ព័ន្ធធនាគារ ដើម្បីបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុរួម។ យើងខ្ញុំទទួលខុសត្រូវក្នុងការដឹកនាំ ការត្រួតត្រាមើល និងការប្រត្តិបត្តិនៃសវនកម្មរបស់សម្ព័ន្ធធនាគារ។ យើងខ្ញុំរក្សាការទទួលខុសត្រូវលើមតិសវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច រួមបញ្ចូលទាំងបញ្ហាផ្សេងទៀត ដូចជាវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏បានផ្តល់សេចក្តីបញ្ជាក់ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចថា យើងខ្ញុំបានអនុលោមតាម លក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈដែលពាក់ព័ន្ធលើឯករាជ្យភាពរបស់យើងខ្ញុំ និងបានជម្រាបជូន ពួកគាត់នូវរាល់ទំនាក់ទំនង និងបញ្ហាផ្សេងៗទៀតដែលអាចត្រូវបានយកមកពិចារណាយ៉ាងសមហេតុផល ថាអាចមានទំនាក់ទំនងទៅនឹងការការពារឯករាជ្យភាពរបស់យើងខ្ញុំ។

បញ្ហាដែលយើងខ្ញុំបានជម្រាបជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច គឺជាបញ្ហាដែលយើងខ្ញុំកំណត់ថាមានសារៈសំខាន់បំផុត នៅក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ហើយបញ្ហានេះគឺជាបញ្ហាសំខាន់ក្នុងការធ្វើសវនកម្ម ។

KPMG

យើងខ្ញុំបង្ហាញបញ្ហានេះ នៅក្នុងរបាយការណ៍សវនកម្មលើកលែងតែច្បាប់ ឬបទប្បញ្ញត្តិ រារាំងនូវការលាតត្រដាងជាសាធារណៈអំពីបញ្ហានេះក្នុងការធ្វើសវនកម្ម ឬក៏ក្នុងកាលៈទេសៈដ៏កម្របំផុត នៅពេលដែលយើងខ្ញុំរកឃើញថាបញ្ហានោះ មិនគួរត្រូវបានបង្ហាញក្នុងរបាយការណ៍ របស់យើងខ្ញុំ ដោយសារតែផលអវិជ្ជមាន អាចមានច្រើនជាងអត្ថប្រយោជន៍ជាសាធារណៈ ដែលកើតចេញពីការជូនដំណឹងនេះ ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**

**ខែ ហ៊ុយ**

*Engagement Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) | ២០១៩<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៥ | ៤១២.៧៥៩.០៥១ | ៤២១.៥២៧.២៣៨ | ១.៦៦៩.៦១០.៣៦១ | ១.៧១៧.៧២៣.៩៩៥ |
| ប្រាក់បញ្ញើនៅធនាគារផ្សេងៗ | ៦ | ៥៣៤.៦៥៣.១៤៦ | ៥៨៧.៧៣០.៥៣១ | ២.១៦២.៦៧១.៩៧៦ | ២.៣៩៥.០០១.៩១៤ |
| ការវិនិយោគហិរញ្ញវត្ថុ | ៧ | ៥៦៦.៦៧៤.៥២៣ | ៥២៧.៤៧៤.៩៧៦ | ២.២៩២.១៩៨.៤៤៦ | ២.១៤៩.៤៦០.៥២៧ |
| ឥណទាន និងបុរេប្រទាន-សុទ្ធ | ៨ | ៤.៤៧១.៣០០.៦១៨ | ៣.៨៤៦.០២០.៥១៩ | ១៨.០៨៦.៤១១.០០០ | ១៥.៦៧២.៥៣៣.៦១៥ |
| ទ្រព្យសកម្មផ្សេងៗ | ៩ | ២២.៧៦៦.៩១៣ | ១៧.៥២៩.៨៣៣ | ៩២.០៩២.១៦៣ | ៧១.៤៣៤.០៧០ |
| ប្រាក់បញ្ញើតាមច្បាប់ | ១០ | ៣៦០.៣៧៧.០០៨ | ៥៨៧.៣៣៦.០៩៩ | ១.៤៥៧.៧២៤.៩៩៧ | ២.៣៩៣.៣៩៤.៦០៣ |
| ទ្រព្យនិងបរិក្ខារ | ១២ | ១២៧.៥៤៦.៤៤១ | ១៣១.១៥៩.៧៩២ | ៥១៥.៩២៥.៣៥៤ | ៥៣៤.៤៧៦.១៥៣ |
| ទ្រព្យសកម្មអរូបី | ១៣ | ១៤.៦៩០.៦៧៥ | ៨.៩៩៨.៩៩៣ | ៥៩.៤២៣.៧៨០ | ៣៦.៦៧០.៨៩៦ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ១៤ | ២៩.៥២៩.៧៦៨ | ៣២.៥៦៩.៤៥៧ | ១១៩.៤៤៧.៩១២ | ១៣២.៧២០.៥៣៧ |
| ទ្រព្យសកម្មពន្ធពន្យារ-សុទ្ធ | ១៥ | ១១.១៩៥.៨៤៥ | ១៤.៨១៤.៣៥៤ | ៤៥.២៨៧.១៩៣ | ៦០.៣៦៨.៤៩៤ |
| **ទ្រព្យសកម្មសរុប** | | ៦.៥៥១.៤៩៣.៩៨៨ | ៦.១៧៥.១៦១.៧៩២ | ២៦.៥០០.៧៩៣.១៨២ | ២៥.១៦៣.៧៨៤.៣០៤ |
| **បំណុលនិងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារនិងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ១៦ | ៣១៧.០០៩.៤៥៩ | ២៨៥.១៧៥.១៤៥ | ១.២៨២.៣០៣.២៦២ | ១.១៦២.០៨៨.៧១៦ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១៧ | ៤.២៩៤.២៨៦.០៤៨ | ៤.០៨២.៧២២.៨៥៣ | ១៧.៣៧០.៣៨៧.០៦៤ | ១៦.៦៣៧.០៩៥.៦២៦ |
| បំណុលផ្សេងៗ | ១៨ | ៦៣.៧៥១.១០៨ | ៥៨.៨១០.៨៧៥ | ២៥៧.៨៧៣.២៣២ | ២៣៩.៦៥៤.៣១៦ |
| ប្រាក់កម្ចី | ១៩ | ៥៤២.៣៩៨.៩១៦ | ៥៦៤.៩៧១.៧០១ | ២.១៩៤.០០៣.៦១៥ | ២.៣០២.២៥៩.៦៨២ |
| បំណុលបន្ទាប់បន្សំ | ២០ | ១៦៧.១៥៨.៦២៣ | ១៣៩.៣០២.៥៨០ | ៦៧៦.១៥៦.៦៣០ | ៥៦៧.៦៥៨.០១៤ |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ២៩(ក) | ៣០.២៩២.៣៧០ | ៣០.៤៥៩.៣០៣ | ១២២.៥៣២.៦៣៧ | ១២៤.១២១.៦៦០ |
| បំណុលភតិសន្យា | ២១ | ២៨.៦១៧.៩០២ | ៣០.៩១៥.៩៣៩ | ១១៥.៧៥៩.៤១៤ | ១២៥.៩៨២.៤៥១ |
| អត្ថប្រយោជន៍និយោជិត | ២២ | ១៨.៣៥៤.០៥៥ | ១៨.៣៤១.៧៩៦ | ៧៤.២៤២.១៥២ | ៧៤.៧៤២.៨១៩ |
| **បំណុលសរុប** | | ៥.៤៦១.៨៦៨.៤៨១ | ៥.២១០.៧០០.១៩២ | ២២.០៩៣.២៥៨.០០៦ | ២១.២៣៣.៦០៣.២៨៤ |
| **មូលធន** | | | | | |
| ដើមទុន | ២៣ | ៤៣៣.១៦៣.០១៩ | ៤២៨.៨១៨.១៥៤ | ១.៧៥២.១៤៤.៤១២ | ១.៧៤៧.៤៣៣.៩៧៨ |
| បុព្វលាភភាគហ៊ុន | ២៣ | ១១.៧០៦.២១៥ | - | ៤៧.៣៥១.៦៤០ | - |
| ទុនបម្រុង | ៣៣ | ៥០៣.០៩៤.២៣៦ | ៤១៤.៧៤៨.៧២៦ | ២.០៤៨.៧០៨.៩៩៧ | ១.៧០៨.០៨៥.២៦៦ |
| ប្រាក់ចំណេញរក្សាទុក | | ១៤១.៦៦២.០៣៧ | ១២០.៨៩៤.៧២០ | ៥៥៩.៣៣០.១២៧ | ៤៧៤.៦៦១.៧៧៦ |
| **មូលធនសរុប** | | ១.០៨៩.៦២៥.៥០៧ | ៩៦៤.៤៦១.៦០០ | ៤.៤០៧.៥៣៥.១៧៦ | ៣.៩៣០.១៨១.០២០ |
| អប្បភាគភាគកម្ម | | - | - | - | - |
| **បំណុលនិងមូលធនសរុប** | | ៦.៥៥១.៤៩៣.៩៨៨ | ៦.១៧៥.១៦១.៧៩២ | ២៦.៥០០.៧៩៣.១៨២ | ២៥.១៦៣.៧៨៤.៣០៤ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០១៩ ដុល្លារអាមេរិក | ២០២០ ពាន់រៀល (កំណត់សម្គាល់ ៤) | ២០១៩ ពាន់រៀល (កំណត់សម្គាល់ ៤) |
|---|---|---|---|---|---|
| ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព | ២៤ | ៥១៥.០៩៤.៤៧៦ | ៤៨៣.៥៤៣.៤៦៦ | ២.១០០.០៤០.១៧៩ | ១.៩៥៩.៣១៨.១២៤ |
| ចំណាយការប្រាក់ | ២៥ | (១៥០.៧៧៧.៣១៧) | (១៥៦.៨៧២.៦៨០) | (៦១៤.៧១៩.១២១) | (៦៣៥.៦៤៨.០៩៩) |
| **ចំណូលការប្រាក់សុទ្ធ** | | ៣៦៤.៣១៧.១៥៩ | ៣២៦.៦៧០.៧៨៦ | ១.៤៨៥.៣២១.០៥៨ | ១.៣២៣.៦៧០.០២៥ |
| ចំណូលកម្រៃនិងជើងសា | ២៦ | ៤៥.៧៧៥.១៦៥ | ៤៨.៧៣៤.៦១៩ | ១៨៦.៦២៥.៣៤៨ | ១៩៧.៤៧២.៦៧៦ |
| ចំណាយកម្រៃនិងជើងសា | | (១.៧៤២.១២៥) | (៩៩៦.៨៩៧) | (៧.១០២.៦៤៤) | (៤.០៣៩.៤២៧) |
| **ចំណូលកម្រៃនិងជើងសាសុទ្ធ** | | ៤៤.០៣៣.០៤០ | ៤៧.៧៣៧.៧២២ | ១៧៩.៥២២.៧០៤ | ១៩៣.៤៣៣.២៤៩ |
| សំវិធានធនសម្រាប់ការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាន និងបុរេប្រទានប្រាក់បញ្ញើនៅធនាគារផ្សេងៗនិងគណនីត្រូវទទួលផ្សេងៗ | ៣៥.១(ច) | (២០.៧៩៤.០៣១) | (២៣.៤១១.២០៥) | (៨៤.៧៧៧.២៦៤) | (៩៤.៨៦២.២០៣) |
| សំវិធានធនសម្រាប់ការខាតបង់ឱនភាពនៃតម្លៃកិច្ចសន្យាក្រៅតារាងតុល្យការ | | ៥៥.១៥៦ | ៨៧.៩៨៩ | ២២០.៧៩៤ | ៣៥៦.៥៣១ |
| ការខាតបង់ឱនភាពនៃតម្លៃសុទ្ធ | | (២០.៧៣៨.៨៧៥) | (២៣.៣២៣.២១៦) | (៨៤.៥៥៦.៤៧០) | (៩៤.៥០៥.៦៧២) |
| **ចំណូលបន្ទាប់ពីសំវិធានធនសម្រាប់ឱនភាពនៃតម្លៃសុទ្ធ** | | ៣៨៧.៦១០.៣២៤ | ៣៥១.០៨៥.២៩២ | ១.៥៨០.២៨៧.២៩២ | ១.៤២២.៥៩៧.៦០២ |
| ចំណូលផ្សេងៗ | ២៧ | ១៨.៣៥១.៣៥៨ | ១៧.៨៩៩.៧២៣ | ៧៤.៨១៨.៤៨៧ | ៧២.៣២៧.០៧៨ |
| ចំណាយទូទៅនិងរដ្ឋបាល | ២៨ | (២២៥.៩២៦.២២០) | (២១៥.៤១២.៣៩៤) | (៩២១.១០១.១៩៩) | (៨៧២.៨៥១.០២០) |
| | | (២២៥.៩២៦.២២០) | (២១៥.៤១២.៣៩៤) | (៩២១.១០១.១៩៩) | (៨៧២.៨៥១.០២០) |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | | ១៨០.០៣៥.៤៦២ | ១៥៣.៥៧២.៦២១ | ៧៣៤.០០៤.៥៨០ | ៦២២.០៧៣.៦៦០ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៩(ខ) | (៣៨.៥៤២.៨៧២) | (៣២.៦៦២.៨០៩) | (១៥៧.១៣៩.២៩១) | (១៣២.៣៤៩.៧០២) |
| **ប្រាក់ចំណេញក្នុងឆ្នាំ(យោងទៅទំព័របន្ទាប់)** | | ១៤១.៤៩២.៥៩០ | ១២០.៨៥៩.៨១២ | ៥៧៦.៨៦៥.២៨៩ | ៤៨៩.៧២៣.៩៥៨ |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) | ២០១៩<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) |
|---|---|---|---|---|---|
| ប្រាក់ចំណេញក្នុងឆ្នាំ(យោងមកពីទំព័រមុន) | | ១៤១.៤៩២.៥៩០ | ១២០.៨៥៩.៨១២ | ៥៧៦.៨៦៥.២៨៩ | ៤៨៩.៧២៣.៩៥៨ |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | | |
| *ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញ ទៅចំណេញ ឬខាត៖* | | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ច អត្ថប្រយោជន៍និយោជិត | | ១៦៩.៤៤៧ | ៣៩.៩០៨ | ៦៩០.៨៣៥ | ១៤១.៤៤៧ |
| *ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញ នៅគ្រាបន្ទាប់ទៅចំណេញ ឬខាត៖* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | (៨.១៦០.០២៦) | ៧.៣៣០.១៦៥ |
| លទ្ធផលលម្អិតផ្សេងៗក្នុងឆ្នាំ | | ១៦៩.៤៤៧ | ៣៩.៩០៨ | (៧.៤៦៩.១៩១) | ៧.៤៧១.៦១២ |
| **លទ្ធផលលម្អិតផ្សេងៗក្នុងឆ្នាំសរុប** | | ១៤១.៦៦២.០៣៧ | ១២០.៨៩៩.៧២០ | ៥៦៩.៣៩៦.០៩៨ | ៤៩៧.១៩៥.៥៧០ |
| | | - | - | - | - |
| **ប្រាក់ចំណេញក្នុងឆ្នាំដែលផ្តល់ជូនដល់៖** | | | | | |
| ភាគហ៊ុនិករបស់ធនាគារ | | ១៤១.៤៩២.៥៩០ | ១២០.៨៥៩.៨១២ | ៥៧៦.៨៦៥.២៨៩ | ៤៨៩.៧២៣.៩៥៨ |
| អប្បភាគភាគកម្ម | | - | - | - | - |
| | | ១៤១.៤៩២.៥៩០ | ១២០.៨៥៩.៨១២ | ៥៧៦.៨៦៥.២៨៩ | ៤៨៩.៧២៣.៩៥៨ |
| | | - | - | - | - |
| **លទ្ធផលលម្អិតសរុបដែលផ្តល់ជូនដល់៖** | | - | - | - | - |
| ភាគហ៊ុនិករបស់ធនាគារ | | ១៤១.៦៦២.០៣៧ | ១២០.៨៩៩.៧២០ | ៥៦៩.៣៩៦.០៩៨ | ៤៩៧.១៩៥.៥៧០ |
| អប្បភាគភាគកម្ម | | - | - | - | - |
| | | ១៤១.៦៦២.០៣៧ | ១២០.៨៩៩.៧២០ | ៥៦៩.៣៩៦.០៩៨ | ៤៩៧.១៩៥.៥៧០ |
| ចំណូលក្នុងមួយភាគហ៊ុនផ្តល់ជូនភាគហ៊ុនិករបស់ធនាគារក្នុងឆ្នាំត្រូវបានបង្ហាញដូចខាងក្រោម៖ | | | | | |
| ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន | ៣០ | ០.៣៣ | ០.២៩ | ១.៣២ | ១.២០ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ | ៣០ | ០.៣៣ | ០.២៩ | ១.៣២ | ១.២០ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍បម្រែបម្រួលមូលធនរួម
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | ផ្តល់ជូនភាគហ៊ុនិករបស់ក្រុមហ៊ុនមេ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | **ដើមទុន** | | **បុព្វលាភភាគហ៊ុន** | | **ទុនបម្រុង** | | **ចំណេញរក្សាទុក** | | **សរុប** | | **[illegible]** | | **មូលធនសរុប** | |
| | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ ៤) | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ ៤) | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ ៤) | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ ៤) | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ ៤) | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ ៤) | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់ ៤) |
| **នាថ្ងៃទី ១ខែមករាឆ្នាំ ២០២០** | ៤២៨.៨១៨.១៥៤ | ១.៧៤៧.៤៣៣.៩៧៨ | - | - | ៣១៤.៧៤៨.៧២៦ | ១.៧០៤.០៨៥.២៦៦ | ១២០.៨៩៤.៧២០ | ៤៧៤.៦៦១.៧៧៦ | ៨៦៤.៤៦១.៦០០ | ៣.៩៣០.១៩១.០២០ | - | - | ៨៦៤.៤៦១.៦០០ | ៣.៩៣០.១៩១.០២០ |
| ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ | - | - | - | - | - | - | ១៩១.៤៩២.៥៩០ | ៥៧៦.៨៥៥.២៨៩ | ១៩១.៤៩២.៥៩០ | ៥៧៦.៨៥៥.២៨៩ | - | - | ១៩១.៤៩២.៥៩០ | ៥៧៦.៨៥៥.២៨៩ |
| *លទ្ធផលលម្អិតផ្សេងៗ៖* | | | | | | | | | | | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | - | - | - | - | - | - | ១៦៩.៤៤៧ | ៦៩០.៨៣៥ | ១៦៩.៤៤៧ | ៦៩០.៨៣៥ | - | - | ១៦៩.៤៤៧ | ៦៩០.៨៣៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (៨.១៦០.០២៦) | - | - | - | (៨.១៦០.០២៦) | - | - | - | (៨.១៦០.០២៦) |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | - | - | - | - | - | (៨.១៦០.០២៦) | ១៩១.៦៦២.០៣៧ | ៥៧៧.៥៥៦.១២៤ | ១៩១.៦៦២.០៣៧ | ៥៦៩.៣៩៦.០៩៨ | - | - | ១៩១.៦៦២.០៣៧ | ៥៦៩.៣៩៦.០៩៨ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក៖** | | | | | | | | | | | | | | |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅជាដើមទុន | - | - | - | - | (៤.៤៥១.៨៦៤) | (១៨.១៥០.២៥០) | ៤.៤៥១.៨៦៤ | ១៨.១៥០.២៥០ | - | - | - | - | - | - |
| ភាគលាភដែលបានបង់ | - | - | - | - | - | - | (៣២.៧១៨.៨២៥) | (១៣៣.៣៩៤.៦៥០) | (៣២.៧១៨.៨២៥) | (១៣៣.៣៩៤.៦៥០) | - | - | (៣២.៧១៨.៨២៥) | (១៣៣.៣៩៤.៦៥០) |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅជាទុនបម្រុង | - | - | - | - | ៦៦.២៨៥.៧៩៥ | ២៧០.២៤៧.១៨៦ | (៦៦.៧៣០.៥៨៥) | (២៧២.០៦០.៥៩៥) | (៤៤៤.៧៩០) | (១.៨១៣.៤០៩) | - | - | (៤៤៤.៧៩០) | (១.៨១៣.៤០៩) |
| ការបោះផ្សាយភាគហ៊ុន | ៤.៣៩៤.៨៦៥ | ១៧.៧១៤.០១៥ | ១១.៧០៦.២១៥ | ៤៧.៧២៦.២៣៩ | - | - | - | - | ១៦.០៥១.០៨០ | ៦៥.៤៤០.២៥៤ | - | - | ១៦.០៥១.០៨០ | ៦៥.៤៤០.២៥៤ |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅជាទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | ២៥.៨៩៧.១៧៤ | ១០៥.៥៨២.៧៧៨ | (២៥.៨៩៧.១៧៤) | (១០៥.៥៨២.៧៧៨) | - | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ - ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស | - | - | - | - | ៦១៤.៤០៥ | ២.៥០៤.៩២៩ | - | - | ៦១៤.៤០៥ | ២.៥០៤.៩២៩ | - | - | ៦១៤.៤០៥ | ២.៥០៤.៩២៩ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១៣.០០៣.៥៨១) | - | (៣៧៤.៥៩៩) | - | (១១.៤០០.៨៨៦) | - | - | - | (២៤.៧៧៩.០៦៦) | - | - | - | (២៤.៧៧៩.០៦៦) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិកសរុប** | ៤.៣៩៤.៨៦៥ | ៤.៧១០.៤៣៤ | ១១.៧០៦.២១៥ | ៤៧.៣៥១.៦៤០ | ៨៨.៣៤៥.៥១០ | ៣៤៨.៧៨៣.៧៥៧ | (១២០.៨៩៤.៧២០) | (៤៩២.៨៨៧.៧៧៣) | (១៦.៤៩៨.១៣០) | (៩២.០៤១.៩៤២) | - | - | (១៦.៤៩៨.១៣០) | (៩២.០៤១.៩៤២) |
| **នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០២០** | ៤៣៣.១៦៣.០១៩ | ១.៧៥២.១៤៤.៤១២ | ១១.៧០៦.២១៥ | ៤៧.៣៥១.៦៤០ | ៤០៣.០៩៤.២៣៦ | ២.០៤៨.៧០៨.៩៩៧ | ១៩១.៦៦២.០៣៧ | ៥៥៩.៣៣០.១២៧ | ១.០៣៩.៦២៥.៥០៧ | ៤.៤០៧.៥៣៥.១៧៦ | - | - | ១.០៣៩.៦២៥.៥០៧ | ៤.៤០៧.៥៣៥.១៧៦ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍បម្រែបម្រួលមូលធនរួម (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | ផ្តល់ជូនភាគហ៊ុនិករបស់ក្រុមហ៊ុនមេ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដើមទុន | | ទុនបម្រុង | | ប្រាក់ចំណេញរក្សាទុក | | សរុប | | អប្បភាគភាគកម្ម | | មូលធនសរុប | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) |
| **នៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៩** | ៣៩៥.២២៤.១០៥ | ១.៥៨៨.០១០.៤៥៤ | ៣៧៧.៧៩៨.២៨៦ | ១.៥២៩.២២៦.៩០៣ | ៧៩.៨១៧.២៩១ | ៣០៩.៤៧២.៤៨២ | ៨៥២.៨៣៩.៦៨២ | ៣.៤២៦.៧០៩.៨៣៩ | - | - | ៨៥២.៨៣៩.៦៨២ | ៣.៤២៦.៧០៩.៨៣៩ |
| ការកែសម្រួលលើការអនុវត្តជាលើកដំបូងនៃ សរ.ហ.អ.ក ១៦ បន្ទាប់ពីកាត់កងពន្ធ | - | - | - | - | - | - | - | - | - | - | - | - |
| **សមតុល្យដែលបានបញ្ជាក់ឡើងវិញនៅ ថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៩** | ៣៩៥.២២៤.១០៥ | ១.៥៨៨.០១០.៤៥៤ | ៣៧៧.៧៩៨.២៨៦ | ១.៥២៩.២២៦.៩០៣ | ៧៩.៨១៧.២៩១ | ៣០៩.៤៧២.៤៨២ | ៨៥២.៨៣៩.៦៨២ | ៣.៤២៦.៧០៩.៨៣៩ | - | - | ៨៥២.៨៣៩.៦៨២ | ៣.៤២៦.៧០៩.៨៣៩ |
| ប្រាក់ចំណេញក្នុងឆ្នាំ | - | - | - | - | ១២០.៨៥៩.៨១២ | ៤៨៩.៧២៣.៩៥៨ | ១២០.៨៥៩.៨១២ | ៤៨៩.៧២៣.៩៥៨ | - | - | ១២០.៨៥៩.៨១២ | ៤៨៩.៧២៣.៩៥៨ |
| *លទ្ធផលលម្អិតផ្សេងៗ៖* | | | | | | | | | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ច អត្ថប្រយោជន៍និយោជិត | - | - | - | - | ៣៤.៩០៨ | ១៤១.៤៤៧ | ៣៤.៩០៨ | ១៤១.៤៤៧ | - | - | ៣៤.៩០៨ | ១៤១.៤៤៧ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | ៧.៣៣០.១៦៥ | - | - | - | ៧.៣៣០.១៦៥ | - | - | - | ៧.៣៣០.១៦៥ |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | - | - | - | ៧.៣៣០.១៦៥ | ១២០.៨៩៤.៧២០ | ៤៨៩.៨៦៥.៤០៥ | ១២០.៨៩៤.៧២០ | ៤៩៧.១៩៥.៥៧០ | - | - | ១២០.៨៩៤.៧២០ | ៤៩៧.១៩៥.៥៧០ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក៖** | | | | | | | | | | | | |
| ភាគលាភជាភាគហ៊ុន | ៣៣.៥៩៤.០៤៩ | ១៣៦.៧៦១.៣៧៣ | - | - | (៣៣.៥៩៤.០៤៩) | (១៣៦.៧៦១.៣៧៣) | - | - | - | - | - | - |
| ភាគលាភជាសាច់ប្រាក់ | - | - | - | - | (៨.៤១៨.២៧៣) | (៣៤.០៦០.៣៣៣) | (៨.៤១៨.២៧៣) | (៣៤.០៦០.៣៣៣) | -- | - | (៨.៤១៨.២៧៣) | (៣៤.០៦០.៣៣៣) |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅជាទុនបម្រុងទូទៅ | - | - | ៥០.២១០.៩៦០ | ២០៤.៤០៨.៨១៨ | (៥០.២១០.៩៦០) | (២០៤.៤០៨.៨១៨) | - | - | - | - | - | - |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិទៅជាប្រាក់ ចំណេញរក្សាទុក | - | - | (១២.៤០៥.៩៩១) | (៥០.៥៥៤.៤១៣) | ១២.៤០៥.៩៩១ | ៥០.៥៥៤.៤១៣ | - | - | - | - | - | - |
| ការទិញយកអប្បភាគភាគកម្មដែលមាននៅAMM | - | - | ១៤.២៧៩.៣៤៤ | ៥៨.១៨៨.៣២៧ | - | - | ១៤.២៧៩.៣៤៤ | ៥៨.១៨៨.៣២៧ | - | - | ១៤.២៧៩.៣៤៤ | ៥៨.១៨៨.៣២៧ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ ក្រុមហ៊ុនបុត្រសម្ព័ន្ធ បរទេស | - | - | (១៥.១៣៣.៨៧៣) | (៦១.៦៧០.៥៣២) | - | - | (១៥.១៣៣.៨៧៣) | (៦១.៦៧០.៥៣២) | - | - | (១៥.១៣៣.៨៧៣) | (៦១.៦៧០.៥៣២) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ២២.៦៦២.១៥១ | - | ២១.១៥៥.៩៩៨ | - | - | - | ៤៣.៨១៨.១៤៩ | - | - | - | ៤៣.៨១៨.១៤៩ |
| **ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុនិកសរុប** | ៣៣.៥៩៤.០៤៩ | ១៥៩.៤២៣.៥២៤ | ៣៦.៩៥០.៤៤០ | ១៧១.៥២៨.១៩៨ | (៧៩.៨១៧.២៩១) | (៣២៤.៦៧៦.១១១) | (៩.២៧២.៨០២) | ៦.២៧៥.៦១១ | - | - | (៩.២៧២.៨០២) | ៦.២៧៥.៦១១ |
| **នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៩** | ៤២៨.៨១៨.១៥៤ | ១.៧៤៧.៤៣៣.៩៧៨ | ៤១៤.៧៤៨.៧២៦ | ១.៧០៨.០៨៥.២៦៦ | ១២០.៨៩៤.៧២០ | ៤៧៤.៦៦១.៧៧៦ | ៩៦៤.៤៦១.៦០០ | ៣.៩៣០.១៨១.០២០ | - | - | ៩៦៤.៤៦១.៦០០ | ៣.៩៣០.១៨១.០២០ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍លំហូរសាច់ប្រាក់រួម
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) | ២០១៩<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញក្នុងឆ្នាំ | | ១៤១.៩៩២.៥៩០ | ១២០.៨៥៥.៨១២ | ៥៧៦.៨៦៥.២៨៩ | ៤៨៩.៧២៣.៩៥៨ |
| *និយ័តភាពលើ៖* | | | | | |
| រំលស់លើទ្រព្យនិងបរិក្ខារ | ១២ | ២១.២៤៩.២១៨ | ២១.៤២៦.៤៧០ | ៨៦.៦៣៣.០៦២ | ៨៦.៨២០.០៥៦ |
| រំលស់លើទ្រព្យសកម្មអរូបី | ១៣ | ៣.៦៦៧.៥៨៣ | ៣.៥៣៧.៤៥៧ | ១៤.៩៥២.៧៣៦ | ១៤.៣៣៣.៧៧៦ |
| រំលស់លើសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ១៤ | ១០.៦២៧.១២០ | ១០.៤៦៩.៨១៩ | ៤៣.៣២៦.៧៦៨ | ៤២.៤២៣.៧០៧ |
| និយ័តភាពលើទ្រព្យនិងបរិក្ខារ | | ១៨.៥៣៤ | ៤៧.៥៥២ | ៧៥.៥៦៣ | ១៩២.៦៨១ |
| និយ័តភាពលើទ្រព្យសកម្មអរូបី | | ២៩០.២៨៤ | ៤០៥.០១៧ | ១.១៨៣.៤៨៨ | ១.៦៤១.១២៩ |
| ចំណាយមូលនិធិសោធននិវត្តន៍ | | - | ២២៩.២១១ | - | ៩២៨.៧៦៣ |
| សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃ | ៨ | ២០.៧៣៩.៨៧៥ | ២៣.៣២៣.២១៦ | ៨៤.៥៥៦.៤៧០ | ៩៤.៥០៥.៦៧២ |
| ចំណាយអត្ថប្រយោជន៍ពេលចូលនិវត្ត | ២២(ក) | ១.៦៩៧.៣៤១ | ១.៥៥៧.៦៥៤ | ៦.៩២០.០៦០ | ៦.៣១១.៦១៥ |
| អត្ថប្រយោជន៍ប្រាក់បំណាច់អតីតភាពការងារ | ២២(គ) | ៦.៥៦៣.៧១៩ | ៣.២៣៣.៩១៥ | ២៦.៧៦០.២៨២ | ១៣.១០៣.៨២៤ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៩(ខ) | ៣៨.៥៤២.៨៧២ | ៣២.៦៦២.៨០៩ | ១៥៧.១៣៩.២៩១ | ១៣២.៣៤៩.៧០២ |
| ទុនបម្រុងសម្រាប់ការប្តូររូបិយប័ណ្ណ | | ៦១៤.៤០៥ | (៨៥៤.៥២៩) | ២.៥០៤.៩២៩ | (៣.៤៦២.៥៥២) |
| ចំណូលការប្រាក់សុទ្ធ | | (៣៦៤.៣១៧.១៥៩) | (៣២៦.៦៧០.៧៨៦) | (១.៤៨៥.៣២១.០៥៨) | (១.៣២៣.៦៧០.០២៥) |
| ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ និងទ្រព្យសកម្មអរូបី | | (៣៦៩.៥២៨) | (៧៦.៤៨១) | (១.៥០៦.៥៦៦) | (៣០៩.៩០១) |
| ចំណេញពីការប្តូររូបិយប័ណ្ណមិនទាន់បានទទួលស្គាល់ | | (២៦២.៣៥៨) | (១.០៩៨.២៧៩) | (១.០៦៩.៦៣៥) | (៤.៤៥០.២២៥) |
| | | (១១៩.៤៤៥.៥០៤) | (១១០.៩៤៧.១៤៣) | (៤៨៦.៩៧៩.៣២១) | (៤៤៩.៥៥៧.៨២០) |
| *បម្រែបម្រួល៖* | | | | | |
| ឥណទាន និងបុរេប្រទាន | | (៦៤៦.០៦៣.៥៣០) | (២៧៤.២៦២.១៥៨) | (២.៦៣៤.០០១.០១២) | (១.១១១.៣១០.២៦៤) |
| ប្រាក់បញ្ញើនៅធនាគារផ្សេងៗ | | ១៨១.៦០២.០៨៦ | (១.១២៧.២៦៩) | ៧៤០.៣៩១.៧០៥ | (៤.៥៦៧.៦៩៤) |
| ប្រាក់បញ្ញើតាមច្បាប់ | | ៤៣.៤៤៩.២៨៨ | (៤៦.៧៦១.១២៦) | ១៧៧.១៤២.៧៤៧ | (១៨៩.៤៧៦.០៨៣) |
| ទ្រព្យសកម្មផ្សេងៗ | | (៥.៥៦០.២៣៧) | ៤.៩៣៣.១១៩ | (២២.៦៦៩.០៨៦) | ១៩.៩៨៨.៩៩៨ |
| ប្រាក់បញ្ញើរបស់អតិថិជន | | ២១១.៥៦៣.១៩៥ | ៥០០.៧៩៩.៣៨១ | ៨៦២.៥៤៣.១៩៦ | ២.០២៩.២៣៩.០៩២ |
| ប្រាក់បញ្ញើពីធនាគារផ្សេងៗនិងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | | ៣១.៨៣៤.៣១៤ | (៣.៦២៧.៤៤៥) | ១២៩.៧៨៨.៩៩៨ | (១៤.៦៩៨.៤០៧) |
| មូលនិធិសោធននិវត្តន៍ | | - | ២១០.១១០ | - | ៨៥១.៣៦៦ |
| មូលនិធិអភិវឌ្ឍន៍វិជ្ជាជីវៈ | | ១.៣១២.៦៤១ | ១.៣៨៥.៤៩៣ | ៥.៣៥១.៦៣៧ | ៥.៦១៤.០១៨ |
| បំណុលផ្សេងៗ | | ១០.៣០១.៧២៨ | (៦.៥២០.៩៥៧) | ៤២.០០០.១៩៥ | (២៦.៤២២.៩១៨) |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/បានពីប្រតិបត្តិការ** | | (២៩១.០០៦.០១៩) | ៦៤.០៨២.០០៥ | (១.១៨៦.៤៣១.៥៩១) | ២៥៩.៦៦០.២៨៨ |
| ចំណូលការប្រាក់បានទទួល | | ៥១៥.៩៦៨.១៧៣ | ៤៨១.៤៦៩.៥៥៥ | ២.១០១.៥៦៣.៧៤១ | ១.៩៥០.៩១៤.៦៣៧ |
| ចំណាយការប្រាក់បានបង់ | | (១៥៤.០១១.៣០៦) | (១៤៧.៧២៣.១២០) | (៦២៧.៩០៤.០៩៥) | (៥៩៨.៥៧៤.០៨២) |
| ពន្ធលើប្រាក់ចំណេញបានបង់ | ២៩(ក) | (៣៥.០៦៤.៦៥២) | (១៩.២១៦.៧៥៦) | (១៤២.៩៥៨.៥៨៦) | (៧៧.៨៦៦.២៩៥) |
| មូលនិធិសោធននិវត្តន៍បានបង់ | | - | (៤៣០.៩៧៣) | - | (១.៧៤៦.៣០៣) |
| អត្ថប្រយោជន៍ពេលចូលនិវត្តបានបង់ | ២២(ក) | (២១៦.៨៤០) | (១៩៥.៤៤៤) | (៨៨៤.០៥៧) | (៧៩១.៩៣៩) |
| មូលនិធិអភិវឌ្ឍន៍វិជ្ជាជីវៈបានបង់ | ២២(ខ) | (២.០៨៥.៣១៥) | (១.៤៦៥.៣៩៣) | (៨.៥០១.៨២៩) | (៥.៩៣៧.៧៧២) |
| អត្ថប្រយោជន៍ប្រាក់បំណាច់អតីតភាពការងារបានបង់ | ២២(គ) | (៦.៩៩៨.២៥៧) | (៦.២២៥.៨៦៩) | (២៨.៥៣១.៨៩៤) | (២៥.២២៧.២២១) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | | ២៦.០៨៥.៧៨៤ | ៣៧០.២៩៤.០០៥ | ១០៦.៣៥១.៧៣៩ | ១.៥០០.៤៣១.៣១៣ |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍លំហូរសាច់ប្រាក់រួម (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) | ២០១៩<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការវិនិយោគហិរញ្ញវត្ថុ | | ២២.៩៤៦.៥៧៦ | ២២.៤០៧.៤៤១ | ៩៣.៥៥៣.១៩០ | ៩០.៧៩៤.៩៥១ |
| ការទិញទ្រព្យនិងបរិក្ខារ | ១២ | (១៧.៧០៤.៤៨៩) | (១៤.៨៣០.៤៩៧) | (៧២.១៨១.២០២) | (៦០.០៩៣.១៧៤) |
| ការទិញទ្រព្យសកម្មអរូបី | ១៣ | (៩.៦៨៩.២៣១) | (២.០២៧.២៥១) | (៣៩.៥០២.៩៩៥) | (៨.២១៤.៤២១) |
| សាច់ប្រាក់បានពីការលក់ទ្រព្យនិងបរិក្ខារ | | ៤០៨.៩៥៨ | ៣៦១.១១៧ | ១.៦៦៧.៣២២ | ១.៤៦៣.២៤៦ |
| **សាច់ប្រាក់(ប្រើប្រាស់ក្នុង)បានពីសកម្មភាពវិនិយោគ** | | (៤.០៣៨.១៨៦) | ៥.៩១០.៨១០ | (១៦.៤៦៣.៦៨៥) | ២៣.៩៥០.៦០២ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការទូទាត់ភាគលាភ | | (៣២.៧១៨.៨២៥) | (៨.៤១៨.២៧៣) | (១៣៣.៣៩៤.៦៥០) | (៣៤.១១០.៨៤២) |
| ការបង់ពន្ធលើការបង្កើនដើមទុននៅឡារ | | (៤៤៤.៧៩០) | - | (១.៨១៣.៤០៩) | - |
| ការសងប្រាក់កម្ចី | | (២០១.១៦៣.២៦៣) | (៤៥៤.៥៥៥.០៧៦) | (៨២០.១៤២.៦២៣) | (១.៨៤១.៨៥៧.១៦៨) |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | ១៧៨.៥៩០.៤៧៨ | ២២៩.២៦៦.៣៨៥ | ៧២៨.១១៣.៣៧៩ | ៩២៨.៩៨៧.៣៩២ |
| ការសងបំណុលបន្ទាប់បន្សំ | | (៧.១៤៣.៩៥៧) | (៣២.០០០.០០០) | (២៩.១២៥.៩១៣) | (១២៩.៦៦៤.០០០) |
| សាច់ប្រាក់បានពីបំណុលបន្ទាប់បន្សំ | | ៣៥.០០០.០០០ | ៩៣.៨៣៣.៦៦៧ | ១៤២.៦៩៥.០០០ | ៣៨០.២១៤.០១៩ |
| សាច់ប្រាក់បានពីការបោះផ្សាយភាគហ៊ុន | | ៤.៣៤៤.៨៦៥ | - | ១៧.៧១៤.០១៥ | - |
| សាច់ប្រាក់បានពីបុព្វលាភភាគហ៊ុន | | ១១.៧០៦.២១៥ | - | ៤៧.៧២៦.២៣៩ | - |
| ការទូទាត់បំណុលភតិសន្យា | ២១ | (១១.៨៣៣.២៧៤) | (១១.២៨២.៤៧០) | (៤៨.២៤៤.២៥៨) | (៤៥.៧១៦.៥៦៨) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន** | | (២៣.៦៦២.៥៥១) | (១៨៣.១៥៥.៧៦៧) | (៩៦.៤៧២.២២០) | (៧៤២.១៤៧.១៦៧) |
| **ការ(ថយចុះ)/កើនឡើងសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | (១.៦១៤.៩៥៣) | ១៩៣.០៤៩.០៤៨ | (៦.៥៨៤.១៦៦) | ៧៨២.២៣៤.៧៤៨ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមឆ្នាំ** | | ១.៤៩៨.៧២០.៤៥៧ | ១.៣០៥.៦៧១.៤០៩ | ៦.១០៧.២៨៥.៨៦២ | ៥.២៤៦.១៨៧.៧២១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | (៤៤.៨០៩.៩៣២) | ៧៨.៨៦៣.៣៩៣ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងឆ្នាំ** | ៣១ | ១.៤៩៧.១០៥.៥០៤ | ១.៤៩៨.៧២០.៤៥៧ | ៦.០៥៥.៧៩១.៧៦៤ | ៦.១០៧.២៨៥.៨៦២ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដោយឡែក
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) | ២០១៩<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៥ | ៤០០.៨១៦.១២៦ | ៤១០.៩៥៥.៨៦៧ | ១.៦២១.៣០១.២៣០ | ១.៦៧៤.៦៩៥.១៥៨ |
| ប្រាក់បញ្ញើនៅធនាគារផ្សេងៗ | ៦ | ៥០៧.៦២៩.៤០៧ | ៥៥៨.៦១២.៣៤០ | ២.០៥៣.៣៦០.៩៥១ | ២.២៧៦.៣៤៥.២៨៦ |
| ការវិនិយោគហិរញ្ញវត្ថុ | ៧ | ៥៦៦.៦៧៤.៥២៣ | ៥២៧.៤៧៤.៩៧៦ | ២.២៩២.១៩៨.៤៨៦ | ២.១៤៩.៤៦០.៥២៧ |
| ឥណទាននិងបុរេប្រទាន-សុទ្ធ | ៨ | ៤.២៩២.៦៤៩.១៥៩ | ៣.៦៨៦.៥៧៨.៩៤៣ | ១៧.៣៦៣.៧៦៥.៨៤៨ | ១៥.០២២.៨០៩.១៩៣ |
| ទ្រព្យសកម្មផ្សេងៗ | ៩ | ២០.២៥៦.១១០ | ១៥.៦៦៧.៥៤០ | ៨១.៩៣៥.៩៦៥ | ៦៣.៨៤៥.២២៦ |
| ប្រាក់បញ្ញើតាមច្បាប់ | ១០ | ៣៥៦.៧៥៣.៧៥៦ | ៥៨៣.១៩៥.៧៤១ | ១.៤៤៣.០៦៨.៩៤៣ | ២.៣៧៦.៥២២.៦៤៥ |
| ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | ១១ | ៩១.១១៥.៥៧១ | ៩១.១៣៥.៥៧១ | ៣៦៨.៥៦២.៤៨៥ | ៣៧១.៣៧៧.៤៥២ |
| ទ្រព្យនិងបរិក្ខារ | ១២ | ៩០.៨៣៦.៤២២ | ៩២.៩១១.៣៤៤ | ៣៦៧.៤៣៣.៣២៧ | ៣៧៨.៦១៣.៧២៨ |
| ទ្រព្យសកម្មអរូបី | ១៣ | ១៣.៨៨៤.៥៥៨ | ៧.៩១៥.៣៦២ | ៥៦.១៦៣.០៣៧ | ៣២.២៥៥.១០០ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ១៤ | ២៦.១៨២.១៧២ | ២៨.៨៤៧.៨៥០ | ១០៥.៩០៦.៨៨៦ | ១១៧.៥៥៤.៩៨៩ |
| ទ្រព្យសកម្មពន្ធពន្យារ-សុទ្ធ | ១៥ | ១២.៦៨៥.៩៤៧ | ១៤.០០៧.៧៤៣ | ៥១.៣១៤.៦៥៦ | ៥៧.០៨១.៥៥៣ |
| **ទ្រព្យសកម្មសរុប** | | ៦.៣៧៩.៤៨៣.៧៥១ | ៦.០១៧.៣០៣.២៧៧ | ២៥.៨០៥.០១១.៧៧៤ | ២៤.៥២០.៥១០.៨៥៧ |
| **បំណុលនិងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារនិងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ១៦ | ២៩៦.៧៦៤.៥៥៤ | ២៧៤.២៧៧.៧២១ | ១.២០០.៤១២.៦២១ | ១.១១៧.៦៨១.៧១៣ |
| ប្រាក់បញ្ញើរបស់អតិថិជន | ១៧ | ៤.១៨០.២៦៨.៧៣៧ | ៣.៩៨២.១៤៦.៥៥៩ | ១៦.៩០៩.១៨៧.០៤១ | ១៦.២២៧.២៤៧.២២៨ |
| បំណុលផ្សេងៗ | ១៨ | ៦២.៤០៨.៨៨២ | ៥៦.៥៩៧.៥៥១ | ២៥២.៤៤៣.៩២៨ | ២៣០.៦៣៥.០២១ |
| ប្រាក់កម្ចី | ១៩ | ៥០៧.៣៥២.៩១៦ | ៥១៨.០៦៨.១២៨ | ២.០៥២.២៤២.៥៤៥ | ២.១១១.១២៧.៦២២ |
| បំណុលបន្ទាប់បន្សំ | ២០ | ១៦៧.១៥៨.៦២៣ | ១៣៩.៣០២.៥៨០ | ៦៧៦.១៥៦.៦៣០ | ៥៦៧.៦៥៨.០១៤ |
| បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន | ២៩(ក) | ២៧.៩៥០.៣៣៤ | ២៩.១៧៥.៥៦០ | ១១៣.០៥៩.១០១ | ១១៨.៨៩០.៤០៧ |
| បំណុលភតិសន្យា | ២១ | ២៥.៧៧២.៣៨៥ | ២៧.៧៨៩.១៦៨ | ១០៤.២៤៩.២៩៧ | ១១៣.២៤០.៨៦០ |
| អត្ថប្រយោជន៍និយោជិត | ២២ | ១៧.៧៨១.៧៦៣ | ១៧.៦៦៧.៤៧៧ | ៧១.៩២៧.២៣១ | ៧១.៩៩៤.៩៦៩ |
| **បំណុលសរុប** | | ៥.២៨៥.៩៥៨.១៩៤ | ៥.០៩៥.០២៤.៧៤៤ | ២១.៣៧៩.៦៧៨.៣៩៤ | ២០.៥៥៨.៤៧៥.៨៣៤ |
| **មូលធន** | | | | | |
| ដើមទុន | ២៣ | ៤៣៣.១៦៣.០១៩ | ៤២៨.៨១៨.១៥៤ | ១.៧៥២.១៤៤.៤១២ | ១.៧៤៧.៤៣៣.៩៧៨ |
| បុព្វលាភភាគហ៊ុន | ២៣ | ១១.៧០៦.២១៥ | - | ៤៧.៣៥១.៦៤០ | - |
| ទុនបម្រុង | ៣៣ | ៥១០.៧៤១.៥៥៤ | ៤២៥.៧០៩.៦១២ | ២.០៧៩.៣៥៧.៨០២ | ១.៧៥២.៣៦៨.៦៥៦ |
| ប្រាក់ចំណេញរក្សាទុក | | ១៣៨.៩១៤.៧៦៩ | ១១៧.៧៥០.៧៦៧ | ៥៤៦.៤៧៩.៥២៦ | ៤៦២.២៣២.៣៨៩ |
| **មូលធនសរុប** | | ១.០៩៤.០២៥.៥៥៧ | ៩៧២.២៧៨.៥៣៣ | ៤.៤២៥.៣៣៣.៣៨០ | ៣.៩៦២.០៣៥.០២៣ |
| **បំណុលនិងមូលធនសរុប** | | ៦.៣៧៩.៤៨៣.៧៥១ | ៦.០១៧.៣០៣.២៧៧ | ២៥.៨០៥.០១១.៧៧៤ | ២៤.៥២០.៥១០.៨៥៧ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗដោយឡែក
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០១៩ ដុល្លារអាមេរិក | ២០២០ ពាន់រៀល (កំណត់សម្គាល់ ៤) | ២០១៩ ពាន់រៀល (កំណត់សម្គាល់ ៤) |
|---|---|---|---|---|---|
| ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើ វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព | ២៤ | ៤៧៨.៧៣៩.៣៤១ | ៤៥២.៦៥១.២៨៩ | ១.៩៥១.៨២០.២៩៣ | ១.៨៣៤.១៩៣.០២៣ |
| ចំណាយការប្រាក់ | ២៥ | (១៣៩.៨៥៦.១៤៧) | (១៤៦.៤៨៣.៩៨៧) | (៥៧០.១៩៣.៥១១) | (៥៩៣.៥៥៣.១១៥) |
| **ចំណូលការប្រាក់សុទ្ធ** | | ៣៣៨.៨៨៣.១៩៤ | ៣០៦.១៦៧.៣០២ | ១.៣៨១.៦២៦.៧៨២ | ១.២៤០.៥៨៩.៩០៨ |
| ចំណូលកម្រៃនិងជើងសា | ២៦ | ៤២.៣៥៤.០៩៤ | ៤៦.០៤៨.២២៤ | ១៧២.៦៧៧.៦៤១ | ១៨៦.៥៨៧.៤០៤ |
| ចំណាយកម្រៃនិងជើងសា | | (១.៥២៦.៣៧០) | (៦៦៧.៩៩២) | (៦.២២៣.០១០) | (២.៧០៦.៧០៤) |
| **ចំណូលកម្រៃនិងជើងសាសុទ្ធ** | | ៤០.៨២៧.៧២៤ | ៤៥.៣៨០.២៣២ | ១៦៦.៤៥៤.៦៣១ | ១៨៣.៨៨០.៧០០ |
| សំវិធានធនលើឱនភាពនៃតម្លៃខាតបង់សម្រាប់ឥណទាន និងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារនានា និងប្រាក់ទទួលបានផ្សេងទៀត | ៣៥.១(ច) | (១៦.២៤៧.៦៧៦) | (២១.៧៨០.៦៣២) | (៦៦.២៤១.៧៧៥) | (៨៨.២៥៥.១២១) |
| សំវិធានធនកិច្ចសន្យាក្រៅតារាងតុល្យការ | | ១៣២.០៨២ | (៣៦០.៣៥៤) | ៥៣៨.៤៩៨ | (១.៤៦០.១៥៤) |
| **ឱនភាពនៃតម្លៃខាតបង់សុទ្ធ** | | (១៦.១១៥.៥៩៤) | (២២.១៤០.៩៨៦) | (៦៥.៧០៣.២៧៧) | (៨៩.៧១៥.២៧៥) |
| **ចំណូលបន្ទាប់ពីសំវិធានធនសម្រាប់ឱនភាពនៃតម្លៃ សុទ្ធ** | | ៣៦៣.៥៩៥.៣២៤ | ៣២៩.៤០៦.៥៤៨ | ១.៤៨២.៣៧៨.១៣៦ | ១.៣៣៤.៧៥៥.៣៣៣ |
| ចំណូលផ្សេងៗ | ២៧ | ១៦.៦៦២.៧៤៨ | ១៦.២៣៣.៧៦៤ | ៦៧.៩៣៤.០២៤ | ៦៥.៧៧៩.២១២ |
| ចំណាយទូទៅនិងរដ្ឋបាល | ២៨ | (២០៨.១០៣.៧៥៧) | (១៩៧.៤១៣.៩១០) | (៨៤៨.៤៣៩.០១៧) | (៧៩៩.៩២១.១៦៣) |
| | | (២០៨.១០៣.៧៥៧) | (១៩៧.៤១៣.៩១០) | (៨៤៨.៤៣៩.០១៧) | (៧៩៩.៩២១.១៦៣) |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | | ១៧២.១៥៤.៣១៥ | ១៤៨.២២៦.៤០២ | ៧០១.៨៧៣.១៤៣ | ៦០០.៦១៣.៣៨២ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៩(ខ) | (៣៣.៨១២.១៣៩) | (៣០.៣៣៩.៦២៣) | (១៣៧.៨៥២.០៩១) | (១២២.៩៣៦.១៥៣) |
| **ប្រាក់ចំណេញក្នុងឆ្នាំ** | | ១៣៨.៣៤២.១៧៦ | ១១៧.៨៨៦.៧៧៩ | ៥៦៤.០២១.០៥២ | ៤៧៧.៦៧៧.២២៩ |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | | |
| *ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅចំណេញឬខាត៖* | | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | | ៧២.៥៩៣ | (១៣៦.០១២) | ២៩៥.៩៦២ | (៥៥១.១២១) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | (៧.៩៦១.៧៩៧) | ៧.១៥៣.៧៥៥ |
| លទ្ធផលលម្អិតផ្សេងៗក្នុងឆ្នាំ | | ៧២.៥៩៣ | (១៣៦.០១២) | (៧.៦៦៥.៨៣៥) | ៦.៦០២.៦៣៤ |
| **លទ្ធផលលម្អិតផ្សេងៗក្នុងឆ្នាំសរុប** | | ១៣៨.៤១៤.៧៦៩ | ១១៧.៧៥០.៧៦៧ | ៥៥៦.៣៥៥.២១៧ | ៤៨៤.២៧៩.៨៦៣ |
| **ប្រាក់ចំណេញដែលផ្តល់ជូនដល់៖** | | | | | |
| ភាគហ៊ុនិករបស់ធនាគារ | | ១៣៨.៣៤២.១៧៦ | ១១៧.៨៨៦.៧៧៩ | ៥៦៤.០២១.០៥២ | ៤៧៧.៦៧៧.២២៩ |
| **លទ្ធផលលម្អិតសរុបផ្តល់ជូនដល់៖** | | | | | |
| ភាគហ៊ុនិករបស់ធនាគារ | | ១៣៨.៤១៤.៧៦៩ | ១១៧.៧៥០.៧៦៧ | ៥៥៦.៣៥៥.២១៧ | ៤៨៤.២៧៩.៨៦៣ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍បម្រែបម្រួលមូលធនដោយឡែក
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | ផ្តល់ជូនភាគហ៊ុនិករបស់ធនាគារ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ដើមទុន | | បុព្វលាភភាគហ៊ុន | | ទុនបម្រុង | | ចំណេញរក្សាទុក | | សរុប | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) |
| **នាថ្ងៃទី ១ខែមករាឆ្នាំ ២០២០** | ៤២៨.៨១៨.១៥៤ | ១.៧៤៧.៤៣៣.៩៧៨ | - | - | ៤២៥.៧០៩.៦១២ | ១.៧៥២.៣៦៨.៦៥៦ | ១១៧.៧៥០.៧៦៧ | ៤៦២.២៣២.៣៨៩ | ៩៧២.២៧៨.៥៣៣ | ៣.៩៦២.០៣៥.០២៣ |
| ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - | ១៣៨.៣៤២.១៧៦ | ៥៦៤.០២១.០៥២ | ១៣៨.៣៤២.១៧៦ | ៥៦៤.០២១.០៥២ |
| *លទ្ធផលលម្អិតផ្សេងៗ៖* | | | | | | | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | - | - | - | - | - | - | ៧២.៥៩៣ | ២៩៥.៩៦២ | ៧២.៥៩៣ | ២៩៥.៩៦២ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (៧.៩៦១.៧៩៧) | - | - | - | (៧.៩៦១.៧៩៧) |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | - | - | - | - | - | (៧.៩៦១.៧៩៧) | ១៣៨.៤១៤.៧៦៩ | ៥៦៤.៣១៧.០១៤ | ១៣៨.៤១៤.៧៦៩ | ៥៥៦.៣៥៥.២១៧ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក៖** | | | | | | | | | | |
| ភាគលាភដែលបានបង់ | - | - | - | - | - | - | (៣២.៧១៨.៨២៥) | (១៣៣.៣៨៤.៦៥០) | (៣២.៧១៨.៨២៥) | (១៣៣.៣៨៤.៦៥០) |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅជាដើមទុនបម្រុង | - | - | - | - | ៦៦.៩៤៩.៣០៥ | ២៧២.៩៥២.៣១៦ | (៦៦.៩៤៩.៣០៥) | (២៧២.៩៥២.៣១៦) | - | - |
| ការបោះផ្សាយភាគហ៊ុន | ៤.៣៤៤.៨៦៥ | ១៧.៧១៤.០១៥ | ១១.៧០៦.២១៥ | ៤៧.៧២៦.២៣៩ | - | - | - | - | ១៦.០៥១.០៨០ | ៦៥.៤៤០.២៥៤ |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុក ទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | ១៨.០៨២.៦៣៧ | ៧៣.៧២២.៩១១ | (១៨.០៨២.៦៣៧) | (៧៣.៧២២.៩១១) | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១៣.០០៣.៥៨១) | - | (៣៧៤.៥៩៩) | - | (១១.៧២៤.២៨៤) | - | - | - | (២៥.១០២.៤៦៤) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិកសរុប** | ៤.៣៤៤.៨៦៥ | ៤.៧១០.៤៣៤ | ១១.៧០៦.២១៥ | ៤៧.៣៥១.៦៤០ | ៨៥.០៣១.៩៤២ | ៣៣៤.៩៥០.៩៤៣ | (១១៧.៧៥០.៧៦៧) | (៤៨០.០៦៩.៨៧៧) | (១៦.៦៦៧.៧៤៥) | (៩៣.០៥៦.៨៦០) |
| **នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ២០២០** | ៤៣៣.១៦៣.០១៩ | ១.៧៥២.១៤៤.៤១២ | ១១.៧០៦.២១៥ | ៤៧.៣៥១.៦៤០ | ៥១០.៧៤១.៥៥៤ | ២.០៧៩.៣៥៧.៨០២ | ១៣៨.៤១៤.៧៦៩ | ៥៤៦.៤៧៩.៥២៦ | ១.០៩៤.០២៥.៥៥៧ | ៤.៤២៥.៣៣៣.៣៨០ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍បម្រែបម្រួលមូលធនដោយឡែក (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | ដើមទុន | | ទុនបម្រុង | | ប្រាក់ចំណេញរក្សាទុក | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៤) |
| **នាថ្ងៃទី១ខែមករាឆ្នាំ២០១៩** | ៣៩៥.២២៤.១០៥ | ១.៥៨៨.០១០.៤៥៤ | ៣៨៩.៧៣០.៩២៣ | ១.៥៧៦.៩៦០.១៨៨ | ៧៧.៩៩១.០១១ | ៣០២.៣៤៦.៥៤២ | ៨៦២.៩៤៦.០៣៩ | ៣.៤៦៧.៣១៧.១៨៤ |
| ការកែសម្រួលលើការអនុវត្តជាលើកដំបូងនៃ សរ.ហរ.អ.ក១៦ បន្ទាប់ពីកាត់កងពន្ធ | - | - | - | - | - | - | - | - |
| **សមតុល្យដែលបានបញ្ជាក់ឡើងវិញនៅថ្ងៃទី១ខែមករាឆ្នាំ ២០១៩** | ៣៩៥.២២៤.១០៥ | ១.៥៨៨.០១០.៤៥៤ | ៣៨៩.៧៣០.៩២៣ | ១.៥៧៦.៩៦០.១៨៨ | ៧៧.៩៩១.០១១ | ៣០២.៣៤៦.៥៤២ | ៨៦២.៩៤៦.០៣៩ | ៣.៤៦៧.៣១៧.១៨៤ |
| | | | | | | | | |
| ប្រាក់ចំណេញក្នុងឆ្នាំ | - | - | - | - | ១១៧.៨៨៦.៧៧៩ | ៤៧៧.៦៧៧.២២៩ | ១១៧.៨៨៦.៧៧៩ | ៤៧៧.៦៧៧.២២៩ |
| *លទ្ធផលលម្អិតផ្សេងៗ៖* | | | | | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | - | - | - | - | (១៣៦.០១២) | (៥៥១.១២១) | (១៣៦.០១២) | (៥៥១.១២១) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | ៧.១៥៣.៧៥៥ | - | - | - | ៧.១៥៣.៧៥៥ |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | - | - | - | ៧.១៥៣.៧៥៥ | ១១៧.៧៥០.៧៦៧ | ៤៧៧.១២៦.១០៨ | ១១៧.៧៥០.៧៦៧ | ៤៨៤.២៧៩.៨៦៣ |
| | | | | | | | | |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិកៈ** | | | | | | | | |
| ភាគលាភជាភាគហ៊ុន | ៣៣.៥៩៩.០៤៩ | ១៣៦.៧៦១.៣៧៣ | - | - | (៣៣.៥៩៩.០៤៩) | (១៣៦.៧៦១.៣៧៣) | - | - |
| ភាគលាភជាសាច់ប្រាក់ | - | - | - | - | (៨.៩១៨.២៧៣) | (៣៩.០៦០.៣៣៣) | (៨.៩១៨.២៧៣) | (៣៩.០៦០.៣៣៣) |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅជាទុនបម្រុងទូទៅ | - | - | ៤៨.៦៥០.៥៩៧ | ១៩៨.០៥៦.៥៨០ | (៤៨.៦៥០.៥៩៧) | (១៩៨.០៥៦.៥៨០) | - | - |
| ការផ្ទេរពីទុនបម្រុងតាមបទប្បញ្ញត្តិទៅជាប្រាក់ចំណេញរក្សាទុក | - | - | (១២.៦៧១.៩០៨) | (៥១.៦៣៨.០២៥) | ១២.៦៧១.៩០៨ | ៥១.៦៣៨.០២៥ | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ២២.៦៦២.១៥១ | - | ២១.៨៣៦.១៥៨ | - | - | - | ៤៤.៤៩៨.៣០៩ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិកសរុប** | ៣៣.៥៩៩.០៤៩ | ១៥៩.៤២៣.៥២៤ | ៣៥.៩៧៨.៦៨៩ | ១៦៨.២៥៤.៧១៣ | (៧៧.៩៩១.០១១) | (៣១៧.២៤០.២៦១) | (៨.៩១៨.២៧៣) | ១០.៤៣៧.៩៧៦ |
| | | | | | | | | |
| **នាថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០១៩** | ៤២៨.៨១៨.១៥៤ | ១.៧៤៧.៤៣៣.៩៧៨ | ៤២៥.៧០៩.៦១២ | ១.៧៥២.៣៦៨.៦៥៦ | ១១៧.៧៥០.៧៦៧ | ៤៦២.២៣២.៣៨៩ | ៩៧២.២៧៨.៥៣៣ | ៣.៩៦២.០៣៥.០២៣ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍លំហូរសាច់ប្រាក់ដោយឡែក
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០១៩ ដុល្លារអាមេរិក | ២០២០ ពាន់រៀល (កំណត់សម្គាល់ ៤) | ២០១៩ ពាន់រៀល (កំណត់សម្គាល់ ៤) |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញក្នុងឆ្នាំ | | ១៣៨.៣៤២.១៧៦ | ១១៧.៨៨៦.៧៧៩ | ៥៦៤.០២១.០៥២ | ៤៧៧.៦៧៧.២២៩ |
| *និយ័តកម្ម៖* | | | | | |
| រំលស់លើទ្រព្យនិងបរិក្ខារ | ១២ | ១៩.១៨១.១៥១ | ១៩.២៧៥.៧៨៧ | ៧៨.២០១.៥៥៣ | ៧៨.១០៥.៤៨៩ |
| រំលស់លើទ្រព្យសកម្មអរូបី | ១៣ | ៣.៣៣៩.៥១០ | ៣.១៨២.៨២១ | ១៣.៦១៥.១៨២ | ១២.៨៩៦.៧៩១ |
| រំលស់លើសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ១៤ | ៩.៧៧០.៦៣៨ | ៩.៦៤៧.៨៧១ | ៣៩.៨៣៤.៨៩១ | ៣៩.០៩៣.១៧៣ |
| និយ័តកម្មលើទ្រព្យនិងបរិក្ខារ | | ១៨.៥៣៤ | ៤២.៧៩៧ | ៧៥.៥៦៣ | ១៧៣.៤១៣ |
| និយ័តកម្មលើទ្រព្យសកម្មអរូបី | | ២៩០.២៨៤ | ៣៩១.១៥០ | ១.១៨៣.៤៨៨ | ១.៥៨៤.៩៤០ |
| សំវិធានធនលើខាតបង់ឱនភាពនៃតម្លៃ | ៨ | ១៦.១១៥.៥៩៤ | ២២.១៤០.៩៨៦ | ៦៥.៧០៣.២៧៧ | ៨៩.៧១៥.២៧៥ |
| ចំណាយអត្ថប្រយោជន៍ពេលចូលនិវត្ត | ២២(ក) | ១.៥៧៧.៦៧៧ | ១.៤០២.០៧៧ | ៦.៤៣២.១៨៩ | ៥.៦៨១.២១៨ |
| អត្ថប្រយោជន៍ប្រាក់បំណាច់អតីតភាពការងារ | ២២(គ) | ៦.៣៧៨.៧៣៨ | ៣.១៧១.១១៦ | ២៦.០០៦.១១៥ | ១២.៨៤៩.៣៦២ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៩(ខ) | ៣៣.៨១២.១៣៩ | ៣០.៣៣៩.៦២៣ | ១៣៧.៨៥២.០៩១ | ១២២.៩៣៦.១៥៣ |
| ចំណូលការប្រាក់សុទ្ធ | | (៣៣៨.៨៨៣.១៩៤) | (៣០៦.១៦៧.៣០២) | (១.៣៨១.៦២៦.៧៨២) | (១.២៤០.៥៨៩.៩០៨) |
| ចំណេញពីការលក់ទ្រព្យនិងបរិក្ខារនិងទ្រព្យសកម្មអរូបី | | (៣២៦.២៩៩) | (៨៤.៦៣៧) | (១.៣៣០.៣២១) | (៣៤២.៩៤៩) |
| ចំណេញពីការប្តូររូបិយប័ណ្ណមិនទាន់បានទទួលស្គាល់ | | (២២៧.៧៩៤) | (១.០១៩.៣៩០) | (៩២៨.៧១៦) | (៤.១៣០.៥៧០) |
| | | (១១០.៦១០.៨៤៦) | (៩៩.៧៩០.៣២២) | (៤៥០.៩៦០.៤១៨) | (៤០៤.៣៥០.៣៨៤) |
| *បម្រែបម្រួល៖* | | | | | |
| ឥណទាននិងបុរេប្រទាន | | (៦២២.២៤៨.០៧៩) | (២៤៨.៤៧៤.៨៥៩) | (២.៥៣៦.៩០៥.៤១៨) | (១.០០៦.៨២០.១២៩) |
| ប្រាក់បញ្ញើនៅធនាគារផ្សេងៗ | | ១៨១.៣៥៩.៣៨៧ | - | ៧៣៩.៤០២.២២១ | - |
| ប្រាក់បញ្ញើតាមច្បាប់ | | ៤២.០៤៧.៥៥៨ | (៤៥.២៤២.៤៦៩) | ១៧១.៤២៧.៨៩៤ | (១៨៣.៣២២.៤៨៤) |
| ទ្រព្យសកម្មផ្សេងៗ | | (៤.៩១០.០៧៥) | ៤.៤៧៣.៦០៩ | (២០.០១៨.៣៧៦) | ១៨.១២៧.០៦៤ |
| ប្រាក់បញ្ញើរបស់អតិថិជន | | ១៩៨.១២២.១៧៨ | ៤៨០.៦៦៤.០៥៦ | ៨០៧.៧៤៤.១២០ | ១.៩៤៧.៦៥០.៧៥៥ |
| ប្រាក់បញ្ញើនៅធនាគារនិងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | | ២២.៤៨៦.៨៣៣ | (១០.២៨៦.៥៨១) | ៩១.៦៧៨.៨១៨ | (៤១.៦៨១.២២៦) |
| មូលនិធិអភិវឌ្ឍន៍វិជ្ជាជីវៈ | | ១.៣១២.៦៤១ | ១.៣៨៥.៤៩៣ | ៥.៣៥១.៦៣៧ | ៥.៦១៤.០១៨ |
| បំណុលផ្សេងៗ | | ១១.៥៨៣.៧៥៦ | (៦.៤៦០.៦៦៨) | ៤៧.២២៦.៩៧៣ | (២៦.១៧៨.៦២៧) |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)បានពីប្រតិបត្តិការ** | | (២៨០.៨៥៦.៦៤៧) | ៧៦.២៦៨.២៥៩ | (១.១៤៥.០៥២.៥៤៩) | ៣០៩.០៣៨.៩៨៧ |
| ចំណូលការប្រាក់បានទទួល | | ៤៧៩.១១៣.៧១៥ | ៤៥២.៦៦៨.៤២៣ | ១.៩៥៣.៣៤៦.៦១៦ | ១.៨៣៤.២១២.៤៥០ |
| ចំណាយការប្រាក់បានបង់ | | (១៤៣.៦២០.៧១៤) | (១៣៨.៦៧២.៩៩៤) | (៥៨៥.៥៤១.៦៥១) | (៥៦១.៩០២.៩៧២) |
| ពន្ធលើប្រាក់ចំណូលបានបង់ | ២៩(ក) | (៣៣.៧១៥.៥៦៩) | (១៧.១៤០.៥៣១) | (១៣៧.៤៥៨.៣៧៥) | (៦៩.៤៥៣.៤៣២) |
| អត្ថប្រយោជន៍ពេលចូលនិវត្តបានបង់ | ២២(ក) | (១៤៣.០០៤) | (១៤៨.៣៥០) | (៥៨៣.០២៧) | (៦០១.១១៤) |
| មូលនិធិអភិវឌ្ឍន៍វិជ្ជាជីវៈបានបង់ | ២២(ខ) | (២.០៨៥.៣១៥) | (១.៤៦៥.៣៩៣) | (៨.៥០១.៨២៩) | (៥.៩៣៧.៧៧២) |
| អត្ថប្រយោជន៍ប្រាក់បំណាច់អតីតភាពការងារបានបង់ | ២២(គ) | (៦.៨១៥.២៤៨) | (៦.១១២.៣១២) | (២៧.៧៨៥.៧៦៦) | (២៤.៧៦៧.០៨៨) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | | ១១.៨៧៧.២១៨ | ៣៦៥.៣៩៧.១០២ | ៤៨.៤២៣.៤១៩ | ១.៤៨០.៥៨៩.០៥៩ |

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## របាយការណ៍លំហូរសាច់ប្រាក់ដោយឡែក (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) | ២០១៩<br>ពាន់រៀល<br>(កំណត់សម្គាល់ ៤) |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការវិនិយោគហិរញ្ញវត្ថុ | | ២២.៩៤៦.៥៧៦ | ២២.៤០៧.៤៤១ | ៩៣.៥៥៣.១៩០ | ៩០.៧៩៤.៩៥១ |
| ការទិញទ្រព្យនិងបរិក្ខារ | ១២ | (១៧.០៩៣.៧៩១) | (១៣.១៧២.៤៣៥) | (៦៩.៦៩១.៣៨៦) | (៥៣.៣៧៤.៧០៧) |
| ការទិញទ្រព្យសកម្មអរូបី | ១៣ | (៩.៦០៣.២៩៧) | (១.៧៥០.៦៥៦) | (៣៩.១៥២.៦៤២) | (៧.០៩៣.៦៥៨) |
| ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | | ២០.០០០ | (៧.៩៦៥.២៩០) | ៨១.៥៤០ | (៣២.២៧៥.៣៥៥) |
| សាច់ប្រាក់បានពីការលក់ទ្រព្យនិងបរិក្ខារ | | ៣៤៨.១០៥ | ៣៣៩.៤៤៩ | ១.៤១៩.២២៤ | ១.៣៧៥.៤៤៧ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | (៣.៣៨២.៤០៧) | (១៤១.៤៩១) | (១៣.៧៩០.០៧៤) | (៥៧៣.៣២២) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ការទូទាត់ភាគលាភ | | (៣២.៧១៨.៨២៥) | (៨.៤១៨.២៧៣) | (១៣៣.៣៩៤.៦៥០) | (៣៤.១១០.៨៤២) |
| ការសងប្រាក់កម្ចី | | (១៨៦.២១៣.២៩៣) | (៤២៩.៩១២.៧៨៥) | (៧៥៩.១៩១.៥៩៦) | (១.៧៤២.០០៦.៦០៥) |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | ១៧៥.៤៩៨.០៨១ | ១៩៤.៣៨៨.៤៥១ | ៧១៥.៥០៥.៦៧៦ | ៧៨៧.៦៦២.០០៣ |
| ការសងបំណុលបន្ទាប់បន្សំ | | (៧.១៤៣.៩៥៧) | (៣២.០០០.០០០) | (២៩.១២៥.៩១៣) | (១២៩.៦៦៤.០០០) |
| សាច់ប្រាក់បានពីបំណុលបន្ទាប់បន្សំ | | ៣៥.០០០.០០០ | ៩៣.៨៣៣.៦៦៧ | ១៤២.៦៩៥.០០០ | ៣៨០.២១៤.០១៩ |
| សាច់ប្រាក់បានពីការបោះផ្សាយភាគហ៊ុន | | ៤.៣៤៤.៨៦៥ | - | ១៧.៧១៤.០១៥ | - |
| សាច់ប្រាក់បានពីបុព្វលាភភាគហ៊ុន | | ១១.៧០៦.២១៥ | - | ៤៧.៧២៦.២៣៩ | - |
| ការទូទាត់បំណុលភតិសន្យា | ២១ | (១០.៨៨៣.៤០៦) | (១០.៤៥២.១៩៥) | (៤៤.៣៧១.៦៤៦) | (៤២.៣៥២.២៩៤) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន** | | (១០.៤១០.៣២០) | (១៩២.៥៦១.១៣៥) | (៤២.៤៤២.៨៧៥) | (៧៨០.២៥៧.៧១៩) |
| **កើនឡើង(ថយចុះ)/កើនឡើងសាច់ប្រាក់ និង សាច់ប្រាក់សមមូលសុទ្ធ** | | (១.៩១៥.៥០៩) | ១៧២.៦៩៤.៤៧៦ | (៧.៨០៩.៥៣០) | ៦៩៩.៧៥៨.០១៨ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមឆ្នាំ** | | ១.៤៥៩.៦១៣.៤៤៨ | ១.២៨៦.៩១៨.៩៧២ | ៥.៩៤៧.៩២៤.៨០១ | ៥.១៧០.៨៤០.៤២៩ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | (៤៣.៧២៧.១០៨) | ៧៧.៣២៦.៣៥៤ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងឆ្នាំ** | ៣១ | ១.៤៥៧.៦៩៧.៩៣៩ | ១.៤៥៩.៦១៣.៤៤៨ | ៥.៨៩៦.៣៨៨.១៦៣ | ៥.៩៤៧.៩២៤.៨០១ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

## ១. ព័ត៌មានទូទៅ

មុនថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ហៅកាត់ថា "ធនាគារ") គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបង្កើតឡើងក្រោមច្បាប់ព្រះរាជាណាចក្រកម្ពុជា ហើយធ្វើប្រតិបត្តិការជាធនាគារឯកទេស ដែលមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ និងមានសាខាចំនួន ១៤ ក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារជាតិ នៃ កម្ពុជា បានផ្តល់អាជ្ញាប័ណ្ណដល់ធនាគារជាធនាគារពាណិជ្ជឯកជន សម្រាប់រយៈពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣។ អាជ្ញាប័ណ្ណរបស់ធនាគារ ត្រូវបានធ្វើជាថ្មីទៅជាអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦។

ទីស្នាក់ការចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ធនាគារធ្វើប្រតិបត្តិការក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ដោយផ្តោតជាពិសេសលើការផ្តល់ឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗទៀតសម្រាប់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាសហគ្រាសធុនតូច និងមធ្យម ព្រមទាំងសកម្មភាពអាជីវកម្មដទៃទៀត ដែលក្រុមប្រឹក្សាភិបាលជឿជាក់ថាគាំទ្រដល់គោលបំណងនេះ។

សកម្មភាពចម្បងៗរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ១១ លើរបាយការណ៍ហិរញ្ញវត្ថុ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ មានបុគ្គលិកចំនួន ១៣.៧០៤ នាក់ (២០១៩៖ ១៣.៦៥៥ នាក់)។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តឲ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗខាងក្រោមនេះ ត្រូវបានអនុវត្តដោយសម្ព័ន្ធធនាគារ និងធនាគារ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ។ គោលនយោបាយទាំងអស់នេះ ត្រូវបានយកមកអនុវត្តប្រកបដោយសង្គតិភាពនៅគ្រប់ការិយបរិច្ឆេទ លើកលែងតែមានការបញ្ជាក់បន្ថែម។

### (ក) មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហៅកាត់ថា ("ស.រ.ទ.ហ.អ.ក")។ របាយការណ៍ហិរញ្ញវត្ថុរួមត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានថ្លៃដើម។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) មូលដ្ឋាននៃការរៀបចំ (ត)

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អនុលោមទៅតាម ស.រ.ទ.ហ.អ.ក តម្រូវឲ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យសំខាន់ៗ។ វាក៏តម្រូវឲ្យក្រុមប្រឹក្សាភិបាលធ្វើការវិនិច្ឆ័យក្នុងដំណើរការអនុវត្តគោលនយោបាយគណនេយ្យរបស់សម្ព័ន្ធធនាគារ និងធនាគារ។ ផ្នែកពាក់ព័ន្ធនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញដែលមានកម្រិតខ្ពស់ ឬផ្នែកដែលមានការសន្មត និងការប៉ាន់ស្មានជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៣។

### (ខ) ស្តង់ដារបានចេញផ្សាយប៉ុន្តែមិនទាន់បានប្រើ

ស្តង់ដារថ្មី និងការធ្វើវិសោធនកម្មស្តង់ដារមួយចំនួន បានចូលជាធរមាន សម្រាប់ការិយបរិច្ឆេទដែលចាប់ផ្តើមបន្ទាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដែលការអនុវត្តមុនកាលកំណត់ត្រូវបានអនុញ្ញាត ប៉ុន្តែសម្ព័ន្ធធនាគារ និងធនាគារ មិនបានអនុវត្តស្តង់ដារមុនកាលកំណត់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះនៅឡើយទេ។

ស្តង់ដារដែលបានវិសោធនកម្មខាងក្រោមនេះ ទាំងនោះមិនត្រូវបានរំពឹងថានឹងមិនមានផលប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ។

- *កិច្ចសន្យាខាតបង់ - ចំណាយដើម្បីបំពេញកិច្ចសន្យា (ការធ្វើវិសោធនកម្មចំពោះ ស.គ.អ.ក ៣៧).*
- *សម្បទានការជួលទាក់ទងនឹងកូវីដ១៩ (ការធ្វើវិសោធនកម្មចំពោះ ស.រ.ហ.អ.ក ១៦)។*
- *ទ្រព្យ រោងចក្រ និងបរិក្ខារៈ ចំណូលមុនពេលប្រើប្រាស់ដែលបានកំណត់ទុកជាមុន (ការធ្វើវិសោធនកម្មចំពោះ ស.គ.អ.ក ១៦)។*
- *ឯកសារយោងចំពោះក្របខ័ណ្ឌទស្សនទាន (ការធ្វើវិសោធនកម្មចំពោះ ស.រ.ហ.អ.ក ៣)។*
- *ការធ្វើចំណាត់ថ្នាក់បំណុល ជាបំណុលរយៈពេលខ្លី ឬពេលវែង (ការធ្វើវិសោធនកម្មចំពោះ ស.គ.អ.ក ១)។*

### (គ) របាយការណ៍ហិរញ្ញវត្ថុរួម

*(i) ក្រុមហ៊ុនបុត្រសម្ព័ន្ធ*

ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាក្រុមហ៊ុនទាំងឡាយណាដែលសម្ព័ន្ធមានអភិបាលភាព។ សម្ព័ន្ធអភិបាលក្រុមហ៊ុនមួយនៅពេលដែលសម្ព័ន្ធប្រឈម ឬមានសិទ្ធិចំពោះផលអថេរពីការវិនិយោគជាមួយក្រុមហ៊ុន និងមានឥទ្ធិពលទៅលើផលទាំងនោះតាមរយៈសិទ្ធិអំណាចរបស់ខ្លួនក្នុងការដឹកនាំសកម្មភាពដែលពាក់ព័ន្ធរបស់ក្រុមហ៊ុន។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០**

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (គ) របាយការណ៍ហិរញ្ញវត្ថុរួម (ត)

*(i) ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ត)*

របាយការណ៍ហិរញ្ញវត្ថុរួម គឺរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់ ដែលបានរៀបចំសម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុនេះ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានរួមបញ្ចូលគ្នាចាប់ពីកាលបរិច្ឆេទដែលអភិបាលភាពត្រូវបានផ្ទេរទៅឲ្យសម្ព័ន្ធធនាគារ និងបញ្ឈប់ការរួមបញ្ចូលគ្នាចាប់ពីកាលបរិច្ឆេទដែលអភិបាលភាពបានបញ្ចប់។

រាល់ប្រតិបត្តិការ និងសមតុល្យជាសារវន្តរវាងសម្ព័ន្ធធនាគារត្រូវបានលុបចោល ហើយរបាយការណ៍ហិរញ្ញវត្ថុរួម ឆ្លុះបញ្ចាំងតែប្រតិបត្តិការខាងក្រៅតែប៉ុណ្ណោះ។ នៅពេលចាំបាច់ គោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានផ្លាស់ប្តូរដើម្បីធានាឲ្យបាននូវសង្គតិភាពជាមួយនឹងគោលនយោបាយដែលអនុវត្តដោយសម្ព័ន្ធ។

*(ii) ការផ្លាស់ប្តូរអត្ថប្រយោជន៍ភាគហ៊ុនិកក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដោយមិនផ្លាស់ប្តូរអភិបាលភាព*

ប្រតិបត្តិការជាមួយអប្បភាគភាគកម្ម ដែលមិនធ្វើឲ្យមានការបាត់បង់អភិបាលភាព ត្រូវបានកត់ត្រាជាប្រតិបត្តិការមូលធន ដូចប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុនក្នុងនាមជាម្ចាស់ដែរ។ ករណីមានការទិញពីអប្បភាគភាគកម្ម លម្អៀងរវាង តម្លៃតបស្នងដែលបានបង់ និងចំណែកពាក់ព័ន្ធនៃតម្លៃយោងទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលបានទិញ ត្រូវបានកត់ត្រាដកចេញពីមូលធន។ ករណីមានការលក់អប្បភាគភាគកម្ម លម្អៀងរវាង តម្លៃតបស្នង ដែលបានទទួល និងចំណែកពាក់ព័ន្ធនៃតម្លៃយោងទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលបានលក់ ក៏ត្រូវកត់ត្រាក្នុងមូលធនដែរ។

*(iii) ការលក់នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ*

នៅពេលដែលសម្ព័ន្ធលែងមានអភិបាលភាព អត្ថប្រយោជន៍ដែលមាននៅក្នុងក្រុមហ៊ុនត្រូវបានវាស់វែងឡើងវិញទៅតាមតម្លៃសមស្រប នៅកាលបរិច្ឆេទដែលអភិបាលភាពបានបាត់បង់ ជាមួយនឹងការផ្លាស់ប្តូរនៃតម្លៃ ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ តម្លៃសមស្របគឺជាតម្លៃយោងដំបូងសម្រាប់គោលបំណងគណនេយ្យជាបន្តបន្ទាប់ សម្រាប់អត្ថប្រយោជន៍ដែលត្រូវទទួលបានទុកជាសមាគត ការដាក់ទុនរួមគ្នា ឬទ្រព្យសកម្មហិរញ្ញវត្ថុ។ លើសពីនេះទៀត ចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅគ្រាមុននៅក្នុងលទ្ធផលលម្អិតផ្សេងៗទាក់ទងនឹងអង្គភាពនោះ ត្រូវកត់ត្រាដូចករណីដែលសម្ព័ន្ធបានលក់ដោយផ្ទាល់នៃទ្រព្យសកម្ម ឬសងបំណុលដែលពាក់ព័ន្ធ។ វាអាចមានន័យថា ចំនួនដែលបានទទួលនៅគ្រាមុននៅក្នុងលទ្ធផលលម្អិតផ្សេងៗ ត្រូវបានចាត់ថ្នាក់ឡើងវិញទៅរបាយការណ៍ប្រាក់ចំណេញ ឬខាត។

## ២. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (គ) របាយការណ៍ហិរញ្ញវត្ថុរួម (ត)

*(iv) ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ*

ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានរាយការណ៍តាមថ្លៃដើម ដកការខាតបង់ឱនភាពនៃតម្លៃបង្គរ នៅក្នុងរបាយការណ៍ដោយឡែករបស់ធនាគារ។ នៅពេលលក់ការវិនិយោគនោះចេញវិញ តម្លៃលម្អៀងរវាងតម្លៃតបស្នងដែលបានមកពីការលក់ និងតម្លៃយោងរបស់វា ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញឬខាត។

ចំនួនទឹកប្រាក់ដែលត្រូវទទួលបានពីក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលធនាគារមិនរំពឹងថានឹងសងត្រឡប់មកវិញនាពេលអនាគត ត្រូវបានចាត់ទុកជាផ្នែកមួយនៃការវិនិយោគរបស់ធនាគារនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ។

### (ឃ) ការប្រែសម្រួលរូបិយប័ណ្ណបរទេស

*(i) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ការបង្ហាញ*

ធាតុនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៃសម្ព័ន្ធ ត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិស្ថានសេដ្ឋកិច្ចសំខាន់ដែលក្រុមហ៊ុនប្រើនៅក្នុងកិច្ចប្រតិបត្តិការ ("រូបិយប័ណ្ណមុខងារ")។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ការបង្ហាញរបស់សម្ព័ន្ធធនាគារ និងធនាគារ។

*(ii) ប្រតិបត្តិការ និងសមតុល្យ*

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្រែសម្រួលទៅជារូបិយប័ណ្ណមុខងារតាមអត្រាប្តូរប្រាក់ នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណបរទេសដែលកើតមកពីការទូទាត់នៃប្រតិបត្តិការទាំងនេះ និងពីការប្រែសម្រួលអត្រាប្តូរប្រាក់ នៅចុងការិយបរិច្ឆេទរបស់ទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ ឬខាត។

*(iii) សម្ព័ន្ធធនាគារ*

របាយការណ៍លទ្ធផល និងស្ថានភាពហិរញ្ញវត្ថុនៃកិច្ចប្រតិបត្តិការក្រៅប្រទេស (ដែលមិនមានរូបិយប័ណ្ណនៃសេដ្ឋកិច្ចដែលមានអតិផរណាខ្ពស់ហួសហេតុ) ដែលមានរូបិយប័ណ្ណមុខងារខុសគ្នាពីរូបិយប័ណ្ណសម្រាប់ការបង្ហាញរបស់ធនាគារ ត្រូវបានប្រែសម្រួលទៅជារូបិយប័ណ្ណសម្រាប់ការបង្ហាញ ដូចខាងក្រោម៖

## ២. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឃ) ការប្រែសម្រួលរូបិយប័ណ្ណបរទេស (ត)

*(iii) សម្ព័ន្ធធនាគារ (ត)*

ក) ទ្រព្យសកម្មនិងបំណុលសម្រាប់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗដែលបានបង្ហាញ ត្រូវបានប្រែសម្រួលតាមអត្រាបិទបញ្ជីនៅចុងការិយបរិច្ឆេទនៃរបាយការណ៍។

ខ) ប្រាក់ចំណូលនិងចំណាយ សម្រាប់ការរាយការណ៍ចំណេញ ឬខាតនីមួយៗ ត្រូវបានប្រែសម្រួលតាមអត្រាប្តូរប្រាក់ជាមធ្យម (លើកលែងតែអត្រាមធ្យមនេះមិនមែនជាភាពប្រហាក់ប្រហែលសមហេតុផលនៃផលប៉ះពាល់បង្គររបស់អត្រានៅកាលបរិច្ឆេទប្រតិបត្តិការក្នុងករណីដែលចំណូល និងចំណាយត្រូវបានប្រែសម្រួលតាមអត្រានៅកាលបរិច្ឆេទនៃប្រតិបត្តិការនេះ) និង

គ) រាល់ភាពខុសគ្នានៃលម្អៀងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជាសមាសធាតុដាច់ដោយឡែកនៃមូលធន។

លម្អៀងពីការប្តូររូបិយប័ណ្ណដែលកើតឡើងពីការប្រែសម្រួលនៃការវិនិយោគសុទ្ធ នៅក្នុងកិច្ចប្រតិបត្តិការបរទេសណាមួយ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ នៅក្នុងមូលដ្ឋាននៃការរួមបញ្ចូលគ្នា។ នៅពេលកិច្ចប្រតិបត្តិការបរទេស ត្រូវបានលក់ដោយផ្នែក លម្អៀងពីការប្តូររូបិយប័ណ្ណ ត្រូវបានចាត់ថ្នាក់ឡើងវិញទៅរបាយការណ៍ចំណេញ ឬខាតដែលជាផ្នែកមួយនៃចំណេញ ឬខាតពីការលក់។

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

*(i) ការទទួលស្គាល់ និងការវាស់វែងលើកដំបូង*

សម្ព័ន្ធធនាគារ ឬធនាគារទទួលស្គាល់លើកដំបូងនូវឥណទាននិងបុរេប្រទាន ប្រាក់បញ្ញើ ប្រាក់កម្ចី និងបំណុលបន្ទាប់បន្សំ នៅកាលបរិច្ឆេទដែលកើតមាន។ ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (រួមមានការទិញ និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុជាប្រចាំ) ត្រូវបានទទួលស្គាល់នៅកាលបរិច្ឆេទជួញដូរ ដែលជាកាលបរិច្ឆេទដែលសម្ព័ន្ធធនាគារ ឬធនាគារក្លាយជាភាគីនៃកិច្ចសន្យារបស់របស់ឧបករណ៍។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកនឹង (សម្រាប់ឧបករណ៍ដែលមិនមែនវាស់វែងតាមតម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL") ចំណាយប្រតិបត្តិការដែលកើតមកពីការទិញ ឬចេញផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០**

## ២. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii) ការធ្វើចំណាត់ថ្នាក់*

នៅក្នុងការទទួលស្គាល់លើកដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ថ្នាក់ជា: តម្លៃដករំលស់តម្លៃសមស្រប តាមរយៈលទ្ធផលលម្អិតផ្សេងៗ ("FVOCI") ឬតម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL")។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមតម្លៃដករំលស់ ប្រសិនបើវាបំពេញតាមលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងម៉ូដែលអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌនៃកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ដែលជាត្រូវទូទាត់តែប្រាក់ដើម និងការប្រាក់ តាមបរិមាណប្រាក់ដើមនៅជំពាក់ ("SPPI")។

ឧបករណ៍បំណុល ត្រូវបានវាស់វែងតាម FVOCI លុះត្រាតែវាបានបំពេញតាមលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងម៉ូដែលអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌនៃកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ដែលជា SPPI។

សម្រាប់ការទទួលស្គាល់ការវិនិយោគលើមូលធនលើកដំបូង ដែលមិនត្រូវបានកាន់កាប់សម្រាប់ជួញដូរ សម្ព័ន្ធធនាគារ និងធនាគារ ត្រូវអាចជ្រើសរើសជាស្ថាពរដើម្បីបង្ហាញការប្រែប្រួលតម្លៃសមស្របនៅគ្រាបន្ទាប់ ក្នុងលទ្ធផលលម្អិតផ្សេងៗ។ ការជ្រើសរើសនេះធ្វើឡើងដោយផ្អែកមូលដ្ឋានតាមការវិនិយោគនីមួយៗ។

**ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ផ្សេងទៀតដែលត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាម FVTPL**

លើសពីនេះ សម្រាប់ការទទួលស្គាល់លើកដំបូង សម្ព័ន្ធធនាគារ ឬធនាគារអាចនឹងកំណត់ជាស្ថាពរនូវទ្រព្យសកម្មហិរញ្ញវត្ថុ វាស់វែងតាម FVTPL ប្រសិនមិនបំពេញតាមលក្ខខណ្ឌក្នុងការវាស់វែងតាមតម្លៃដករំលស់ ឬតាម FVOCI ប្រសិនបើអនុវត្តដូច្នេះត្រូវលុបបំបាត់ឬកាត់បន្ថយជាសារវន្តនូវភាពមិនស៊ីគ្នានៃគណនេយ្យដែលនឹងកើតឡើង។

## ២. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii) ការធ្វើចំណាត់ថ្នាក់ (ត)*

**ការវាយតម្លៃម៉ូដែលអាជីវកម្ម**

សម្ព័ន្ធធនាគារ ឬធនាគារ ធ្វើការវាយតម្លៃអំពីគោលបំណងនៃម៉ូដែលអាជីវកម្ម ដែលទ្រព្យសកម្មមួយត្រូវបានកាន់កាប់ក្នុងកម្រិតសម្ពាធហ្វាស៊ីលីធីមួយ ព្រោះវាឆ្លុះបញ្ចាំងបានល្អបំផុតអំពីមធ្យោបាយដែលអាជីវកម្មត្រូវបានគ្រប់គ្រង និងព័ត៌មានទៅដែលបានផ្តល់ជូនអ្នកគ្រប់គ្រង។ ព័ត៌មានទាំងនោះរួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានចែងសម្រាប់សម្ពាធហ្វាស៊ីលីធី និងការអនុវត្តជាក់ស្តែងនូវគោលនយោបាយទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់អ្នកគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា រក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ធ្វើឲ្យស៊ីសង្វាក់គ្នារវាងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ទៅនឹងរយៈពេលនៃបំណុល ដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឲ្យមានលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម

- វិធីក្នុងការវាយតម្លៃលទ្ធផលនៃសម្ពាធហ្វាស៊ីលីធី និងវិធីរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់សម្ព័ន្ធធនាគារ ឬធនាគារ

- ហានិភ័យដែលជះឥទ្ធិពលដល់លទ្ធផលនៃម៉ូដែលអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងម៉ូដែលអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ

- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់ផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង

- ភាពញឹកញាប់ បរិមាណនិងរយៈពេលនៃការលក់ក្នុងគ្រាមុន មូលហេតុនៃការលក់ទាំងនោះ និងការរំពឹងទុកអំពីសកម្មភាពនៃការលក់នាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពនៃការលក់មិនត្រូវបានយកមកពិចារណាដាច់ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃទាំងមូលនៃវិធីសាស្ត្រដែលសម្ព័ន្ធធនាគារ ឬធនាគារ បានចែងអំពីគោលបំណងសម្រាប់សម្រេចបានការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងវិធីសាស្ត្រក្នុងការទទួលបានលំហូរសាច់ប្រាក់។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលទុកសម្រាប់ការជួញដូរ ឬចាត់ចែង ហើយដែលលទ្ធផលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាយតម្លៃតាមមូលដ្ឋានតម្លៃសមស្រប ត្រូវបានវាស់វែងតាម FVTPL ព្រោះទ្រព្យសកម្មទាំងនោះមិនមែនទុកសម្រាប់ប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ឬមិនមែនទុកសម្រាប់ទាំងការប្រមូលសាច់ប្រាក់តាមកិច្ចសន្យានិងសម្រាប់លក់ឡើយ។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii). ការធ្វើចំណាត់ថ្នាក់ (ត)*

*ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាជាការទូទាត់តែប្រាក់ដើម និងការប្រាក់*

ចំពោះគោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" គឺជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់លើកដំបូង។ "ការប្រាក់" គឺជាតម្លៃតបស្នងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ សម្រាប់រយៈពេលណាមួយ និងសម្រាប់ហានិភ័យដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើម នៅជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ចំណាយរួមទាំងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសន្ទនីយភាព និងចំណាយរដ្ឋបាល)រួមទាំងកម្រិតប្រាក់ចំណេញ។

សម្ព័ន្ធធនាគារ និងធនាគារពិចារណាទៅលើលក្ខខណ្ឌកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ ដើម្បីវាយតម្លៃថាតើសាច់ប្រាក់តាមកិច្ចសន្យា គឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ដែរ ឬទេ។ វារួមបញ្ចូលការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុ មានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលមិនអាចបំពេញតាមលក្ខខណ្ឌនៃការទូទាត់តែប្រាក់ដើម និងការប្រាក់។

ក្នុងការវាយតម្លៃ សម្ព័ន្ធធនាគារ និងធនាគារ ពិចារណាលើ៖

- ព្រឹត្តិការណ៍ជាយថាហេតុដែលអាចផ្លាស់ប្តូរចំនួន និងពេលវេលានៃលំហូរសាច់ប្រាក់
- លក្ខណៈពិសេសអានុភាព
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យារពេលសង
- លក្ខខណ្ឌដែលកម្រិតសម្ព័ន្ធធនាគារឬធនាគារក្នុងការទាមទារមកវិញនូវសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ដូចជា ឥណទានមានទ្រព្យដាក់បញ្ចាំជាក់លាក់) និង
- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ (ឧទាហរណ៍ ការកំណត់អត្រាការប្រាក់ឡើងវិញតាមរយៈពេលកំណត់) ។

សម្ព័ន្ធធនាគារ ឬធនាគារមានសម្ពាធឥណទានមានអត្រាថេររយៈពេលវែងដែលសម្ព័ន្ធធនាគារ ឬធនាគារមានជម្រើសស្នើឲ្យកែប្រែអត្រាការប្រាក់នៅកាលបរិច្ឆេទនៃការកំណត់ជាថ្មីឡើងវិញតាមរយៈពេលកំណត់។ សិទ្ធិកំណត់ឡើងវិញទាំងនេះ ត្រូវបានកម្រិតតាមអត្រាទីផ្សារនៅពេលមានការកែប្រែដែលសម្ព័ន្ធធនាគារ ឬធនាគារមានជម្រើសក្នុងការទទួលយកអត្រាការប្រាក់ដែលបានកែតម្រូវ ឬសងប្រាក់ដើមឥណទានដោយមិនមានការពិន័យ។ សម្ព័ន្ធធនាគារ ឬធនាគារបានកំណត់ថា លំហូរសាច់ប្រាក់តាមកិច្ចសន្យានៃឥណទានទាំងនេះ គឺជា SPPI ពីព្រោះជម្រើសមានការផ្លាស់ប្តូរអត្រាការប្រាក់តាមរបៀបមួយដែលជាតម្លៃតបស្នងសម្រាប់ពេលវេលានៃការប្រើប្រាស់សាច់ប្រាក់ ហានិភ័យឥណទាន ចំណាយ និងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត ទាក់ទងនឹងចំនួនប្រាក់ដើមដែលនៅជាប់ជំពាក់។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii). ការធ្វើចំណាត់ថ្នាក់ (ត)*

*ឥណទានដែលមានទ្រព្យដាក់បញ្ចាំជាក់លាក់*

ក្នុងករណីខ្លះ ឥណទានដែលផ្តល់ដោយសម្ព័ន្ធធនាគារ ឬធនាគារ ដែលត្រូវបានធានាដោយទ្រព្យដាក់បញ្ចាំរបស់អតិថិជន បានកម្រិតសម្ព័ន្ធធនាគារ ឬធនាគារក្នុងការទាមទារលំហូរសាច់ប្រាក់របស់ទ្រព្យដាក់បញ្ចាំ (ឥណទានដែលមានទ្រព្យដាក់បញ្ចាំជាក់លាក់)។ ក្នុងករណីនេះ សម្ព័ន្ធធនាគារ ឬធនាគារធ្វើការវិនិច្ឆ័យក្នុងការវាយតម្លៃថាតើឥណទាននោះ បំពេញតាមលក្ខខណ្ឌទូទាត់តែប្រាក់ដើម និងការប្រាក់ដែរ ឬទេ។ ជាទូទៅសម្ព័ន្ធធនាគារ ឬធនាគារពិចារណាលើព័ត៌មានខាងក្រោមក្នុងការវិនិច្ឆ័យ៖

- ថាតើកិច្ចសន្យាមានបញ្ជាក់ច្បាស់ពីចំនួន និងកាលបរិច្ឆេទនៃសំណងឥណទានដែរ ឬទេ
- តម្លៃសមស្របនៃទ្រព្យបញ្ចាំពាក់ព័ន្ធនឹងចំនួននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការធានា
- សមត្ថភាព និងឆន្ទៈរបស់អតិថិជន ក្នុងការទូទាត់សងតាមកិច្ចសន្យា ទោះបីមានឱនភាពនៃតម្លៃទ្រព្យបញ្ចាំក៏ដោយ
- ថាតើអតិថិជនគឺជារូបវន្តបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមានគោលបំណងពិសេស
- ហានិភ័យរបស់សម្ព័ន្ធធនាគារ ឬធនាគារនៃការបាត់បង់ទ្រព្យសកម្ម ទាក់ទងនឹងឥណទានដែលទ្រព្យដាក់បញ្ចាំពេញលេញ
- វិសាលភាពដែលទ្រព្យដាក់បញ្ចាំបង្ហាញពីទ្រព្យសកម្មរបស់អតិថិជនទាំងអស់ ឬជាផ្នែកណាមួយ និង
- ថាតើសម្ព័ន្ធធនាគារ ឬធនាគារនឹងទទួលបានអត្ថប្រយោជន៍ពីការកើនតម្លៃនៃទ្រព្យសកម្មនេះ ឬទេ។

*ការធ្វើចំណាត់ថ្នាក់ឡើងវិញ*

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចាត់ថ្នាក់ឡើងវិញបន្ទាប់ពីការទទួលស្គាល់លើកដំបូងឡើយ លើកលែងតែក្នុងអំឡុងពេលបន្ទាប់ពីសម្ព័ន្ធធនាគារ ឬធនាគារផ្លាស់ប្តូរម៉ូដែលអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

*បំណុលហិរញ្ញវត្ថុ*

សម្ព័ន្ធធនាគារ ឬធនាគារ បានចាត់ថ្នាក់បំណុលហិរញ្ញវត្ថុរបស់ខ្លួន (ក្រៅពីការធានាហិរញ្ញវត្ថុ និងការសន្យាផ្តល់ឥណទាន) ជាការវាស់វែងតាមតម្លៃដករំលស់ថ្លៃដើម ឬ FVTPL។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(iii) ការឈប់ទទួលស្គាល់*

**ទ្រព្យសកម្មហិរញ្ញវត្ថុ**

សម្ព័ន្ធធនាគារ ឬធនាគារ ឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិតាមកិច្ចសន្យាក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ (សូមមើល(iv)) ឬការផ្ទេរសិទ្ធិទទួលលំហូរសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលរាល់ហានិភ័យ និងផលចំណេញស្ទើរតែទាំងអស់នៃភាពជាកម្មសិទ្ធិ នៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលសម្ព័ន្ធធនាគារ ឬធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវហានិភ័យ និងផលចំណេញស្ទើរតែទាំងអស់នៃភាពជាកម្មសិទ្ធិ ហើយវាមិនរក្សាអភិបាលភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

នៅពេលដែលមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពលម្អៀងរវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬតម្លៃយោងដែលជាចំណែកនៃទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i). តម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបាន ដកបំណុលថ្មីដែលបានទទួលយក) និង (ii). ចំណេញ ឬខាតសរុប ដែលបានទទួលស្គាល់ក្នុង OCI ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ។

ការចំណេញ ឬខាតបង់សរុប ដែលត្រូវបានទទួលស្គាល់នៅក្នុង OCI ទាក់ទងនឹងមូលបត្រវិនិយោគមូលធនដែលបានកំណត់ជា FVOCI មិនត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬខាត នៅពេលដែលមានការឈប់ទទួលស្គាល់នូវមូលបត្របែបនេះឡើយ ដូចដែលបានពន្យល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតនិងលទ្ធផលលម្អិតផ្សេងៗ។ ភាគកម្មលើទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានផ្ទេរដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការឈប់ទទួលស្គាល់ដែលត្រូវបានបង្កើត ឬរក្សាទុកដោយសម្ព័ន្ធធនាគារ ឬធនាគារ ត្រូវបានទទួលស្គាល់ជា ទ្រព្យសកម្ម ឬបំណុលដាច់ដោយឡែក។

**បំណុលហិរញ្ញវត្ថុ**

សម្ព័ន្ធធនាគារ ឬធនាគារឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុមួយ នៅពេលកាតព្វកិច្ចតាមកិច្ចសន្យាត្រូវបានបោះបង់ចោល ឬត្រូវបានលុបចោល ឬផុតកាលកំណត់។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(iv). ការកែប្រែនៃទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ*

**ទ្រព្យសកម្មហិរញ្ញវត្ថុ**

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះសម្ព័ន្ធធនាគារ ឬធនាគារវាយតម្លៃថាតើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែនោះ មានភាពខុសគ្នាខ្លាំង ឬទេ។

ប្រសិនបើលំហូរសាច់ប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវបានចាត់ទុកថាផុតកាលកំណត់។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវឈប់ទទួលស្គាល់ (សូមមើល (iii)) ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មីមួយត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប បូកនឹង ចំណាយប្រតិបត្តិការដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ថ្លៃសេវានានាដែលទទួលបានជាផ្នែកនៃការកែប្រែនេះ ត្រូវបានកត់ត្រាដូចខាងក្រោម៖

- ថ្លៃសេវាដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងថ្លៃសេវាដែលជាសំណងនៃចំណាយប្រតិបត្តិការដែលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងលើកដំបូងនៃទ្រព្យសកម្ម និង
- ថ្លៃសេវាផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងចំណេញ ឬខាត ដែលជាផ្នែកមួយនៃការចំណេញ ឬខាតលើការឈប់ទទួលស្គាល់។

ប្រសិនបើលំហូរសាច់ប្រាក់ត្រូវបានកែប្រែនៅពេលដែលអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃការកែប្រែជាទូទៅគឺដើម្បីទទួលបានមកវិញជាអតិបរមានៃលក្ខខណ្ឌតាមកិច្ចសន្យាដើម ជាជាងបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង។ ប្រសិនបើសម្ព័ន្ធធនាគារ ឬធនាគារមានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយដែលអាចនាំឲ្យមានការលើកលែងចំពោះលំហូរសាច់ប្រាក់ នោះត្រូវពិចារណាជាដំបូងថាតើផ្នែកមួយនៃទ្រព្យសកម្មគួរតែត្រូវបានលុបចេញពីបញ្ជី មុនពេលធ្វើការកែប្រែកើតឡើងដែរ ឬទេ (សូមមើលគោលនយោបាយការលុបចេញពីបញ្ជី នៅខាងក្រោម)។ វិធីសាស្ត្រនេះមានផលប៉ះពាល់ដល់លទ្ធផលនៃការវាយតម្លៃបរិមាណ និងមានន័យថាលក្ខណៈវិនិច្ឆ័យនៃកាឈប់ទទួលស្គាល់ ជាធម្មតាមិនបំពេញបានករណីទាំងនេះទេ។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(iv). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)*

**ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)**

ប្រសិនបើការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមតម្លៃដករំលស់ ឬ FVOCI មិនបណ្តាលឲ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេ នោះសម្ព័ន្ធធនាគារ ឬធនាគារនឹងគណនាឡើងវិញនូវតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុជាមុន ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលនៃការកែតម្រូវជាចំណេញ ឬខាត នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលធ្លាប់បានប្រើដើម្បីគណនាចំណេញ ឬខាតពីការកែប្រែ ត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែប្រែ។ រាល់ចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបាន ដែលជាផ្នែកមួយនៃការកែប្រែ ធ្វើការកែតម្រូវតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានធ្វើការប្រែ និងត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែនោះ។

ប្រសិនបើការកែប្រែនេះ ត្រូវបានធ្វើឡើងដោយសារតែអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ (សូមមើល (vii)) នោះចំណេញ ឬខាតត្រូវបានបង្ហាញជាមួយគ្នានឹងការខាតបង់លើឱនភាពនៃតម្លៃរបស់ទ្រព្យសកម្ម។ ក្នុងករណីផ្សេងទៀត ត្រូវបានបង្ហាញជាចំណូលការប្រាក់ ដែលគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព (សូមមើល (កំណត់សម្គាល់២ (ថ)))។

**បំណុលហិរញ្ញវត្ថុ**

សម្ព័ន្ធធនាគារ ឬធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែប្រែ ហើយលំហូរសាច់ប្រាក់នៃបំណុលដែលបានកែប្រែនោះមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មីមួយ ត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ ភាពលម្អៀងរវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលត្រូវបានឈប់ទទួលស្គាល់ និងតម្លៃតបស្នងដែលបានទូទាត់ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬ ខាត។ តម្លៃតបស្នងដែលបានទូទាត់រួមមាន ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ (ប្រសិនបើមាន) និងការទទួលយកបំណុលថ្មី រួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែប្រែថ្មី។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(iv). ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)*

**បំណុលហិរញ្ញវត្ថុ (ត)**

ប្រសិនបើការកែប្រែបំណុលហិរញ្ញវត្ថុនេះមិនធ្វើឲ្យមានការឈប់ទទួលស្គាល់ទេ នោះតម្លៃដករំលស់នៃបំណុលត្រូវបានគណនាឡើងវិញដោយធ្វើអប្បហារលំហូរសាច់ប្រាក់ដែលបានកែប្រែ តាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ហើយលទ្ធផលនៃចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ សម្រាប់បំណុលហិរញ្ញវត្ថុដែលមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលធ្លាប់បានប្រើដើម្បីគណនាចំណេញ ឬខាតពីការកែប្រែ ត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែប្រែ។ រាល់ចំណាយ និងថ្លៃសេវាដែលកើតឡើង ត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើតម្លៃយោងនៃបំណុល និងត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុដែលបានកែប្រែនោះ ដោយធ្វើការគណនាអត្រាការប្រាក់ប្រសិទ្ធភាពឡើងវិញលើឧបករណ៍ហិរញ្ញវត្ថុ។

*(v). ការកាត់កង*

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចកាត់កងគ្នាបាន និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែសម្ព័ន្ធធនាគារ ឬធនាគារ មានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏លក់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

ចំណូល និងចំណាយ ត្រូវបានបង្ហាញជាមូលដ្ឋានសុទ្ធនៅពេលដែលត្រូវបានអនុញ្ញាតដោយ ស.រ.ហ.អ.ក ឬសម្រាប់ចំណេញ ឬខាត ដែលកើតឡើងពីក្រុមនៃប្រតិបត្តិការស្រដៀងគ្នា ដូចជានៅក្នុងសកម្មភាពជួញដូររបស់សម្ព័ន្ធធនាគារ ឬធនាគារ។

*(vi). ការវាស់វែងតម្លៃសមស្រប*

តម្លៃសមស្រប គឺជាថ្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬថ្លៃដែលបានសងចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារនានានៅកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត ដែលសម្ព័ន្ធធនាគារ ឬធនាគារ អាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យមិនមែនប្រតិបត្តិការ។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vi). ការវាស់វែងតម្លៃសមស្រប (ត)*

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណៈពិសេសនៃតម្រូវការ (ឧទាហរណ៍ ប្រាក់បញ្ញើតាមតម្រូវការ) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវសងតាមតម្រូវការទេ ដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចតម្រូវឲ្យសង។

សម្ព័ន្ធធនាគារ ឬធនាគារទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមនៃតម្លៃសមស្រប នៅចុងការិយបរិច្ឆេទនៃរបាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

*(vii). ឱនភាពនៃតម្លៃ*

សម្ព័ន្ធធនាគារ ឬធនាគារទទួលស្គាល់សំវិធានធនលើការខាតបង់ សម្រាប់ការខាតបង់ឥណទានដែលរំពឹងទុក (ECL) ចំពោះឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាម FVTPL ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលជាឧបករណ៍បំណុល
- គណនីភតិសន្យាត្រូវទទួល
- កិច្ចសន្យាធានាហិរញ្ញវត្ថុដែលបានបោះផ្សាយ និង
- កិច្ចសន្យាផ្តល់ឥណទានដែលបានបោះផ្សាយ

ពុំមានការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់លើការវិនិយោគមូលធនឡើយ។

សម្ព័ន្ធធនាគារ ឬធនាគារវាស់វែងសំវិធានធនលើការខាតបង់ តាមចំនួនដែលស្មើនឹង ECL ពេញមួយអាយុកាល លើកលែងឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាម ECL ១២ ខែ ដូចខាងក្រោមនេះ៖

- មូលបត្រវិនិយោគបំណុលដែលត្រូវបានកំណត់ថាមានហានិភ័យឥណទានទាប នាកាលបរិច្ឆេទរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីគណនីភតិសន្យាត្រូវទទួល) ដែលហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង។

សំវិធានធនលើការខាតបង់សម្រាប់គណនីភតិសន្យាត្រូវទទួលតែងតែត្រូវបានវាស់វែងតាមចំនួនស្មើនឹង ECL ពេញមួយអាយុកាល។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

សម្ព័ន្ធធនាគារ ឬធនាគារពិចារណាលើមូលបត្រវិនិយោគបំណុលមួយថាមានហានិភ័យឥណទានទាប នៅពេលដែលចំណាត់ថ្នាក់ហានិភ័យឥណទានរបស់វាស្មើទៅនឹងនិយមន័យដែលត្រូវបានគេស្គាល់ជាសកលនៃ "ថ្នាក់វិនិយោគ"។ សម្ព័ន្ធធនាគារ ឬធនាគារមិនអនុវត្តការលើកលែងហានិភ័យឥណទានទាបចំពោះឧបករណ៍ហិរញ្ញវត្ថុដទៃទៀតឡើយ។

ECL ១២ ខែ គឺជាផ្នែកនៃ ECL ដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល ១២ ខែ របស់ឧបករណ៍ហិរញ្ញវត្ថុមួយដែលអាចកើតឡើងក្នុងរយៈពេល ១២ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាម ECL ១២ខែ ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី ១"។

ECL ពេញមួយអាយុកាល (Life-time ECL) គឺជា ECL ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងអាយុកាលដែលរំពឹងទុក (expected life) ទាំងអស់របស់ឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាម ECL ពេញមួយអាយុកាល ប៉ុន្តែមិនមែនមានឱនភាពនៃតម្លៃឥណទាន (credit-impaired) ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី ២"។

*ការវាស់វែង ECL*

ECL គឺជាការប៉ាន់ស្មានដែលបានថ្លឹងតាមប្រូបាប៊ីលីតេនៃការខាតបង់ឥណទាន។ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះខាតសាច់ប្រាក់ទាំងអស់ (ពោលគឺភាពខុសគ្នារវាងលំហូរសាច់ប្រាក់ដែលជំពាក់ ដោយយោងតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែលសម្ព័ន្ធធនាគារ ឬធនាគាររំពឹងទុកថានឹងទទួលបាន)។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាភាពខុសគ្នារវាងតម្លៃយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគតដែលរំពឹងទុក។
- កិច្ចសន្យាផ្តល់ឥណទានដែលមិនទាន់បានប្រើប្រាស់៖ ជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលជំពាក់សម្ព័ន្ធធនាគារ ឬធនាគារ ប្រសិនបើកិច្ចសន្យាឥណទានត្រូវបានប្រើប្រាស់ និងលំហូរសាច់ប្រាក់ដែលសម្ព័ន្ធធនាគារ ឬធនាគាររំពឹងទុកថានឹងទទួលបាន និង
- កិច្ចសន្យាធានាហិរញ្ញវត្ថុ៖ ការទូទាត់ដែលរំពឹងទុក ចំពោះចំនួនទឹកប្រាក់ដែលនឹងផ្តល់ទៅអ្នកទទួលផលដោយដកចេញនូវចំនួនទឹកប្រាក់ដែលសម្ព័ន្ធធនាគារ ឬធនាគាររំពឹងថានឹងទទួលបានមកវិញ។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

***ការវាស់វែង ECL (ត)***

ធាតុចូលសំខាន់ៗ ក្នុងការវាស់វែង ECL គឺបានមកពីអថេរដូចខាងក្រោមៈ

- ប្រូបាប៊ីលីតេនៃការខកខានសង (PD);
- ការខាតបង់ដែលបណ្តាលមកពីការខកខានសង (LGD) និង
- ទំហំនៃការខកខានសង (EAD)

ECL សម្រាប់ទំហំក្នុងដំណាក់កាលទី ១ ត្រូវបានគណនាដោយផលគុណនៃប្រូបាប៊ីលីតេនៃការខកខានសង ក្នុង ១២ ខែ នឹង ការខាតបង់ដែលបណ្តាលមកពីការខកខានសង នឹង ទំហំនៃការខកខានសង។ ECL ពេញមួយអាយុកាល ត្រូវបានគណនាដោយផលគុណនៃប្រូបាប៊ីលីតេនៃការខកខានសង ពេញមួយអាយុកាល នឹង ការខាតបង់ដែលបណ្តាលមកពីការខកខានសង នឹង ទំហំនៃការខកខានសង។

ប្រូបាប៊ីលីតេនៃការខកខានសង (PD) ផ្តល់នូវការប៉ាន់ប្រមាណនៃលទ្ធភាពដែលអតិថិជនម្នាក់នឹងមិនអាចបំពេញកាតព្វកិច្ចបំណុល ឬភាពខកខានក្នុងរយៈពេលជាក់លាក់មួយ។ ទ្រព្យសកម្មហិរញ្ញវត្ថុក្រោម វិធីសាស្ត្រទូទៅដែលតម្រូវមានដំណាក់កាលនឹងតម្រូវទាំងការប៉ាន់ស្មានប្រូបាប៊ីលីតេនៃការខកខានសងក្នុង១២ខែ និង ប្រូបាប៊ីលីតេនៃការខកខានសងក្នុងពេញមួយអាយុកាល ដោយយោងទៅតាមទិន្នន័យប្រវត្តិសាស្រ្តដោយប្រើវិធីសាស្រ្ត Migration (migration approach) ឬវិធីសាស្ត្រការផ្តល់ចំណាត់ថ្នាក់លទ្ធភាពសងពីភាគីឯករាជ្យ។

ការខាតបង់ដែលបណ្តាលមកពីការខកខានសង គឺជាកម្រិតដែលអាចបាត់បង់ប្រសិនបើមានការខកខានសង។ ការខាតបង់ដែលបណ្តាលមកពីការខកខានសង ត្រូវបានកំណត់ជាភាគរយនៃទំហំប្រឈមដែលធនាគារអាចនឹងបាត់បង់ក្នុងករណីដែលអតិថិជនខកខានសង។ ការខាតបង់ទាំងនេះជាធម្មតាត្រូវបានបង្ហាញជាភាគរយនៃទំហំនៃការខកខានសង (EAD) ហើយពឹងផ្អែកលើប្រភេទនិងចំនួនទ្រព្យដាក់បញ្ចាំព្រមទាំងប្រភេទនៃអតិថិជន និងការប្រមូលបំណុលដែលរំពឹងទុកពីអតិថិជន ។

ជាមួយនឹងតម្លៃទ្រព្យដាកបញ្ចាំដែលត្រឹមត្រូវ ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មពីមួយពេលទៅមួយពេល ធនាគារអាចពិចារណាយកទ្រព្យដាក់បញ្ចាំចូលទៅក្នុងការគណនា ការខាតបង់ដែលបណ្តាលមកពីការខកខានសង សម្រាប់ការគណនា ECL។ ក្នុងករណីមានទ្រព្យដាក់បញ្ចាំលើសលុប កម្រិតទាបបំផុតរបស់ ការខាតបង់ដែល បណ្តាលមកពីការខកខានសង មួយ នឹងត្រូវយកទៅអនុវត្តសម្រាប់ការគណនា ECL។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

*ការវាស់វែង ECL (ត)*

ទំហំនៃការខកខានសង គឺជាចំនួនទឹកប្រាក់នៅជំពាក់ នៅពេលមានការខកខានសង។ ទោះយ៉ាងណា ទំហំនៃការខកខានសង ខុសគ្នាទៅតាមលក្ខណៈនៃផលិតផលៈ

- ហ្វាស៊ីលីធីរំលស់៖ ចំនួនទឹកប្រាក់បច្ចុប្បន្នដែលត្រូវបានអនុញ្ញាតក្រោមកិច្ចសន្យា និងកើតឡើងពីការធ្វើរំលស់
- ហ្វាស៊ីលីធីអាចប្រើប្រាស់ឡើងវិញ៖ អត្រាប្រើប្រាស់
- ក្រៅតារាងតុល្យការ៖ កត្តាបំប្លែងឥណទាន ("CCF")

ដូចការរៀបរាប់ខាងលើ និងដោយផ្អែកលើការប្រើប្រាស់ជាអតិបរមានៃប្រូបាប៊ីលីតេនៃការខកខានសងក្នុង ១២ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុនៅដំណាក់កាលទី១ សម្ព័ន្ធធនាគារ ឬធនាគារវាស់វែង ECL ដោយពិចារណាលើហានិភ័យនៃការខកខានសង ក្នុងរយៈពេលតាមកិច្ចសន្យាជាអតិបរមា (រួមបញ្ចូលទាំងជម្រើសការពន្យារពេលសងរបស់អតិថិជនប្រសិនបើមាន) ដែលប្រឈមនឹងហានិភ័យឥណទាន ទោះបីជាក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទានក៏ដោយ សម្ព័ន្ធធនាគារ ឬ ធនាគារពិចារណាលើរយៈពេលដែលវែងជាងមួយ។ រយៈពេលដែលវែងបំផុត គឺគិតត្រឹមថ្ងៃដែលសម្ព័ន្ធធនាគារ ឬធនាគារមានសិទ្ធិទាមទារការសងត្រឡប់នៃឥណទាន ឬបុរេប្រទាន ឬបញ្ចប់កិច្ចសន្យាធានា ឬកិច្ចសន្យាផ្តល់ឥណទាន។

ទោះយ៉ាងណាក៏ដោយ សម្រាប់ហ្វាស៊ីលីធីប័ណ្ណឥណទានដែលរួមមានទាំងឥណទាន និងធាតុការសន្យាផ្តល់ឥណទានដែលមិនទាន់បានប្រើប្រាស់ ដែលសម្ព័ន្ធធនាគារ ឬធនាគារវាស់វែង ECL ក្នុងរយៈពេលមួយវែងជាងរយៈពេលតាមកិច្ចសន្យាអតិបរមា ប្រសិនបើ សមត្ថភាពតាមកិច្ចសន្យារបស់សម្ព័ន្ធធនាគារ ឬធនាគារ ក្នុងការទាមទារសំណង និងលុបចោលការសន្យាផ្តល់ឥណទានដែលមិនទាន់បានប្រើប្រាស់ មិនកំណត់ការប្រឈមរបស់សម្ព័ន្ធធនាគារ ឬធនាគារចំពោះការខាតបង់ឥណទានចំពោះរយៈពេលជូនដំណឹងតាមកិច្ចសន្យា។ ហ្វាស៊ីលីធីទាំងនេះមិនមានរយៈពេលថេរ ឬរចនាសម្ព័ន្ធសងត្រឡប់ទេ ហើយត្រូវបានគ្រប់គ្រងលើមូលដ្ឋានហ្វាស៊ីលីធីក្រុម។ សម្ព័ន្ធធនាគារ ឬធនាគារអាចលុបចោលពួកគេដោយប្រសិទ្ធភាពភ្លាមៗ ប៉ុន្តែសិទ្ធិតាមកិច្ចសន្យានេះមិនត្រូវបានអនុវត្តនៅក្នុងការគ្រប់គ្រងប្រចាំថ្ងៃជាធម្មតាទេ ប៉ុន្តែនៅពេលដែលសម្ព័ន្ធធនាគារ ឬ ធនាគារ ដឹងអំពីការកើនឡើងហានិភ័យឥណទាននៅកម្រិតហ្វាស៊ីលីធី។ រយៈពេលវែងជាងនេះ ត្រូវបានប៉ាន់ប្រមាណដោយគិតគូរពីសកម្មភាពគ្រប់គ្រងហានិភ័យឥណទាន ដែលសម្ព័ន្ធធនាគារ ឬធនាគាររំពឹងថានឹងអនុវត្ត ហើយដែលអាចជួយកាត់បន្ថយ ECL បាន។ ទាំងនេះរួមបញ្ចូលទាំងការកាត់បន្ថយកម្រិតកំណត់ការលុបចោលនៃហ្វាស៊ីលីធី និង/ឬ បង្វែរសមតុល្យដែលនៅជំពាក់ទៅជាឥណទានដែលមានលក្ខខណ្ឌសងត្រឡប់វិញថេរ។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ*

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចរចា ឬកែប្រែ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ដោយសារស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជន នោះការវាយតម្លៃត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុគួរតែត្រូវឈប់ទទួលស្គាល់ ឬទេ ហើយ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ប្រសិនបើការរៀបចំឡើងវិញ មិននាំឲ្យការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ទេ នោះលំហូរសាច់ប្រាក់ដែលរំពឹងទុកថាកើតមានពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែ ត្រូវបានបញ្ចូលនៅក្នុងការគណនាកង្វះខាតនៃសាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់។
- ប្រសិនបើការរៀបចំឡើងវិញ នាំឲ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះតម្លៃសមស្របរំពឹងទុកនៃទ្រព្យសកម្មថ្មីនោះ ត្រូវបានចាត់ទុកជាលំហូរសាច់ប្រាក់ចុងក្រោយទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន នៅពេលដែលឈប់ទទួលស្គាល់។ ចំនួនទឹកប្រាក់នេះត្រូវបានបញ្ចូលទៅក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ដែលត្រូវបានធ្វើអប្បហារពីកាលបរិច្ឆេទរំពឹងទុកនៃការឈប់ទទួលស្គាល់ ទៅកាលបរិច្ឆេទរាយការណ៍ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន។

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាន*

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ សម្ព័ន្ធធនាគារ និងធនាគារវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកត់ត្រាតាមតម្លៃដករំលស់ និងទ្រព្យសកម្មហិរញ្ញវត្ថុបំណុលដែលបានកត់ត្រាតាម FVOCI និងគណនីត្រូវទទួលភតិសន្យាហិរញ្ញវត្ថុមានឱនភាពនៃតម្លៃឥណទានដែរ ឬទេ (សំដៅលើ "ទ្រព្យសកម្មហិរញ្ញវត្ថុនៅដំណាក់កាលទី៣"។ ទ្រព្យសកម្មហិរញ្ញវត្ថុមួយមានឱនភាពនៃតម្លៃឥណទាន នៅពេលដែលព្រឹត្តិការណ៍មួយ ឬច្រើន ដែលនាំឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរសាច់ប្រាក់នាពេលអនាគតដែលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុ បានកើតឡើង។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃឥណទាន រួមមានទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាសារវន្តរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃឥណទាន ឬបុរេប្រទាន ដោយសម្ព័ន្ធធនាគារ ឬធនាគារ លើលក្ខខណ្ឌដែលសម្ព័ន្ធធនាគារ ឬធនាគារមិនគួរយល់ព្រម
- អតិថិជនទំនងជានឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុផ្សេងទៀតឡើងវិញ
- ការបាត់បង់ទីផ្សារសកម្មចំពោះទ្រព្យដាក់បញ្ចាំមួយដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ។

ឥណទានដែលត្រូវបានចរចាឡើងវិញ ដោយសារតែការធ្លាក់ចុះនៃស្ថានភាពរបស់អតិថិជន ត្រូវបានចាត់ទុកថាមាឱនភាពនៃតម្លៃឥណទាន លុះត្រាតែមានភស្តុតាងបញ្ជាក់ថាហានិភ័យនៃការមិនទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាបានថយចុះជាសារវន្ត និងមិនមានសូចនាករផ្សេងទៀតដែលនាំឲ្យមានឱនភាពនៃតម្លៃ។ បន្ថែមលើនេះ ឥណទានសម្រាប់ការជួញដូររាយដែលហួសកាលកំណត់សង ៩០ថ្ងៃ ឬលើសពីនេះ ត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃឥណទាន ទោះបីជានិយមន័យនៃការខកខានសងតាមបទប្បញ្ញត្តិបានកំណត់ផ្សេងគ្នាក៏ដោយ។

**ការបង្ហាញសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ**

សំវិធានធនខាតបង់សម្រាប់ ECL ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងដោយតម្លៃដករំលស់៖ ជាការកាត់បន្ថយពីតម្លៃយោងដុលរបស់ទ្រព្យសកម្ម
- ការសន្យាផ្តល់ឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុ៖ ជាទូទៅ ជាការធ្វើសំវិធានធន
- នៅពេលដែលឧបករណ៍ហិរញ្ញវត្ថុមួយរួមបញ្ចូលទាំងសមាសធាតុមិនទាន់បានប្រើប្រាស់ និងបានប្រើប្រាស់ ហើយសម្ព័ន្ធធនាគារ ឬធនាគារមិនអាចកំណត់ ECL លើសមាសធាតុការសន្យាផ្តល់ឥណទានដោយឡែកពីសមាសធាតុនៃការសន្យាផ្តល់ឥណទានដែលបានប្រើប្រាស់ សម្ព័ន្ធធនាគារ ឬធនាគារធ្វើការបង្ហាញសំវិធានធនខាតបង់រួមបញ្ចូលគ្នាសម្រាប់សមាសធាតុទាំងពីរ។ ចំនួនរួមបញ្ចូលគ្នាត្រូវបានបង្ហាញជាការកាត់ចេញពីតម្លៃយោងដុលនៃសមាសធាតុដែលបានបានប្រើប្រាស់។ ចំនួនលើសរបស់សំវិធានធនខាតបង់លើតម្លៃយោងដុលនៃសមាសធាតុដែលបានប្រើប្រាស់ ត្រូវបានបង្ហាញជាការធ្វើសំវិធានធន និង

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

សំវិធានធនខាតបង់សម្រាប់ ECL ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដូចខាងក្រោម៖ (ត)

- ឧបករណ៍បំណុលដែលវាស់វែងតាម FVOCI៖ មិនមានសំវិធានធនខាតបង់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុទេ ពីព្រោះតម្លៃយោងនៃទ្រព្យសកម្មទាំងនេះគឺជាតម្លៃសមស្រប។ ទោះយ៉ាងណាក៏ដោយសំវិធានធនខាតបង់ត្រូវបានលាតត្រដាង និងទទួលស្គាល់នៅក្នុងទុនបម្រុងតម្លៃសមស្រប។

**ការលុបចេញពីបញ្ជី**

ឥណទាន និងមូលបត្របំណុលត្រូវបានលុបចេញពីបញ្ជី (ជាផ្នែក ឬទាំងស្រុង) នៅពេលមិនមានការរំពឹងទុកសមហេតុផលថា អាចប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង ឬចំណែកណាមួយ។ ករណីនេះមានជាទូទៅ នៅពេលសម្ព័ន្ធធនាគារ ឬធនាគារកំណត់ថាអ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរសាច់ប្រាក់គ្រប់គ្រាន់ដើម្បីទូទាត់សងនូវចំនួនដែលត្រូវលុបចេញពីបញ្ជី។ ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងតាមកម្រិតទ្រព្យសកម្មទោល។

ទឹកប្រាក់ដែលប្រមូលបានមកវិញពីចំនួនដែលបានលុបចេញពីបញ្ជី ត្រូវបញ្ចូលទៅក្នុងខ្ទង់ "ការខាតបង់ឱនភាពនៃតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ" នៅក្នុងរបាយការណ៍ចំណេញ ឬខាត និង OCI។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចេញពីបញ្ជី នៅតែអាចជាកម្មវត្ថុចំពោះសកម្មភាពទាមទារសងមកវិញតាមផ្លូវច្បាប់ ដើម្បីអនុលោមតាមនីតិវិធីរបស់សម្ព័ន្ធធនាគារ ឬធនាគារក្នុងការប្រមូលមកវិញនូវទឹកប្រាក់ដែលនៅជំពាក់។

**ការធានាហិរញ្ញវត្ថុមិនមែនជាផ្នែកសំខាន់នៃកិច្ចសន្យា**

សម្ព័ន្ធធនាគារ ឬធនាគារ វាយតម្លៃថាតើកិច្ចសន្យាធានាហិរញ្ញវត្ថុ គឺជាធាតុផ្សំមួយដ៏សំខាន់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានរាប់បញ្ចូលជាសមាសធាតុនៃឧបករណ៍នោះ ឬជាកិច្ចសន្យាដែលត្រូវបានកត់ត្រាដោយឡែកពីគ្នា។ កត្តាដែលសម្ព័ន្ធធនាគារ ឬធនាគារពិចារណានៅពេលធ្វើការវាយតម្លៃនេះរួមមាន៖

- ការធានាគឺជាផ្នែកមួយនៃលក្ខខណ្ឌតាមកិច្ចសន្យារបស់ឧបករណ៍បំណុល
- ការធានាត្រូវបានទាមទារដោយច្បាប់ និងបទប្បញ្ញត្តិដែលគ្រប់គ្រងកិច្ចសន្យារបស់ឧបករណ៍បំណុល
- ការធានាត្រូវបានបញ្ចូលក្នុងពេលដំណាលគ្នានិងឧបករណ៍បំណុល និង
- ការធានាត្រូវបានផ្តល់ដោយក្រុមហ៊ុនមេរបស់អ្នកខ្ចី ឬក្រុមហ៊ុនផ្សេងទៀតនៅក្នុងសម្ព័ន្ធរបស់អ្នកខ្ចី។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii). ឱនភាពនៃតម្លៃ (ត)*

ប្រសិនបើសម្ព័ន្ធធនាគារ ឬធនាគារ កំណត់ថាការធានាគឺជាធាតុផ្សំសំខាន់មួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ នោះបុព្វលាភត្រូវសងណាមួយទាក់ទងនឹងការទទួលស្គាល់លើកដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ទុកថាជាចំណាយ ប្រតិបត្តិការក្នុងការធ្វើលទ្ធកម្មទ្រព្យសកម្មហិរញ្ញវត្ថុ។ សម្ព័ន្ធធនាគារ ឬធនាគារពិចារណាលើផលប៉ះពាល់នៃការការពារនៅពេលវាស់វែងតម្លៃសមស្របនៃឧបករណ៍បំណុល និងនៅពេលវាស់វែង ECL។

ប្រសិនបើសម្ព័ន្ធធនាគារ ឬធនាគារកំណត់ថាការធានាមិនមែនជាធាតុផ្សំសំខាន់នៃឧបករណ៍បំណុលទេ នោះវាទទួលស្គាល់ជាទ្រព្យសកម្មមួយ ដែលបង្ហាញពីការបង់ប្រាក់ជាមុននៃបុព្វលាភនៃការធានា និងសិទ្ធិទូទាត់សងសម្រាប់ការខាតបង់ឥណទាន។ ទ្រព្យសកម្មបុព្វលាភបង់មុន ត្រូវបានទទួលស្គាល់លុះត្រាតែការធានាមិនមានឱនភាពនៃតម្លៃឥណទាន ឬមិនមានការកើនឡើងជាសារវន្តនូវ ហានិភ័យឥណទាននៅពេលការធានាត្រូវបានទទួលស្គាល់។ ទ្រព្យសកម្មទាំងនេះត្រូវបានទទួលស្គាល់នៅក្នុង "ទ្រព្យសកម្មផ្សេងៗ"។ សម្ព័ន្ធធនាគារ ឬធនាគារបង្ហាញពីចំណេញ ឬខាត លើសិទ្ធិទទួលបានសំណងនៅក្នុងចំណេញ ឬខាត ក្នុងធាតុជួរ "ការខាតបង់លើឱនភាពនៃតម្លៃរបស់ឧបករណ៍ហិរញ្ញវត្ថុ"។

### (ច) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យសាច់ប្រាក់ក្នុងធនាគារ ប្រាក់បញ្ញើដែលឥណប្រតិទានដំបូងមានរយៈពេល ៣ខែ ឬតិចជាង និងដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ។

សាច់ប្រាក់ និងសមមូលសាច់ប្រាក់ ត្រូវបានគិតតាមតម្លៃដករំលស់ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### (ឆ) ឥណទាន និងបុរេប្រទាន

"ឥណទាន និងបុរេប្រទាន" ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមមានឥណទាន និងបុរេប្រទាន ដែលបានវាស់វែងតាមតម្លៃដករំលស់។ ឥណទាន និងបុរេប្រទានត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកនឹងចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់បន្ថែម ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមតម្លៃដករំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ជ) ការវិនិយោគហិរញ្ញវត្ថុ

"មូលបត្រហិរញ្ញវត្ថុ" ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមមាន៖

- មូលបត្រវិនិយោគបំណុល ដែលបានវាស់វែងតាមតម្លៃដករំលស់ថ្លៃដើម។ មូលបត្រវិនិយោគបំណុលទាំងនេះត្រូវបានវាស់លើកដំបូង តាមតម្លៃសមស្របបូកនឹងចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់បន្ថែម ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមតម្លៃដករំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។
- មូលបត្របំណុលដែលវាស់វែងតាម FVOCI និង
- មូលបត្រវិនិយោគលើមូលធនដែលបានកំណត់តាម FVOCI។

ចំពោះមូលបត្របំណុលដែលបានវាស់វែងតាម FVOCI ចំណេញ និងខាត ត្រូវបានទទួលស្គាល់នៅក្នុង OCI លើកលែងតែចំណុចដូចខាងក្រោម ដែលត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត តាមរបៀបដូចគ្នានឹងទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់តាមតម្លៃដករំលស់៖

- ចំណូលការប្រាក់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព
- ECL និងការកត់ត្រាបញ្រ្ចាស និង
- ចំណេញ និងខាតលើការប្តូររូបិយប័ណ្ណបរទេស។

នៅពេលដែលមូលបត្របំណុលវាស់វែងតាម FVOCI ត្រូវបានឈប់ទទួលស្គាល់ ចំណេញ ឬខាតបង្គរដែលបានទទួលស្គាល់ពីមុននៅក្នុង OCI ត្រូវបានចាត់ថ្នាក់ឡើងវិញពីមូលធន ទៅរបាយការណ៍ចំណេញ ឬខាត។

សម្ព័ន្ធធនាគារ ឬធនាគារជ្រើសរើសបង្ហាញនៅក្នុង OCI អំពីការផ្លាស់ប្តូរនៅក្នុងតម្លៃសមស្របនៃការវិនិយោគជាក់លាក់នៅក្នុងឧបករណ៍មូលធន ដែលមិនត្រូវបានទុកសម្រាប់ជួញដូរ។ ការជ្រើសរើសនេះធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃឧបករណ៍នីមួយៗនៅពេលទទួលស្គាល់លើកដំបូងនិងជាស្ថាពរ។

ចំណេញ និងខាតលើឧបករណ៍មូលធនទាំងនេះនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅរបាយការណ៍ចំណេញ ឬខាតទេ ហើយក៏ពុំមានឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតដែរ។ ភាគលាភត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត លើកលែងតែវាបង្ហាញយ៉ាងច្បាស់ពីការប្រមូលបានមកវិញលើផ្នែកខ្លះរបស់ថ្លៃដើមនៃការវិនិយោគ ក្នុងករណីដែលពួកគេត្រូវបានទទួលស្គាល់នៅក្នុង OCI។ ចំណេញ និងខាតបង្គរដែលត្រូវបានទទួលស្គាល់នៅក្នុង OCI ត្រូវបានផ្ទេរទៅប្រាក់ចំណេញរក្សាទុកលើការលក់ចេញរបស់ការវិនិយោគ។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឈ) ដើមទុន

ភាគហ៊ុនធម្មតា ត្រូវបានចាត់ថ្នាក់ជាមូលធន។ ភាគហ៊ុនដទៃទៀតត្រូវបានចាត់ថ្នាក់ជាមូលធន និង/ឬបំណុល ផ្អែកលើសមាសធាតុសេដ្ឋកិច្ចនៃឧបករណ៍ទាំងនោះ។ ការបែងចែកទៅអ្នកកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុមួយ ដែលបានចាត់ថ្នាក់ជាឧបករណ៍មូលធន ត្រូវបានទូទាត់ដោយផ្ទាល់ពីមូលធន។

### (ញ) ទ្រព្យ និងបរិក្ខារ

ទ្រព្យ និងបរិក្ខារត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃបង្គរ។ ថ្លៃដើមរួមមានការចំណាយផ្ទាល់នានា ក្នុងការធ្វើលទ្ធកម្មទ្រព្យសកម្មទាំងនោះ។

ចំណាយបន្តបន្ទាប់ផ្សេងៗត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យដាច់ដោយឡែក តាមការសមស្រប តែនៅពេលដែលមានភាពប្រាកដប្រជាថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត នៃទ្រព្យនោះនឹងហូរចូលមកក្នុងសម្ព័ន្ធធនាគារ និងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះអាចត្រូវបានវាស់វែងគួរឲ្យជឿជាក់បានតែប៉ុណ្ណោះ។ តម្លៃយោងផ្នែកនៃទ្រព្យដែលបានជំនួសត្រូវបានឈប់ទទួលស្គាល់។ រាល់ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍ចំណេញ ឬខាតក្នុងឆ្នាំដែលប្រតិបត្តិការនោះកើតឡើង។

ដីធ្លីមិនត្រូវបានធ្វើរំលស់ទេ។ ទ្រព្យ និងបរិក្ខារផ្សេងទៀតត្រូវបានធ្វើរំលស់តាមមូលដ្ឋានរំលស់ថេរ ដើម្បីលុបចេញពីបញ្ជីនូវថ្លៃដើមនៃទ្រព្យសកម្មត្រឹមតម្លៃកាកសំណល់លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃ ទ្រព្យសកម្មនីមួយៗ សង្ខេបដូចខាងក្រោម៖

| | *ឆ្នាំ* |
|---|---|
| ការកែលម្អលើដី | ៣ - ២០ |
| អគារ និង ការកែលម្អ | ៣ - ៣០ |
| ការកែលម្អលើទ្រព្យជួល | ១ - ៣ |
| បរិក្ខារការិយាល័យ | ១ - ១០ |
| បរិក្ខារកុំព្យូទ័រ | ១ - ១០ |
| យានយន្ត | ៣ - ៥ |

តម្លៃកាកសំណល់របស់ទ្រព្យសកម្ម និងអាយុកាលប្រើប្រាស់ត្រូវបានត្រួតពិនិត្យ និងកែតម្រូវប្រសិនជាមានភាពសមស្រប នៅរៀងរាល់ចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ញ) ទ្រព្យ និងបរិក្ខារ (ត)

រំលស់លើទ្រព្យសកម្មដែលកំពុងសាងសង់ចាប់ផ្តើមនៅពេលដែលទ្រព្យសកម្មត្រូវបានត្រៀមរួចរាល់ សម្រាប់ការប្រើប្រាស់ដែលបានគ្រោងទុក។

ទ្រព្យ និងបរិក្ខារ ត្រូវបានពិនិត្យឡើងវិញ សម្រាប់ការបង្ហាញពីឱនភាពនៃតម្លៃនៅរៀងរាល់កាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ និងរាល់ពេលដែលព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈបង្ហាញថាតម្លៃយោងអាចនឹងមិនអាចប្រមូលបានមកវិញ។ នៅពេលដែលតម្លៃយោងនៃទ្រព្យសកម្មណាមួយលើសពីតម្លៃដែលអាចប្រមូលបានមកវិញដែលប៉ាន់ស្មាន ត្រូវបានកត់ត្រាបន្ថយឲ្យនៅត្រឹមតម្លៃដែលអាចប្រមូលបានមកវិញ។

ចំណេញ និងខាតពីការលក់ទ្រព្យ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបចំណូលបានមកពីការលក់ និងតម្លៃយោង ហើយត្រូវបានកត់ត្រានៅក្នុងចំណូលផ្សេងៗ។

### (ដ) ទ្រព្យសកម្មអរូបី

ទ្រព្យអរូបីរួមមានអាជ្ញាប័ណ្ណសូហ្វវែរកុំព្យូទ័រដែលបានធ្វើលទ្ធកម្ម និងចំណាយដែលទាក់ទង។ ទ្រព្យសកម្មអរូបីត្រូវបានទទួលស្គាល់តែនៅពេលដែលការចំណាយរបស់វាអាចវាស់វែងដោយជឿទុកចិត្តបាន ហើយទំនងជាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលរំពឹងទុក នឹងហូរចូលក្នុងសម្ព័ន្ធធនាគារ និងធនាគារ។

ទ្រព្យសកម្មអរូបីត្រូវបានរាយការណ៍តាមថ្លៃដើមប្រវត្តិសាស្ត្រដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃបង្គរ ប្រសិនជាមាន។ ទ្រព្យសកម្មអរូបីត្រូវបានធ្វើរំលស់ដោយប្រើប្រាស់វិធីសាស្ត្រថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្ម។ អាយុកាលប្រើប្រាស់របស់សូហ្វវែរកុំព្យូទ័រមានរយៈពេលប្រាំឆ្នាំ លើកលែងតែអាជ្ញាប័ណ្ណកម្មរបស់ប្រព័ន្ធធនាគារស្នូល ដែលមានអាយុកាលប្រើប្រាស់ដប់ឆ្នាំ។

ចំណាយផ្សេងៗពាក់ព័ន្ធនឹងការថែរក្សាសូហ្វវែរកុំព្យូទ័រ ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលប្រតិបត្តិការនោះបានកើតឡើង។

### (ឋ) ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មដែលមានអាយុកាលមិនអាចកំណត់បានមិនមែនជាកម្មវត្ថុក្នុងការធ្វើរំលស់ទេ និងត្រូវបានធ្វើតេស្តឡើងវិញជាប្រចាំឆ្នាំដើម្បីកំណត់ឱនភាពនៃតម្លៃ។ ទ្រព្យសកម្មជាកម្មវត្ថុក្នុងការធ្វើរំលស់ត្រូវបានត្រួតពិនិត្យឡើងវិញនៅពេលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរក្នុងកាលៈទេសៈ ដែលបង្ហាញថាតម្លៃយោងអាចនឹងមិនប្រមូលបានមកវិញ។ ការខាតបង់ឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ស្មើនឹងចំនួនដែលតម្លៃយោងរបស់ ទ្រព្យសកម្ម លើសពីតម្លៃដែលអាចប្រមូលបានមកវិញ។

## ២. សេចក្ដីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឋ) ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)

សម្រាប់គោលបំណងនៃការធ្វើតេស្តឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗបំផុតដែលមានលំហូរសាច់ប្រាក់អាចកំណត់បានដោយឡែក (អង្គភាពរកសាច់ប្រាក់)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុក្រៅពីមូលនិធិពាណិជ្ជកម្មដែលទទួលរងនូវឱនភាពនៃតម្លៃ ត្រូវបានពិនិត្យឡើងវិញចំពោះការកត់ត្រាបញ្ច្រាស់មកវិញរបស់ឱនភាពនៃតម្លៃដែលអាចកើតមាន។ ការខាតបង់ឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

### (ឌ) ទុនបម្រុង

ទុនបម្រុងរួមមាន ទុនបម្រុងទូទៅ ទុនបម្រុងតាមបទប្បញ្ញត្តិ និងទុនបម្រុងផ្សេងៗ។

ទុនបម្រុងទូទៅ ត្រូវបានបង្កើតឡើងសម្រាប់ហានិភ័យហិរញ្ញវត្ថុទូទៅ។ ក្រុមប្រឹក្សាភិបាលអនុវត្តការសម្រេចចិត្តរបស់ខ្លួន សម្រាប់ការប្រើប្រាស់ និងថែរក្សាទុនបម្រុងទូទៅ។ ការផ្ទេរពីប្រាក់ចំណេញរក្សាទុក ទៅទុនបម្រុងទូទៅត្រូវមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននីមួយៗនៅក្នុងសម្ព័ន្ធ។

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នានៃសំវិធានធនរវាងឱនភាពនៃតម្លៃឥណទានអនុលោមតាម ស.រ.ហ.អ.ក និងសំវិធានធនតាមបទប្បញ្ញត្តិ។ វាត្រូវបានផ្ទេររវាងប្រាក់ចំណេញរក្សាទុក និងទុនបម្រុងតាមបទប្បញ្ញត្តិ។

ទុនបម្រុងផ្សេងៗ គឺសម្រាប់លម្អៀងពីការប្តូររូបិយប័ណ្ណនៃការវិនិយោគសុទ្ធក្នុងកិច្ចប្រតិបត្តិការបរទេស។

### (ឍ) ពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន និងពន្ធពន្យារ

ការចំណាយពន្ធសម្រាប់ការិយបរិច្ឆេទរួមមាន ពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន និងពន្ធពន្យារ។ ពន្ធត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត លើកលែងតែវិសាលភាពដែលវាទាក់ទងទៅនឹងខ្ទង់ដែលត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ ឬដោយផ្ទាល់ក្នុងមូលធន។ ក្នុងករណីនេះ ពន្ធត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ ឬដោយផ្ទាល់ក្នុងមូលធនរៀងៗគ្នា។

ចំណាយពន្ធបច្ចុប្បន្ន ត្រូវបានកំណត់យោងទៅតាមច្បាប់ពន្ធនៃយុត្តាធិការនីមួយៗ ដែលសម្ព័ន្ធធនាគារប្រតិបត្តិការ និងបង្កើតប្រាក់ចំណេញដែលជាប់ពន្ធ និងរាប់បញ្ចូលពន្ធទាំងអស់ដែលផ្អែកលើប្រាក់ចំណេញជាប់ពន្ធ។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឈ) ពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន និងពន្ធពន្យារ (ត)

ពន្ធលើប្រាក់ចំណូលពន្យារ ត្រូវបានទទួលស្គាល់ទាំងអស់ដោយប្រើវិធីសាស្រ្តបំណុលលើភាពខុសគ្នាបណ្តោះអាសន្នដែលកើតឡើងរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និងចំនួនតម្លៃយោងរបស់ពួកគេនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ទោះយ៉ាងណាក៏ដោយពន្ធលើប្រាក់ចំណូលពន្យារ មិនត្រូវបានរាប់បញ្ចូលប្រសិនបើវាកើតឡើងពីការទទួលស្គាល់លើកដំបូងនៃទ្រព្យសកម្ម ឬបំណុល នៅក្នុងប្រតិបត្តិការណាមួយក្រៅពីការរួមបញ្ចូលអាជីវកម្មដែលនៅពេលប្រតិបត្តិការមិនប៉ះពាល់ដល់គណនេយ្យ ឬចំណេញ ឬខាត ដែលជាប់ពន្ធ។

ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់ក្នុងវិសាលភាពដែលវាទំនងថាប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតនឹងកើតមានសម្រាប់ភាពខុសគ្នាបណ្តោះអាសន្ន និងការខាតបង់ពន្ធដែលមិនបានប្រើ ឬឥណទានពន្ធដែលមិនបានប្រើ ។

### (ញ) អត្ថប្រយោជន៍និយោជិត

*(i). អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី*

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់នូវការទទួលស្គាល់បំណុល និងចំណាយសម្រាប់ប្រាក់បន្ថែម។ សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់សំវិធានធនមួយនៅពេលមានកាតព្វកិច្ចមានកិច្ចសន្យា ឬមានការអនុវត្តកន្លងមកដែលបានបង្កើតកាតព្វកិច្ចស្ថាបនា។

ប្រាក់ឈ្នួល ប្រាក់បៀវត្សរ៍ ប្រាក់បន្ថែម និងអត្ថប្រយោជន៍រយៈពេលខ្លីផ្សេងៗ ត្រូវបានទទួលស្គាល់ជាចំណាយក្នុងការិយបរិច្ឆេទ ដែលសេវាកម្មពាក់ព័ន្ធ ត្រូវបានផ្តល់ជូនដោយនិយោជិតរបស់សម្ព័ន្ធធនាគារ និងធនាគារ។

*(ii) អត្ថប្រយោជន៍ក្រោយពីបំពេញការងារ*

សម្ព័ន្ធធនាគារ និងធនាគារមានផែនការអត្ថប្រយោជន៍ក្រោយពីបំពេញការងារផ្សេងៗច្រើន។ ផែនការអត្ថប្រយោជន៍ទាំងនេះមានដូចខាងក្រោម។

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)**
**សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០**

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ណ) អត្ថប្រយោជន៍និយោជិត (ត)

*(ii) អត្ថប្រយោជន៍ក្រោយពីបំពេញការងារ (ត)*

**អត្ថប្រយោជន៍អតីតភាពការងារ**

យោងទៅតាមប្រកាសលេខ ៤៤៣ កប/ប្រ.ក.ខ.ល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ និងសេចក្តីណែនាំ លេខ ០៤២/១៩ កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ លើកលែងតែធនាគារអេស៊ីលីដាឡាវ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ ស៊ីលីដាមីយ៉ាន់ម៉ា នឹងផ្តល់ជូននិយោជិតនូវប្រាក់បំណាច់អតីតភាពការងារ ដូចខាងក្រោមៈ

- ប្រាក់បំណាច់អតីតភាពការងារបច្ចុប្បន្នៈ និយោជិតដែលបម្រើការចាប់ពី ១ខែ ដល់ ៦ខែ (មិនរាប់បញ្ចូលរយៈពេលសាកល្បងការងារ) គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឬថ្ងៃទី៣១ ខែធ្នូ នឹងទទួលបានប្រាក់បំណាច់អតីតភាពការងារចំនួន ៧.៥ថ្ងៃ។
- ប្រាក់បំណាច់រំលឹកអតីតភាពការងារៈ និយោជិតដែលបម្រើការក្រោមកិច្ចសន្យាការងារមានថេរវេលាមិនកំណត់ ហើយបម្រើការចាប់ពី ១ខែ ដល់ ៦ខែ ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ នឹងទទួលបានប្រាក់រំលឹកអតីតភាពការងារស្មើនឹង ៣ថ្ងៃ ហើយក្នុងករណីបម្រើការងារលើសពី ៣ខែ នឹងទទួលបាន ១៥ថ្ងៃ។ ប្រាក់បំណាច់អតិបរមាដែលត្រូវទូទាត់ មិនត្រូវលើសពី ៦ថ្ងៃ នៃប្រាក់ឈ្នួលមូលដ្ឋានគិតជាមធ្យមតាមឆ្នាំនីមួយៗដែលបានទូទាត់ ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨ ប៉ុន្តែមិនត្រូវលើសពី ១៥៦ថ្ងៃ ឡើយ។ ប្រាក់បំណាច់នឹងត្រូវទូទាត់ចាប់ពីខែធ្នូ ឆ្នាំ២០២១។

បំណុលនេះត្រូវបានទទួលស្គាល់តាមតម្លៃបច្ចុប្បន្ន នៃកាតព្វកិច្ចដែលបានកំណត់នាកាលបរិច្ឆេទរាយការណ៍ ដោយប្រើវិធីសាស្ត្រឥណទានតាមឯកតាព្យាករណ៍ ដើម្បីប៉ាន់ស្មានតម្លៃអត្ថប្រយោជន៍ចុងក្រោយរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលនិយោជិតត្រូវទទួលបានចំពោះសេវាកម្មរបស់ពួកគេនៅក្នុងពេលបម្រើការងារចាប់ពីឆ្នាំ២០០៨ ដល់ ២០១៨។ សម្ព័ន្ធធនាគារ និងធនាគារបែងចែកអត្ថប្រយោជន៍ទៅតាមថេរវេលា ដែលត្រូវទូទាត់ប្រាក់បំណាច់រំលឹកអតីតភាពនេះ។ កាតព្វកិច្ចនេះកើតឡើងនៅពេលនិយោជិតបម្រើការងារដើម្បីទទួលបានប្រាក់បំណាច់រំលឹកអតីតភាពការងារ ដែលសម្ព័ន្ធធនាគារ និងធនាគាររំពឹងថានឹងត្រូវទូទាត់នៅកាលបរិច្ឆេទរាយការណ៍នាពេលអនាគត។

តម្លៃបច្ចុប្បន្នប្រាក់បំណាច់រំលឹកអតីតភាពការងារ ត្រូវបានកំណត់ដោយធ្វើអប្បហារប្រាក់ដែលត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាការប្រាក់បញ្ញើមានកាលកំណត់សម្រាប់រយៈពេល ៦០ខែ។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ណ) អត្ថប្រយោជន៍និយោជិត (ត)

*(ii) អត្ថប្រយោជន៍និយោជិតក្រោយពីបំពេញការងារ (ត)*

**អត្ថប្រយោជន៍ពេលចូលនិវត្តន៍**

ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ លើកលែងតែស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ផ្តល់ជូនផែនការអត្ថប្រយោជន៍ពេលចូលនិវត្តន៍ដែលមិនត្រូវបានផ្តល់ជាមូលនិធិ ដែលជាផែនការអត្ថប្រយោជន៍ដែលបានកំណត់សម្រាប់បុគ្គលិកដែលមានសិទ្ធិទទួលនៅពេលដែលពួកគាត់ដល់អាយុចូលនិវត្តន៍ ដូចខាងក្រោម៖

- បុគ្គលិកដែលមានអតីតភាពការងារជាមួយសម្ព័ន្ធធនាគារ ឬធនាគារ ចំនួន ១៥ឆ្នាំ ឬលើស ហើយត្រូវចូលនិវត្តន៍នៅអាយុ ៥៨ឆ្នាំ ចំពោះអ្នកគ្មានជំនាញ និង ៦០ឆ្នាំ ចំពោះអ្នកមានជំនាញ នឹងទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្តន៍ស្មើនឹងប្រាក់បៀវត្សរ៍ចំនួន ១២ខែ នៃប្រាក់បៀវត្សរ៍ចុងក្រោយ។
- បុគ្គលិកដែលមានអតីតភាពការងារជាមួយសម្ព័ន្ធធនាគារ ឬធនាគារចំនួន ១៥ឆ្នាំ ឬលើស ហើយត្រូវចូលនិវត្តន៍មុន នៅអាយុ ៥៥ឆ្នាំ ចំពោះអ្នកគ្មានជំនាញ និង ៥៧ឆ្នាំ ចំពោះអ្នកមានជំនាញ នឹងទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្តន៍ស្មើនឹងប្រាក់បៀវត្សរ៍ចំនួន ៦ខែ នៃប្រាក់បៀវត្សរ៍ចុងក្រោយ។

ចំពោះអត្ថប្រយោជន៍ពេលចូលនិវត្តន៍នេះ មិនមានរក្សាទុកក្នុងមូលនិធិដាច់ដោយឡែកទេ ហើយការប្រាក់ត្រូវបានផ្តល់សម្រាប់អត្ថប្រយោជន៍ពេលចូលនិវត្តន៍។

បំណុល ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុតាមតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចដែលបានកំណត់ នាការិយបរិច្ឆេទរាយការណ៍ ដោយប្រើវិធីសាស្ត្រឥណទានតាមឯកតាព្យាករណ៍ ដើម្បីប៉ាន់ស្មានតម្លៃចុងក្រោយបំផុតដែលសម្ព័ន្ធធនាគារ និងធនាគារត្រូវចំណាយចំពោះអត្ថប្រយោជន៍ដែលនិយោជិតត្រូវទទួលបានជាថ្នូរនឹងការបម្រើការងាររបស់ពួកគេក្នុងពេលបច្ចុប្បន្ន និងពេលកន្លងមក។ សម្ព័ន្ធធនាគារ និងធនាគារបែងចែកអត្ថប្រយោជន៍តាមគ្រានីមួយៗ ដែលកាតព្វកិច្ចផ្តល់អត្ថប្រយោជន៍ពេលចូលនិវត្តន៍បានកើតឡើង។ កាតព្វកិច្ចនោះកើតឡើងនៅពេលដែលបុគ្គលិកបម្រើការងារ ដើម្បីទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្តន៍ ដែលសម្ព័ន្ធធនាគារ និងធនាគារ រំពឹងថានឹងទូទាត់ក្នុងការិយបរិច្ឆេទរាយការណ៍នាពេលអនាគត ។

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្តន៍ ត្រូវបានកំណត់ដោយធ្វើការអប្បហារការទូទាត់ដែលរំពឹងទុកនាពេលអនាគត ដោយយោងទៅតាមអត្រាការប្រាក់នៃប្រាក់បញ្ញើមានកាលកំណត់សម្រាប់រយៈពេលប្រាំមួយឆ្នាំរបស់ធនាគារ ដោយសារមិនមានទីផ្សារមូលបត្រក្រុមហ៊ុនដែលមានគុណភាពខ្ពស់ ហើយក៏មិនមែនជាមូលបត្របំណុលរាជរដ្ឋាភិបាលដែរ ។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ណ) អត្ថប្រយោជន៍និយោជិត (ត)

*(ii) អត្ថប្រយោជន៍និយោជិតក្រោយពីបំពេញការងារ (ត)*

**អត្ថប្រយោជន៍ពេលចូលនិវត្ត (ត)**

ចំណេញ និងខាតដែលគណនាដោយផ្អែកលើមូលដ្ឋានច្បាស់លាស់ កើតឡើងពីការកែតម្រូវគណនីសម្រង់ និងពីបម្រែបម្រួលការសន្មត ដែលគណនាដោយផ្អែកលើមូលដ្ឋានច្បាស់លាស់ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ និងទទួលស្គាល់ដោយផ្ទាល់ នៅក្នុងប្រាក់ចំណេញរក្សាទុក ក្នុងការិយបរិច្ឆេទដែលប្រតិបត្តិការនោះកើតឡើង។ ចំណាយទាក់ទិននឹងការផ្តល់អត្ថប្រយោជន៍ទាំងនេះ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ ដើម្បីធ្វើការបែងចែកចំណាយទាំងនោះទៅតាមរយៈពេលបម្រើការងារ ដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍នេះ។ តម្លៃសេវាកម្មពីអតីតកាល ត្រូវបានទទួលស្គាល់ភ្លាមៗនៅក្នុងចំណេញ ឬខាត។

***អត្ថប្រយោជន៍អភិវឌ្ឍន៍វិជ្ជាជីវៈគ្រប់គ្រង***

ធនាគារផ្តល់អត្ថប្រយោជន៍ភិវឌ្ឍន៍វិជ្ជាជីវៈគ្រប់គ្រងដល់និយោជិត បម្រើការងារនៅក្នុងតួនាទីគ្រប់គ្រង ដូចខាងក្រោម៖

| លំដាប់ថ្នាក់មុខតំណែងគ្រប់គ្រង | អត្ថប្រយោជន៍ |
|---|---|
| លំដាប់ថ្នាក់ទី ៦ | ១.២៥០ ដុល្លារអាមេរិក |
| លំដាប់ថ្នាក់ទី ៧ | ២.៥០០ ដុល្លារអាមេរិក |
| លំដាប់ថ្នាក់ទី ៨ | ៣.៣៧៥ ដុល្លារអាមេរិក ទៅ ៣.៧៥០ ដុល្លារអាមេរិក |

ពួកគេមានសិទ្ធិទទួលបានសមាជិកភាព លុះត្រាតែពួកគេបានធ្វើការចាប់តាំងពីកាលបរិច្ឆេទនៃការតែងតាំងនៅក្នុងមុខតំណែងគ្រប់គ្រងបានរយៈពេលពីរឆ្នាំជាប់ៗគ្នា ហើយការវាយតម្លៃលទ្ធផលការងាររបស់ពួកគេមានកម្រិតខ្ពស់ (ឧទាហរណ៍: ពិន្ទុនៃការវាយតម្លៃស្មើនឹង ឬខ្ពស់ជាង ៧០០ និងគ្មានលិខិតព្រមាន)។ ពួកគេនឹងមានសិទ្ធិទទួលបានសមាជិកភាពដោយស្វ័យប្រវត្តិនៅថ្ងៃដំបូងនៃឆ្នាំទីបីរបស់ពួកគេ។

បំណុលត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍នៅចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដោយប្រើវិធីសាស្ត្រឥណទានតាមឯកតាព្យាករណ៍។ តម្លៃបច្ចុប្បន្ន ត្រូវបានកំណត់ដោយការធ្វើអប្បហារការទូទាត់នាពេលអនាគតដែលបានប៉ាន់ស្មាន ដោយយោងទៅលើអត្រាការប្រាក់បញ្ញើមានកាលកំណត់សម្រាប់រយៈពេលបីឆ្នាំ ដោយសារសិទ្ធិក្នុងការទទួលបានអត្ថប្រយោជន៍មានរយៈពេលបីឆ្នាំ។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ត) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលសម្ព័ន្ធធនាគារ និងធនាគារមានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចស្ថាបនា នាពេលបច្ចុប្បន្ន ដែលជាលទ្ធផល នៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាអាចមានការហូរចេញនៃធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយទឹកប្រាក់នៃកាតព្វកិច្ចអាចត្រូវបានប៉ាន់ស្មានដោយភាពជឿជាក់។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន ភាពដែលកើតមានឡើងនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ដោយធ្វើការពិចារណាទៅលើថ្នាក់នៃកាតព្វកិច្ចទាំងមូល។ សំវិធានធនត្រូវបានទទួលស្គាល់ទោះបីជាលទ្ធភាពនៃលំហូរចេញទាក់ទងនឹងធាតុណាមួយដែលបានរួមបញ្ចូលនៅក្នុងថ្នាក់ដូចគ្នានៃកាតព្វកិច្ច អាចមានតិចតួចក៏ដោយ។

សំវិធានធន ត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃចំណាយដែលរំពឹងថានឹងត្រូវធ្វើការទូទាត់កាតព្វកិច្ចនោះដោយប្រើប្រាស់អត្រាមុនគិតពន្ធ ដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃតាមទីផ្សារបច្ចុប្បន្ននៃពេលវេលានៃការប្រើប្រាស់សាច់ប្រាក់ និងហានិភ័យជាក់លាក់ចំពោះកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធនដោយសារ ការកន្លងផុតទៅនៃពេលវេលា ត្រូវបានទទួលស្គាល់ជាចំណាយការប្រាក់។

### (ថ) ការប្រាក់

*អត្រាការប្រាក់ប្រសិទ្ធភាព*

ចំណូល និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអប្បហារការទទួល ឬទូទាត់សាច់ប្រាក់នាពេលអនាគតដែលរំពឹងទុក ក្នុងអាយុកាលដែលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុ មកស្មើនឹង៖

- តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- តម្លៃដករំលស់របស់បំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ក្រៅពីទ្រព្យសកម្មដែលមានឱនភាពនៃតម្លៃឥណទាននៅពេលធ្វើលទ្ធកម្ម ឬបង្កើត សម្ព័ន្ធធនាគារ ឬធនាគារធ្វើការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតដោយពិចារណារាល់លក្ខខណ្ឌតាមកិច្ចសន្យាទាំងអស់របស់ឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ដែលរំពឹងទុក (ECL) នោះទេ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាននៅពេលធ្វើលទ្ធកម្ម ឬបង្កើត អត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវហានិភ័យឥណទាន ត្រូវបានគណនាដោយប្រើលំហូរសាច់ប្រាក់នាពេលអនាគតដែលប៉ាន់ស្មានរួមបញ្ចូលទាំងការខាតបង់ឥណទានដែលរំពឹងទុក (ECL)។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ថ) ការប្រាក់ (ត)

*អត្រាការប្រាក់ប្រសិទ្ធភាព (ត)*

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាពរួមបញ្ចូលនូវចំណាយប្រតិបត្តិការ និងកម្រៃដែលបានបង់ ឬទទួល ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព។ ចំណាយប្រតិបត្តិការរួមមាន ការចំណាយបន្ថែមដែលចូលរួមដោយផ្ទាល់ទៅនឹងការធ្វើលទ្ធកម្ម ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

*តម្លៃដករំលស់ និងតម្លៃយោងដុល*

តម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់លើកដំបូង ដកការសងមកវិញនូវប្រាក់ដើម បូក ឬដករំលស់បង្គរដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព នៃភាពខុសគ្នារវាងចំនួនដែលទទួលស្គាល់លើកដំបូង និងចំនួននៅឥណប្រតិទាន និងត្រូវធ្វើនិយ័តកម្មចំពោះការខាតបង់ឥណទានដែលរំពឹងទុក (ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ)។

តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាតម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលធ្វើនិយ័តកម្មសំវិធានធនលើការខាតបង់ឥណទានដែលរំពឹងទុក។

*ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់*

អត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនាលើការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ ក្នុងការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានអនុវត្តលើតម្លៃយោងដុលរបស់ទ្រព្យសកម្ម (នៅពេលដែលទ្រព្យសកម្មមិនត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃឥណទាន) ឬតម្លៃដករំលស់នៃបំណុល។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានធ្វើការកែប្រែឡើងវិញ ដែលជាលទ្ធផលនៃការប៉ាន់ស្មានឡើងវិញតាមពេលកំណត់ របស់លំហូរសាច់ប្រាក់នៃឧបករណ៍ដែលមានអត្រាការប្រាក់អថេរ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរអត្រាការប្រាក់ទីផ្សារ។ អត្រាការប្រាក់ប្រសិទ្ធភាពក៏ត្រូវធ្វើការកែប្រែឡើងវិញ សម្រាប់ការធ្វើនិយ័តកម្មតម្លៃសមស្របនៃការទប់ស្កាត់ហានិភ័យ នៅកាលបរិច្ឆេទធ្វើរំលស់នៃការធ្វើនិយ័តកម្មការទប់ស្កាត់ហានិភ័យ ត្រូវចាប់ផ្តើម។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទានបន្ទាប់ពីបានទទួលស្គាល់លើកដំបូង ចំណូលការប្រាក់ ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព លើតម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុលែងមានឱនភាពនៃតម្លៃឥណទាន នោះការគណនាចំណូលការប្រាក់ត្រូវប្តូរមកលើមូលដ្ឋានតម្លៃដុលវិញ។

## ២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ថ) ការប្រាក់ (ត)

*ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់*

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាននៅពេលទទួលស្គាល់លើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវឥណទាន លើតម្លៃដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ។ ការគណនាចំណូលការប្រាក់នេះ មិនត្រូវប្តូរទៅមូលដ្ឋានតម្លៃដុលវិញទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះ មានភាពប្រសើរក៏ដោយ។

*ការបង្ហាញ*

ចំណូលការប្រាក់ ត្រូវបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាព ដែលបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និង OCI រួមមាន៖

- ការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់តាមតម្លៃដករំលស់
- ការប្រាក់លើឧបករណ៍បំណុលវាស់វែងតាម FVOCI
